Public Disclosure Authorized

Public Disclosure Authorized

# ព្រះរាជាណាចក្រកម្ពុជា

## គម្រោងពិពិធកម្មវិស័យកសិកម្មនៅកម្ពុជា (CASDP)
## ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF)

រៀបចំដោយៈ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ក្រសួងអភិវឌ្ឍន៍ជនបទ
ក្រសួងធនធានទឹក និងឧតុនិយម
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រាជធានីភ្នំពេញ ប្រទេសកម្ពុជា
**ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៨**

តារាងមាតិកា

បញ្ជីពាក្យកាត់ ........ 1
សេចក្តីសង្ខេប ........ 4
1.0 សេចក្តីណែនាំអំពីក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ........ 7
1.1 គោលបំណងនៃក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ........ 7
2.0 គម្រោងពិពិធកម្មវិស័យកសិកម្មនៅកម្ពុជា ........ 7
2.1 គោលបំណងនៃការរៀបចំគម្រោង ........ 7
2.2 ការរៀបចំគម្រោង និងសមាសភាគ ដែលត្រូវបានស្នើឡើង ........ 7
2.3 អ្នកទទួលផលគម្រោង និងទីតាំងគម្រោង ........ 10
3.0 ក្របខ័ណ្ឌគោលនយោបាយ គតិយុត្ត និងរដ្ឋបាល ........ 11

3. 1 ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ ដែលពាក់ព័ន្ធ ..... 11
3.2 គោលនយោបាយស្តីពីការការពារផលប៉ះពាល់របស់ធនាគារពិភពលោក ដែលត្រូវយកមកអនុវត្ត ..... 13
3.3 ការវិភាគគម្លាត ..... 18
3.4 ការអនុវត្តល្អ ផ្នែកកសិកម្ម (GAP) ..... 21
4.0 ផលប៉ះពាល់ដែលអាចកើតឡើង និងវិធានការសម្រាលផលប៉ះពាល់ទាំងនេះ ..... 22
4.1 ផលប៉ះពាល់បរិស្ថាន ដែលអាចកើតមានឡើង ..... 23
4.2 ផលប៉ះពាល់សង្គម ដែលអាចកើតមានឡើង ..... 30
5.0 នីតិវិធីសម្រាប់ពិនិត្យបឋម ពិនិត្យឡើងវិញ ផ្តល់ការអនុញ្ញាត និងអនុវត្តឧបករណ៍ការពារផលប៉ះពាល់សម្រាប់អនុគម្រោង ..... 35
6.0 ការរៀបចំការអនុវត្ត ..... 44
6.1. ការទទួលខុសត្រូវលើការអនុវត្ត ESMF ..... 44
6.2 ការរៀបចំរបាយការណ៍ ..... 48
7.0 ការកសាងសមត្ថភាព និងការបណ្តុះបណ្តាល ..... 48
7.1 ការវាយតម្លៃសមត្ថភាពស្ថាប័ន ..... 48
7.2 ការបណ្តុះបណ្តាល ..... 48
8.0 ថវិកាសម្រាប់អនុវត្ត ESMF ..... 49
9.0 យន្តការដោះស្រាយបណ្តឹងសាទុក្ខ (GRM) ..... 50
10.0 កិច្ចពិគ្រោះយោបល់ និងបង្ហាញព័ត៌មានអំពី ESMF ..... 53
ឧបសម្ព័ន្ធទី ១៖ ការវិភាគគម្លាតរវាងក្របខ័ណ្ឌគតិយុត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយោបាយរបស់ធនាគារពិភពលោក ..... 54
ឧបសម្ព័ន្ធ ២.១៖ បញ្ជីសកម្មភាព ដែលពុំបានបំពេញតាមលក្ខណៈវិនិច្ឆ័យសមស្រប ..... 59
ឧបសម្ព័ន្ធ ២.២៖ បញ្ជីត្រួតពិនិត្យបឋមលើបរិស្ថាន និងសង្គមសម្រាប់អនុគម្រោង ..... 61
ឧបសម្ព័ន្ធទី ៣៖ ការរៀបចំ EMP ឬ ESMP ..... 72
ឧបសម្ព័ន្ធទី ៤៖ ក្រមប្រតិបត្តិបរិស្ថាន (ECOPs) សម្រាប់ការងារសាងសង់ ឬការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ ខ្នាតតូច ..... 83
ឧបសម្ព័ន្ធ ៥៖ ឧទាហរណ៍អំពីសេចក្តីពិពណ៌នាបរិស្ថាន សម្រាប់គម្រោង/អនុគម្រោងប្រភេទ B ..... 89
ឧបសម្ព័ន្ធទី ៧៖ លក្ខខណ្ឌការងារសម្រាប់ទីប្រឹក្សាគ្រប់គ្រងការការពារផលប៉ះពាល់បរិស្ថាន និងទីប្រឹក្សាគ្រប់គ្រងការការពារផលប៉ះពាល់សង្គម ..... 104
ឧបសម្ព័ន្ធទី ៨៖ ផែនការគ្រប់គ្រងសមាសភាគចង្រៃ ..... 108
ឧបសម្ព័ន្ធទី ៩៖ ការគ្រប់គ្រងសមាសភាគចង្រៃចម្រុះ ..... 111
ឧបសម្ព័ន្ធទី ១០៖ ទម្រង់សម្រាប់ពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ នៃសហគ្រាសកសិកម្ម និងសហគ្រាសដែលមានស្រាប់ ដែលត្រូវទទួលបានហិរញ្ញប្បទានក្រោមសមាសភាគរង ១.២ ..... 115
ឧបសម្ព័ន្ធទី ១១៖ បញ្ជីវត្តមានអ្នកចូលរួមក្នុងកិច្ចពិគ្រោះយោបល់ស្តីពី ESMF កាលពីថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៨ ..... 119

## បញ្ជីពាក្យកាត់

| | | |
|---|---|---|
| AVCF | Agriculture Value Chain Facility | កម្មវិធីសង្វាក់តម្លៃកសិកម្ម |
| BPl | Business Plan | ផែនការធុរកិច្ច |
| BPr | Business Proposal | សំណើធុរកិច្ច |
| CASDP | Cambodia Agricultural Sector Diversification Project | គម្រោងពិពិធកម្មវិស័យកសិកម្មនៅកម្ពុជា |
| CSC | Consultation Supervision Consultant | ទីប្រឹក្សាគ្រប់គ្រងការពិគ្រោះយោបល់ |
| DP | Development Plan | ផែនការអភិវឌ្ឍន៍ |
| DUC | Dam Under Construction | ទំនប់ដែលកំពុងសាងសង់ |
| E&S | Environmental and Social | បរិស្ថាន និងសង្គម |
| EA | Environment Assessment | ការវាយតម្លៃបរិស្ថាន |
| ECOPs | Environmental Code of Practices | ក្រមអនុវត្តបរិស្ថាន |
| EHS | Environmental Health and Safety | សុខភាព និងសុវត្ថិភាពបរិស្ថាន |
| EIA | Environmental Impact Assessment | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| EMA | External Monitoring Agency | ទីភ្នាក់ងារពិនិត្យតាមដានខាងក្រៅ |
| EMC | Environmental Management Consultant | ទីប្រឹក្សាគ្រប់គ្រងបរិស្ថាន |
| EMDP | Ethnic Minority Development Plan | ផែនការអភិវឌ្ឍន៍ជនជាតិភាគតិច |
| EMF | Environmental Management Framework | ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន |
| EMP | Environmental Management Plan | ផែនការគ្រប់គ្រងបរិស្ថាន |
| EPC | Environmental Protection Commitment | ការប្តេជ្ញាការពារបរិស្ថាន |
| ESIA | Environmental and Social Impact Assessment | ការវាយតម្លៃហេតុប៉ះពាក់បរិស្ថាន និងសង្គម |
| ESMF | Environmental and Social Management Framework | ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម |
| ESMP | Environment and Social Management Plan | ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម |
| ESMP | Environmental and Social Management Plan | ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម |
| ESU | Environmental and Social Unit | អង្គភាពបរិស្ថាន និងសង្គម |
| EU | Environmental Unit | អង្គភាពបរិស្ថាន |
| FAO | Food and Agriculture Organization | អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ |
| FFS | Famer Field School | សាលារៀនស្រែកសិករ |
| FSs | Feasibility Studies | ការសិក្សាសមិទ្ធិលទ្ធភាព |
| FT-PRR | Famer Training on Pesticide Risk Reduction | ការបណ្តុះបណ្តាលកសិករស្តីពីការកាត់បន្ថយហានិភ័យនៃការប្រើថ្នាំកសិកម្ម |
| GAP | Good Agricultural Practices | ការអនុវត្តល្អផ្នែកកសិកម្ម |
| GDA | General Department of Agriculture | អគ្គនាយកដ្ឋានកសិកម្ម |
| GDP | Good Domestic Product | ផលិតផលសរុបក្នុងស្រុក |
| GDR | General Department of Resettlement | អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ |
| GHG | Greenhouse Gasses | ឧស្ម័នផ្ទះកញ្ចក់ |
| GNI | Gross National Income | ចំណូលសរុបរបស់ជាតិ |
| GRM | Grievance Redress Mechanism | យន្តការដោះស្រាយបណ្តឹងសារទុក្ខ |
| ICM | Integrated Crop Management | ការគ្រប់គ្រងដំណាំចម្រុះ |
| ICR | Implementation Completion and Result Report | របាយការណ៍ស្តីពីការបញ្ចប់ និងលទ្ធផលនៃការអនុវត្ត |

| | | |
|---|---|---|
| IEE | Initial Environmental Examination | ការពិនិត្យបរិស្ថានបឋម |
| IEIA | Initial Environmental Impact Assessment | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបឋម |
| IPDP | Indigenous People Development Plan | ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច |
| IPM | Integrated Pest Management | ការគ្រប់គ្រងសមាសភាគចង្រៃចម្រុះ |
| IPM | Irrigated Pest Management | ការគ្រប់គ្រងសមាសភាគចង្រៃចម្រុះ |
| IRC | Inter-Ministry Resettlement Committee | គណៈកម្មាធិការ<br>អន្តរក្រសួងដោះស្រាយផលប៉ះពាល់ |
| LACP | Lao Agriculture Commercialization Project | គម្រោងពាណិជ្ជភាវូបនីយកម្ម<br>កសិកម្មឡាវ |
| MAFF | Ministry of Agricultural Forestry and Fishery | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MOC | Ministry of Commerce | ក្រសួងពាណិជ្ជកម្ម |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MoIH | Ministry of Industry and Handicraft | ក្រសួងកសិកម្ម និងសិប្បកម្ម |
| MOWA | Ministry of Women Affairs | ក្រសួងកិច្ចការនារី |
| MOWRAM | Ministry of Water Resources and Meteorology | ក្រសួងធនធានទឹក និងឧតុនិយម |
| MRD | Ministry of Rural Development | ក្រសួងអភិវឌ្ឍន៍ជនបទ |
| MSDS | Material Safety Data Sheets | តារាងទិន្នន័យសុវត្ថិភាព |
| MSF | Micro Finance Institution/Bank | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធនាគារ/ |
| MTR | Midterm Term Review | ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ |
| NGO | Non-Government Organization | អង្គការមិនមែនរដ្ឋាភិបាល |
| NSDP | National Strategy Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| NTFP | Non-Timber Forest Products | ទិន្នផលអនុផលព្រៃឈើ |
| ODA | Official Development Assistance | ជំនួយអភិវឌ្ឍន៍ផ្លូវការ |
| OP | Operation Policies | គោលនយោបាយប្រតិបត្តិ |
| PAD | Project Appraisal Documentation | ឯកសារវាយតម្លៃគម្រោង |
| PAH | Project Affected Household | គ្រួសារដែលរង<br>ផលប៉ះពាល់ដោយសារគម្រោង |
| PAP | Project Affected People | ជនដែលរង<br>ផលប៉ះពាល់ដោយសារគម្រោង |
| PAPs | Project Affective Persons | ជនដែលរងផលប៉ះពាល់<br>ដោយសារគម្រោង |
| PASO | Provincial Agriculture and Forestry Offices | មន្ទីរកសិកម្ម និងរុក្ខាប្រមាញ់ |
| PCO | Project Coordination Office | ការិយាល័យសម្របសម្រួលគម្រោង |
| PCR | Physical Cultural Resource | សារធាតុធនធានវប្បធម៌រូបវន្ត |
| PIM | Project Implementation Manual | សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង |
| PMP | Pesticide Management Plan | ផែនការគ្រប់គ្រងសមាសភាគចង្រៃ |
| PMU | Project Management Unit | អង្គភាពគ្រប់គ្រងគម្រោង |
| POM | Project Operation Manual | សៀវភៅណែនាំស្តីពីប្រតិបត្តិការគម្រោង |
| POs | Project Operation | ប្រតិបត្តិការគម្រោង |
| PRSC | Provincial Resettlement Sub-Committee Working Group | ក្រុមការងារ<br>អនុគណៈកម្មាធិការដោះស្រាយ<br>ផលប៉ះពាល់នៅថ្នាក់ខេត្ត |
| RDB | Rural Development Bank | ធនាគារអភិវឌ្ឍន៍ជនបទ |
| REA | Regional Environmental Assessment | ការវាយតម្លៃបរិស្ថានថ្នាក់តំបន់ |

| | | |
|---|---|---|
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| RP | Resettlement Plan | ផែនការដោះស្រាយផលប៉ះពាល់តាំង/ទីលំនៅ |
| RPF | Resettlement Policy Framework | ក្របខ័ណ្ឌគោលនយោបាយ ដោះស្រាយផលប៉ះពាល់តាំងទីលំនៅ/ |
| SARD | Sustainable Agriculture and Rural Development | ការអភិវឌ្ឍកសិកម្ម និងជនបទប្រកបដោយចីរភាព |
| SEO | Safety and Environment Officer | មន្ត្រីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថាន |
| SMAs | Small and Medium Agri-Business | សហគ្រាសកសិកម្មខ្នាតតូច និងខ្នាតមធ្យម |
| TA | Technical Assistance | ជំនួយបច្ចេកទេស |
| TNA | Training Need Assessment | ការវាយតម្លៃតម្រូវការបណ្តុះបណ្តាល |
| TOR | Term of Reference | លក្ខខណ្ឌប្រតិបត្តិ |
| TWGAW | Technical Working Group on Agriculture and Water | ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក |
| WB | World Bank | ធនាគារពិភពលោក |
| WTO | World Trade Organization | អង្គការពាណិជ្ជកម្មពិភពលោក |

## សេចក្តីសង្ខេប

1. ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ដែលហៅថា ESMF) នេះ ត្រូវបានរៀបចំឡើងដោយក្រុមការងាររៀបចំគម្រោងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានជាតុចូលពីក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម។ អ្នកនិពន្ធសូមសម្តែងនូវសេចក្តីថ្លែងអំណរគុណចំពោះក្រុមការងារ (tasks team) របស់ធនាគារពិភពលោក ដែលបានផ្តល់ការគាំទ្រ និងការណែនាំ។

2. ESMF នេះ ត្រូវបានរៀបចំឡើងជាផ្នែកមួយនៃគម្រោងពិពិធកម្មវិស័យកសិកម្មនៅកម្ពុជា (ដែលហៅកាត់ថា CASDP) ដែលត្រូវទទួលបានហិរញ្ញប្បទានពីក្រុមធនាគារពិភពលោក តាមរយៈហិរញ្ញប្បទានកម្ចីពីសមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA) និងរាជរដ្ឋាភិបាលកម្ពុជា។ ក្របខ័ណ្ឌនេះត្រូវបានរៀបចំឡើង ដើម្បីធានាយ៉ាងណាឱ្យគម្រោងដែលទទួលបានហិរញ្ញប្បទានពីធនាគារមិនបង្កផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងសង្គម ក្នុងអំឡុង ពេលអនុវត្ត និងក្រោយពេលអនុវត្តគម្រោង។ ទីតាំងគម្រោង រួមមាន ខេត្តនៅតំបន់ជនបទផង និងនៅតំបន់ប្រជុំជនផង។ ទីតាំងគម្រោងដែលលើកស្នើដំបូង រួមមាន ខេត្តបាត់ដំបង មណ្ឌលគិរី ស្ទឹងត្រែង រតនគិរី ព្រះវិហារ សៀមរាប ត្បូងឃ្មុំ ក្រចេះ កំពង់ចាម កណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង និងភ្នំពេញ។

3. ឯកសារណែនាំនេះ មានគោលបំណង (១) រៀបរាប់ពីសារតៈរបស់គម្រោង, (២) សនិទានភាពនៃក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម, គោលបំណង និងវិសាលភាពនៃក្របខ័ណ្ឌនេះ, (៣) អភិក្រម និងវិធីសាស្ត្រដែលប្រើប្រាស់សម្រាប់រៀបចំ ESMF និង (៤) រចនាសម្ព័ន្ធនៃក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF)។ ឯកសារណែនាំនេះ មានគោលបំណងផ្តល់ការណែនាំអំពីការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបឋម (IEIA), ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA), និងផ្តល់ការណែនាំ និងបញ្ជីត្រួតពិនិត្យតទូទៅ។ ក្រសួងបរិស្ថាន ទទួលបន្ទុកពិនិត្យលើរបាយការណ៍នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការតាមដានបន្តដែលចាំបាច់ត្រូវមាន និងការពិនិត្យតាមដាន។ ESMF នេះក៏មានគោលបំណងកាត់បន្ថយផលប៉ះពាល់នៃការអនុវត្តកសិកម្មតាមបែបប្រពៃណី (តាមរយៈការជំរុញឱ្យមានការអនុវត្តការគ្រប់គ្រងសមាសភាគចង្រៃបែបចម្រុះ (IPM) និងការអនុវត្តល្អផ្នែកកសិកម្ម (GAP) និងការសាកល្បងគំរូកសិកម្មដែលល្អសម្រាប់បរិស្ថាន បន្ថែមទៀត។

4. ក្រៅពីផលជះវិជ្ជមានធំៗទាំងនេះ គម្រោងនេះក៏មានគោលបំណងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានផងដែរ។ ការវាយតម្លៃលើផលប៉ះពាល់អវិជ្ជមាន ដែលអាចកើតមានឡើង ត្រូវបានធ្វើឡើង តាមរយៈការចុះដល់ទីតាំងផ្ទាល់ ការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកទទួលផល និងការប្រើប្រាស់ព័ត៌មានដែលមានស្រាប់ពីប្រភពមួយចំនួន។ បញ្ហា និងការព្រួយបារម្ភផ្នែកបរិស្ថាន អាចកើតមាន ដែលត្រូវបានកំណត់ រួមមាន៖ (i) ផលប៉ះពាល់មកលើបរិស្ថាន ដែលបង្កឡើងដោយសកម្មភាពកសិកម្ម, (ii) ការងារហេដ្ឋារចនាសម្ព័ន្ធ, និង (iii) ការគ្រប់គ្រងសំណល់រឹងចេញពីសកម្មភាពកែច្នៃរបស់សហគ្រាសកសិកម្ម។

5. របាយការណ៍ពិនិត្យលើគម្រោង/អនុគម្រោង នឹងកំណត់ពីគោលនយោបាយស្តីពីការការពារផលប៉ះពាល់បរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក ដែលត្រូវអនុវត្តចំពោះគម្រោងនេះ ក៏ដូចជាកំណត់ពីពេល និងរបៀបដែលត្រូវអនុវត្ត ឬមិនត្រូវអនុវត្តគោលនយោបាយស្តីពីការពារផលប៉ះពាល់របស់ធនាគារទាំងនេះ។ គម្រោងនេះត្រូវអនុវត្តគោលនយោបាយស្តីពីការការពារផលប៉ះពាល់ចំនួនប្រាំ។ គោលនយោបាយស្តីពីការវាយតម្លៃបរិស្ថាន (OP/BP 4.01), ការគ្រប់គ្រងសមាសភាគចង្រៃ (OP/BP 4.09), ធនធានវប្បធម៌រូបវន្ត (OP/BP 4.11), សុវត្ថិភាពទំនប់ (OP/BP 4.37), និងគោលនយោបាយ ពាក់ព័ន្ធនឹងច្បាប់ចំនួនមួយសម្រាប់គម្រោងនៅក្នុងផ្លូវទឹកអន្តរជាតិ (OP/BP 7.50)។ គោលនយោបាយស្តីពីការការពារផលប៉ះពាល់ទាំងនេះត្រូវយកមកអនុវត្ត ដោយសារតែគេរំពឹងថា នឹងមានផលប៉ះពាល់ទ្រង់ទ្រាយតូចដែលពុំអាចប្តូរត្រលប់មកស្ថានភាពដើមវិញបាន កើតចេញពី (i) ជំនួយបច្ចេកទេស និងការងារសាងសង់ ដូចជា ការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ, ការសាងសង់ផ្លូវភ្ជាប់ពីកសិដ្ឋានទៅ ទីផ្សារ, ការប្រើប្រាស់គ្រឿងយន្តកសិកម្ម, សេវាហេដ្ឋារចនាសម្ព័ន្ធ និង (ii) ការប្រើប្រាស់ថ្នាំកសិកម្ម ឬសារធាតុគីមី

ដើម្បីបង្កើនផលិតកម្ម។

6. បច្ចុប្បន្ននេះ ហានិភ័យសង្គម សម្រាប់គម្រោងនេះ ត្រូវបានដាក់ចំណាត់ថ្នាក់ថាមានកម្រិតមធ្យម។ គេរំពឹងថា ផលប៉ះពាល់សង្គមអាចនឹងកើតមានឡើង ក្នុងកម្រិត និងវិសាលភាពខុសៗគ្នា ចេញពីការអនុវត្តអនុគម្រោង អាស្រ័យទៅតាមវិសាលភាព និងទីតាំងរបស់អនុគម្រោងទាំងនោះ ដែលពុំទាន់ត្រូវបានកំណត់លម្អិតនៅឡើយ។ ផ្អែកតាមការពិភាក្សាបឋមជាមួយអ្នកទទួលផលសក្តានុពល ពាក់ព័ន្ធនឹងការវិនិយោគ ដែលអាចធ្វើឡើងដោយគម្រោងនេះ គម្រោងនេះទំនងជានាំឱ្យមានការអនុវត្តគោលនយោបាយស្តីពីការការពារផលប៉ះពាល់សង្គមរបស់ធនាគារពិភពលោកចំនួនពីរ៖ គោលនយោបាយស្តីពីជនជាតិដើមភាគតិច (OP/BP 4.10) និងការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត (OP/BP 4.12) និងគោលនយោបាយស្តីពីការការពារផលប៉ះពាល់បរិស្ថានចំនួនប្រាំពីរ ដូចជា៖ គោលនយោបាយស្តីពីការវាយតម្លៃបរិស្ថាន (OP/BP 4.01), ដែនជម្រកធម្មជាតិ (OP/BP 4.04), ព្រៃឈើ (OP/BP 4.36), ការគ្រប់គ្រងសមាសភាគចង្រៃ (OP 4.09), ធនធានវប្បធម៌រូបវន្ត (OP/BP 4.11), សុវត្ថិភាពទំនប់ (OP/BP 4.37), និងគម្រោងលើផ្លូវទឹកអន្តរជាតិ (OP/BP 7.50)។

7. នីតិវិធីសម្រាប់ពិនិត្យបឋម ពិនិត្យឡើងវិញ ផ្តល់ការឯកភាព និងអនុវត្តលិខិតុបករណ៍ការពារផលប៉ះពាល់ក្នុងអនុគម្រោង មានគោលបំណងធានាយ៉ាងណាឱ្យមានការឆ្លើយតប ឱ្យបានគ្រប់គ្រាន់ចំពោះការព្រួយបារម្ភផ្នែកបរិស្ថាន និងសង្គម តាមរយៈការរៀបចំស្ថាប័ន និងនីតិវិធីដែលគម្រោងត្រូវប្រើប្រាស់ ដើម្បីគ្រប់គ្រងចាត់ចែងការកំណត់ ការរៀបចំ ការអនុម័ត និងការអនុវត្តអនុគម្រោង។ នីតិវិធីក្នុង ESMF ត្រូវបានភ្ជាប់ទំនាក់ទំនងយ៉ាងជាក់ច្បាស់ជាមួយនឹងវដ្តអនុគម្រោង ដែលត្រូវបានកំណត់ សម្រាប់គម្រោងនេះ ហើយដែលគេអាចបញ្ចូលទៅក្នុង *សៀវភៅណែនាំស្តីពីប្រតិបត្តិការគម្រោង ឬសៀវភៅណែនាំស្តីពីការអនុវត្តគម្រោង*។

8. ការរៀបចំអនុគម្រោងក្នុងអំឡុងពេលអនុវត្តគម្រោង ធ្វើឡើងដោយប្រើប្រាស់ជំហានចំនួនបួនសំខាន់ៗ ដូចជា៖ ជំហានទី ១៖ ការពិនិត្យលើវិធានការ ការពារផលប៉ះពាល់ និងការវាយតម្លៃផលប៉ះពាល់, ជំហានទី ២៖ ការរៀបចំឯកសារស្តីពីការការពារផលប៉ះពាល់ តាមការតម្រូវ រួមនឹងការរៀបចំវិធានការសម្រាលផលប៉ះពាល់ និងការពិគ្រោះយោបល់ជាសាធារណៈ, ជំហានទី ៣៖ ការឯកភាពលើវិធានការការពារផលប៉ះពាល់ និងការបង្ហាញព័ត៌មាន និងជំហានទី ៤៖ ការពិនិត្យតាមដាន និងការរៀបចំរបាយការណ៍។ ការពិនិត្យបឋមលើការការពារផលប៉ះពាល់មានពីរជំហាន ការពិនិត្យលើការបំពេញតាមលក្ខណៈសម្បត្តិសមស្រប និងការពិនិត្យបច្ចេកទេស ដើម្បីវាយតម្លៃលើផលប៉ះពាល់ដែលអាចកើតមានឡើង គោលនយោបាយដែលត្រូវអនុវត្ត និងលិខិតុបករណ៍ដែលត្រូវរៀបចំ។

9. ដើម្បីគ្រប់គ្រងហានិភ័យសង្គម និងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយនឹងក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទ បានរៀបចំក្របខ័ណ្ឌគោលនយោបាយស្តីពីការដោះស្រាយផលប៉ះពាល់/ការតាំងទីលំនៅ ក្របខ័ណ្ឌផែនការជនជាតិដើមភាគតិច ផ្អែកតាមការវាយតម្លៃបឋមលើសង្គម និងក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម។ លើសពីនេះ មន្ត្រីបង្គោលទទួលបន្ទុកការពារផលប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានតែងតាំងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ការរៀបចំ និងការអនុវត្តគម្រោង។ ការអនុវត្តការការពារផលប៉ះពាល់បរិស្ថាន និងសង្គម ត្រូវធ្វើ ទៅតាមការរៀបចំការអនុវត្តគម្រោង ពោលគឺត្រូវអនុវត្តទៅតាម "ប្រព័ន្ធរបស់រដ្ឋាភិបាល" ក្រោមការណែនាំ/ដឹកនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមនឹងអង្គភាព ឬស្ថាប័នដែលស្ថិតក្រោមចំណុះក្រសួងនេះ។ ការណែនាំស្តីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាន នឹងត្រូវផ្តល់ដោយគណៈកម្មាធិការដឹកនាំគម្រោងនៅកម្រិតខ្ពស់ ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាប្រធាន។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាទីភ្នាក់ងារអនុវត្តចម្បង ដោយសហការជាមួយនឹងក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរក្រោមចំណុះក្រសួងទាំងពីរ ដែលបំពេញតួនាទីជា "អ្នកសហការអនុវត្ត" គម្រោង ហេដ្ឋារចនាសម្ព័ន្ធមួយចំនួន។ នៅថ្នាក់ជាតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលខុសត្រូវលើការអនុវត្តជារួម និងលើ ប្រសិទ្ធភាព ការសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ រួមទាំងការគ្រប់គ្រង

ការការពារផលប៉ះពាល់បរិស្ថាន និងសង្គមផងដែរ។

10. សៀវភៅណែនាំស្ដីពីការប្រតិបត្តិការគម្រោង (POM) មានផ្នែកអំពីបញ្ហា/នីតិវិធីបរិស្ថាន ការដោះស្រាយផលប៉ះពាល់/ការតាំងទីលំនៅ និងការផ្ដល់សំណង និងផែនការជនជាតិភាគតិច។ ផ្នែកទាំងនេះនឹងផ្សារភ្ជាប់ទំនាក់ទំនងជាមួយៈ (i) ការពិនិត្យបឋមលើអនុគម្រោង, (ii) វិធានការសម្រាលផលប៉ះពាល់សមស្រប និង/ ECOP, (iii) ទម្រង់ការពារផលប៉ះពាល់ ដែលបានធ្វើតេស្តបញ្ជាក់ជាមុនសម្រាប់ប្រើប្រាស់នៅកម្រិតអនុគម្រោង, (iv) ការរៀបចំឧបករណ៍/ការណែនាំបន្ថែម, (v) ព័ត៍មានលម្អិតអំពីរបៀបពិនិត្យតាមដាន និងវាយតម្លៃលើការការពារផលប៉ះពាល់ និង (vi) និយមន័យ និងតួនាទីនៃការធ្វើសវនកម្មពីភាគីទី ៣។

11. លើសពីនេះ គម្រោងនេះ បានបង្កើតគណៈកម្មាធិការដោះស្រាយបណ្ដឹងសារទុក្ខនៅថ្នាក់មូលដ្ឋាន (ខេត្ត ស្រុក និងឃុំ) ដែលត្រូវដឹកនាំដោយអភិបាលខេត្ត ឬអភិបាលខេត្តរង អភិបាលស្រុក និងមេឃុំ។ នៅថ្នាក់ឃុំ សមាជិកនៃយន្តការដោះស្រាយបណ្ដឹងសារទុក្ខ ត្រូវមានសមាសភាពជាតំណាងពីគ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោង ដែលត្រូវជ្រើសរើសចេញពីក្នុងចំណោមជនដែលរងផលប៉ះពាល់ដោយសារគម្រោង។ ក្នុងករណីសហគមន៍ជនជាតិដើមភាគតិចនឹងមានការបង្កើតគណៈកម្មាធិការនៅថ្នាក់ឃុំ ដោយត្រូវឆ្លងកាត់ដំណើរការពិគ្រោះយោបល់ដោយសេរីជាមុន ផ្អែកតាមព័ត៍មានត្រឹមត្រូវ និងមានការបង្កើតរចនាសម្ព័ន្ធធ្វើសេចក្ដីសម្រេចចិត្តដែលមានលក្ខណៈពិសេស សម្រាប់សហគមន៍ជនជាតិដើមភាគតិចនីមួយៗ ព្រមទាំងកំណត់ពីលក្ខខណ្ឌតម្រូវ ដើម្បីឱ្យមានតុល្យភាពយេនឌ័រ និងតុល្យភាពអន្តរជំនាន់។

## 1.0 សេចក្តីណែនាំអំពីក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម

1. ឯកសារនេះ គឺជាក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) សម្រាប់គម្រោងពិពិធកម្មវិស័យកសិកម្មនៅកម្ពុជា (CASDP) ដែលត្រូវស្នើឡើង និងរៀបចំ តាមរយៈការសហការរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីអាចទទួលបានហិរញ្ញប្បទានពីធនាគារពិភពលោក។

## 1.1 គោលបំណងនៃក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម

2. ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) មានគោលបំណងធានាយ៉ាងណាឱ្យមានការពិនិត្យបឋមលើសកម្មភាពនៃគម្រោង CASDP ដើម្បីកំណត់ពីផលប៉ះពាល់អវិជ្ជមានមកលើសង្គម និងបរិស្ថាន និងមានការពិចារណាពីវិធានការសម្រាលផលប៉ះពាល់ទាំងនេះ ក្នុងការរៀបចំ និងអនុវត្តសកម្មភាព។ និយាយម្យ៉ាងទៀត ក្របខ័ណ្ឌ ESMF ត្រូវបានរៀបចំឡើង ដើម្បីធានាថាការវិនិយោគរបស់គម្រោង CASDP ពុំបង្កើតឱ្យមាន ឬនាំឱ្យមានផលប៉ះពាល់អវិជ្ជមានគួរឱ្យកត់សម្គាល់លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងបរិស្ថាន និងមានការកំណត់បញ្ចៀស ឬយ៉ាងហោចណាស់កាត់បន្ថយឱ្យនៅតិចជាអប្បបរមានូវផលប៉ះពាល់ ដែលអាចកើតមានឡើង។ ជាពិសេសក្របខ័ណ្ឌ ESMF មានគោលបំណងដាក់ចេញនូវដំណើរការពិនិត្យ និងគោលការណ៍ណែនាំបរិស្ថាន និងសង្គម ក្នុងគោលបំណង៖

- (ក) បង្ការ និង/ឬសម្រាលផលប៉ះពាល់បរិស្ថាន និងសង្គម ដែលអាចកើតឡើងដោយសារសកម្មភាព ដែលត្រូវបានលើកស្នើឡើងទាំងនេះ
- (ខ) ធានានិរន្តរភាពបរិស្ថានរយៈពេលវែងនៃអត្ថប្រយោជន៍ ដែលបានពីសកម្មភាព ដែលស្នើឡើងតាមរយៈការធានាមូលដ្ឋានធនធានធម្មជាតិ ដែលសកម្មភាពទាំងនេះពឹងអាស្រ័យលើ និង
- (គ) សម្របសម្រួលបែបផ្តួចផ្តើមជាមុននូវសកម្មភាពទាំងឡាយណា ដែលគេរំពឹងថានឹងនាំឱ្យមានបង្កើនប្រសិទ្ធភាពការប្រើប្រាស់ និងកែលម្អការគ្រប់គ្រងធនធានធម្មជាតិ ដែលនាំឱ្យមានស្ថិរភាព និង/ឬការកែលម្អគុណភាពបរិស្ថាននៅមូលដ្ឋាន ព្រមទាំងសុខុមាលភាពរបស់មនុស្ស។

## **2.0** គម្រោងពិពិធកម្មវិស័យកសិកម្មនៅកម្ពុជា

### **2.1** គោលបំណងនៃការរៀបចំគម្រោង

3. គោលបំណងនៃការរៀបចំគម្រោង ដែលត្រូវបានស្នើឡើងនេះ គឺដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍសង្វាក់តម្លៃផលិតផលវិស័យកសិកម្ម ដែលមានលក្ខណៈពិពិធកម្ម នៅតាមទីតាំងភូមិសាស្ត្រមួយចំនួននៅកម្ពុជា និងផ្តល់ការឆ្លើយតបជាបន្ទាន់ ប្រកបដោយប្រសិទ្ធភាព ក្នុងករណីដែលមានវិបត្តិ ឬស្ថានភាពអាសន្ន ដែលបំពេញទៅតាមលក្ខណៈសមស្រប ដើម្បីទទួលបានការគាំទ្រពីគម្រោងនេះ។ ការវាស់វែងការសម្រេចគោលបំណងនៃការអភិវឌ្ឍគម្រោង នឹងត្រូវធ្វើឡើងដោយប្រើប្រាស់សូចនាករខាងក្រោម៖ (ក) ការកើនឡើងនូវតម្លៃលក់សរុបនៅកម្រិតកសិដ្ឋានដែលទទួលផល (ភាគរយ), (ខ) ការបង្កើនតម្លៃនៃការលក់សរុបរបស់សហគ្រាសកសិកម្ម ដែលទទួលផលពីគម្រោង (ភាគរយ), (គ) ភាគរយផលិតផលមិនមែនស្រូវអង្ករនៃបរិមាណផលិតកម្មសរុប ក្នុងតំបន់គោលដៅរបស់គម្រោង។

### 2.2 ការរៀបចំគម្រោង និងសមាសភាគ ដែលត្រូវបានស្នើឡើង

4. **ពិពណ៌នាអំពីគម្រោង៖** គម្រោង CASDP មានបួនសមាសភាគ ដូចតទៅ៖ (ក) ការផ្តល់លទ្ធភាពឱ្យមានការធ្វើពិពិធកម្មកសិកម្ម, (ខ) ការលើកកម្ពស់ប្រព័ន្ធព័ត៌មានកសិកម្ម និងការគ្រប់គ្រងការត្រួតពិនិត្យគុណភាព, (គ) ការគ្រប់គ្រងគម្រោង និងការពិនិត្យតាមដាន និងវាយតម្លៃ និង (ឃ) ការឆ្លើយតបចំពោះស្ថានភាពអាសន្ន ជាយថាហេតុ។

5. គម្រោងដែលត្រូវបានស្នើឡើងនេះ ត្រូវបានគាក់តែងឡើង ដើម្បីបង្កើនឱកាសទីផ្សារ

និងការធ្វើពិពិធកម្មកសិកម្ម ដោយប្រើប្រាស់អភិក្រមបែបបរិយាបន្ន ដោយអ្នកទទួលផលជាអ្នកដឹកនាំ។ គម្រោងនេះបែងចែកជាបីសមាសភាគ បូករួមនឹងសមាសភាគទី ៤ ដែលពុំមានការវិភាជន៍ធនធានទុក សម្រាប់ករណីដែលមានវិបត្តិ ឬស្ថានភាពអាសន្ន ដែលបំពេញទៅតាមលក្ខណៈវិនិច្ឆ័យសមស្រប ដើម្បីទទួលបានការគាំទ្រពីគម្រោង។ សមាសភាគទី ១ គឺជាផ្នែកដ៏ធំនៃការវិយោគទាំងនេះ ហើយគឺជាសមាសភាគដែលអនុវត្តជាម៉ូឌុល និងអាចពង្រីក និងកែសម្រួលឱ្យស្របទៅតាមទីតាំងភូមិសាស្ត្រ និងផលិតផល/សង្វាក់តម្លៃ។ សមាសភាគទី ២ ផ្ដោតលើការពង្រឹងស្ថាប័ន និង បង្កើនផលជះរយៈពេលវែងនៃការវិនិយោគ ដែលធ្វើឡើងក្នុងសមាសភាគទី ១ ក្នុងរយៈពេលមធ្យម និងរយៈពេលវែង ដោយធានានូវនិរន្តរភាព និងការពង្រីកអត្ថប្រយោជន៍ទូទាំងប្រទេសកម្ពុជា។

6. ការប្រមូលព័ត៌មានអំពីការគាំទ្រសង្វាក់តម្លៃ រួមនឹងជំនួយបច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធ និងសេវាហិរញ្ញវត្ថុក្រោមសមាសភាគទី ១ ផ្ដោតការយកចិត្តទុកដាក់លើទំនាក់ទំនងដ៏ជិតស្និទ្ធរវាងការគាំទ្រផ្ទាល់ដល់កសិករ ក្រុមអ្នកផលិត និងអាជីវកម្មកសិកម្មខ្នាតតូច និងខ្នាតមធ្យមរបស់គម្រោង ជាមួយនឹងការវិនិយោគលើផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ។ រាល់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទាំងអស់ នឹងត្រូវអនុវត្តជាផ្នែកមួយនៃការគាំទ្រដល់អនុគម្រោងដែលអាចបំពេញទៅតាមលក្ខណៈសម្បត្តិសមស្រប និងដែលមានទំនាក់ទំនងជាមួយនឹងក្រុមផលិតជាក់លាក់។

7. **សមាសភាគទី ១៖ ផ្ដល់លទ្ធភាពឱ្យមានការធ្វើពិពិធកម្មកសិកម្ម។** សមាសភាគទី ១ នេះនឹងប្រើប្រាស់អភិក្រមសង្វាក់តម្លៃ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ទៅតាមស្ថានភាពទីផ្សារ និងស្ថានភាពតម្រូវការ ដើម្បីកសាងនូវសង្វាក់តម្លៃ ដែលមានលក្ខណៈប្រកួតប្រជែង និងមានពិពិធភាព ដែលក្នុងនោះអង្គការអ្នកផលិត (POs) និងសមាជិករបស់អង្គការទាំងនេះ អាចទទួលបានទីផ្សារក្នុងស្រុក និងអន្តរជាតិ ដែលផ្ដល់ឱ្យពួកគេនូវប្រាក់ចំណេញខ្ពស់ត្រលប់មកវិញ ហើយសហគ្រាសកសិកម្មខ្នាតតូច និងខ្នាតមធ្យម អាចទទួលបានវត្ថុធាតុដើមដែលកាន់តែមានគុណភាពជាប់ជាប្រចាំ ហើយក្នុងពេលជាមួយគ្នា បង្កើនសមត្ថភាពស្រូបយក និងសម្រេចស្តង់ដារ គុណភាព ដែលទីផ្សារត្រូវការ។ សមាសភាគនេះ ពោរពេញដោយការប្រកួតប្រជែង និងភាគច្រើនដឹកនាំ ដោយ វិស័យឯកជន ដោយរដ្ឋាភិបាលបំពេញតួនាទីជាអ្នកសម្របសម្រួល។ ប៉ុន្តែ សមាសភាគនេះក៏នឹងផ្ដល់ការគាំទ្រដល់រដ្ឋាភិបាល និងតួអង្គក្នុងវិស័យសាធារណៈ ក្នុងការផ្ដល់សេវាចាំបាច់នានា ដូចជា ការផ្សព្វផ្សាយកសិកម្ម ដែលភ្ជាប់ទំនាក់ទំនងជាមួយនឹងទីផ្សារ និងផ្ដល់នូវហេដ្ឋារចនាសម្ព័ន្ធដែលមានលក្ខណៈល្អប្រសើរជាងមុន ដូចជា ផ្លូវជនបទ និង ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដែលកាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុន (higher order irrigation infrastructure) ក្នុងករណីដែលពុំមានសេវាដែលផ្ដល់ដោយវិស័យឯកជន ឬប្រជាពលរដ្ឋពុំអាចទទួលសេវាដែលផ្ដល់ដោយវិស័យឯកជនបាន។

8. ***សមាសភាគរង ១.១៖ ការគាំទ្រដល់ការរៀបចំ និងការអនុវត្តផែនការពិពិធកម្ម។*** សមាសភាគរងនេះ មានគោលបំណងផ្សព្វផ្សាយព័ត៌មានអំពីគម្រោងដល់តួអង្គពាក់ព័ន្ធនានា ផ្ដល់ការគាំទ្រដល់ការបង្កើតក្រុមការងារ ការកំណត់រកឱកាសអាជីវកម្ម និងនិងការបំប្លែងឱកាសទាំងនេះជាផែនការពិពិធកម្ម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដូចជា ការរៀបចំសំណើអាជីវកម្ម (BPr) និងផែនការអាជីវកម្ម (BPl) ដែលមានប្រសិទ្ធភាព និងធ្វើការវាយតម្លៃ និងជ្រើសរើសសំណើ និងផែនការទាំងនោះ និងចុងក្រោយពង្រឹងសមត្ថភាពក្រុមអ្នកផលិត ដែលបានជ្រើសរើស ព្រមទាំងសមាជិករបស់ក្រុមទាំងនោះ ព្រមទាំងសហគ្រាសកសិកម្មខ្នាតតូច និងខ្នាតមធ្យម។ សមាសភាគរងនេះនឹងផ្ដល់ហិរញ្ញប្បទានដល់៖ (ក) យុទ្ធនាការបង្កើនការយល់ដឹង និងការប្រមូលតួអង្គពាក់ព័ន្ធនានា ដើម្បីបង្កើតជាក្រុម, (ខ) ការរៀបចំ និងការវាយតម្លៃផែនការពិពិធកម្ម ដែលមានប្រសិទ្ធភាព និងសំណើអាជីវកម្ម ដែលអាចផ្ដល់នូវប្រាក់ចំណេញ និង (គ) ការរៀបចំ និងការវាយតម្លៃផែនការពិពិធកម្មពេញលេញ រាប់បញ្ចូលទាំងផែនការអាជីវកម្ម សម្រាប់សំណើអាជីវកម្មដែលត្រូវបានជ្រើសរើស និង (ឃ) ការគាំទ្រដល់ការអភិវឌ្ឍផែនការអាជីវកម្ម។

9. ***សមាសភាគរង ១.២៖ ការផ្ដល់ហិរញ្ញប្បទានដល់ការធ្វើពិពិធកម្មកសិកម្ម។*** ដើម្បីសម្រួលដល់ការផ្ដល់ហិរញ្ញប្បទានដល់ការវិនិយោគលើសកម្មភាពផលិតកម្ម និងជំនួយបច្ចេកទេស ក្នុងសំណើ

ធ្វើពិពិធកម្ម និងផែនការរអាជីវកម្ម ដែលទទួលបានការអនុម័ត គម្រោងនេះនឹងបង្កើតនូវកម្មវិធីផ្តល់ឥណទាន (Credit Line) ដោយមានការបំពេញបន្ថែមដោយកម្មវិធីផ្គូរផ្គងជំនួយខ្នាតតូច។ ឧបករណ៍ហិរញ្ញវត្ថុទាំងនេះ នឹងជួយសម្រេចគោលបំណងជារួមរបស់គម្រោង ពោលគឺការធ្វើពិពិធកម្មទៅរកដំណាំដែលមានតម្លៃខ្ពស់ និងការធ្វើពាណិជ្ជកាវូបនីយកម្មវិស័យកសិកម្ម។ ដូច្នេះ ឧបករណ៍ហិរញ្ញវត្ថុទាំងនេះនឹងផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគច្រើនប្រភេទ ពាក់ព័ន្ធនឹងការធ្វើពិពិធកម្មកសិកម្ម ដូចជា ឧបករណ៍កែច្នៃ ឧបករណ៍ធារាសាស្ត្រក្នុងកសិដ្ឋាន (ឧបករណ៍ស្រោចស្រពបែបបន្តក់ទឹក (drip) យន្តហោះខ្នាតតូច (microject) ប្រព័ន្ធបាចទឹក (sprinkler) ឃ្លាំងរក្សាកសិផលក្នុងកសិដ្ឋាន ។ល។) គ្រឿងយន្តកសិកម្ម ឃ្លាំង (ត្រជាក់) យានយន្ត ឧបករណ៍សម្រាប់វេចខ្ចប់ និងធ្វើពាណិជ្ជកម្ម ដំណោះស្រាយប្រព័ន្ធបច្ចេកវិទ្យានិងសារគមនាគមន៍ ធនធានកសិកម្ម និងការវិនិយោគសមស្របផ្សេងទៀត។

10. ***សមាសភាគរង ១.៣៖ ហេដ្ឋារចនាសម្ព័ន្ធសាធារណ:។*** គម្រោងនេះនឹងគាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធ សាធារណ: ហេដ្ឋារចនាសម្ព័ន្ធធារាសាស្រ្ត ដែលមិននៅជាប់ជាមួយនឹងកសិដ្ឋាន និងផ្លូវជនបទ ដើម្បីបង្កើន លទ្ធភាពរបស់ក្រុមអ្នកផលិតក្នុងការធ្វើពិពិធកម្ម ការដាំដុះរបស់ខ្លួនតាមរយៈការបង្កើនការផ្គត់ផ្គង់ទឹកទៅតាមតម្រូវការជាក់ស្តែង និង ដឹកជញ្ជូនកសិផលទៅកាន់ទីផ្សារប្រកបដោយប្រសិទ្ធភាព ដែលអាចជួយពន្លឿនការផ្គត់ផ្គង់ និងកាត់បន្ថយការខាតបង់ឱ្យនៅតិចជាអប្បបរមា។

11. **សមាសភាគទី ២៖ លើកកម្ពស់ប្រព័ន្ធព័ត៌មានកសិកម្ម និងការគ្រប់គ្រងការត្រួតពិនិត្យគុណភាព។** គោលបំណងនៃសមាសភាគទី ២ នេះ គឺដើម្បីពង្រឹងចំណេះដឹងជាមូលដ្ឋាន សមត្ថភាពវិភាគទិន្នន័យ និងប្រព័ន្ធអនុវត្តលិខិតបទដ្ឋានគតិយុត្តិក្នុងវិស័យសាធារណ: ព្រមទាំងការអនុវត្ត និងការពង្រឹងការអនុវត្តប្រព័ន្ធទាំងនេះ។ ការងារទាំងនេះនឹងរួមចំណែកពង្រីក និងបង្កើនតម្លាភាពចំណេះដឹង ព្រមទាំងកែលម្អការធ្វើសេចក្តីសម្រេចចិត្តរបស់តួអង្គក្នុងវិស័យសាធារណ: និងវិស័យឯកជន ដែលផលសម្រេចបាននឹងមានវិសាលភាពលើសពីអនុគម្រោង PA ដែលបានទទួលការគាំទ្រទៅទៀត។ ប្រព័ន្ធព័ត៌មានកសិកម្ម និងគ្រប់គ្រងគុណភាពកសិកម្ម នឹងផ្តល់ប្រយោជន៍ដល់អ្នកពាក់ព័ន្ធផ្ទាល់ ក៏ដូចជា កសិករ ក្រុមអ្នកផលិត និងសហគ្រាសកសិកម្មខ្នាតតូច និងខ្នាតមធ្យម ដែលកំពុងប្រតិបត្តិការនៅក្នុងឃុំ និងខេត្តផ្សេងទៀត ក្រៅតែពីតំបន់គម្រោងផងដែរ។ សមាសភាគនេះក៏នឹងផ្តល់ហិរញ្ញប្បទានដល់ការងារវិភាគ និងផ្តល់ប្រឹក្សាគោលនយោបាយ ដើម្បីតម្រង់ទិសការវិនិយោគរបស់រដ្ឋាភិបាលក្នុងការគាំទ្រដល់ការអភិវឌ្ឍវិស័យកសិកម្ម។

12. ***សមាសភាគរង ២.១៖ ប្រព័ន្ធព័ត៌មានកសិកម្ម។*** នឹងមានការផ្តល់ហិរញ្ញប្បទានសម្រាប់ការវិនិយោគលើការបន្តអភិវឌ្ឍន៍ និងលើកកម្ពស់ការប្រើប្រាស់ផែនទីដី/ក្បេត្របរិស្ថាន ប្រព័ន្ធផ្តល់ព័ត៌មានទាន់ពេលវេលាពាក់ព័ន្ធនឹងកសិកម្ម ស្ថិតិផលិតកម្មអាហារ និងកសិកម្ម/ទិន្នន័យជំរឿន (ព័ត៌មានទីផ្សារកសិកម្ម និងប្រព័ន្ធព័ត៌មានទីផ្សារ) និងទិន្នន័យដទៃទៀត។ បច្ចេកវិទ្យា ICT ថ្មីៗ នឹងត្រូវយកមកប្រើប្រាស់ ដើម្បីធានាឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយបំផុត និង ការប្រើប្រាស់ឱ្យបានល្អបំផុតនូវទិន្នន័យ និងព័ត៌មានដែលមាន សម្រាប់ការរៀបចំផែនការ និងការធ្វើសេចក្តីសម្រេចចិត្តរបស់តួអង្គពាក់ព័ន្ធក្នុងវិស័យសាធារណ: និងវិស័យឯកជនពាក់ព័ន្ធនឹងផលិតកម្ម ការកែច្នៃ ការស្វែងរកទីផ្សារផលិតផលកសិកម្ម និងសេវាកម្ម។ លើសពីនេះ ក៏នឹងមានការគាំទ្រដល់ការប្រមូលព័ត៌មានទីផ្សារ ដើម្បីកំណត់រកឱកាសរយ:ពេលមធ្យម និងរយ:ពេលវែងសម្រាប់ផលិតផលសមស្របផងដែរ។ នឹងមានការផ្តល់ថវិកា សម្រាប់ផ្តល់ព័ត៌មានឱ្យចំក្រុមគោលដៅដោយប្រើប្រាស់បច្ចេកវិទ្យាសមស្របថ្មីៗ ដើម្បីផ្តល់ព័ត៌មានដល់កសិករជាស្ត្រីចូលរួមក្នុងគម្រោង ដែលមានលទ្ធភាពតិចតួច ដើម្បីយល់ពីឯកសារជាលាយល័ក្ខណ៍អក្សរ។ ការផ្សព្វផ្សាយព័ត៌មាន នឹងបញ្ចូលសារអប់រំ ពាក់ព័ន្ធនឹងអាហារូបត្ថម្ភ និងឯកសារនានា ពាក់ព័ន្ធនឹងការពង្រឹងលទ្ធផលអាហារូបត្ថម្ភរបស់គម្រោង។

13. ***សមាសភាគរង ២.២ ការគ្រប់គ្រងគុណភាព។*** ការវិនិយោគ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការការពាររុក្ខជាតិ និងភូតគាមអនាម័យ សុខភាពសត្វ និងការឃ្លាំមើលភូតគាមអនាម័យ សុខភាពសត្វ និងសុវត្ថិភាពអាហារ ប្រព័ន្ធរាយការណ៍ និងប្រព័ន្ធអធិការកិច្ច ហើយនឹងមានការគាំទ្រ

ដល់ប្រព័ន្ធពង្រឹងការអនុវត្តការគ្រប់គ្រងលើវត្ថុធាតុដើមកសិកម្ម។ ការគាំទ្រនេះ រួមមានការគាំទ្រដល់ការបង្កើតសេវាចេញវិញ្ញាបនបត្រ ផ្តល់អាជ្ញាប័ណ្ណ និងត្រួតពិនិត្យ និងគ្រប់គ្រងគុណភាពផ្សេងទៀត ព្រមទាំងការរៀបចំ និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តិ អំពីការអនុវត្តល្អផ្នែកកសិកម្ម (GAP) និងការអនុវត្តល្អផ្នែកផលិតផលសរីរាង្គ ការចិញ្ចឹមសត្វ និងការប្រើប្រាស់ព័ត៌មានសម្គាល់ ភូមិសាស្ត្រ។ល។

14. **សមាសភាគទី ៣៖ ការគ្រប់គ្រងគម្រោង និងការពិនិត្យតាមដាន និងវាយតម្លៃ។** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាទីភ្នាក់ងារប្រតិបត្តិចម្បង សម្រាប់អនុវត្ត និងគ្រប់គ្រងការសម្របសម្រួលជារួម។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអង្គភាពបច្ចេកទេស នៃក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម ដែលជាដៃគូអនុវត្តទទួលខុសត្រូវលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ជនបទ។ នឹងមានការគាំទ្រដល់ការបង្កើតក្រុមសម្របសម្រួលគម្រោង និងគាំទ្រការអនុវត្តក្រោមការដឹកនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលស្ថិតនៅជាមួយលេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក។ ការបង្កើតគណៈកម្មាធិការដឹកនាំកម្រិតខ្ពស់ នឹងត្រូវធ្វើឡើងផងដែរ ដើម្បីផ្តល់ដំបូន្មាន និងដោះស្រាយបញ្ហាអន្តរវិស័យ ដែលកើតឡើងថ្មីៗ។ ព័ត៌មានលំអិត នឹងត្រូវរៀបរាប់ ក្នុងសៀវភៅណែនាំស្តីពីប្រតិបត្តិការ គម្រោង។

15. **សមាសភាគទី ៤៖ សមាសភាគឆ្លើយតប ចំពោះស្ថានភាពអាសន្នជាយថាហេតុ។** គោលបំណងនៃ សមាសភាគឆ្លើយតបចំពោះស្ថានភាពអាសន្នជាយថាហេតុ ដែលមានការវិភាជន៍ថវិកាបណ្តោះអាសន្នស្មើសូន្យនេះ គឺដើម្បីផ្តល់លទ្ធភាពឱ្យមានការវិភាជន៍ថវិកាឡើងវិញ ទៅតាមយន្តការឆ្លើយតបបន្ទាន់របស់ IDA សំដៅផ្តល់ការឆ្លើយតបបន្ទាន់ ចំពោះវិបត្តិ ឬស្ថានភាពអាសន្ន ទៅតាមការចាំបាច់។ សៀវភៅណែនាំស្តីពីការឆ្លើយតបចំពោះ ស្ថានភាពអាសន្ន (ERM) នឹងត្រូវរៀបចំឡើង សម្រាប់សកម្មភាពនានា ក្រោមសមាសភាគនេះ ដោយរៀបរាប់លម្អិតពីការរៀបចំសម្រួលនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ កិច្ចលទ្ធកម្ម ការការពារផលប៉ះពាល់ និងការរៀបចំការអនុវត្តចាំបាច់ផ្សេងទៀត។ ក្នុងករណីដែលត្រូវអនុវត្តសមាសភាគនេះ នឹងមានការកែសម្រួលក្របខ័ណ្ឌលទ្ធផល ដោយធ្វើការរៀបចំរចនាសម្ព័ន្ធផ្លូវការសារជាថ្មី ដើម្បីបញ្ចូលសូចនាករសមស្រប ពាក់ព័ន្ធនឹងសកម្មភាពឆ្លើយតបចំពោះស្ថានភាពអាសន្ន។

2.3 អ្នកទទួលផលគម្រោង និងទីតាំងគម្រោង

16. **ទីតាំងភូមិសាស្ត្រគោលដៅ៖** គម្រោងនេះនឹងអនុវត្តក្នុងខេត្តចំនួន ១២ បូករួមទាំងទីក្រុងភ្នំពេញ។ ខេត្តទាំងនេះត្រូវបានជ្រើសរើស ដោយសារស្ថានភាពក្សេត្របរិស្ថានសមស្រប សម្រាប់ផលិតផល ដែលមានតម្លៃខ្ពស់ ដោយទីក្រុងភ្នំពេញ គឺជាទីតាំង ដែលអាចមានសហគ្រាសកសិកម្មខ្នាតតូចជាច្រើនមានលទ្ធភាពចូលរួម។ ខេត្តទាំងនេះ រួមមាន បាត់ដំបង មណ្ឌលគិរី ស្ទឹងត្រែង រតនគិរី ព្រះវិហារ កំពង់ចាម កំពង់ធំ ក្រចេះ សៀមរាប កណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង និងភ្នំពេញ។ នៅតាមបណ្តាខេត្តទាំងនេះ គេរំពឹងថាទីតាំងគម្រោង ដែលបំពេញតាមលក្ខណៈសម្បត្តិសមស្រប នឹងស្ថិតនៅតាមតំបន់ ដែល (i) មានក្រុមអ្នកផលិតសកម្ម ដែលបានចងក្រងគ្នាជាក្រុមរួចជាស្រេច, (ii) មានទឹកប្រើប្រាស់ច្រើនរដូវក្នុងកម្រិតអាចជឿទុកចិត្តបាន និង (iii) មានផ្លូវតូចៗ ដែលមានស្រាប់ ដែលមានប្រវែងអតិបរមា ១០ គីឡូម៉ែត្រ សម្រាប់ភ្ជាប់ជាមួយនឹងផ្លូវដែលអាចប្រើប្រាស់បានគ្រប់រដូវ។

17. **អ្នកទទួលផលគោលដៅ៖** អ្នកទទួលផលផ្ទាល់ពីគម្រោងនេះ រួមមាន កសិករខ្នាតតូច និងខ្នាតមធ្យម ដែលត្រូវបានចងក្រងជាក្រុមអ្នកផលិត ឬជាសហគមន៍ និងបង្ហាញពីសក្តានុពល និងចំណាប់អារម្មណ៍ចង់អភិវឌ្ឍន៍ អាជីវកម្មកសិកម្មរបស់ពួកគេ និងអាជីវកម្មកសិកម្មខ្នាតតូច និងខ្នាតមធ្យម ដែលចាប់អារម្មណ៍ចង់សហការដោយផ្ទាល់ជាមួយកសិករ ដើម្បីរួមគ្នាអភិវឌ្ឍន៍អាជីវកម្ម/សង្វាក់តម្លៃរបស់ខ្លួន។ អ្នកទទួលផលដោយប្រយោលផ្សេងទៀត រួមមាន អ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ដែលត្រូវបានកែសម្អសម្រាប់លើកកម្ពស់ការភ្ជាប់ទំនាក់ទំនងជាមួយទីផ្សារ ផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ។ ការបង្កើនភាពអាចរក

បាននូវទិន្នន័យ និងព័ត៌មាន និងលទ្ធភាពទទួលបានទិន្នន័យ និងព័ត៌មានទាំងនេះ ព្រមទាំងយន្តការធានាគុណភាព (ដូចជា ក្របខ័ណ្ឌនិយតកម្ម ហេដ្ឋារចនាសម្ព័ន្ធ) នឹងផ្តល់ជាប្រយោជន៍ដល់វិស័យទាំងមូល។

## 3.0 ក្របខ័ណ្ឌគោលនយោបាយ គតិយុត្ត និងរដ្ឋបាល

18. ផ្នែកនេះរៀបរាប់ពីលក្ខខណ្ឌតម្រូវពាក់ព័ន្ធនៅក្នុងប្រទេស ជុំវិញការគ្រប់គ្រងបរិស្ថាន និងសង្គម, គោលនយោបាយស្តីពីការការពារផលប៉ះពាល់របស់ធនាគារ ដែលត្រូវអនុវត្តចំពោះគម្រោងនេះ និងអនុគម្រោង និងការវិភាគគម្លាតរវាងលក្ខខណ្ឌតម្រូវរបស់រដ្ឋាភិបាល និងលក្ខខណ្ឌតម្រូវក្នុងគោលនយោបាយរបស់ធនាគារ និងវិធានការដើម្បីបំពេញគម្លាតទាំងនេះ។

## 3. 1 ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ ដែលពាក់ព័ន្ធ

19. ផ្នែកនេះរៀបរាប់ពីច្បាប់ ក្រឹត្យ សារាចរ សេចក្តីសម្រេច និងលិខិតបទដ្ឋានគតិយុត្ត និងស្តង់ដារបច្ចេកទេសរបស់ជាតិ ពាក់ព័ន្ធនឹងគម្រោងនេះ។ ជាការសំខាន់ណាស់ ដែលលិខិតបទដ្ឋានគតិយុត្តតាមវិស័យ (ឧទាហរណ៍ ថាមពល ជនបទ សុខាភិបាល) ស្តីពីបរិស្ថាន និងសង្គម ពាក់ព័ន្ធនឹងគម្រោងនេះ ត្រូវលើកយកមករៀបរាប់ក្នុងផ្នែកនេះដែរ។

20. ការគ្រប់គ្រងបរិស្ថានជារួម ស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងបរិស្ថាន ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៣។ ក្រសួងបរិស្ថាន ទទួលបន្ទុកអនុវត្តច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ នៅថ្នាក់រាជធានីខេត្ត មានមន្ទីរបរិស្ថានរាជធានីខេត្ត ជាសេនាធិការឱ្យក្រសួងបរិស្ថាន។ មន្ទីរទាំងនេះទទួលខុសត្រូវពង្រឹងការអនុវត្តច្បាប់បរិស្ថាន ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។ ទោះជាយ៉ាងណាក៏ដោយ មុខងារប្រតិបត្តិការប្រចាំថ្ងៃរបស់មន្ទីរទាំងនេះ ជាធម្មតាស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អាជ្ញាធរខេត្ត។

21. ច្បាប់ក្របខ័ណ្ឌ អំពាវនាវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបឋម (IEIA) ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) អាស្រ័យទៅតាមប្រភេទ និងសកម្មភាព និងទីតាំងរបស់គម្រោង (អនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបឋម/ពេញលេញ (មាត្រា ១ និង ២ នៃអនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបឋម/ពេញលេញ) ដែលត្រូវធ្វើសម្រាប់គ្រប់គម្រោងឯកជន ឬគម្រោងរដ្ឋទាំងអស់ និងត្រូវពិនិត្យដោយក្រសួងបរិស្ថាន មុនពេលដាក់ជូនរដ្ឋាភិបាល ដើម្បីធ្វើការសម្រេចចិត្តចុងក្រោយ។ រាល់សកម្មភាពដែលស្នើឡើង និងសកម្មភាពដែលមានស្រាប់ទាំងអស់ ត្រូវបំពេញទៅតាមលក្ខខណ្ឌតម្រូវនេះ។ កាលពីពេលថ្មីៗនេះ សេចក្តីប្រកាសស្តីពីការណែនាំទូទៅលេខ ៣៧៦ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបឋម និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវបានចុះហត្ថលេខា និងដាក់ឱ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួងបរិស្ថានកាលពីថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០០៨។ ឯកសារណែនាំនេះ មានគោលដៅអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបឋម (IEIA), ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA), និងផ្តល់ការណែនាំព្រមទាំងបញ្ជីត្រួតពិនិត្យទូទៅ។ គ្រប់គម្រោងទាំងអស់ ចាំបាច់ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបឋម ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ អាស្រ័យទៅតាមប្រភេទ និងសកម្មភាព និងទីតាំងរបស់គម្រោង (អនុក្រឹត្យស្តីពីដំណើរការ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបឋម/ពេញលេញ (មាត្រា ១ និង ២ នៃអនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបឋម/ពេញលេញ)។ ក្រសួងបរិស្ថានទទួលបន្ទុកពិនិត្យលើរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការតាមដានបន្តដែលចាំបាច់ និងការពិនិត្យតាមដាន។

### ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

22. ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវបានអនុម័តដោយរដ្ឋសភា និងប្រកាសដាក់ឱ្យអនុវត្តដោយព្រះរាជក្រម ន.ស-រ.ក.ម ១២៩៦/៣៦។ ច្បាប់នេះ ត្រូវបានអនុម័តកាលពីថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦។ ច្បាប់នេះមានគោលបំណងដូចខាងក្រោម៖

(ក) ការពារ និងលើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពសាធារណៈ តាមរយៈការបង្ការ ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុល

(ខ) វាយតម្លៃលើហេតុប៉ះពាល់បរិស្ថាននៃរាល់គម្រោង ដែលស្នើឡើងទាំងអស់ មុនពេលរាជរដ្ឋាភិបាលចេញសេចក្តីសម្រេច

(គ) ធានាឱ្យមានការអភិរក្ស ការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប ប្រកបដោយចីរភាព ក្នុងព្រះរាជាណាចក្រកម្ពុជា

(ឃ) លើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណជន អាចចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និង

(ង) បង្ក្រាបអំពើទាំងឡាយដែលបង្កឱ្យមានផលប៉ះពាល់មកលើបរិស្ថាន។

23. ក្រោមច្បាប់នេះ អ្នកអភិវឌ្ឍន៍ ឬម្ចាស់គម្រោង ចាំបាច់ត្រូវរៀបចំរបាយការណ៍ IEIA ឬ EIA សម្រាប់គម្រោងអភិវឌ្ឍន៍ ដែលស្នើឡើង ឬដែលមានស្រាប់។

**អនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន**

24. អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៩៩៩។ មាត្រាពាក់ព័ន្ធសំខាន់ៗ មានដូចតទៅ៖ អនុក្រឹត្យនេះ មានគោលបំណង៖

(ក) កំណត់ពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) សម្រាប់រាល់គម្រោង ឬសកម្មភាពឯកជន និងសាធារណៈទាំងអស់ ដោយត្រូវឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រសួងបរិស្ថាន មុនពេលដាក់ជូនរាជរដ្ឋាភិបាល ធ្វើសេចក្តីសម្រេចចិត្ត។

(ខ) កំណត់ពីប្រភេទ និងទំហំគម្រោង និងសកម្មភាពដែលស្នើឡើង រួមទាំងសកម្មភាពដែលមានស្រាប់ និងដែលកំពុងអនុវត្តក្នុងវិស័យឯកជន និងវិស័យសាធារណៈ មុនពេលអនុវត្តដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

(គ) លើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណជនទូទៅ ក្នុងការអនុវត្តដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងមានការពិចារណាលើគំនិតយោបល់ និងសំណូមពររបស់សាធារណជន ដើម្បីយកទៅធ្វើការពិចារណា មុនពេលអនុវត្តគម្រោងនានា។

**អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក**

25. អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ចុះកាលបរិច្ឆេទថ្ងៃទី ៦ ខែមេសា ឆ្នាំ ១៩៩៩។ អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រងការត្រួតពិនិត្យការបំពុលទឹក ដើម្បីបង្ការ និងកាត់បន្ថយការបំពុលទឹកនៅតាមដែនទឹកសាធារណៈ ដើម្បីការពារសុខភាពមនុស្ស និងអភិរក្សជីវៈចម្រុះ, មាត្រា ១។

26. អនុក្រឹត្យនេះ អនុវត្តចំពោះរាល់ប្រភពនៃការបំពុល និងរាល់សកម្មភាពទាំងអស់ ដែលបង្កឱ្យមានការបំពុល ដែនទឹកសាធារណៈ, មាត្រា ២។ អនុក្រឹត្យនេះ ក៏ចែងពីប្រភេទនៃការបំពុល ស្តង់ដារនៃការបញ្ចេញសំណល់ និងស្តង់ដាគ្រប់គ្រងគុណភាពទឹកនៅតាមតំបន់ផ្សេងៗផងដែរ។ សម្រាប់គម្រោងនេះ ស្តង់ដារគុណភាពទឹកមួយចំនួនសម្រាប់ដែនទឹកសាធារណៈនឹងត្រូវយកមកអនុវត្ត។

**អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង**

27. អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩។ អនុក្រឹត្យនេះមានគោលបំណងកំណត់ពីការគ្រប់គ្រងសំណល់រឹង ទៅតាមបច្ចេកទេសសមស្រប និងមានសុវត្ថិភាព ដើម្បីធានាឱ្យមានការការពារសុខភាពមនុស្ស និងការអភិរក្សជីវចម្រុះ។

28. អនុក្រឹត្យនេះ អនុវត្តចំពោះគ្រប់សកម្មភាពទាំងអស់ ពាក់ព័ន្ធនឹងការចោល ការរក្សាទុក ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ និងការចោលសំរាម និងសំណល់គ្រោះថ្នាក់។

### អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់

29. អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងសំឡេងរំខាន ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០។ អនុក្រឹត្យនេះ មានគោលបំណងការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ពីសារធាតុបំពុលខ្យល់ និងការបំពុលដោយសំឡេង តាមរយៈវិភាគ និងពិនិត្យតាមដាន ទប់ស្កាត់ និង សម្រាលផលប៉ះពាល់។ អនុក្រឹត្យនេះ អនុវត្តចំពោះប្រភពចល័ត និងប្រភពអចល័តទាំងអស់ ដែលបង្ក ការបំពុលខ្យល់ និងសំឡេងរំខាន។

### កម្មវិធីជាតិគ្រប់គ្រងសមាសភាគចង្រៃចម្រុះ ឆ្នាំ ១៩៩៣

30. ការគ្រប់គ្រងសមាសភាគចង្រៃចម្រុះ (IPM) នៅកម្ពុជា ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៣ បន្ទាប់ពី សិក្ខាសាលាជាតិស្តីពី "បរិស្ថាន និងការគ្រប់គ្រងសមាសភាគចង្រៃចម្រុះ"។ កម្មវិធី IPM មានគោលដៅរួម លើកកម្ពស់សន្តិសុខស្បៀងនៅកម្ពុជា តាមរយៈការពង្រឹងនិរន្តរភាពប្រព័ន្ធផលិតកម្ម ដំណាំបែបប្រពលវប្បកម្ម តាមរយៈការបង្កើនជំនាញគ្រប់គ្រងដំណាំចម្រុះ (ICM) នៅកម្រិតកសិដ្ឋាន។ កម្មវិធីនេះមានគោលបំណងៈ

(ក) កាត់បន្ថយការពឹងអាស្រ័យលើសារធាតុគីមីកសិកម្ម ជាពិសេសថ្នាំកសិកម្ម ក្នុងផលិតកម្មកសិកម្ម និងកាត់បន្ថយគ្រោះថ្នាក់លើសុខភាពមនុស្ស សត្វ និងបរិស្ថាន

(ខ) អភិវឌ្ឍន៍សមត្ថភាពកសិករ និងមន្ត្រីបច្ចេកទេសកសិកម្ម ក្នុងការរៀបចំ ការបណ្តុះបណ្តាល និងការពិសោធ ដើម្បីឱ្យពួកគេអាចកំណត់ពីបញ្ហាដែលកើតមានឡើង ក្នុងផលិតកម្មកសិកម្ម និងស្វែងរកដំណោះស្រាយសមស្រប ដើម្បីដោះស្រាយជាមួយនឹងបញ្ហានេះ ដោយខ្លួនឯង។

(គ) អប់រំកសិករអំពីបច្ចេកវិទ្យាកសិកម្ម តាមរយៈការបង្កើនចំណេះដឹងរបស់ពួកគេអំពីប្រព័ន្ធបរិស្ថាននៅមូលដ្ឋាន និងអភិវឌ្ឍន៍ជំនាញរបស់កសិករ ឱ្យចេះពិនិត្យតាមដាន និងវិភាគស្ថានភាពនៅមូលដ្ឋាន ដែលផ្តល់លទ្ធភាព ឱ្យពួកគេអាចគ្រប់គ្រងដំណាំឱ្យបានត្រឹមត្រូវ។

3.2 គោលនយោបាយស្តីពីការការពារផលប៉ះពាល់របស់ធនាគារពិភពលោក ដែលត្រូវយកមកអនុវត្ត

31. ***ផ្នែកនេះ គួររៀបរាប់ពីគោលនយោបាយស្តីពីការការពារផលប៉ះពាល់របស់ធនាគារពិភពលោក ដែលត្រូវយកមកអនុវត្ត។*** របាយការណ៍ពិនិត្យបឋមលើគម្រោង/អនុគម្រោង ត្រូវកំណត់ពីគោលនយោបាយស្តីពីការការពារផលប៉ះពាល់បរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក ដែលត្រូវអនុវត្តចំពោះគម្រោងនេះ ព្រមទាំងត្រូវកំណត់ពីពេល និងរបៀបដែលត្រូវអនុវត្ត ឬមិនអនុវត្ត គោលនយោបាយស្តីពីការការពារផលប៉ះពាល់របស់ធនាគារពិភពលោក។ ចំណាត់ថ្នាក់នៃការវាយតម្លៃ បរិស្ថាន (EA) របស់ធនាគារពិភពលោក ដែលត្រូវផ្តល់សម្រាប់គម្រោងនេះ និងបញ្ហាបរិស្ថាន និងសង្គម សំខាន់ៗ ដែលត្រូវបានកំណត់ ក្រោមគោលនយោបាយស្តីពីការការពារផលប៉ះពាល់ ក៏ត្រូវលើកយក មកធ្វើការពិភាក្សាក្នុងផ្នែកនេះផងដែរ។ សម្រាប់គោលនយោបាយស្តីពីការការពារផលប៉ះពាល់ នីមួយៗរបស់ធនាគារពិភពលោក ដែលត្រូវអនុវត្តដោយគម្រោង ត្រូវមានការរៀបរាប់ ដោយសង្ខេប ដើម្បីពន្យល់ពីហេតុផលដែលនាំឱ្យមានការអនុវត្តគោលនយោបាយនេះ លក្ខខណ្ឌតម្រូវ ដែលមានចែង ក្នុងគោលនយោបាយ និងអនុលោមតាមលក្ខខណ្ឌតម្រូវទាំងនេះ។ គោលនយោបាយស្តីពីការការពារ ផលប៉ះពាល់ទាំងអស់ ដែលត្រូវអនុវត្តក្រោមគម្រោងនេះ ចាំបាច់ត្រូវលើកយកមកធ្វើការពិភាក្សា។

*32.* ***គោលនយោបាយនេះ តម្រូវឱ្យមានការអនុវត្តគោលនយោបាយស្តីពីការការពារផលប៉ះពាល់ បរិស្ថានចំនួនប្រាំ ដូចជាគោលនយោបាយស្តីពី*** ការវាយតម្លៃបរិស្ថាន (OP/BP 4.01), ការគ្រប់គ្រងសមាសភាគចង្រៃ (OP/BP 4.09), ធនធានវប្បធម៌រូបវន្ត (OP/BP 4.11), សុវត្ថិភាពទំនប់ទឹក (OP/BP 4.37), និងគោលនយោបាយច្បាប់ចំនួនមួយ សម្រាប់គម្រោងអនុវត្តលើផ្លូវទឹកអន្តរជាតិ (OP/BP 7.50)។ គោលនយោបាយស្តីពីការការពារផលប៉ះពាល់ទាំងនេះ ត្រូវយកមកអនុវត្ត ដោយសារគេរំពឹងថា អាចនឹងមានផលប៉ះពាល់ជាទ្រង់ទ្រាយតូច ដែលពុំអាចផ្តល់ត្រលប់មកស្ថានភាពដើមវិញបាន ចេញពី (i) ជំនួយបច្ចេកទេស និងការងារសាងសង់ ដូចជា ការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ ផ្លូវ

ភ្ជាប់ពីកសិដ្ឋានទៅទីផ្សារ ការប្រើប្រាស់គ្រឿងយន្តកសិកម្ម សេវាហេដ្ឋារចនាសម្ព័ន្ធ និង (ii) លទ្ធភាពប្រើប្រាស់ថ្នាំកសិកម្ម និងសារធាតុគីមី ដើម្បីបង្កើនផលិតកម្មក្រោមសមាសភាគទី ១ និងទី ២។

33. ***ការវាយតម្លៃបរិស្ថាន (OP/BP 4.01)*** ។ គោលនយោបាយនេះត្រូវយកមកអនុវត្ត ដោយសារការផ្តល់ជំនួយបច្ចេកទេស និងផលប៉ះពាល់អវិជ្ជមាន ដែលអាចកើតមានក្រោមការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជា ការធ្វើពិពិធកម្ម ប្រព័ន្ធកសិកម្ម ការបង្កើនផលិតភាព និងការអភិវឌ្ឍទីផ្សារផលិតផលកែច្នៃ និងផលិតផលចំណីអាហារ ដែលមានតម្លៃខ្ពស់, ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដូចជា ផ្លូវកម្រិតទី ៣ និងការស្តារសំណង់ធារាសាស្ត្រ និងការបង្កើនសមត្ថភាពមន្ទីរពិសោធន៍។ ដោយសារគេពុំទាន់ដឹងទីតាំងនៅឡើយ គម្រោងនេះនឹងរៀបចំលិខិតុបករណ៍ជាក់លាក់តាមទីតាំងនីមួយៗ (ដូចជា ESMP ឬ ESIA) ផ្អែកទៅតាម ESMF របស់គម្រោងទាំងមូល បន្ទាប់ពីមានការកំណត់ដឹងពីអនុគម្រោងរួច។ គោលការណ៍ណែនាំអន្តរកាលស្តីពីការអនុវត្តគោលនយោបាយស្តីពីការការពារផលប៉ះពាល់ចំពោះសកម្មភាពជំនួយបច្ចេកទេស ក្រោមក្របខ័ណ្ឌនៃគម្រោង ដែលទទួលបានហិរញ្ញប្បទានពីធនាគារ និងត្រូវបញ្ចូលទៅក្នុងលក្ខខណ្ឌប្រតិបត្តិសម្រាប់អន្តរាគមន៍ក្នុងគម្រោងជំនួយបច្ចេកទេស និងសេវាហិរញ្ញវត្ថុ ដែលត្រូវបានរៀបចំឡើង ក្រោមគម្រោងនេះ។

34. ***ស្តង់ដារលទ្ធផលការងារ សម្រាប់សកម្មភាពវិស័យឯកជន (OP/BP 4.03)*** ពុំត្រូវបានយកមកអនុវត្តឡើយ។ ទោះជាយ៉ាងណាក៏ដោយ រាល់អនុគម្រោងទាំងអស់ ក្រោមកម្មវិធីផ្តល់ជំនួយសម្រាប់ផ្គូរផ្គងដៃគូ និងការផ្តល់ហិរញ្ញ-ប្បទានក្នុងទម្រង់ជាគណនីសម្រាប់ការវិនិយោគនៅក្នុងកសិដ្ឋាន សហគ្រាសកសិកម្ម និងសហគ្រាសផ្សេងទៀត ចាំបាច់ត្រូវអនុវត្តតាម ESMF និងឧបករណ៍ការពារផលប៉ះពាល់ពាក់ព័ន្ធដទៃទៀត។ នឹងមានការពិនិត្យបឋមលើគ្រប់អនុគម្រោងទាំងអស់ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃសហគ្រាសកសិកម្ម និងសហគ្រាសផ្សេងទៀត ដើម្បីអាចក្លាយជាអ្នកទទួលផលរបស់គម្រោង ដូចដែលតម្រូវក្នុងឧបសម្ព័ន្ធទី ១០។

35. ***ដែនជម្រកធម្មជាតិ (OP/BP 4.04)*** ។ គោលនយោបាយនេះ ពុំត្រូវយកមកអនុវត្តឡើយ ដោយសារតែ ការងារសំណង់នានា ដូចជា ធារាសាស្ត្រ និងការជួសជុលកែលម្អផ្លូវជាដើម នឹងត្រូវធ្វើឡើងក្នុងតំបន់កសិកម្ម ឬតំបន់ថ្មី ដែលគេរំពឹងថា នឹងបង្កផលប៉ះពាល់ ឬទន្ទ្រានដែនជម្រកធម្មជាតិ ដែលគេធ្លាប់ស្គាល់កន្លងមកនោះឡើយ។

***ព្រៃឈើ (OP/BP 4.36)*** ។ គោលនយោបាយនេះពុំត្រូវអនុវត្តឡើយ ដោយសារតែការងារសំណង់ ដូចជា ការស្តារប្រព័ន្ធធារាសាស្ត្រ និងជួសជុលកែលម្អផ្លូវថ្នល់ និងធ្វើឡើងក្នុងតំបន់កសិកម្ម ឬតំបន់ថ្មី ដែលគេរំពឹងថា នឹងមិនបង្កឱ្យមានផលប៉ះពាល់ ឬទន្ទ្រានដែនជម្រកធម្មជាតិ ដែលគេធ្លាប់បានស្គាល់នោះឡើយ។

36. ***ការគ្រប់គ្រងសមាសភាគចង្រៃ (OP/BP 4.09)*** ។ គោលនយោបាយនេះត្រូវយកមកអនុវត្ត ដោយសារនៅក្នុងគម្រោងនេះមានការប្រើប្រាស់ ឬការជំរុញឱ្យមានការទិញថ្នាំកសិកម្ម ជីគីមី ឬសារធាតុគីមី សម្រាប់ផលិតកម្មកសិកម្ម។ បើទោះបីជាគោលនយោបាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជំរុញឱ្យមានការធ្វើកសិកម្មបែបសរីរាង្គ និងការធ្វើកសិកម្មដោយពុំប្រើប្រាស់ថ្នាំកសិកម្មយ៉ាងណាក៏ដោយ អ្នកខ្ចីបានបញ្ចូលផែនការគ្រប់គ្រងថ្នាំកសិកម្ម (PMP) ក្នុង ESMF របស់គម្រោងនេះ ដើម្បីឆ្លើយតបចំពោះហានិភ័យ ដែលកើតឡើងដោយសារសកម្មភាពពាក់ព័ន្ធនឹងថ្នាំកសិកម្ម។ សូមមើលផែនការគ្រប់គ្រងសមាសភាគចង្រៃ (PMP) ក្នុងឧបសម្ព័ន្ធទី ៨។ PMP ត្រូវបានរៀបចំឡើងផ្អែកតាមគោលការណ៍ស្តីពីការគ្រប់គ្រងសមាសភាគចង្រៃចម្រុះ (IPM) ដែលរៀបរាប់ពីក្របខ័ណ្ឌគតិយុត្តជាតិ ស្ថានភាពនៃការត្រួតពិនិត្យសមាសភាគចង្រៃ និងជំងឺ យន្តការពិនិត្យតាមដាន និងគ្រប់គ្រង។ ផែនការគ្រប់គ្រងសមាសភាគចង្រៃមានបីផ្នែកៈ (i) ការអនុវត្តលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋាភិបាលស្តីពីការត្រួតពិនិត្យការប្រើប្រាស់ថ្នាំកសិកម្ម, (ii) ការបណ្តុះបណ្តាលអំពីទស្សនទានស្តីពីការប្រើប្រាស់ថ្នាំកសិកម្មចម្រុះ និង/ឬវិធីសាស្ត្រផ្សេងទៀត សម្រាប់ប្រើប្រាស់ថ្នាំកសិកម្មប្រកបដោយសុវត្ថិភាព និង (iii) ការពិនិត្យតាមដាន។ ផែនការគ្រប់គ្រងសមាសភាគចង្រៃកំណត់ពីសកម្មភាពជាច្រើន ដើម្បីពង្រឹងការអនុវត្តការគ្រប់គ្រងសមាសភាគចង្រៃចម្រុះ និងការបង្កើនការយល់ដឹង និងមានបញ្ចូលកម្មវិធីកសាងសមត្ថភាព និងពិនិត្យតាមដាន ដើម្បី

បង្កលក្ខណៈងាយស្រួលដល់ការអនុវត្តផងដែរ។ គេរំពឹងថា នឹងពុំមានការធ្វើលទ្ធកម្មថ្នាំកសិកម្ម ក្រោមគម្រោងនេះឡើយ ហើយការប្រើប្រាស់ថ្នាំកសិកម្មជារួម នឹងមានការថយចុះ ដោយសារការដាក់ឱ្យអនុវត្តនូវការអនុវត្តល្អផ្នែកកសិកម្ម (GAP)។ ទោះបីជាបែបនេះក៏ដោយ ថ្នាំកសិកម្មនៅកំពុងត្រូវបានប្រើដោយកសិករក្នុងតំបន់គម្រោង ដូច្នេះផែនការនេះនឹងត្រូវអនុវត្តចំពោះសកម្មភាពគម្រោង ដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរការអនុវត្តកសិកម្ម និង/ឬការស្តារឡើងវិញ ឬការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ដែលអាចជំរុញឱ្យកសិករបង្កើនថ្នាំកសិកម្មរបស់ពួកគេ ប្រសិនបើពុំមានការបណ្តុះបណ្តាល ឬការពិនិត្យតាមដាននោះទេ។ ផែនការនេះមានបីផ្នែកៈ (i) ការអនុវត្តលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋាភិបាលស្តីពីការត្រួតពិនិត្យថ្នាំកសិកម្ម, (ii) ការបណ្តុះបណ្តាលអំពីទស្សនទានស្តីពីការប្រើប្រាស់ថ្នាំកសិកម្មចម្រុះ និង/ឬវិធីសាស្ត្រផ្សេងទៀត សម្រាប់ការប្រើប្រាស់ថ្នាំកសិកម្មប្រកបដោយសុវត្ថិភាព និង (iii) ការពិនិត្យតាមដាន។

37. ***ធនធានវប្បធម៌រូបវន្ត (OP/BP 4.11)។*** គោលនយោបាយនេះ ត្រូវយកមកអនុវត្ត ដោយសារគម្រោងនេះផ្តល់ហិរញ្ញប្បទានដល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជា ការស្តារផ្លូវ និងប្រព័ន្ធធារាសាស្ត្រ ដែលអាចបង្កផលប៉ះពាល់ដល់ធនធានវប្បធម៌រូបវន្ត ដែលគេពុំទាន់ដឹងនៅឡើយ ដូចដែលមានចែងក្នុង OP/BP 4.11។ នីតិវិធីសម្រាប់ចាត់ចែងវត្ថុដែលរកឃើញដោយចៃដន្យនៅតាមទីតាំងធនធានវប្បធម៌រូបវន្ត ត្រូវបានបញ្ចូលក្នុងឧបសម្ព័ន្ធទី ៤ ស្តីពីក្រមប្រតិបត្តិបរិស្ថាន (ECOP) និងត្រូវបញ្ចូលក្នុងកិច្ចសន្យាសាងសង់ សម្រាប់ជាវិធានការបង្ការជាមុន។

38. ***សុវត្ថិភាពទំនប់ (OP/BP 4.37)។*** គោលនយោបាយនេះ ត្រូវអនុវត្តដោយសារគម្រោងនេះផ្តល់ហិរញ្ញវប្បទានដល់ការស្តារប្រព័ន្ធធារាសាស្ត្រ ដែលត្រូវបានដាក់ចំណាត់ថ្នាក់ថាជា “ទំនប់តូចៗ” ដូចកំណត់ក្នុង OP 4.37។ ការស្តារប្រព័ន្ធធារាសាស្ត្រខ្នាតតូច ដែលមានកម្ពស់មិនលើសពី ១៥ ម៉ែត្រ ដោយគេរំពឹងថានឹងពុំមានទំនប់ខ្នាតមធ្យម ទៅធំឡើយ។ ម្ចាស់អនុគម្រោង (ឧ. ក្រសួងធនធានទឹក និងឧតុនិយម) ត្រូវបញ្ចូលវិធានការសុវត្ថិភាពទំនប់ទូទៅ ដែលត្រូវបញ្ចូលក្នុងការរៀបចំ និងការអនុវត្តការជួសជុល/កែលម្អសំណង់ធារាសាស្ត្រ ស្របតាម OP/BP4.37។ វិស្វករធារាសាស្ត្រជាន់ខ្ពស់ម្នាក់ (ឬអ្នកឯកទេសផ្នែកធារាសាស្ត្រ ដែលមានសមត្ថភាព) របស់ធនាគារពិភពលោក នឹងផ្តល់ការគាំទ្រ និងត្រួតពិនិត្យការអនុវត្តវិធានការសុវត្ថិភាពទំនប់ទាំងនេះ។

39. ***គម្រោងក្នុងផ្លូវទឹកអន្តរជាតិ (OP/BP 7.50)។*** គោលនយោបាយនេះ ត្រូវអនុវត្តដោយសារគម្រោងនេះផ្តល់ហិរញ្ញប្បទានដល់ការស្តារសំណង់ផ្គត់ផ្គង់ទឹកដល់ប្រព័ន្ធធារាសាស្ត្រ ដែលមានស្រាប់ ដូចជា ប្រឡាយកម្រិតទីបី (tertiary) និងប្រឡាយកម្រិតទីបួន (quaternary) ដែលទំនងជានឹងទាញទឹកពីដៃទន្លេ ផ្លូវទឹកអន្តរជាតិ ឬមានទំនាក់ទំនងជាមួយផ្លូវទឹកអន្តរជាតិ ឬបង្ហូរទឹកចូលទៅក្នុងផ្លូវទឹកអន្តរជាតិ (ដូចជា ទន្លេសាប និងទន្លេមេគង្គ) ដែលបង្កើតជាព្រំប្រទល់រវាងដែនទឹក ឬទឹកនៅលើដី ដែលហូរកាត់ប្រទេសជាប់ទន្លេ ចាប់ពីពីរឡើងទៅ។ ទោះជាយ៉ាងណាក៏ដោយ ការទាញទឹកពីទន្លេអន្តរជាតិនឹងពុំមានការកើនឡើងនោះឡើយ ដោយសារតែគម្រោងនេះ ផ្តល់ហិរញ្ញ-ប្បទានតែប្រព័ន្ធធារាស្ត្រដែលមានស្រាប់ប៉ុណ្ណោះ និងបង្កើតឱ្យមានប្រព័ន្ធធារាសាស្ត្រ ដែលកាន់តែមានប្រសិទ្ធភាពជាងមុន។ ក្នុងករណីនេះ លិខិតលើកលែងពី RVP ទទួលបានការឯកភាពរួចអស់ហើយ។

40. ***គម្រោងក្នុងតំបន់មានជម្លោះ OP 7.60។*** គោលនយោបាយនេះ ពុំត្រូវអនុវត្តឡើយ។ គម្រោងនេះពុំមានពាក់ព័ន្ធនឹងសកម្មភាពក្នុងតំបន់ជម្លោះឡើយ។

41. គម្រោងនេះគួរពិចារណាពីគោលការណ៍ណែនាំស្តីពីបរិស្ថាន សុខភាព និងសុវត្ថិភាព របស់ក្រុមធនាគារពិភពលោក[1] (ដែលហៅកាត់ថា “គោលការណ៍ណែនាំ EHS”)។ គោលការណ៍ណែនាំ EHS គឺជាឯកសារយោងបច្ចេកទេស ដែលបង្ហាញឧទាហរណ៍អំពីការអនុវត្តល្អផ្នែកឧស្សាហកម្មអន្តរជាតិ ដែលមានលក្ខណៈទូទៅ និងជាក់លាក់តាមឧស្សាហកម្ម។ គោលការណ៍ណែនាំ EHS បង្ហាញព័ត៌មានអំពីកម្រិតលទ្ធផលការងារ និងវិធានការនានា ដែលជាធម្មតាអាចទទួលយកបាន

[1] *គោលការណ៍ណែនាំ EHS អាចចូលមើលបាន តាមរយៈគេហទំព័រ* www.ifc.org/ifcext/enviro.nsf/Content/EnvironmentalGuidelines

ចំពោះក្រុមធនាគារពិភពលោក និងទូទៅត្រូវបានចាត់ទុកថាអាចសម្រេចទៅបាននៅតាមទីតាំងថ្មីៗ ក្នុងតំម្លៃសមស្រប ដោយប្រើប្រាស់បច្ចេកវិទ្យាដែលមានស្រាប់។ ដំណើរការវាយតម្លៃបរិស្ថាន អាចផ្តល់អនុសាសន៍ឱ្យមានការកំណត់កម្រិត ឬវិធានការផ្សេងទៅវិញ (អាចខ្ពស់ជាង ឬទាបជាង) ហើយដែលប្រសិនបើអាចទទួលយកបានចំពោះធនាគារពិភពលោក នឹងក្លាយជាលក្ខខណ្ឌតម្រូវសម្រាប់គម្រោង ឬសម្រាប់ទីតាំងជាក់លាក់។

42. នៅពេលដែលគោលនយោបាយស្តីពីការការពារផលប៉ះពាល់របស់ធនាគារស្តីពីការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត (OP/BP 4.12) និងជនជាតិដើមភាគតិច (OP/BP 4.10) ត្រូវអនុវត្ត ជាការសំខាន់ណាស់ ដែលផ្នែកនេះត្រូវផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹង RPF, EMPF, ឬក្របខ័ណ្ឌដំណើរការប្រសិនបើក្របខ័ណ្ឌណាក្នុងចំណោមក្របខ័ណ្ឌទាំងនេះ ត្រូវបានកំណត់សម្រាប់គម្រោងនេះ។ បើទោះបីជាក្របខ័ណ្ឌទាំងនេះ និងឧបករណ៍ការពារផលប៉ះពាល់សង្គមពាក់ព័ន្ធផ្សេងទៀតក៏ដោយ សេចក្តីពិពណ៌នាដោយសង្ខេបអំពីក្របខ័ណ្ឌទាំងនេះ ត្រូវបានបង្ហាញក្នុងប្រអប់ទី ២ ខាងក្រោម។

***ប្រអប់ទី ២. ក្របខ័ណ្ឌការពារផលប៉ះពាល់សង្គម***

***ក្របខ័ណ្ឌរៀបចំផែនការជនជាតិភាគតិច (EMPF)*៖*** គោលនយោបាយស្តីពីជនជាតិដើមភាគតិច (OP/BP 4.10) ត្រូវបានរៀបចំឡើង ដើម្បីធានាយ៉ាងណាឱ្យដំណើរការអភិវឌ្ឍន៍គោរពឱ្យបានពេញលេញនូវសេចក្តីថ្លៃថ្នូរ សិទ្ធិមនុស្ស សេដ្ឋកិច្ច និងវប្បធម៌របស់ជនជាតិដើមភាគតិច។ នៅពេលដែលការពិនិត្យបឋមរបស់ធនាគារពិភពលោកបង្ហាញថាក្រុមជនជាតិភាគតិច ទំនងជានឹងមានវត្តមាន ឬមានទំនាក់ទំនងជាសមូហភាពជាមួយតំបន់គម្រោង ប៉ុន្តែវត្តមានរបស់ពួកគេ ឬទំនាក់ទំនងជាសមូហភាពបែបនេះពុំអាចកំណត់ដឹងបាន រហូតដល់ពេលមានការកំណត់ពីកម្មវិធី ឬអនុគម្រោង អ្នកខ្ចីកម្ចីត្រូវរៀបចំ EMPF មុនពេលមានការវាយតម្លៃ។ ចាំបាច់ត្រូវមានការកំណត់វិធានការទាំងនេះ ក្នុងក្របខ័ណ្ឌផែនការអភិវឌ្ឍន៍ជនជាតិភាគតិច (EMDP) ដែលបានកំណត់។ EMDP គួរជាផ្នែកមួយ ឬគួរបញ្ចូលទៅក្នុងពាក្យសុំអនុវត្តគម្រោង។ ទោះជាក្នុងករណីណាក៏ដោយ ចាំបាច់ត្រូវមានការរៀបចំ EMDP ដែលអាចទទួលយកបាន មុនពេលដែលគេអាចផ្តល់ការឯកភាពចុងក្រោយ ដល់អនុគម្រោង និងអាចអនុវត្តអនុគម្រោងបាន។

***ក្របខ័ណ្ឌគោលនយោបាយស្តីពីការដោះស្រាយផលប៉ះពាល់/ការតាំងទីលំនៅ (RPF)**៖*** គោលនយោបាយស្តីពីការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត (OP/BP 4.12) មានគោលបំណងបង្ការការលំបាកធ្ងន់ធ្ងរក្នុងរយៈពេលវែង ការធ្លាក់ចូលទៅក្នុងភាពក្រីក្រ និងការខូចខាតបរិស្ថានដល់ក្រុមទទួលរងផលប៉ះពាល់ក្នុងអំឡុងពេលតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត។ នៅពេលដែលគម្រោងណាមួយតម្រូវឱ្យមានការធ្វើលទ្ធកម្មដីធ្លី ឬនាំឱ្យមានការផ្លាស់ប្តូរលទ្ធភាពទទួលបានធនធាន ដោយសារតែគម្រោងនេះ នោះគោលនយោបាយនេះ ត្រូវយកមកអនុវត្ត។ គោលនយោបាយរបស់ធនាគារ តម្រូវឱ្យមានការរៀបចំក្របខ័ណ្ឌគោលនយោបាយស្តីពីការដោះស្រាយផលប៉ះពាល់/ការតាំងទីលំនៅ ហើយអ្នកខ្ចីត្រូវដាក់ក្របខ័ណ្ឌនេះមុនពេលមានការវាយតម្លៃដោយអនុលោមទៅតាមគោលនយោបាយនេះ។ ក្របខ័ណ្ឌគោលនយោបាយស្តីពីការដោះស្រាយផលប៉ះពាល់/ការតាំងទីលំនៅ មានគោលបំណងបញ្ជាក់ឱ្យបានច្បាស់ពីគោលការណ៍ស្តីពីការដោះស្រាយផលប៉ះពាល់/ការតាំងទីលំនៅ ការរៀបចំស្ថាប័ន និងលក្ខណៈវិនិច្ឆ័យរៀបចំ ដែលត្រូវអនុវត្តចំពោះអនុគម្រោង។ គោលនយោបាយរបស់ធនាគារក៏តម្រូវឱ្យមានការរៀបចំផែនការដោះស្រាយផលប៉ះពាល់/តាំងទីលំនៅ (RP) សម្រាប់អនុគម្រោងទាំងឡាយណា ដែលធ្វើឱ្យប្រជាពលរដ្ឋចាកចេញពីដី ឬធនធានផលិតកម្មរបស់ពួកគេដោយមិនស្មគ្រចិត្ត ហើយការផ្លាស់ចេញបែបនេះ នាំឱ្យមាន៖ i) ការផ្លាស់ប្តូរទីតាំង ការបាត់បង់ទីជម្រក ការបាត់បង់ទ្រព្យសម្បត្តិ ឬលទ្ធភាពទទួលបានទ្រព្យសម្បត្តិ ដែលមានសារៈសំខាន់សម្រាប់ផលិតកម្ម, ii) ការបាត់បង់ប្រភពចំណូល ឬមធ្យោបាយចិញ្ចឹមជីវិត ឬ iii) ការបាត់បង់លទ្ធភាពចូលទៅកាន់ទីតាំង ដែលផ្តល់ចំណូលខ្ពស់ជាងមុន ឬចំណាយតិចជាងមុន ដល់អាជីវកម្ម ឬបុគ្គល។

## 3.3 ការវិភាគគម្លាត

43. ផ្នែកនេះផ្តោតលើការកំណត់ពីគម្លាតរវាងប្រព័ន្ធការពារផលប៉ះពាល់របស់ប្រទេស និងគោលនយោបាយស្តីពីការការពារផលប៉ះពាល់ ដែលពាក់ព័ន្ធរបស់ធនាគារពិភពលោក។ ប្រព័ន្ធទាំងពីរមានចំណុចខុសប្លែកគ្នាជាច្រើន ដែលចាំបាច់ត្រូវមានការរៀបចំវិធានការបំពេញគម្លាត ដើម្បីបញ្ចូលទៅក្នុង ESMF។ ផ្នែកទី III - ទំនាក់ទំនងរវាងលក្ខខណ្ឌតម្រូវរបស់ធនាគារពិភពលោក និងលក្ខខណ្ឌតម្រូវរបស់រដ្ឋាភិបាល។ ការវិភាគលម្អិតលើគម្លាតរវាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលកំពុងចូលជាធរមានរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយោបាយស្តីពីការការពារផលប៉ះពាល់របស់ធនាគារ ត្រូវបានរៀបរាប់ក្នុងឧបសម្ព័ន្ធទី ១។ តារាងទី ១ បង្ហាញឧទាហរណ៍អំពីការវិភាគគម្លាតរវាងអនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយោបាយ O.P.4.01 របស់ធនាគារពិភពលោក។

| **តារាងទី ១ ការវាយតម្លៃគម្លាតរវាងក្របខ័ណ្ឌច្បាប់/គតិយុត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និង OP4.01 គោលនយោបាយវាយតម្លៃបរិស្ថានរបស់ធនាគារពិភពលោក** | | | |
|---|---|---|---|
| **ប្រធានបទ** | OP 4.01 | **រាជរដ្ឋាភិបាលកម្ពុជា** | **គម្លាត/វិធានការរបស់គម្រោង** |
| ***1. ដំណើរការវាយតម្លៃបរិស្ថាន*** | | | |
| 1.1 ការវាយតម្លៃបរិស្ថានធ្វើការពិចារណាលើទិដ្ឋភាពធម្មជាតិ និងសង្គមរួមគ្នា ដោយពិចារណាពីកាតព្វកិច្ច ក្នុងសន្ធិសញ្ញា និងកិច្ចព្រមព្រៀង ក្នុងប្រទេស និងអន្តរជាតិ | វាយតម្លៃលើភាពគ្រប់ជ្រុងជ្រោយនៃក្របខ័ណ្ឌច្បាប់ និងស្ថាប័នដែលពាក់ព័ន្ធ រួមនឹងកិច្ចព្រមព្រៀងបរិស្ថានអន្តរជាតិដែលកំពុងចូលជាធរមាន និងធ្វើការបញ្ជាក់ថា កិច្ចព្រមព្រៀងទាំងនេះ ពិតជាបានចែងតម្រូវថា រដ្ឋាភិបាលដែលសហការជាមួយធនាគារនឹងមិនផ្តល់ហិរញ្ញប្បទានដល់សកម្មភាពគម្រោង ដែលផ្ទុយគ្នាទៅនឹងកាតព្វកិច្ចអន្តរជាតិទាំងនេះឡើយ។ | ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ៖<br>▪ មាត្រា ៦ – ការវាយតម្លៃហេតុប៉ះពាល់ បរិស្ថាន ត្រូវធ្វើឡើងសម្រាប់គ្រប់គម្រោង និងសកម្មភាពទាំងអស់ មិនថាឯកជន ឬសាធារណ: និងត្រូវមានការពិនិត្យ និងវាយតម្លៃ ដោយក្រសួងបរិស្ថាន មុនពេលដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើសេចក្តីសម្រេច។<br>អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (១៩៩៩)៖<br>▪ មាត្រា ១ – ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ត្រូវធ្វើឡើងក្នុងគ្រប់គម្រោង និងសកម្មភាពទាំងអស់ មិនថាឯកជន ឬសាធារណ: និងត្រូវមានការពិនិត្យឡើងវិញដោយក្រសួងបរិស្ថាន មុនពេលដាក់ជូនរាជរដ្ឋាភិបាល ដើម្បីធ្វើសេចក្តីសម្រេច។<br>▪ មាត្រា – អ្នកគាំទ្រគម្រោងត្រូវធ្វើការវាយតម្លៃលើហេតុប៉ះពាល់បរិស្ថានបឋម(IEIA) សម្រាប់គម្រោងដែលចាំបាច់ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចរៀបរាប់ ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។ | OP 4.01 នីតិវិធីគោលនយោបាយនឹងត្រូវយកមកអនុវត្ត ដើម្បីធានាថាអនុគម្រោងមិនអនុវត្តផ្ទុយទៅនឹងកាតព្វកិច្ចក្នុងសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងនានា មិនថាការវាយតម្លៃបរិស្ថានគឺជាលក្ខខណ្ឌតម្រូវឬអត់ ក្រោមលិខិតបទដ្ឋានគតិយុត្តរបស់ជាតិនោះទេ។ |
| 1.2 ការវាយតម្លៃលើ | ចែងពីការវាយតម្លៃលើជម្រើសផ្សេងទៀត ដែលអាចមាន សម្រាប់ | ពុំបានបញ្ចូល | OP 4.01 នីតិវិធីគោលនយោបា |

| តារាងទី ១ ការវាយតម្លៃគម្លាតរវាងក្របខ័ណ្ឌច្បាប់/គតិយុត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និង OP4.01 គោលនយោបាយវាយតម្លៃបរិស្ថានរបស់ធនាគារពិភពលោក | | | |
|---|---|---|---|
| **ប្រធានបទ** | OP 4.01 | **រាជរដ្ឋាភិបាលកម្ពុជា** | **គម្លាត/វិធានការរបស់គម្រោង** |
| ជម្រើសផ្សេងៗរបស់គម្រោង | ការវិនិយោគ ជម្រើសបច្ចេកទេស និងជម្រើសទីតាំង រួមទាំងជម្រើស "ពុំធ្វើសកម្មភាពតែម្តង" ផលប៉ះពាល់ដែលអាចកើតមានឡើង លទ្ធភាពសម្រាលផលប៉ះពាល់ទាំងនេះ ចំណាយមូលធន និងចំណាយចរន្ត ដោយសារផលប៉ះពាល់ទាំងនេះ ភាពសមស្របនៃជម្រើសទាំងនេះ ក្រោមស្ថានភាពនៅមូលដ្ឋាន លក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងស្ថាប័ន ការបណ្តុះបណ្តាល និងការពិនិត្យតាមដានពាក់ព័ន្ធនឹងជម្រើសទាំងនេះ។ | | យនឹងត្រូវអនុវត្ត ដើម្បីធានាថា ការវាយតម្លៃលើផលប៉ះពាល់ដែលអាចបង្កឡើង ដោយគម្រោង បានពិនិត្យលើជម្រើសនានា ដែលអាចមាន រួមទាំងជម្រើស "ពុំធ្វើសកម្មភាពតែម្តង" ផងដែរ។ |
| 1.3 ការរក្សាទុកទីប្រឹក្សាគម្រោង | អ្នកខ្ចីកម្ចីជាធម្មតាគួរបង្កើតគណៈកម្មាធិការប្រឹក្សាគម្រោងមួយ ដែលមានសមាសភាពជាអ្នកឯកទេសផ្នែកបរិស្ថានឯករាជ្យ និងមានការទទួលស្គាល់ជាអន្តរជាតិ ដើម្បីផ្តល់ដំបូន្មានអំពីគ្រប់ទិដ្ឋភាពទាំងអស់របស់គម្រោង ពាក់ព័ន្ធនឹងការវាយតម្លៃបរិស្ថាន។ | ពុំបានបញ្ចូល | OP 4.01 នីតិវិធីគោលនយោបាយនឹងត្រូវអនុវត្ត ដើម្បីផ្តល់ការណែនាំប្រសិនបើមានការផ្តល់ដំបូន្មានដល់អ្នកខ្ចីឱ្យប្រើប្រាស់អ្នកឯកទេសផ្នែកបរិស្ថានឯករាជ្យ និងមានការទទួលស្គាល់ជាអន្តរជាតិឱ្យផ្តល់ដំបូន្មានអំពីការពិនិត្យឡើងវិញលើគម្រោង។ |
| ***2. កិច្ចពិគ្រោះយោបល់ជាសាធារណៈ និងការបង្ហាញព័ត៌មាន*** | | | |
| 2.1 ដំណើរការវាយតម្លៃបរិស្ថាន ត្រូវបញ្ចូលការពិគ្រោះយោបល់សាធារណៈ និងការបង្ហាញព័ត៌មាន | ប្រសិនបើសមស្រប ធនាគារអាចតម្រូវឱ្យមានកិច្ចពិគ្រោះយោបល់ និងការបង្ហាញព័ត៌មានជាសាធារណៈ។<br><br>អ្នកខ្ចីកម្ចីត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រុម ដែលរងផលប៉ះពាល់ដោយសារគម្រោង និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ | ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ៖<br>▪ មាត្រា ១ – គោលបំណងនៃច្បាប់នេះគឺ៖<br>  ○ លើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណៈជនចូលរួម ក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។<br>▪ មាត្រា ១៦ – បន្ទាប់ពីមានការស្នើសុំពីសាធារណជន ក្រសួងបរិស្ថានត្រូវផ្តល់ព័ត៌មានអំពីសកម្មភាពរបស់ខ្លួន និងត្រូវជំរុញឱ្យមានការចូលរួមពីសាធារណៈជនក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។<br>អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (១៩៩៩)៖ | OP 4.01 នីតិវិធីគោលនយោបាយត្រូវអនុវត្ត ដើម្បីផ្តល់ការណែនាំអំពីការពិគ្រោះយោបល់ និងការបង្ហាញព័ត៌មានជាសាធារណៈ ដើម្បីផ្តល់ជាព័ត៌មានដល់ក្រុមដែលរងផលប៉ះពាល់ដោយសារគម្រោង និងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងស្រុក។ |

| តារាងទី ១ ការវាយតម្លៃគម្លាតរវាងក្របខ័ណ្ឌច្បាប់/គតិយុត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និង OP4.01 គោលនយោបាយវាយតម្លៃបរិស្ថានរបស់ធនាគារពិភពលោក | | | |
|---|---|---|---|
| **ប្រធានបទ** | OP 4.01 | **រាជរដ្ឋាភិបាលកម្ពុជា** | **គម្លាត/វិធានការរបស់គម្រោង** |
| | | ▪ មាត្រា ១ – លើកកម្ពស់ការចូលរួមរបស់សាធារណជនក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយត្រូវពិចារណាពីក្តីបារម្ភរបស់ពួកគេក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តរបស់គម្រោង។ | |
| ***3. ការពិនិត្យតាមដាន និងវាយតម្លៃ*** | | | |
| 3.1 ចាំបាច់ត្រូវមានការពិនិត្យតាមដាន ផ្ទៃក្នុង និងការពិនិត្យតាមដាន ដោយឯករាជ្យពីខាងក្រៅ | ក្នុងអំឡុងពេលអនុវត្តគម្រោង អ្នកខ្ចីត្រូវរៀបរបាយការណ៍ស្តីពីភាពអនុលោមទៅតាមវិធានការដែលបានឯកភាពគ្នាជាមួយនឹងធនាគារ ផ្អែកទៅតាមលទ្ធផលរកឃើញ និងលទ្ធផលនៃការវាយតម្លៃ បរិស្ថាន រួមនឹងអំពីការអនុវត្ត EMP។ | អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (១៩៩៩)៖<br>▪ មាត្រា ៣ – ក្រសួងបរិស្ថានត្រូវចាត់វិធានការរដ្ឋបាលឱ្យបានសមស្រប ធ្វើការឃ្លាំមើល និងពិនិត្យតាមដាន ដើម្បីធានាឱ្យមានការរៀបចំផែនការគ្រប់គ្រងបរិស្ថាន ក្នុងអំឡុងពេលសាងសង់របស់គម្រោង ប្រតិបត្តិការគម្រោង ពេលបិទគម្រោង ដែលព័ត៌មានទាំងនេះ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបានទទួលការឯកភាព ដែលត្រូវអនុវត្តដោយអ្នកគាំទ្រគម្រោង។ | OP 4.01 នីតិវិធីគោលនយោបាយនឹងត្រូវអនុវត្ត។ ការិយាល័យសម្របសម្រួលគម្រោង (PCO) ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់/គណៈកម្មាធិការអន្តរក្រសួង ដោះស្រាយផលប៉ះពាល់ ត្រូវធ្វើការពិនិត្យតាមដានផ្ទៃក្នុងលើការអនុវត្តការដោះស្រាយផលប៉ះពាល់ និងការបំពេញទៅតាមលក្ខខណ្ឌតម្រូវនៃការរៀបចំរបាយការណ៍សម្រាប់ ការអនុវត្ត ESMMP។ ការពិនិត្យតាមដាននេះ ត្រូវបញ្ចូលរបាយការណ៍វឌ្ឍនភាព ស្ថានភាពនៃការអនុវត្តផែនការដោះស្រាយផលប៉ះពាល់/តាំងទីលំនៅ ព័ត៌មានអំពីទីតាំង និងចំនួនមនុស្សដែលរងផលប៉ះពាល់ ចំនួនសំណងដែលទូទាត់ បែងចែកទៅតាមខ្ទង់ និងជំនួយដែលបានផ្តល់ដល់គ្រួសារដែលរងផលប៉ះពាល់ដោយ |

| តារាងទី ១ ការវាយតម្លៃគម្លាតរវាងក្របខ័ណ្ឌច្បាប់/គតិយុត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និង OP4.01 គោលនយោបាយវាយតម្លៃបរិស្ថានរបស់ធនាគារពិភពលោក | | | |
|---|---|---|---|
| ប្រធានបទ | OP 4.01 | រាជរដ្ឋាភិបាលកម្ពុជា | គម្លាត/វិធានការរបស់គម្រោង |
| | | | សារគម្រោង។ របាយការណ៍លទ្ធផលនៃការពិនិត្យតាមដាន ត្រូវរៀបចំដោយក្រសួងអភិវឌ្ឍន៍ជនបទ និងដាក់ជូនគណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ និងធនាគារពិភពលោករៀងរាល់ត្រីមាស។ |

3.4 ការអនុវត្តល្អ ផ្នែកកសិកម្ម (GAP)

44. ការអនុវត្តល្អផ្នែកកសិកម្ម (GAP) ក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះ ផ្តោតសំខាន់លើសុវត្ថិភាពចំណីអាហារ និរន្តរភាពបរិស្ថាន និងនិរន្តរភាពសេដ្ឋកិច្ច។ ក្រមស្តង់ដារ និងបទដ្ឋានគតិយុត្តជុំវិញការអនុវត្តល្អផ្នែកកសិកម្មជាច្រើន ត្រូវបានរៀបចំឡើងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រដ្ឋាភិបាលឧស្សាហកម្មចំណេះអាហារ និងសមាគមអ្នកផលិត ក្នុងគោលបំណងរៀបចំចងក្រងការអនុវត្តកសិកម្មនៅកម្រិតកសិដ្ឋាន សម្រាប់ទំនិញជាច្រើនប្រភេទ។ ការអនុវត្តល្អទាំងនេះ មានគោលបំណងខុសៗគ្នា ចាប់ពីការបំពេញទៅតាមលក្ខខណ្ឌតម្រូវផ្នែកពាណិជ្ជកម្ម និងលក្ខខណ្ឌតម្រូវដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋាភិបាល (ជាពិសេស ពាក់ព័ន្ធនឹងសុវត្ថិភាព និងគុណភាពចំណីអាហារ រហូតដល់លក្ខខណ្ឌតម្រូវជាក់លាក់ សម្រាប់ផ្គត់ផ្គង់ដល់ទីផ្សារពិសេស។ គោលបំណងនៃក្រមស្តង់ដារ និងបទដ្ឋានគតិយុត្តស្តីពីការអនុវត្តល្អផ្នែកកសិកម្ម រួមមាន (ក្នុងកម្រិតខុសៗគ្នា)៖

- ធានាសុវត្ថិភាព និងគុណភាពនៃកសិផលក្នុងសង្វាក់ចំណីអាហារ
- ច្បាមយកឧត្តមភាពទីផ្សារថ្មីៗ តាមរយៈការកែសម្រួលអភិបាលកិច្ចសង្វាក់ផ្គត់ផ្គង់
- កែលម្អការប្រើប្រាស់ធនធានធម្មជាតិ លើកម្ពស់ស្ថានភាពសុខភាព និងលក្ខខណ្ឌការងាររបស់កម្មករ និង/ឬ
- បង្កើតឱកាសទីផ្សារថ្មីៗ សម្រាប់កសិករ និងអ្នកនាំចេញក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

45. ការអនុវត្តល្អផ្នែកកសិកម្ម សំដៅលើ "ការអនុវត្តដែលផ្តោតការយកចិត្តទុកដាក់លើនិរន្តរភាពបរិស្ថាន សេដ្ឋកិច្ច និងសង្គម សម្រាប់ដំណើរការក្នុងកសិដ្ឋាន ដែលនាំឱ្យមានការផលិតផលិតផលអាហារ និងផលិតផលកសិកម្ម មិនមែនអាហារ ប្រកបដោយសុវត្ថិភាព និងគុណភាព" (ឯកសារ GAP របស់ FAO COAG ២០០៣)។ "សសរស្តម្ភ" ទាំងបួននៃ GAP (ប្រសិទ្ធភាពសេដ្ឋកិច្ច និរន្តរភាពបរិស្ថាន ភាពអាចទទួលយកបានចំពោះសង្គម និងសុវត្ថិភាព និងគុណភាពចំណីអាហារ) ត្រូវបានបញ្ចូលទៅក្នុងស្តង់ដារភាគច្រើនរបស់វិស័យឯកជន និងវិស័យសាធារណៈ ប៉ុន្តែវិសាលភាពនៃសសរស្តម្ភទាំងនេះ ជាក់ស្តែងមានការប្រែប្រួលខុសៗគ្នា។ ទស្សនទានការអនុវត្តល្អផ្នែកកសិកម្ម អាចប្រើប្រាស់ជាឧបករណ៍ផ្ទៀងផ្ទាត់សម្រាប់ធ្វើការសម្រេចចិត្តពីការអនុវត្ត និង/ឬលទ្ធផលដែលមាននិរន្តរភាពផ្នែកបរិស្ថាន និងអាចទទួលយកបានក្នុងសង្គម នៅកម្រិតជំហាននីមួយៗនៃដំណើរការផលិតកម្ម។ ដូច្នេះការអនុវត្ត GAP គួររួមចំណែកនាំឱ្យមានការធ្វើកសិកម្ម និងការអភិវឌ្ឍជនបទ ប្រកបដោយចីរភាព។

46. នាពេលបច្ចុប្បន្ននេះ ការធ្វើកសិកម្មនៅកម្ពុជាភាគច្រើនជាការធ្វើកសិកម្មចិញ្ចឹមជីវិត ឬជាកសិកម្មដែលប្រើប្រាស់ធនធានតិច និងទទួលបានទិន្នផលតិច។ បើតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រដ្ឋាភិបាល នាពេលអនាគតនឹងមានការជំរុញឱ្យវិស័យកសិកម្ម

បង្កើនកំណើនដល់ប្រមាណ ៥% ក្នុងមួយឆ្នាំ តាមរយៈការបង្កើន ផលិតភាពកសិកម្ម ការធ្វើពិពិធកម្ម និងការធ្វើពាណិជ្ជកម្មូបនីយកម្មផ្អែកតាមផែនការប្រើប្រាស់ដីធ្លី ដោយផ្តោតលើការជំរុញការនាំចេញអង្ករ និងបង្កើនទិន្នផលនៃប្រភេទទំនិញអាទិភាពសំខាន់ៗ សម្រាប់ការប្រើប្រាស់ក្នុងប្រទេស និងការនាំចេញ។ នេះគឺជានិន្នាការនាពេលបច្ចុប្បន្ន ហើយនិងមានការពន្លឿនបន្ថែមទៀតនៅក្នុងឆ្នាំខាងមុខនេះ។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើពាណិជ្ជកម្មូបនីយកម្មកសិកម្មនៅក្នុងប្រទេស ដែលកម្លាំងពលកម្ម ៤១,៥% (២០១៥) កំពុងធ្វើការងារក្នុងវិស័យកសិកម្ម និងភាគច្រើនមានដីជាកម្មសិទ្ធិផ្ទាល់ខ្លួនក្រោម ១ ហិចតា ពុំមែនជារឿងដែលងាយស្រួលនោះឡើយ។ នេះតម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងតាមស្ថានភាពជាក់ស្តែង ដើម្បីធានាប្រសិទ្ធភាព សមធម៌ និងនិរន្តរភាពទៅតាមការរំពឹងទុក។ មេរៀនដែលទទួលបានពីប្រទេសជិតខាងនៅក្នុងតំបន់ បង្ហាញថា ការបង្កើនការប្រើប្រាស់ធនធាននៅតាមកសិដ្ឋានមិនមែនសុទ្ធតែនាំឱ្យមានការបង្កើនប្រាក់ចំណេញ និងចំណូលសម្រាប់កសិករនោះឡើយ។ មេរៀនដែលទទួលបានពីប្រទេសវៀតណាម ដែលជាប្រទេសផលិតស្រូវមួយដែរនោះ បង្ហាញថា កសិករបានប្រើប្រាស់គ្រាប់ពូជដែលមានការបញ្ជាក់ត្រឹមត្រូវ និងប្រើប្រាស់របៀបដាំដុះដែលមាននិរន្តរភាព (ដូចជា កាត់បន្ថយជីគីមី ថ្នាំកសិកម្ម ការបាត់បង់ក្រោយពេលប្រមូលផល និងការប្រើប្រាស់ទឹក អាចរក្សាប្រាក់ចំណេញបានខ្ពស់ ចន្លោះពី ២០-៣០% ដោយសារតែស្រូវមានគុណភាពខ្ពស់ បង្កើនទិន្នផល ៥-១០% និងកាត់បន្ថយចំណាយផលិតកម្មពី ២០-៣០%។ ដូច្នេះ ការវិនិយោគ និងកិច្ចខិតខំប្រែង បង្កើនគុណភាព និងតម្លៃកសិផល និងកាត់បន្ថយការបាត់បង់ក្រោយការប្រមូលផល និងថ្លៃដើមផលិតកម្ម សម្រាប់កសិករ គួរជាទិសដៅសម្រាប់បង្កើនសមត្ថភាពប្រកួតប្រជែងរបស់កសិករ និងនិរន្តរភាពនៃវិស័យកសិកម្មនៅក្នុងរយៈពេលវែង។

## 4.0 ផលប៉ះពាល់ដែលអាចកើតឡើង និងវិធានការសម្រាលផលប៉ះពាល់ទាំងនេះ

47. សម្រាប់គម្រោងដែលពុំទាន់មានការកំណត់ គ្រប់អនុគម្រោងទាំងអស់ក្នុងអំឡុងពេលរៀបចំគម្រោងបែបនេះ គេអាចកំណត់ដឹងពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានដែលអាចកើតមានឡើង និងវិធានការសម្រាលផលប៉ះពាល់ សម្រាប់គោលបំណងនៃការរៀបចំ ESMF បាន។

48. លើសពីនេះ គោលការណ៍ណែនាំស្តីពី EHS នៃក្រុមធនាគារពិភពលោក ដែលមានបញ្ចូលព័ត៌មានអំពីកម្រិតនៃលទ្ធផលការងារ និងវិធានការនានា ដែលជាទូទៅ ត្រូវបានកំណត់ថាអាចសម្រេចបានក្នុងកម្មវិធីថ្មីៗ ដែលប្រើប្រាស់បច្ចេកវិទ្យាដែលមានស្រាប់ និងអស់ចំណាយសមរម្យ ក៏អាចយកមកប្រើប្រាស់ជាព័ត៌មានយោងបច្ចេក-ទេស សម្រាប់កំណត់ពីផលប៉ះពាល់បង្កឡើងដោយគម្រោង និងវិធានការសម្រាលផលប៉ះពាល់ទាំងនេះ។ លើសពីនេះ គេហទំព័រវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់ប្រទេសកម្ពុជា[2] បង្ហាញពីលិខិតបទដ្ឋានគតិយុត្ត និង គោលការណ៍ណែនាំទូទៅអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលអាចប្រើប្រាស់សម្រាប់ព្យាករណ៍ពីផលប៉ះពាល់ និងវិធានការសម្រាលផលប៉ះពាល់នានា ដែលកើតឡើង ដោយសារការវិនិយោគរបស់គម្រោង។ ចាំបាច់ត្រូវមានការកំណត់ពីផលប៉ះពាល់ ដែលកើតឡើងក្នុងអំឡុងដំណាក់កាលផ្សេងៗរបស់គម្រោង។ ការអនុវត្តល្អគឺត្រូវបង្កើតតារាងបង្ហាញពីផលប៉ះពាល់ មុនពេលសាងសង់ ក្នុងអំឡុងពេលសាងសង់ ប្រតិបត្តិការ និងអំឡុងពេលរុះរើសំណង់របស់គម្រោង។ ផលប៉ះពាល់រួមមាន ផលប៉ះពាល់លើជីវៈរូបវន្ត សុខភាព យេនឌ័រ ការតាំងទីលំនៅ ជនជាតិភាគតិច ធនធានវប្បធម៌ និងផលប៉ះពាល់សរុប។

49. ផ្នែកស្តីពីផលប៉ះពាល់ដែលអាចបង្កឡើងដោយគម្រោង អាចបែងចែកជាបីផ្នែកតូចៗ៖ i) ផលប៉ះពាល់វិជ្ជមាន ដែលអាចកើតមានឡើង, ii) ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានឡើង, iii) ផលប៉ះពាល់សរុប ដែលអាចកើតមានឡើង ប្រសិនបើពាក់ព័ន្ធ។ ដូច្នេះគ្នានេះដែរ ផ្នែកស្តីពីវិធានការសម្រាលផលប៉ះពាល់របស់គម្រោង គួរឆ្លើយតបចំពោះគ្រប់ផលប៉ះពាល់ទាំងអស់ ដែលត្រូវបានកំណត់ រួមទាំងឱកាស ដើម្បីបង្កើនផលប៉ះពាល់វិជ្ជមានផងដែរ។

[2] *គេហទំព័រ EIA របស់កម្ពុជា* *http://www.moe.gov.kh/*

## 4.1 ផលប៉ះពាល់បរិស្ថាន ដែលអាចកើតមានឡើង

50. គេរំពឹងថា គម្រោងនេះនឹងនាំឱ្យមានផលប៉ះពាល់ជាវិជ្ជមានធំៗមួយចំនួន ដោយសារតែសកម្មភាពគម្រោងមានគោលដៅរួម គឺដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងនៃកសិផល និងបង្កើនលទ្ធភាពទទួលបានទីផ្សារ ដែលមានស្ថិរភាពសម្រាប់កសិករ ដែលនាំឱ្យមានការបង្កើនសន្តិសុខផ្នែកចំណូលរបស់កសិករ។ សកម្មភាពគម្រោងមានគោលបំណងកាត់បន្ថយផលប៉ះពាល់ដែលបង្កឡើងដោយការធ្វើកសិកម្មបែបប្រពៃណី តាមរយៈការជំរុញឱ្យមានការអនុវត្ត IPM និង GAP។

51. ក្រៅតែពីផលប៉ះពាល់វិជ្ជមានធំៗទាំងនេះ គម្រោងនេះក៏អាចបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានតិចតួចមួយចំនួនផងដែរ។ ការវាយតម្លៃលើផលប៉ះពាល់អវិជ្ជមាន ដែលអាចកើតមានឡើង ធ្វើឡើងតាមរយៈការចុះដលទីតាំង ការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកទទួលផលការប្រើប្រាស់ព័ត៌មានពីប្រភពដែលមានស្រាប់។ ផ្នែកនេះសង្ខេបពីផលប៉ះពាល់បរិស្ថាន ដែលអាចកើតមានឡើង និងវិធានការសម្រាលផលប៉ះពាល់ ដែលចាំបាច់ ដែលត្រូវបញ្ចូលទៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ដែលរៀបចំសម្រាប់អនុគម្រោងនានា ទៅតាមលក្ខខណ្ឌតម្រូវ។ បញ្ហា និងក្តីបារម្ភផ្នែកបរិស្ថាន ដែលអាចកើតមានឡើង ដែលត្រូវបានកំណត់ រួមមានៈ (i) ផលប៉ះពាល់លើបរិស្ថានដែលកើតឡើងដោយសារសកម្មភាពកសិកម្ម, (ii) ការងារហេដ្ឋារចនាសម្ព័ន្ធ និង(iii) ការគ្រប់គ្រងសំណល់រឹងចេញពីការកែច្នៃរបស់សហគ្រាសកសិកម្ម។ ការព្រួយបារម្ភនីមួយៗក្នុងចំណោមការព្រួយបារម្ភទាំងនេះ ត្រូវបានលើកយកមកបង្ហាញលម្អិតខាងក្រោម។

### សមាសភាគទី ១៖ លើកម្ពស់ពិពិធកម្មកសិកម្ម

52. សមាសភាគទី ១ នេះនឹងប្រើប្រាស់អភិក្រមសង្វាក់តម្លៃ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយទៅតាមស្ថានភាពទីផ្សារ និងស្ថានភាពតម្រូវការ ដើម្បីកសាងនូវសង្វាក់តម្លៃដែលមានលក្ខណៈប្រកួតប្រជែង និងមានពិពិធភាព ដែលក្នុងនោះអង្គការអ្នកផលិត (POs) និងសមាជិករបស់អង្គការទាំងនេះ អាចទទួលបានទីផ្សារក្នុងស្រុក និងអន្តរជាតិ ដែលផ្តល់ឱ្យពួកគេនូវប្រាក់ចំណេញខ្ពស់ត្រលប់មកវិញ ហើយសហគ្រាសកសិកម្មខ្នាតតូច និងខ្នាតមធ្យម អាចទទួលបានវត្ថុធាតុដើមដែលកាន់តែមានគុណភាពជាប់ជាប្រចាំ ហើយក្នុងពេលជាមួយគ្នាបង្កើនសមត្ថភាពស្រូបយក និងសម្រេចស្តង់ដារគុណភាព ដែលទីផ្សារត្រូវការ។ សមាសភាគនេះពោរពេញដោយការប្រកួតប្រជែង និងភាគច្រើនដឹកនាំ ដោយវិស័យឯកជនដោយរដ្ឋាភិបាលបំពេញតួនាទីជាអ្នកសម្របសម្រួល។ ប៉ុន្តែ សមាសភាគនេះក៏នឹងផ្តល់ការគាំទ្រដល់រដ្ឋាភិបាល និងតួអង្គក្នុងវិស័យសាធារណៈ ក្នុងការផ្តល់សេវាចាំបាច់នានា ដូចជា ការផ្សព្វផ្សាយកសិកម្ម ដែលភ្ជាប់ទំនាក់ទំនងជាមួយនឹងទីផ្សារ និងផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធដែលមានលក្ខណៈល្អប្រសើរជាងមុន ដូចជា ផ្លូវជនបទ និងហេដ្ឋារចនា-សម្ព័ន្ធធារាសាស្ត្រ ដែលកាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុន (higher order irrigation infrastructure) ក្នុងករណីដែលពុំមានសេវាដែលផ្តល់ដោយវិស័យឯកជន ឬប្រជាពលរដ្ឋពុំអាចទទួលសេវា ដែលផ្តល់ដោយវិស័យឯកជនបាន។

53. ***សមាសភាគរងទី ១៖ ការគាំទ្រដល់ការរៀបចំ និងការអនុវត្តផែនការពិពិធកម្ម។*** សមាសភាគរងនេះមានគោលបំណងផ្សព្វផ្សាយគម្រោងដល់តួអង្គពាក់ព័ន្ធនានា ផ្តល់ការគាំទ្រដល់ការបង្កើតក្រុមការងារ ការកំណត់រកឱកាសអាជីវកម្ម និងការបំប្លែងឱកាសទាំងនេះជាផែនការពិពិធកម្ម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដូចជា ការរៀបចំសំណើអាជីវកម្ម (BPr) និងផែនការអាជីវកម្ម (BPl) ដែលមានប្រសិទ្ធភាព និងធ្វើការវាយតម្លៃ និងជ្រើសរើសសំណើ និងផែនការទាំងនោះ និងចុងក្រោយពង្រឹងសមត្ថភាពក្រុមអ្នកផលិត ដែលបានជ្រើសរើស ព្រមទាំងសមាជិកក្រុមទាំងនោះ ព្រមទាំងសហគ្រាសកសិកម្មខ្នាតតូច និងខ្នាតមធ្យម។ សមាសភាគរងនេះ នឹងផ្តល់ហិរញ្ញប្បទានដល់៖ (ក) យុទ្ធនាការបង្កើនការយល់ដឹង និងការប្រមូលតួអង្គពាក់ព័ន្ធនានាដើម្បីបង្កើតជាក្រុម, (ខ) ការរៀបចំ និងការវាយតម្លៃផែនការពិពិធកម្ម ដែលមានប្រសិទ្ធភាព និងសំណើអាជីវកម្ម ដែលអាចផ្តល់នូវប្រាក់ចំណេញ (គ) ការរៀបចំ និងការវាយតម្លៃផែនការពិពិធកម្មពេញលេញ រាប់បញ្ចូលទាំងផែនការអាជីវកម្ម សម្រាប់សំណើអាជីវកម្ម ដែលត្រូវបានជ្រើសរើស និង (ឃ) ការគាំទ្រដល់ការអភិវឌ្ឍផែនការអាជីវកម្ម។

54. ***សមាសភាគរង ១.២៖ ការផ្តល់ហិរញ្ញប្បទានដល់ការធ្វើពិពិធកម្មកសិកម្ម។*** ដើម្បីសម្រួលដល់ការផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគលើសកម្មភាពផលិតកម្ម និងជំនួយបច្ចេកទេស ក្នុងសំណើធ្វើពិពិធកម្ម និងផែនការរអាជីវកម្ម ដែលទទួលបានការអនុម័ត គម្រោងនេះនឹងបង្កើតនូវកម្មវិធីផ្តល់ឥណទាន (Credit Line) ដោយមានការបំពេញបន្ថែមដោយកម្មវិធីផ្គូរផ្គងជំនួយខ្នាតតូច។ ឧបករណ៍ហិរញ្ញវត្ថុទាំងនេះ នឹងជួយសម្រេចគោលបំណងជារួមរបស់គម្រោង ពោលគឺការធ្វើពិពិធកម្មទៅរកដំណាំដែលមានតម្លៃខ្ពស់ និងការធ្វើពាណិជ្ជកម្មភាវូបនីយកម្មវិស័យកសិកម្ម។ ដូច្នេះ ឧបករណ៍ហិរញ្ញវត្ថុទាំងនេះនឹងផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគច្រើនប្រភេទ ពាក់ព័ន្ធនឹងការធ្វើពិពិធកម្មកសិកម្ម ដូចជា ឧបករណ៍កែច្នៃ ឧបករណ៍ធារាសាស្ត្រក្នុងកសិដ្ឋាន ឧបករណ៍ស្រោចស្រពបែបបន្តក់ទឹក (drip) យន្តហោះខ្នាតតូច (microject) ប្រព័ន្ធបាចទឹក (sprinkler) ឃ្លាំងរក្សាកសិផលក្នុងកសិដ្ឋាន ។ល។) គ្រឿងយន្តកសិកម្ម ឃ្លាំង (ត្រជាក់) យានយន្ត ឧបករណ៍សម្រាប់វេចខ្ចប់ និងធ្វើពាណិជ្ជកម្ម ដំណោះស្រាយប្រព័ន្ធបច្ចេកវិទ្យានិងសារគមនាគមន៍ ធនធានកសិកម្ម និងការវិនិយោគសមស្របផ្សេងទៀត។

55. *សមាសភាគរង ១.១ និង ១.២* នឹងពុំបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានឡើយ។ គោលការណ៍ណែនាំអន្តរកាលស្តីពីការអនុវត្តគោលនយោបាយការពារផលប៉ះពាល់ សម្រាប់សកម្មភាពជំនួយបច្ចេកទេស ត្រូវបញ្ចូលទៅក្នុងលក្ខខណ្ឌប្រតិបត្តិសម្រាប់អន្តរាគមន៍រៀបចំផែនការ និងដាក់អាទិភាព ដើម្បីជំរុញឱ្យមានផលប៉ះពាល់ជាវិជ្ជមាន ក្រោម ESMF នេះ។

*56.* ***សមាសភាគរង ១.៣៖ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។*** គម្រោងនេះ នឹងគាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដែលមិននៅជាប់ជាមួយនឹងកសិដ្ឋាន និងផ្លូវជនបទភ្ជាប់ទៅកាន់ទីផ្សារ ដើម្បីបង្កើនលទ្ធភាពរបស់ក្រុមអ្នកផលិតក្នុងការធ្វើពិពិធកម្មការដាំដុះរបស់ខ្លួន តាមរយៈការបង្កើនការផ្គត់ផ្គង់ទឹកទៅតាមតម្រូវការជាក់ស្តែង និងដឹកជញ្ជូនកសិផលទៅកាន់ទីផ្សារប្រកបដោយប្រសិទ្ធភាព ដែលអាចជួយពន្លឿនការផ្គត់ផ្គង់ និងកាត់បន្ថយការខាតបង់ឱ្យនៅតិចជាអប្បបរមា។

57. ក្រៅពីផលប៉ះពាល់វិជ្ជមាន ពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធ ការសាងសង់ និងប្រតិបត្តិការនៃទីតាំងដែលស្នើឡើង នឹងមានផលប៉ះពាល់ និងហានិភ័យសង្គម បរិស្ថាន អវិជ្ជមានមួយចំនួន។ បញ្ហាដែលអាចរងផលប៉ះពាល់ ដោយសារសកម្មភាពសាងសង់ ឬសកម្មភាពប្រតិបត្តិការ អាចមានដូចជា៖

- ការធ្វើលទ្ធកម្មដីធ្លី (ការផ្តល់អំណោយដីធ្លីដោយស្ម័គ្រចិត្ត)
- សមត្ថភាពរៀបចំផែនការ
- បរិស្ថានខ្យល់៖ ធូលី សំឡេងរំខាន ក្លិន រំញ័រ
- ដែនទឹក៖ ការផ្លាស់ប្តូរសំណើម, កំណរល្បាប់, សារធាតុពុលដែលរលាយ និងមិនរលាយក្នុងទឹក
- ដី៖ ការច្រោះដី និងទឹកកខ្វក់
- ធនធានជីវសាស្ត្រ៖ ស្មៅ/រុក្ខជាតិ កំប៉ុតព្រៃ សត្វ ព្រៃឈើ។ល។
- ទេសភាព ឋានលេខាសាស្ត្រ៖ ទីជម្រាល ភ្នំ
- វត្ថុវប្បធម៌ សំណង់នានា ដូចជា បូជនីយដ្ឋាន រូបចម្លាក់ ផ្នូរ វត្ថុសិល្បៈ ដើមឈើសក្ការៈបូជា ប្រាសាទ វិហារកាត់គូលិច។ល។
- សម្ភារៈរូបវន្ត ដែលមានស្រាប់នៅនឹងទីតាំងជាក់ស្តែង ដូចជាផ្លូវថ្នល់ ការផ្គត់ផ្គង់ទឹក ប្រព័ន្ធលូ។ល។
- ។ល។

**តារាង ៦.១៖ ផលប៉ះពាល់អវិជ្ជមាន ដែលអាចកើតមានឡើងលើបរិស្ថាន ដោយសារសេវាហេដ្ឋារចនាសម្ព័ន្ធ**

| | ផលប៉ះពាល់/ហានិភ័យដែលអាចកើតមានឡើង | សេចក្តីពិពណ៌នាអំពីបញ្ហា/ហានិភ័យ | សកម្មភាពធម្មតា ដែលអាចបង្ក ឱ្យមានផលប៉ះពាល់/ហានិភ័យ |
|---|---|---|---|
| **ដំណាក់កាលសាងសង់** | | | |
| ១. | ការខូចខាត ឬការបាត់បង់គម្របរុក្ខជាតិ និងដើមឈើ | គម្របរុក្ខជាតិ និង/ឬដើមឈើនៅទីតាំងសំណង់ (ផ្លូវថ្នល់ ប្រព័ន្ធលូ។ល។) ឬទីតាំងផ្សេងទៀត ដែលត្រូវប្រើប្រាស់ដោយគម្រោង អាចត្រូវបានដកចេញ ឬទទួលរងការរំខាន ក្នុងអំឡុងដំណាក់កាលសាងសង់។ គេអាចបញ្ចៀសកាត់បន្ថយជាអតិបរមា ឬសម្រាលផលប៉ះពាល់នេះបាន។ | • ការសម្អាតទីតាំងសម្រាប់សាងសង់ បោះជំរំ<br>• ការប្រើប្រាស់ និង/ឬរក្សាទុកវត្ថុធាតុដើមសម្រាប់បម្រើដល់ការសាងសង់ |
| ២. | ការបាត់បង់ ឬការរេចរឹលធនធានធម្មជាតិ/បរិស្ថានដ៍មានតម្លៃ | • ប្រសិនបើដីខ្សាច់ ក្រួស និងថ្ម ពីបាតទន្លេត្រូវបានទាញយកមកប្រើប្រាស់ នោះលំហូររបស់ទន្លេអាចរងផលប៉ះពាល់ធ្ងន់ធ្ងរ។ ទឹកទន្លេអាចហូរជុំវិញសសរស្ពាន និងគ្រឹះស្ពាន ដែលអាចប៉ះពាល់ធ្ងន់ធ្ងរដល់លំនឹងរបស់ស្ពាន។ ទន្លេអាចធ្វើឱ្យច្រោះដីនៅផ្នែកផ្សេងទៀតនៃបាតទន្លេ និងច្រាំទន្លេ និងបង្កឱ្យមានបញ្ហាធ្ងន់ធ្ងរនៅកន្លែងផ្សេងទៀត។<br>• ទីតាំងមួយចំនួនអាចមានសារៈសំខាន់ចំពោះសហគមន៍មូលដ្ឋានផ្នែកវប្បធម៌/សាសនា/ប្រវត្តិសាស្ត្រ/បុរាណវិទ្យា។<br>• ប្រសិនបើការសាងសង់ធ្វើឡើងនៅ ឬជិតទីតាំងដែលងាយរងផលប៉ះពាល់ចំពោះសង្គម និងបរិស្ថានបែបនេះ ការគំរាមកំហែង ឬការខូចខាតធ្ងន់ធ្ងរ/ជាអចិន្ត្រៃយ៍ អាចកើតឡើងចំពោះទីតាំងទាំងនេះ។<br>• ការចូលរបស់មនុស្សទៅដល់តំបន់ដែលពុំទទួលរងការរំខាន អាចនាំឱ្យមានការខូចខាត (ដូចជា ដោយសារតែមានការប្រមូលរុក្ខជាតិ ការចាប់សត្វព្រៃ ការបរបាញ់ ការបង្កាត់ភ្លើង ការចោលសំរាម។ល។) ដល់គម្របរុក្ខជាតិដែលជាដែនជម្រកនៃសត្វព្រៃ ឬបង្កឱ្យមានហានិភ័យ អគ្គីភ័យកើតមានឡើង។ | • ការសម្អាតទីតាំង<br>• ការសាងសង់<br>• ការទាញយកធនធានធម្មជាតិ ដើម្បីទទួលបានវត្ថុធាតុដើមសម្រាប់ការសាងសង់នៅទីតាំងសំខាន់ៗ ជាពិសេសក្រួសពីបាតទន្លេ។ល។ |
| 3. | ការរេចរឹលតំបន់ទេសភាពដែលមានស្រាប់ | ផលប៉ះពាល់ទាំងនេះ អាចកើតមានឡើង នៅពេលគម្របរុក្ខជាតិ/ស្រទាប់ដីផ្នែកខាងលើត្រូវបានដកចេញ ឬមានការសាងសង់សំណង់នៅទីកន្លែង ដែលធម្មជាតិធ្លាប់ទទួលរងការរំខានតិចតួចកន្លងមក ឬនៅពេលដែលសំណង់ថ្មីៗបាំងមិនឱ្យគេមើលឃើញតំបន់ទេសភាពដ៍ស្រស់ស្អាតដែលកំពុងមានស្រាប់។ | • ការសម្អាតទីតាំង<br>• ការសាងសង់សំណង់ថ្មីៗនៅតំបន់ដែលមានទេសភាពស្រស់ស្អាត/មានតម្លៃ |
| 4. | ការផ្ទេរលទ្ធកម្មដីធ្លីពុំទទួលបានជោគជ័យ | ដីមួយចំនួនតូចអាចនឹងត្រូវផ្ទេរលទ្ធកម្មតាមរយៈការផ្តល់អំណោយ ឬតាមរយៈការផ្តល់សំណង សម្រាប់សកម្មភាពកសិកម្ម ចិញ្ចឹមសត្វ និងនេសាទ ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធផលិតកម្មខ្នាតតូច (ឧទាហរណ៍ បរិក្ខារកែច្នៃក្រោយពេលប្រមូលផល ឃ្លាំងស្តុកទុក និងរោងចិញ្ចឹមបក្សី។ល។)។ | • វត្តមានរបស់ក្រុមហ៊ុនម៉ៅការនៅទីតាំង<br>• ការចាប់ផ្តើមសាងសង់ ឬសកម្មភាពដែលកំពុងអនុវត្តបន្ត |
| 5. | ធនធានវប្បធម៌រូបវន្តមាននៅទីតាំងអនុគម្រោង | ក្នុងអំឡុងពេលរៀបចំផែនការ ឬសាងសង់អនុគម្រោង មានការរកឃើញធនធានរូបវន្តធនធានវប្បធម៌ និងធនធានសាសនា | • ការសម្អាតទីតាំងសម្រាប់ទីតាំងសាងសង់ បោះជំរំ<br>• ការប្រើប្រាស់វត្ថុធាតុដើមសម្រាប់ការសាងសង់ និង/ឬការ |

| | ផលប៉ះពាល់/ហានិភ័យដែលអាចកើតមានឡើង | សេចក្តីពិពណ៌នាអំពីបញ្ហា/ហានិភ័យ | សកម្មភាពធម្មតា ដែលអាចបង្ក<br>ឱ្យមានផលប៉ះពាល់/ហានិភ័យ |
|---|---|---|---|
| | | | រក្សាទុកវត្ថុធាតុដើមទាំងនោះ |
| 6. | ការបង្កើតសំណល់រឹង | ការកកាយដីអាចនាំឱ្យមានសំណល់ សំណល់ក៏អាចកើតចេញពីសម្ភារៈ ដែលពុំត្រូវបានប្រើប្រាស់ផងដែរ ដូចជា ឈើ/ស្មៅ/លោហៈធាតុ សម្ភារៈវេចខ្ចប់ និង សំណល់ដែលបង្កឡើងដោយកម្មករះ ប្រអប់ដាក់បាយ អាហារដែលនៅសល់។ល។ | • ការកកាយដី<br>• សំណង់<br>• សកម្មភាពប្រចាំថ្ងៃរបស់កម្មករ |
| 7. | ការបង្កើតទឹកស្អុយ | • ទឹកស្អុយដែលបង្កើតឡើងដោយកម្មករពីការលាងដៃ និងការប្រើប្រាស់បង្គន់<br>• ការបង្កើតទឹកស្អុយ ដោយពុំមានការគ្រប់គ្រងត្រឹមត្រូវ អាចនាំឱ្យមានការបំពុលបរិស្ថាន ការរំខាន និង បញ្ហា សុខភាពសម្រាប់កម្មករ និង សាធារណជនទូទៅ | • ការកកាយដី<br>• ការប្រើប្រាស់វត្ថុធាតុដើមសម្រាប់សាងសង់<br>• សកម្មភាពរបស់កម្មករនៅនឹងការដ្ឋាន |
| 8. | ការបង្កើតសំណល់គីមី និងសំណល់គ្រោះថ្នាក់ | ប្រេងដែលប្រើរួច ថ្នាំលាប ប្រេងរំអិល អាគុយ និងសម្ភារៈដែលមានផ្ទុកសារធាតុអាបេស្តូស គឺជាសំណល់ពុល។<br>សំណល់រឹងមួយចំនួន អាចប្រឡាក់ប្រឡូកជាមួយនឹងប្រេង ថ្នាំលាប។ល។ និងអាចបញ្ចេញជាតិពុល និងបង្កហានិភ័យដល់សុខភាពសាធារណៈ។ | • ការសម្អាតទីតាំង<br>• ការជួសជុលយានយន្ត<br>• ការលាបថ្នាំ |
| 9. | ធូលី ការបំពុលខ្យល់ | ការប៉ះពាល់ និងធូលី និងផ្សែងក្នុងកម្រិតខ្ពស់ អាចបង្កផលប៉ះពាល់ដល់សុខភាពៈ ប៉ះពាល់ដល់ប្រព័ន្ធផ្លូវដង្ហើម ភ្នែក | • ការសម្អាតទីតាំង<br>• ការកកាយដី<br>• ការដំណើរការម៉ាស៊ីន<br>• ការលើកដាក់សម្ភារៈសាងសង់ |
| 10. | សំឡេងរំខាន និងរំញ័រ | សំឡេងរំខានប៉ះពាល់ដល់ការស្តាប់ឮ ការស្តាប់ និងអាចនាំឱ្យមានបញ្ហាស្ត្រេស/ឈឺក្បាល។ រំញ័រអាចនាំឱ្យមានស្នាមប្រេះ/ខូចខាតសំណង់ដែលមានស្រាប់។ | • ការចាក់គ្រឹះ<br>• ការបង្ហាប់ដី |
| 11. | ការបង្កើនហានិភ័យនៃការច្រោះដី/ការធ្វើឱ្យទឹកកាន់តែល្អក់/កំណរល្បាប់ | • ទីជម្រាលលែងមានស្ថិរភាពទៀត នៅពេលដែលផ្ទៃដីខាងលើ ទទួលរងការរំខាន។ ទឹកអាចហូរលឿនជាងមុន និងអាចច្រោះដីនៅលើទីជម្រាល ដែលលែងមានគម្របរុក្ខជាតិទៀត។ ដូច្នេះ ហានិភ័យនៃការច្រោះដី និងការបាក់ដីអាចមានការកើនឡើង ប្រសិនបើអគារមានទីតាំងនៅលើជម្រាលភ្នំ ឬ ប្រសិនបើសកម្មភាពសាងសង់បង្ករំខានដល់ជម្រាល។<br>• ដីនៅផ្ទៃខាងលើ ដែលហូរច្រោះ នឹងធ្លាក់ទៅផ្នែកខាងក្រោម បន្ទាប់មកត្រូវបានទឹកភ្លៀងហូរច្រោះបន្ត ដែលនាំឱ្យទឹកត្រូវល្អក់ខ្លាំង និងធ្វើឱ្យមានកំណដីល្បាប់នៅបាតទន្លេ/ក្នុងស្ទឹង។ | • ការសម្អាតទីតាំង<br>• សកម្មភាពកកាយដីនាំឱ្យតំបន់លែងមានគម្របរុក្ខជាតិក្នុងអំឡុងពេល និងក្រោយពេលសាងសង់<br>• ការងារសាងសង់ដែលធ្វើឡើង នៅទីជម្រាលដែលចោទខ្លាំង និង/ឬដែលមិនសូវមានលំនឹង |

| | ផលប៉ះពាល់/ហានិភ័យដែលអាចកើតមានឡើង | សេចក្តីពិពណ៌នាអំពីបញ្ហា/ហានិភ័យ | សកម្មភាពធម្មតា ដែលអាចបង្ក ឱ្យមានផលប៉ះពាល់/ហានិភ័យ |
|---|---|---|---|
| 12. | ការរេចរឹលគុណភាពទឹក | • សំណល់ និងស្អុយ, សម្ភារៈសាងសង់ពីការសាងសង់អាចលេចធ្លាយ ឬប៉ះពាល់ទៅក្នុងប្រភពទឹក នៅជិតទីតាំងសាងសង់ ឬនៅខ្សែទឹកខាងក្រោមនៃការដ្ឋានសាងសង់។<br>• គុណភាពទឹកនៅក្នុងស្ទឹង និងទន្លេអាចរងផលប៉ះពាល់ប្រសិនបើដីពីជម្រាលនៅតំបន់រងទឹកភ្លៀង ត្រូវហូរច្រោះចូលទៅក្នុងដែនទឹក ដោយសារការច្រោះដី/ការបាក់ដីដែលបង្កឡើង ដោយសារការកកាយដីនៅការដ្ឋានសាងសង់។<br>• សកម្មភាពប្រើប្រាស់ទឹកដោយពុំមានការប្រុងប្រយ័ត្នរបស់កម្មករ ឧទាហរណ៍ ការលាងសម្អាតឧបករណ៍ដោយផ្ទាល់នៅប្រភពទឹក។<br>• ប្រេង, ឥន្ធនៈ ឬសារធាតុរាវដទៃទៀតដែលត្រូវបានប្រើប្រាស់ក្នុងអំឡុងពេលសាងសង់ ដូចជា ការជួសជុលម៉ាស៊ីននៅទីតាំងផ្ទាល់ អាចលេចធ្លាយ ឬកំពប់ចូលទៅក្នុងដី។ បន្ទាប់មកទឹកភ្លៀងអាចហូរច្រោះសារធាតុកខ្វក់ទាំងនេះចូលទៅក្នុងដែនទឹកដែលនៅជិតនោះ។ | • ការសាងសង់ស្ពាននៅស្ទឹង ឬបាតទន្លេ<br>• សំណល់ពីការសាងសង់ និងការបញ្ចេញទឹកស្អុយ<br>• ការលាងសម្អាត និងការជួសជុលឧបករណ៍ និងគ្រឿងម៉ាស៊ីននានា |
| 13. | ប៉ះពាល់ដល់ទីតាំងវប្បធម៌ ដូចជា វិហារកាតូលិច ទីតាំងប្រវត្តិសាស្ត្រ ផ្នូរ។ល។ | ទីតាំងវប្បធម៌អាចរងផលប៉ះពាល់ដោយសារធូលី សំឡេងរំខានពីការលើកដាក់/សំណល់ និងសំរាម។ វត្ថុសិល្បៈមួយចំនួនអាចត្រូវបានរកឃើញក្នុងអំឡុងពេលកកាយដីនៅនឹងការដ្ឋាន។ | • សកម្មភាពដែលបង្កើតឱ្យមានធូលី និងសំឡេងរំខាន<br>• ការលើក/ដាក់សម្ភារៈសាងសង់ និងសំណង់ |
| 14. | ការរំខានដល់សហគមន៍នៅមូលដ្ឋាន៖<br><br>✓ ចរាចរណ៍/ការដឹកជញ្ជូន<br>✓ ការផ្គត់ផ្គង់ទឹក<br>✓ ធារាសាស្ត្រ<br>✓ ការធ្វើកសិកម្ម<br>✓ កិច្ចប្រជុំ/ព្រឹត្តិការណ៍ក្នុងសហគមន៍។ល។ | • ប្រសិនបើការងារធ្វើឡើងនៅ ឬជិតផ្លូវ ឬប្រព័ន្ធលូដែលមានស្រាប់, សកម្មភាពសាងសង់ អាចរំខាន ឬបង្អាក់ចរាចរនៅលើផ្លូវដែលមានស្រាប់។<br>• ការកកាយដីក៏អាចបង្កឱ្យមានការបាត់បង់គម្របរុក្ខជាតិ និងបង្កការរំខានដល់ដីផងដែរ។<br>• ការកកាយដីអាចរំខានដល់ប្រតិបត្តិការនៃសេវាដែលផ្តល់ដោយទីតាំងដែលមានស្រាប់ ដូចជា ការផ្គត់ផ្គង់ទឹក ប្រព័ន្ធលូ ការផ្គត់ផ្គង់ថាមពល។ល។ ប្រសិនបើបំពង់លូ/ខ្សែភ្លើងកាត់តំបន់ដែលមានការកកាយដី។<br>• គំនរដីដែលបានកកាយ។<br>• ប្រសិនបើសកម្មភាពសាងសង់ធ្វើឡើងនៅជិតតំបន់កសិកម្ម ការចូលទៅដីកសិដ្ឋានអាចរងការរំខាន។ សម្ភារៈសំណល់ និងទឹកស្អុយពីការដ្ឋានសំណង់ អាចហូរចូលទៅក្នុងកសិដ្ឋានបង្កឱ្យមានការថយចុះផលិតភាព និងធ្វើឱ្យមានទំនាស់ក្នុងសង្គម។<br>• ប្រសិនបើការដ្ឋានសាងសង់មានទីតាំងនៅជិតមជ្ឈមណ្ឌលសហគមន៍ ការលើកដាក់សម្ភារៈ ឬសំឡេងរំខានពីការកាត់ការស្វាន ការផ្សារសម្ភារៈនានា អាចធ្វើឱ្យរាំងស្ទះដល់ការចូលទៅដល់មជ្ឈមណ្ឌលសហគមន៍ ឬរំខានកិច្ចប្រជុំជាសាធារណៈ។ | • ការសម្អាតទីតាំង<br>• ការកកាយដី<br>• ដំណើរការគ្រឿងម៉ាស៊ីន<br>• ការរាំងស្ទះជាបណ្តោះអាសន្ន នៅទន្លេ/ស្ទឹង/ប្រឡាយស្រោចស្រពដែលមានស្រាប់ សម្រាប់ការងារសាងសង់<br>• ការរាំងស្ទះបណ្តោះអាសន្ននៅផ្លូវសម្រាប់សាងសង់កំណាត់ផ្លូវភ្ជាប់ទៅនឹងផ្លូវថ្មី |

| | ផលប៉ះពាល់/ហានិភ័យដែលអាចកើតមានឡើង | សេចក្តីពិពណ៌នាអំពីបញ្ហា/ហានិភ័យ | សកម្មភាពធម្មតា ដែលអាចបង្កឱ្យមានផលប៉ះពាល់/ហានិភ័យ |
|---|---|---|---|
| 15. | សុខភាព/អនាម័យនៅក្នុងសហគមន៍មូលដ្ឋាន | • ទឹកនឹង ដែលកើតចេញពីតំបន់រងការរំខាននៅការដ្ឋានសាងសង់ ជាកន្លែងដែលនាំឱ្យមានការកកើតមូស ដែលជាភ្នាក់ងារចម្លងជំងឺឆ្លងតាមទឹក។<br>• សំណល់ដែលបង្កើតឡើងដោយកម្មករដែលស្នាក់នៅទីតាំងអាចទាក់ទាញពពួកសត្វមានពិស និងសត្វល្អិត<br>• ការង្កើតទឹកស្អុយអាចបង្កឱ្យមានការរំខាន និងហានិភ័យសុខភាពដល់មនុស្ស។ | • ការកកាយដីនាំឱ្យមានគ្រលុកជ្រៅៗ ឬគ្រលុករាក់ៗ |
| 16. | ហានិភ័យសុវត្ថិភាពចំពោះសហគមន៍ | សកម្មភាពពាក់ព័ន្ធនឹងការសាងសង់អាចបង្កឱ្យមានហានិភ័យសុវត្ថិភាពដល់សហគមន៍មូលដ្ឋាន ជាពិសេសកុមារ។ ប្រសិនបើកុមារចូលទៅតំបន់ដែលមានរណ្តៅជ្រៅៗ ឬមានវត្ថុមាននៅនឹងការដ្ឋាន ក្នុងអំឡុងពេលដឹកជញ្ជូន/លើកដាក់សម្ភារៈនានា។ | • ការដឹកជញ្ជូនសម្ភារៈ/សំណល់<br>• ការលើក/ដាក់សម្ភារៈ<br>• គ្រលុកដែលកើតឡើងដោយសារការកកាយដី<br>• ដំណើរការគ្រឿងម៉ាស៊ីន |
| 17. | សុខភាព និងសុវត្ថិភាពកម្មករ | រណ្តៅដែលពុំមានការការពារនៅនឹងទីតាំង ការងាយនឹងប៉ះពាល់នឹងចរាចរនៅតាមចិញ្ចើមផ្លូវ ខ្សែភ្លើងដែលតពុំបានត្រឹមត្រូវ ដំណើរការ និងការគ្រប់គ្រងគ្រឿងចក្រសំណង់ គ្រឿងម៉ាស៊ីន និងឧបករណ៍នានាអាចបង្កឱ្យមានហានិភ័យសុវត្ថិភាពចំពោះកម្មករ។ | • សកម្មភាពសាងសង់ទូទៅ ដំណើរការឧបករណ៍ និងរោងចក្រ |
| **ដំណាក់កាលប្រតិបត្តិការ** | | | |
| 1. | ការបំពុលទឹក/ដី | ការលេចធ្លាយ ឬការបង្ហូរសំណល និងទឹកស្អុយដែលកើតចេញពីការដ្ឋាន។ | សកម្មភាពប្រើប្រាស់ទឹកនៅក្នុងអគារ/ទីជម្រក |
| 2. | ការបំពុលទឹក/ដី | • ទឹកស្អុយដែលហូរចេញពីអាងស្តុកទឹកស្អុយ អាចបំពុលទឹកក្រោមដី ឬទឹកលើដី ជាពិសេសប្រសិនបើបំពង់លូត្រូវបានតភ្ជាប់ជាមួយនឹងប្រព័ន្ធលូបើក។<br>• ទឹកស្អុយដែលត្រូវបានសម្អាតខ្លះ និងដែលហូរចេញពីអាងស្តុកទឹកស្អុយ អាចបំពុលទឹកក្នុងដី នៅក្នុងអណ្តូងដៃ ទោះបីជារាប់ឆ្នាំក្រោយមកទៀតក៏ដោយ។<br>• ទឹកនៅលើដីដែលទទួលរងការបំពុលពីបរិវេណជុំវិញអាងស្តុកទឹកស្អុយ អាចហូចចូលទៅក្នុងទឹកក្នុងដី។ | បរិក្ខារអនាម័យ |
| 3. | ផលប៉ះពាល់លើសោភ័ណ្ឌភាព | ប្រសិនបើអគារស្ថិតនៅក្នុងតំបន់សាធារណៈ និងធ្វើឱ្យប៉ះពាល់ដល់តម្លៃទេសភាពជុំវិញ។ | បរិក្ខារអនាម័យ/ប្រព័ន្ធលូ |
| 4. | សំឡេងរំខាន ក្លិន ស្ថានភាពពុំមានអនាម័យ ហានិភ័យសុខភាពសាធារណៈ | • ទឹកស្អុយពីអាងស្តុកទឹកស្អុយមានក្លិនអាក្រក់ និងអាចបង្កឱ្យមានការរំខានដល់សាធារណៈជនទូទៅ នៅពេលដែលសាធារណជនធុំក្លិន/មើលឃើញទឹកស្អុយទាំងនោះ។<br>• ទឹកស្អុយនៅក្នុងអាងស្តុកទឹកស្អុយ ត្រូវបានសម្អាតបានខ្លះតែប៉ុណ្ណោះ ដូច្នេះវាអាចសាយភាយមេរោគ និងជំងឺ ដែលអាចបង្កឱ្យមានហានិភ័យដល់សុខភាព។<br>• កង្វះប្រព័ន្ធលូត្រឹមត្រូវនៅជុំវិញរ៉ូប៊ីណេទឹកសាធារណៈ នាំឱ្យមានភក់ជ្រាំជុំវិញរ៉ូប៊ីណេទាំងនោះ ឬបរិវេណជុំវិញ។ ទឹកដែលដក់នៅទីនោះ អាចក្លាយជាកន្លែង | អនាម័យ |

| | **ផលប៉ះពាល់/ហានិភ័យដែលអាចកើតមានឡើង** | **សេចក្តីពិពណ៌នាអំពីបញ្ហា/ហានិភ័យ** | **សកម្មភាពធម្មតា ដែលអាចបង្កឱ្យមានផលប៉ះពាល់ /ហានិភ័យ** |
|---|---|---|---|
| | | មូសបង្កកំណើត និង បង្កភាពមិនងាយស្រួលដល់អ្នកប្រើប្រាស់ទឹក។<br>• កន្លែងប្រើប្រាស់ទឹកចំហ ឬពុំមានរ៉ូប៊ីណេត្រឹមត្រូវ អាចធ្វើឱ្យកំពប់ទឹកយ៉ាងច្រើន នៅពេលថ្ងៃ។ នេះគឺជាខ្ជះខ្ជាយទឹកដ៏មានតម្លៃ ដែលអ្នកប្រើប្រាស់ដទៃទៀតអាចត្រូវការ។ | |
| 6. | ស្ថានភាពពុំមានអនាម័យ ហានិភ័យសុខភាពសាធារណៈ | ភក់ជ្រាំ/ការឡើងល្អក់នៃទឹក នៅរ៉ូប៊ីណេសាធារណៈ នាំឱ្យមានស្ថានភាពពុំមានអនាម័យ និង/ឬ កន្លែងមូសពង។ | ការផ្គត់ផ្គង់ទឹក |
| 7. | ទំនាស់ជាមួយនឹងតម្រូវការទឹក នៅខ្សែទឹកខាងក្រោម | នៅពេលដែលទឹកហូរចូលមក ត្រូវបានរក្សាទុកខ្លះ នៅខ្សែទឹកខាងលើ ដោយអ្នកប្រើប្រាស់ទឹកមួយក្រុមណានោះ ក្រុមផ្សេងទៀត អាចមានទឹកដែលពួកគេត្រូវការក្នុងបរិមាណតិចតួចជាងមុន ដែលអាចនាំឱ្យមានទំនាស់រវាងក្រុមសហគមន៍ផ្សេងៗគ្នា។ | ការផ្គត់ផ្គង់ទឹក |
| 8. | ព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ/គ្រោះមហន្តរាយធម្មជាតិ ដូចជា ខ្យល់ព្យុះជាដើម | • ព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ រគ្រោះមហន្តរាយធម្មជាតិអាចបង្កការខូចខាតដល់សំណង់ ដែលសាងសង់ដោយគម្រោង ឬរំខានដល់សេវាដែលផ្តល់ដោយទីតាំងទាំងនេះ។<br>• នៅក្នុងករណីមួយចំនួន ព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ ដូចជាព្យុះស៊ីក្លូន អាចមិនបង្កផលប៉ះពាល់ដោយផ្ទាល់ដល់ទីតាំងផ្តល់សេវាទាំងនេះ ប៉ុន្តែអាចធ្វើឱ្យខូចខាតដល់វត្ថុជុំវិញ ហើយវត្ថុទាំងនេះអាចបង្កឱ្យមានការខូចខាតដល់ទីតាំងផ្តល់សេវា ដែលសាងសង់ដោយគម្រោង ដូចជា ការដួលរលំដើមឈើ ចូលទៅក្នុងអគាររក្សាទុកទឹកជាដើម។ | ភ្លៀងធ្លាក់ខ្លាំង |

58. **សមាសភាគទី ២៖ លើកកម្ពស់ប្រព័ន្ធព័ត៌មានកសិកម្ម និងការគ្រប់គ្រងការត្រួតពិនិត្យគុណភាព ។** គោលបំណងនៃសមាសភាគទី ២ នេះ គឺដើម្បីពង្រឹងចំណេះដឹងជាមូលដ្ឋាន សមត្ថភាពវិភាគទិន្នន័យ និងប្រព័ន្ធអនុវត្តលិខិតបទដ្ឋានគតិយុត្តិក្នុងវិស័យសាធារណៈ ព្រមទាំងការអនុវត្ត និងការពង្រឹងការអនុវត្តប្រព័ន្ធទាំងនេះ។ ការងារទាំងនេះនឹងរួមចំណែកពង្រីក និងបង្កើនតម្លាភាពចំណេះដឹង ព្រមទាំងកែលម្អការធ្វើសេចក្តីសម្រេចចិត្តរបស់តួអង្គក្នុងវិស័យសាធារណៈ និងវិស័យឯកជន ដែលផលសម្រេចបាន នឹងមានវិសាលភាពលើសពីអនុគម្រោង PA ដែលបានទទួលការគាំទ្រទៅទៀត។ ប្រព័ន្ធព័ត៌មានកសិកម្ម និងគ្រប់គ្រងគុណភាពកសិកម្ម នឹងផ្តល់ប្រយោជន៍ដល់អ្នកពាក់ព័ន្ធផ្ទាល់ ក៏ដូចជា កសិករ ក្រុមអ្នកផលិត និងសហគ្រាសកសិកម្មខ្នាតតូច និងខ្នាតមធ្យម ដែលកំពុងប្រតិបត្តិការនៅក្នុងឃុំ និងខេត្តផ្សេងទៀត ក្រៅតែពីតំបន់គម្រោងផងដែរ។ សមាសភាគនេះក៏នឹងផ្តល់ហិរញ្ញប្បទានដល់ការងារវិភាគ និងផ្តល់ប្រឹក្សាគោលនយោបាយ ដើម្បីតម្រង់ទិសការវិនិយោគរបស់រដ្ឋាភិបាលក្នុងការគាំទ្រដល់ការអភិវឌ្ឍវិស័យកសិកម្ម។

59. ***សមាសភាគរង ២.១៖ ប្រព័ន្ធព័ត៌មានកសិកម្ម។*** នឹងមានការផ្តល់ហិរញ្ញប្បទានសម្រាប់ការវិនិយោគលើការបន្តអភិវឌ្ឍន៍ និងលើកកម្ពស់ការប្រើប្រាស់ផែនទីដី/កសិ-បរិស្ថាន ប្រព័ន្ធផ្តល់ព័ត៌មានទាន់ពេលវេលាពាក់ព័ន្ធនឹងកសិកម្ម ស្ថិតិផលិតកម្មអាហារ និងកសិកម្ម/ទិន្នន័យជំរឿន (ព័ត៌មានទីផ្សារកសិកម្ម និងប្រព័ន្ធព័ត៌មានទីផ្សារ) និងទិន្នន័យដទៃទៀត។ បច្ចេកវិទ្យា ICT ថ្មីនឹងត្រូវយកមកប្រើប្រាស់ ដើម្បីធានាឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយបំផុតនូវទិន្នន័យ

និងព័ត៌មានដែលមាន សម្រាប់ការរៀបចំផែនការ និងការធ្វើសេចក្តីសម្រេចចិត្តរបស់តួអង្គពាក់ព័ន្ធក្នុងវិស័យសាធារណៈ និងវិស័យឯកជន ពាក់ព័ន្ធនឹងផលិតកម្ម ការកែច្នៃ ការស្វែងរកទីផ្សារផលិតផលកសិកម្ម និងសេវាកម្ម។ លើសពីនេះ ក៏នឹងមានការគាំទ្រដល់ការប្រមូលព័ត៌មានទីផ្សារ ដើម្បីកំណត់រកឱកាសរយៈពេលមធ្យម និងរយៈពេលវែងសម្រាប់ផលិតផលសមស្របផងដែរ។ នឹងមានការផ្តល់ថវិកា សម្រាប់ការផ្តល់ព័ត៌មានឱ្យចំគោលដៅ ដោយប្រើប្រាស់បច្ចេកវិទ្យាសមស្របថ្មីៗ ដើម្បីឱ្យព័ត៌មានបានទៅដល់កសិករជាស្ត្រីចូលរួមក្នុងគម្រោងនេះ ដែលការយល់ដឹងព័ត៌មានពីឯកសារសរសេរនៅមានកម្រិត។ ការផ្សព្វផ្សាយព័ត៌មាន ក៏នឹងបញ្ចូលសារ និងឯកសារពាក់ព័ន្ធនឹងអាហារូបត្ថម្ភផងដែរ ដើម្បីពង្រឹងលទ្ធផលអាហារូបត្ថម្ភរបស់គម្រោង។

60. ***សមាសភាគរង ២.២ ការគ្រប់គ្រងគុណភាព។*** ការវិនិយោគ ដើម្បីពង្រឹងប្រសិទ្ធភាពការការពាររុក្ខជាតិ និងភូតគាមអនាម័យ សុខភាពសត្វ និងការឃ្លាំមើលភូតគាមអនាម័យ សុខភាពសត្វ និងសុវត្ថិភាពអាហារ ប្រព័ន្ធរាយការណ៍ និងប្រព័ន្ធអធិការកិច្ច និងប្រព័ន្ធពង្រឹងការអនុវត្តការគ្រប់គ្រងលើវត្ថុធាតុដើមកសិកម្ម នឹងទទួលបានការគាំទ្រ។ ការគាំទ្រនេះ រួមមានការគាំទ្រដល់ការបង្កើតនូវសេវាចេញវិញ្ញាបនបត្រ ផ្តល់អាជ្ញាប័ណ្ណ និងត្រួតពិនិត្យ និងគ្រប់គ្រងគុណភាពផ្សេងទៀត ព្រមទាំងការបង្កើត និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តិ អំពីការអនុវត្តល្អផ្នែកកសិកម្ម (GAP) និងការអនុវត្តល្អ ផ្នែកផលិតផលសរីរាង្គ ការចិញ្ចឹមសត្វ និងការប្រើប្រាស់ព័ត៌មានសម្គាល់ភូមិសាស្ត្រ។ល។

61. សមាសភាគរង ២.១, ២.២ នឹងពុំមិនបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានឡើយ។ គោលការណ៍ណែនាំអន្តរកាលស្តីពីការអនុវត្តគោលនយោបាយស្តីពីការការពារ លើផលប៉ះពាល់ចំពោះសកម្មភាពជំនួយបច្ចេកទេស នឹងត្រូវបញ្ចូលទៅក្នុងលក្ខខណ្ឌប្រតិបត្តិស្តីពីការរៀបចំផែនការ និងការដាក់អាទិភាពលើអន្តរាគមន៍នានា ដើម្បីជំរុញឱ្យមានផលប៉ះពាល់ជាវិជ្ជមានក្រោម ESMF នេះ។

4.2 ផលប៉ះពាល់សង្គម ដែលអាចកើតមានឡើង

62. **ជាតិពន្ធុនៅកម្ពុជា៖** បើតាមការអង្កេតប្រជាជនចុងក្រោយគេ (ក្រសួងផែនការ ឆ្នាំ ២០១៣) ជនជាតិដើមភាគតិចមាន ២៤ ក្រុមនៅកម្ពុជា។ តំបន់ដែលមានប្រជាជនជាជនជាតិដើមភាគតិចរស់នៅច្រើនជាងគេ គឺភាគខាងជើង និងភាគឦសាននៃប្រទេសកម្ពុជា ដែលជាដង់ស៊ីតេប្រជាជនទាប ដូចជា៖ ខេត្តក្រចេះ (ស្ទៀង ក្រោល មិល ព្នង កួយ ថ្មូន), ខេត្តមណ្ឌលគិរី (ព្នង ស្ទៀង ក្រោល រ្វូង រ៉ាដ), ខេត្តរតនគិរី (ទំពួន ជារាយ គ្រឹង ព្រៅ ឡូន ក្រវ៉េត កាចក់), ខេត្តស្ទឹងត្រែង (កួយ ព្នង កាវ៉េត គ្រឹង ខ្មែរឃិឡូន ព្រៅ), ខេត្តព្រះវិហារ (កួយ) និងខេត្តកំពង់ធំ (កួយ) ក៏ដូចជាកុលសម្ព័ន្ធតំបន់ភ្នំក្នុងខេត្តកោះកុង (ព័រ), ខេត្តពោធិ៍សាត់ (ព័រ), ខេត្តកំពង់ស្ពឺ (សួយ) និងខេត្តព្រះសីហនុ (សើច)។ តំបន់ទាំងនេះ ភាគច្រើនស្ថិតនៅជាប់ព្រំដែនជាមួយប្រទេសវៀតណាម ឡាវ និងថៃ។ ផ្ទុយទៅវិញ ភូមិភាគកណ្តាល និងតំបន់ជាប់ទន្លេមេគង្គ គឺជាតំបន់ ដែលសំបូរប្រជាជនរដ្ឋខ្មែររស់នៅ។ ការពុំមានការសិក្សាអំពីប្រជាជន នាំឱ្យគេមានការលំបាកក្នុងការកំណត់ពីចំនួនក្រុមជាតិពន្ធុនៅកម្ពុជា។ ក្រសួងអភិវឌ្ឍន៍ជនបទបានលើកឡើងថា ជនជាតិដើមភាគតិច អាចរស់នៅក្នុងសហគមន៍របស់ពួកគេលាយឡំជាមួយនឹងសហគមន៍ខ្មែរទូទៅ ឬបានធ្វើសមាហរណកម្មពេញលេញចូលទៅក្នុងសហគមន៍ជនជាតិខ្មែរ ប៉ុន្តែនៅបន្តរក្សាលក្ខណៈជនជាតិរបស់ពួកគេ និងនៅក្នុងករណីមួយចំនួន នៅបន្តប្រើប្រាស់ភាសារបស់ពួកគេ។ ការចុះប្រមូលទិន្នន័យនៅតាមខេត្ត ដែលអាចនឹងត្រូវជ្រើសរើសដើម្បីអនុវត្តគម្រោងនេះ បានបញ្ជាក់ថា ក្រុមដែលកំណត់ខ្លួនឯងថាជាជនជាតិដើមភាគតិចបានលើកឡើងថា ពួកគេអាចប្រាស្រ័យទាក់ទង ដោយប្រើប្រាស់ភាសាខ្មែរបាន ហើយក្នុងពេលជាមួយគ្នានៅតែបន្តប្រើប្រាស់ភាសាជនជាតិដើមភាគតិចរបស់ពួកគេទៀត។ ពួកគេភាគច្រើនបានលើកឡើងថា ពួកគេបាន និងកំពុងរស់នៅជាមួយសហគមន៍ជនជាតិខ្មែរទូទៅ ជាងមួយជំនាន់ហើយ។

63. ដូចដែលត្រូវបានរកឃើញក្នុងជំរឿនប្រជាជន រដ្ឋាភិបាលបានលើកឡើងថា មានប្រជាជនចំនួន ២៦៤.៦០០ នាក់ ស្ថិតក្នុងក្រុមជនជាតិភាគតិច ដែលរស់នៅក្នុងប្រទេសនេះ ឬស្មើនឹងប្រមាណ ៤% នៃចំនួនប្រជាជនសរុប។ ជនជាតិចាម ដែលមានឈ្មោះម្យ៉ាងទៀត ខ្មែរអ៊ិស្លាម គឺជាសហគមន៍ជនជាតិភាគតិចធំជាងគេទី ២ នៅកម្ពុជា បន្ទាប់ពីក្រុមជនជាតិខ្មែរ ដែលជាក្រុមជនជាតិភាគច្រើន។ សហគមន៍ជនជាតិចិន ដែលមានចំនួនប្រមាណ ៣៤.៥០០ នាក់ គឺជាក្រុមធំជាងគេទី ៣ ហើយគួរឱ្យភ្ញាក់ផ្អើលនោះ ក្រុមធំជាងគេទី ៤ គឺក្រុមជនជាតិដែលរស់នៅតំបន់ខ្ពស់រាប

ដែលមានឈ្មោះថា ពួង។ សហគមន៍ជនជាតិវៀតណាម ត្រូវបានដាក់ចំណាត់ថ្នាក់ថាជាក្រុមធំជាងគេទី ៧។ រហូតមកដល់ឆ្នាំ ១៩៩២ សហគមន៍ជនជាតិចិន និងជនជាតិវៀតណាម ត្រូវបានចាត់ទុកថាជាក្រុមជនជាតិភាគតិចនៅកម្ពុជា ដែលរួមគ្នាជាមួយនឹងជនជាតិដើមភាគតិច និងជនជាតិចាម។

64. លើកលែងតែរាជធានីភ្នំពេញចេញ រាល់ខេត្តដែលស្នើឡើង ដើម្បីអនុវត្តគម្រោង គឺជាតំបន់ដែលក្រសួងអភិវឌ្ឍន៍ជនបទទទួលស្គាល់ថាមានវត្តមាន គ្រួសារជនជាតិភាគតិច អាចរស់នៅ ឬធ្វើកសិកម្មដាច់ដោយឡែក ឬ រស់នៅក្នុងសហគមន៍ ឬធ្វើកសិកម្មជាគ្នានឹងសហគមន៍ជនជាតិខ្មែរ។ ដូច្នេះ ក្នុងអំឡុងពេលនៃការអនុវត្តគម្រោងនេះ សកម្មភាពអនុគម្រោងមួយចំនួនទំនងជានឹងមានការចូលរួមពីគ្រួសារជនជាតិភាគតិចមួយចំនួន។ ប៉ុន្តែ ដោយសារតែលក្ខណៈនៃអន្តរាគមន៍គម្រោងដែលលើកស្នើឡើង និងសកម្មភាពចិញ្ចឹមជីវិតរបស់ជនជាតិភាគតិច នៅក្នុងខេត្តអនុវត្តគម្រោង ហានិភ័យសង្គមដែលអាចពាក់ព័ន្ធជាមួយនឹងពួកគេ ត្រូវបានចាត់ទុកថា មានតិចតួចតែប៉ុណ្ណោះ ហើយភាគច្រើនពាក់ព័ន្ធជាមួយនឹងភាពចាំបាច់ ដើម្បីធ្វើការពិគ្រោះយោបល់ជាមួយពួកគេ អំពីការងារសាងសង់ និងការកែសម្រួល និងបកប្រែឯកសារបណ្តុះបណ្តាលអំពីបញ្ហានានា ដូចជា ការប្រើប្រាស់ថ្នាំកសិកម្ម ព័ត៌មានពាក់ព័ន្ធនឹងកសិកម្ម ក៏ដូចជា ឯកសារបង្កើនការយល់ដឹងនានា។

65. **វិស័យកសិកម្មនៅក្នុងប្រទេសកម្ពុជា៖** ដោយទទួលស្គាល់ពីសារៈសំខាន់នៃវិស័យកសិកម្មក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ច ការធានាសមធម៌ និងសន្តិសុខស្បៀង និងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចនៅតំបន់ជនបទ រដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្រ្តចំនួនបី៖ (១) ការបង្កើនផលិតភាព ការធ្វើពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម តាមរយៈការអនុវត្តវិធានការ ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ដែលរាប់បញ្ចូលទាំងការកសាង និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្រ្ត ថាមពល/អគ្គិសនី និងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍) ផងដែរ, (២) ការកែលម្អការផ្តល់សេវាផ្សព្វផ្សាយ និង (៣) ការកែលម្អធនធានកសិកម្ម កំណែទម្រង់ការគ្រប់គ្រងដីធ្លី ហិរញ្ញវត្ថុ ការផ្សព្វផ្សាយសេវាទីផ្សារ ការចងក្រងកសិករ ការកសាងស្ថាប័ន និងការសម្របសម្រួល។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ បានរំលេចឱ្យឃើញពីគោលដៅរបស់រដ្ឋាភិបាល ក្នុងការបង្កើនផលិតភាព ការធ្វើពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម។

66. ក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញផ្សាយឯកសារជំរឿនកសិកម្ម នៃព្រះរាជាណាចក្រកម្ពុជា កាលពីឆ្នាំ ២០១៥។ របាយការណ៍នេះបានរកឃើញថា មានប្រជាពលរដ្ឋ ២,២ លានគ្រួសារ កំពុងប្រលូកក្នុងសកម្មភាពកសិកម្ម។ ក្នុងចំណោមគ្រួសារទាំងនេះ ៨៥% (ស្មើនឹង ១,៨៧ លានគ្រួសារ) ត្រូវបានរាយការណ៍ថា កំពុងដាំដុះដំណាំក្នុងកសិដ្ឋានកសិកម្ម។ វិស័យកសិកម្មរួមចំណែក ៣៤% នៃផ.ស.ស របស់ជាតិ និងផ្តល់ការងារដល់កម្លាំងពលកម្ម ៦៣% ក្នុងចំណោមកម្លាំងពលកម្មសរុប (៨,២ លាននាក់)។ ផ្ទៃដីកសិកម្មសរុប (ដែលអាចដាំដុះបាន និងមានលក្ខណៈអចិន្ត្រៃយ៍) មានប្រមាណ ៤,៥ លានហិចតា៖ ដីមានជីជាតិ ៣,៩៩ លានហិចតា និងដីដាំដំណាំជាអចិន្ត្រៃយ៍ ០,៥១ លានហិចតា។ ផ្ទៃដីផលិតកម្មដំណាំភាគច្រើន (ស្រូវ បន្លែ ពោត ម្រេចខ្មៅ) មានការកើនឡើងជាបន្តបន្ទាប់ ដោយផ្ទៃដីសម្រាប់ដាំដុះដំណាំកៅស៊ូ និងដំឡូងមីកើនឡើង ៣ ដង។ ផ្ទៃដីសម្រាប់ដំណាំអំពៅ ដូងប្រេង ធុរេន និងពោត ក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ខណៈពេលដែលផ្ទៃដីដាំដំណាំមួយចំនួន ដូចជា ដំឡូងជ្វា, សណ្តែកបាយ, ល្ង, ក្រចៅ, កាហ្វេ និងក្របៃក មានការថមថយ។

67. ប្រព័ន្ធដាំដុះនៅក្នុងប្រទេសកម្ពុជា ផ្តោតសំខាន់លើដំណាំស្រូវ ដែលដាំទាំងរដូវវស្សា ទាំងរដូវប្រាំង។ ស្រូវរដូវវស្សា (២.៥៦៧.៧២៣ ហិចតា) ភាគច្រើនដាំនៅតំបន់វាលទំនាប ដែលត្រូវពឹងអាស្រ័យលើទឹកភ្លៀង (៨០%) ខ្ពង់រាប (២%) និងដាំក្នុងតំបន់ទឹកជ្រៅ/បណ្តែតទឹក (២%)។ ស្រូវរដូវប្រាំង (៤៨៤.៦៩៧ ហិចតា ស្មើនឹង ១៦%) ដាំភាគច្រើននៅតំបន់វាលទំនាប ដែលមានប្រព័ន្ធស្រោចស្រព ជាពិសេស តំបន់ដែលទទួលរងទឹកជំនន់ពីទន្លេមេគង្គ (រួមទាំងតំបន់ជុំវិញបឹងទន្លេសាបផងដែរ)។ កសិករកម្ពុជាក៏ដាំដំណាំផ្សេងទៀត ក្នុងប្រព័ន្ធបង្កបង្កើនផលស្រូវផងដែរ ដូចជា បន្លែ សណ្តែក ដើមឈើហូបផ្លែ។ល។ ដែលជាផ្នែកមួយនៃការដាំដំណាំឆ្លាស់គ្នា ដាំដំណាំចម្រុះលាយជាមួយគ្នា និងដាំដំណាំ

មួយមុខៗ ដោយឡែកៗពីគ្នា។ ដំណាំស្រូវ-ដាំឆ្លាស់ជាមួយនឹងសណ្ដែកបាយ ឬដំណាំសណ្ដែកបាយ-ដាំឆ្លាស់ជាមួយនឹងស្រូវ គឺជាប្រភេទដំណាំដាំឆ្លាស់គ្នា ដោយកសិករនៅក្នុងខេត្ត កំពង់ស្ពឺ តាកែវ កណ្ដាល និងកំពង់ឆ្នាំង។ នៅតំបន់ខ្ពង់រាប និងតំបន់ភ្នំវិញ មានការដាំដំណាំឧស្សាហកម្ម និងដើមឈើហូបផ្លែ ដូចជា កៅស៊ូ ដូងប្រេង អំពៅ ម្រេចខ្មៅ ដំឡូងមី ស្វាយ សារម៉ាវ មាន ជាដើម។ នៅដំណាក់កាលដំបូងៗនៃការដាំដំណាំកៅស៊ូ កសិករដាំពពួកសណ្ដែកមួយចំនួននៅចន្លោះដើមកៅស៊ូ ដូចជា សណ្ដែកសៀង សណ្ដាយបាយ និងសណ្ដែកដីជាដើម ដែលដំណាំទាំងនេះ ក៏ភាគច្រើនត្រូវបានដាំនៅតំបន់ខ្ពស់រាបផងដែរ។

68. ដើម្បីបង្កើនផលិតភាព និងការធ្វើពិពិធកម្ម ជំនួយបច្ចេកទេស និងជំនួយផ្នែកហិរញ្ញវត្ថុនៅតែត្រូវការជាចាំបាច់ក្នុងទ្រង់ទ្រាយធំ ក៏ដូចជាការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីលើកកម្ពស់ និងបង្កើនលទ្ធភាពទទួលបានសេវាផ្សព្វផ្សាយកសិកម្ម ប្រព័ន្ធធារាសាស្ត្រ គ្រាប់ពូជ និងបច្ចេកទេសដាំដុះ ដែលធន់ទៅនឹងអាកាសធាតុ ព្រមទាំងការប្រើប្រាស់ធនធានកសិកម្ម និងឥណទានឱ្យបានសមស្រប។ ពូជស្រូវ ១០ មុខ ដែលត្រូវបានជ្រើសរើសសម្រាប់ការបង្កើនផលិតភាព ក្រោមការសាកល្បងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពុំទាន់បានផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់កសិករទាំងអស់នោះឡើយ។ លើសពីនេះ បរិមាណពូជស្រូវទាំង ១០ មុខ នេះ នៅមិនទាន់គ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ដល់កសិករផងដែរ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធផ្សេងទៀត មានគោលបំណងរួមគ្នាជម្នះបញ្ហានេះ តាមរយៈការបង្កើតកសិដ្ឋានស្រាវជ្រាវរបស់រដ្ឋ ដើម្បីផ្គត់ផ្គង់ស្រូវពូជទៅឱ្យក្រុមផលិតស្រូវពូជ ដែលត្រូវផ្គត់ផ្គង់បន្តដល់កសិករ។

69. ប្រទេសកម្ពុជាទទួលរងគ្រោះញឹកញាប់ដោយសារគ្រោះមហន្តរាយនានា ជាពិសេសគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះធ្ងន់ធ្ងរ ដែលនាំឱ្យមានការបាត់បង់អាយុជីវិត និងការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ លំនៅដ្ឋាន និងផលដំណាំនានា។ ចាប់តាំងពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៣ មានផ្ទៃដីប្រមាណ ៤៥២.២១១ ហិចតា (ស្មើនឹង ១៥% នៃផ្ទៃដីដាំដុះស្រូវសរុប) ទទួលរងការបំផ្លិចបំផ្លាញដោយសារគ្រោះរាំងស្ងួត ទឹកជំនន់ និងសត្វល្អិត (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០០៦-២០១៣)។ ក្នុងឆ្នាំ ២០១១ ប្រទេសកម្ពុជាជួបប្រទះនឹងគ្រោះទឹកជំនន់ធ្ងន់ធ្ងរជាងគេមិនធ្លាប់មានក្នុងទសវត្សរ៍ចុងក្រោយនេះ។ អង្គការស្បៀង និងកសិកម្មពិភពលោក (២០១២) បានរាយការណ៍ថាមានប្រជាពលរដ្ឋ ៦០.០០០គ្រួសារ (ស្មើនឹង ២៥%) ក្នុងចំណោមគ្រួសារដែលទទួលរងផលប៉ះពាល់ដោយសារទឹកជំនន់ក្នុងខេត្តចំនួន ១៨ ជួបប្រទះនឹងបញ្ហាអសន្តិសុខស្បៀង ដែលស្ដែងចេញ តាមរយៈការមានបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវ និងរាំរ៉ៃ ក្នុងចំណោមកុមារក្នុងកម្រិតមួយខ្ពស់។ ក្នុងឆ្នាំ ២០០៩ ខ្យល់ព្យុះកេតសាណាបានវាយប្រហារប្រទេសកម្ពុជាចន្លោះពីថ្ងៃទី ២៩ ខែ កញ្ញា និងថ្ងៃទី ៥ ខែ តុលា។ ក្នុងចំណោមខេត្ត ២៤ មានខេត្តចំនួន ១៤ ទទួលរងផលប៉ះពាល់ដោយសារខ្យល់ព្យុះនេះ និងទឹកជំនន់ទឹកភ្លៀង ដែលកើតឡើងក្រោយព្រឹត្តិការណ៍ខ្យល់ព្យុះនេះ។ ខ្យល់ព្យុះសង្ឃរានេះ ធ្វើឱ្យមនុស្សបាត់បង់ជីវិតចំនួន ៤៣ នាក់ និង ៦៧ នាក់ទទួលរងរបួសធ្ងន់ធ្ងរ។ ខ្យល់ព្យុះនេះបានបំផ្លាញផ្ទះសម្បែង និងមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រមាណ ៤៩.០០០ គ្រួសារ (ស្មើនឹង ១,៤% នៃចំនួនប្រជាជនសរុបនៅកម្ពុជា)។ ការខាតបង់ ដែលកើតឡើងដោយសារខ្យល់ព្យុះនេះ មានតម្លៃប្រមាណ ៥៦,៥ លានដុល្លារ។ ចុងក្រោយតំបន់ឆ្នេរនៃប្រទេសកម្ពុជា ដែលមានទីតាំងស្ថិតនៅភាគខាងលិច នៃប្រទេស (ខេត្តកំពត ព្រះសីហនុ និងកោះកុង) ជាកន្លែងដែលមានការដាំដុះដំណាំស្រូវ និងដំណាំដទៃទៀត កំពុងជួបប្រទះនឹងការកើនឡើងនូវកម្រិតជាតិប្រៃក្នុងដី ដែលនាំឱ្យមានការថយចុះនៃការស្រូបយកជាតិទឹក (ស្រដៀងគ្នានឹងផលប៉ះពាល់នៃគ្រោះរាំងស្ងួតផងដែរ)។ លើសពីនេះ ការកើនឡើងនៃកម្ពស់ទឹកសមុទ្រ ដោយសារការប្រែប្រួលអាកាសធាតុ មានន័យថា ផ្ទៃដីដាំដំណាំស្រូវនៅតំបន់ឆ្នេរ នឹងមានការជ្រាបចូលនូវទឹកសមុទ្រ ដែលក៏នឹងបង្កផលប៉ះពាល់ដល់ការដាំដុះដំណាំផ្សេងទៀតផងដែរ។

70. ស្ត្រីក្នុងវិស័យកសិកម្ម៖ ដូចដែលត្រូវបានរាយការណ៍ក្នុងជំរឿនឆ្នាំ ២០១៥ ការងារកសិកម្ម គឺជាប្រភពការងារដ៏សំខាន់ សម្រាប់បុរស និងស្ត្រីជាច្រើននាក់ (ស្ត្រី ៧៥%) ដែលកំពុងប្រឡូកក្នុងការដាំដុះជាលក្ខណៈគ្រួសារសម្រាប់ហូបចុក។ ស្ត្រីខ្មែរដែលរស់នៅតាមជនបទភាគច្រើន ធ្វើការងារកសិកម្មលើដីខ្លួនឯង ឬធ្វើការងារកសិកម្មដោយពុំទទួលបានប្រាក់ឈ្នួល។ ក្នុងប្រទេសកម្ពុជា ប្រជាពលរដ្ឋដែលប្រកបរបបកសិកម្មមាន ២,៣ លានគ្រួសារ ក្នុងនោះ ៨០% (១.៦១៨.៥៨៨) មានបុរសជា

មេគ្រួសារ និង ២០% មានស្ត្រីជាមេគ្រួសារ (៤១២.៥១០)។ កសិករជាស្ត្រីបំពេញតួនាទីយ៉ាងសំខាន់នៅក្នុងការបំប្លែងកសិផល ជាការធានាសន្តិសុខស្បៀង អាហារូបត្ថម្ភសម្រាប់គ្រួសាររបស់ពួកគេ។ ស្ត្រីជាអ្នកទទួលខុសត្រូវលើការងារផលិតស្បៀង ការជ្រើសរើស និងការរៀបចំចំណីអាហារ ក៏ដូចជាការថែទាំ និងផ្តល់អាហារដល់កុមារ។ ដូច្នេះពួកគេមានតួនាទីយ៉ាងសំខាន់ ក្នុងការធានាសន្តិសុខស្បៀងដល់គ្រួសាររបស់ពួកគេ។ ស្ត្រីក៏កាន់តែចូលរួមក្នុងផលិតកម្មកសិកម្មសម្រាប់ធ្វើពាណិជ្ជកម្មផងដែរ ជាពិសេសនៅក្នុងសង្វាក់តម្លៃសាកវប្បកម្ម។ ស្ត្រីនៅក្នុងប្រទេសកម្ពុជាក៏បំពេញតួនាទីសំខាន់នៅក្នុងផ្សារលក់ដុំ និងលក់រាយកសិផលផងដែរ។ ស្ត្រីទាំងនេះ បំពេញតួនាទីជាអ្នកដើរប្រមូលទិញ និង/ឬឈ្មួញ ហើយក៏ជាអ្នកលក់រាយដ៏សំខាន់ផងដែរ ដោយពួកគេធ្វើការងារនៅតាមផ្សារមូលដ្ឋាន ផ្សារខេត្ត និងផ្សារនៅថ្នាក់ជាតិ។ លើសពីនេះ ស្ត្រីក៏ជាដៃគូសំខាន់ក្នុងសហគ្រាសកសិកម្ម ដែលជាសហគ្រាសផ្គត់ផ្គង់ធនធានកសិកម្ម ដោយពួកគេជាអ្នកធ្វើការងារដោយផ្ទាល់ជាមួយនឹងអតិថិជន ផ្តល់ព័ត៌មាន និងចំណេះដឹងអំពីការប្រើប្រាស់ធនធានកិសកម្ម ដីគីមី និងថ្នាំពុលកសិកម្មជាដើម។

71. ការពិនិត្យលើឯកសារពាក់ព័ន្ធ និងការសម្ភាសដែលត្រូវបានធ្វើឡើងកន្លង បានបញ្ជាក់ថាឧបសគ្គផ្អែកតាមយេនឌ័រ ដែលធ្វើឱ្យរាំងស្ទះដល់ការចុះបញ្ជីដីធ្លី រួមមានៈ បញ្ហាក្នុងការទទួលបានព័ត៌មានអំពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ការលំបាកដែលគ្រួសារដែលមានស្ត្រីជាមេគ្រួសារជួបប្រទះក្នុងការទទួលបានឯកសារ ដើម្បីបញ្ជាក់ពីភាពនៅលីវរបស់ពួកគេ ជាកត្តារាំងស្ទះដល់លទ្ធភាពរបស់ពួកគេក្នុងចុះបញ្ជីដីធ្លី អតុល្យភាពយេនឌ័រក្នុងការគ្រប់គ្រង និងធ្វើសេចក្តីសម្រេចចិត្ត។ ជំរឿនឆ្នាំ ២០១៥ បានរកឃើញថា ក្នុងចំណោមគ្រួសារ ដែលប្រកបរបរកសិកម្មសរុបនៅកម្ពុជា មានប្រមាណ ៨៥% មានដីកសិកម្មប្រើប្រាស់ ដោយជាមធ្យមគ្រួសារប្រកបរបរកសិកម្មមួយមានផ្ទៃដីជាមធ្យម ១.៦៣៧ ហិចតា។ បុរសមានចំនួន ១,៤ លាននាក់ ឬ ៧៣% នៃអ្នកមានប័ណ្ណកម្មសិទ្ធិទាំងអស់ ខណៈពេលដែលស្ត្រីដែលមាមានប័ណ្ណកម្មសិទ្ធិមាន ០,៥ លាននាក់ ឬស្មើនឹង ២៧%។

72. ជំរឿនកសិកម្មក៏បានរកឃើញផងដែរថា កសិករជាស្ត្រីបំពេញតួនាទីកាន់តែសំខាន់នៅក្នុងការផ្គត់ផ្គង់កសិផលបែបប្រពៃណី ដែលមានតម្លៃខ្ពស់ដល់ទីផ្សារក្នុងស្រុក។ ទោះជាយ៉ាងណាក៏ដោយ បើធៀបជាមួយនឹងបុរស ស្ត្រីនៅជួបប្រទះនឹងការចាញ់ប្រៀបជាច្រើន ដូចជាលទ្ធភាពផ្លាស់ទីមានកម្រិតទាបជាង កម្រិតអក្ខរកម្មទាបជាង លទ្ធភាពតិចជាងក្នុងការទទួលបានការបណ្តុះបណ្តាល លទ្ធភាពតិចជាងក្នុងទទួលបានព័ត៌មានទីផ្សារ និងលទ្ធភាពតិចជាងក្នុងទទួលបានធនធានផលិតកម្មនានា។ ចំណេះដឹងហិរញ្ញវត្ថុទាបរបស់ស្ត្រី បើធៀបនឹងបុរស និងឧបសគ្គពាក់ព័ន្ធនឹងសុវត្ថិភាពក្នុងការធ្វើដំណើរ ត្រូវបានចាត់ទុកថាជាគម្លាតយេនឌ័រដ៏ធំមួយនៅកម្ពុជា ដើម្បីឱ្យស្ត្រីទទួលបានទីផ្សារ។ ភស្តុតាងនានាក៏បង្ហាញផងដែរថាបុរសអាចប្រឡូកក្នុងការងារផលិតកម្ម និងការផ្សព្វផ្សាយទីផ្សារនៅពេលដែលការធ្វើការងារទាំងនេះផ្តល់នូវប្រាក់ចំណេញក្នុងកម្រិតមួយខ្ពស់។ ដើម្បីស្វែងរកទីផ្សារលក់កសិផលរបស់ខ្លួន កសិកជាស្ត្រីនៅកម្ពុជាត្រូវការព័ត៌មានទីផ្សារទាន់ពេលវេលា អាចជឿទុកចិត្តបាន និងងាយស្រួលយល់។ ការផ្តល់កម្ចីនិងឥណទានក៏មានសារៈសំខាន់ផងដែរ ដើម្បីឱ្យស្ត្រី ដែលប្រកបកសិកម្មខ្នាតតូច អាចមានលទ្ធភាពទិញធនធានកសិកម្មផ្សេងៗ កែលម្អរបៀបដាំដុះ និងអភិវឌ្ឍន៍សហគ្រាសកសិកម្មខ្នាតតូចរបស់ពួកគេ ដើម្បីផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ពួកគេខ្លួនឯង ព្រមទាំងទ្រទ្រង់ជីវភាពគ្រួសាររបស់ពួកគេ។ ការធ្វើសកម្មភាពរួមគ្នា អាចបំពេញតួនាទីសំខាន់ ដើម្បីឱ្យស្ត្រីដែលប្រកបរបរកសិកម្មខ្នាតតូចអាចបង្កើនផលិតភាព និងទទួលបានទីផ្សារ។ លើសពីនេះ គំនិតផ្តួចផ្តើមដើម្បីបង្កលក្ខណៈងាយស្រួលដល់ការទទួលបានទីផ្សារ ក៏ចាំបាច់ត្រូវគិតគូរពិចារណា និងឆ្លើយតបចំពោះឧបសគ្គពាក់ព័ន្ធនឹងយេនឌ័រ ដែលកសិករខ្នាតតូច និងសហគ្រិនកសិកម្មជាស្ត្រីជួបប្រទះផងដែរ។ ដូច្នេះ ការពង្រឹងលទ្ធភាពទទួលបានទីផ្សាររបស់ពួកគេតម្រូវឱ្យមានការវិភាគលើសង្វាក់តម្លៃ និងអន្តរាគមន៍ផ្តោតចំគោលដៅ។

73. ជាលក្ខណៈប្រពៃណី ដំណាក់កាលដំបូងៗនៃការបង្កបង្កើនផលស្រូវ គឺជាការងារដែលបុរសត្រូវធ្វើ ហើយដំណាក់កាលក្រោយៗ គឺជាការងារដែលស្ត្រីត្រូវធ្វើ។ ជាទូទៅបុរសបំពេញការងាររៀបចំដី

ខណៈពេលដែលការងារស្ទូង និងសម្អាតស្មៅ ច្រើនតែជាការងារដែលប្រគល់ឱ្យស្ត្រីជាអ្នកធ្វើ។ សកម្មភាពផ្សេងទៀត ដូចជា ការប្រមូលផល ការច្រូត ស្ទូង និងការរកទីផ្សារលក់កសិផល ជាទូទៅ គឺជាការងារដែលធ្វើរួមគ្នា។ បច្ចុប្បន្នតួនាទីទាំងនេះ មានការប្រែប្រួលជាមួយនឹងការប្រើប្រាស់គ្រឿងយន្តកសិកម្ម និងការធ្វើចំណាកស្រុកយុវជន ចេញពីតំបន់ជនបទ។ ដូច្នេះស្ត្រីកាន់តែប្រឡូកខ្លាំងជាងមុន ក្នុងគ្រប់ការងារដាំដុះទាំងអស់ ដូចជា ការរៀបចំដី ធារាសាស្ត្រ ការបោកស្រូវ និងការជ្រើសរើសកម្មករ ការគ្រប់គ្រងកសិដ្ឋាន និងការជួញដូរជាដើម។ ការរួមចំណែករបស់កសិករជាស្ត្រីចំពោះការដាំដុះដំណាំបន្ទាប់បន្សំ ដូចជា បន្លែ និងការចិញ្ចឹមសត្វពាហនៈ មានវិសាលភាពរីតតែធំផងដែរ។ ដំណាំដែលដាំដុះនៅក្នុងច្បារដំណាំក្នុងបរិវេណផ្ទះ និងសត្វពាហនៈទាំងនេះ ផ្តល់នូវសារជាតុចិញ្ចឹមដ៏សំខាន់ និងរួមចំណែកដល់ការធានាសន្តិសុខស្បៀងរបស់គ្រួសារ។ ដូច្នេះទីផ្សារនៅមូលដ្ឋាន ផ្តល់ឱកាសកាន់តែល្អ ដើម្បីឱ្យស្ត្រីអាចរកប្រាក់ចំណូល តាមរយៈការលក់បន្លែ ដំណាំ និងសត្វពាហនៈជាទ្រង់ទ្រាយតូច។

74. ជនជាតិដើមភាគតិចក្នុងវិស័យកសិកម្ម។ បើតាមក្រសួងអភិវឌ្ឍន៍ជនបទ លក្ខណៈពិសេសជាងគេមួយ របស់សហគមន៍ជនជាតិដើមភាគតិច គឺយុទ្ធសាស្ត្រចិញ្ចឹមជីវិតរបស់ពួកគេ ដោយប្រើប្រាស់ផលិតកម្មកសិកម្មជាគោល ដូចជា ការដាំដុះពនេចរ ការដាំដុះស្រូវលិចទឹក ការចិញ្ចឹមជ្រូក និងមាន់ ការប្រមូលអនុផលព្រៃឈើធ្វើជាអាហារ ការបរបាញ់ និងការនេសាទ។ ពួកគេក៏ផលិត និងលក់ទំនិញ និងកម្លាំងពលកម្មតិចតួចផងដែរ។ កសិករជាជនជាតិដើមភាគតិច ភាគច្រើននៅប៉ែកឦសាននៃប្រទេសកម្ពុជា នៅបន្តប្រើប្រាស់បច្ចេកទេសដាំដុះបែបប្រពៃណីៈ ការដាំដុះពាក់កណ្តាលពនេចរ ការដាំដុះបែបពនេចរ។ បើទោះបីជាពួកគេមួយចំនួនចាប់ផ្តើមបង្កបង្កើនផលស្រូវនៅតំបន់វាលទំនាប បន្ទាប់ពីដំណើរការនៃការធ្វើសមាហរណកម្មក្នុងទសវត្សរ៍ ៦០ យ៉ាងណាក៏ដោយ ពួកគេនៅបន្តរក្សាវាលសម្រាប់ការធ្វើកសិកម្មពនេចរផងដែរ ដែលនៅតាមទីកន្លែងទាំងនេះ ពួកគេដាំដុះស្រូវតំបន់ខ្ពង់រាប និងដំណាំដទៃទៀត សម្រាប់ធានាសន្តិសុខស្បៀងរបស់ពួកគេ។ មានដំណាំតិចតួចតែប៉ុណ្ណោះ ដែលដាំនៅក្នុងភូមិ ដោយសារតែពួកគេពិបាកការពារពីសត្វស្រុក ដែលជាធម្មតាត្រូវបានគេចិញ្ចឹមឱ្យដើររកចំណីស៊ីពាសវាលពាសកាល។ ដំណាំស្រូវគឺជាដំណាំហូបចុកដ៏សំខាន់នៅក្នុងប្រព័ន្ធដាំដុះពនេចរ ប៉ុន្តែដំណាំផ្សេងទៀត ក៏ត្រូវបានដាំសម្រាប់ហូបចុកក្នុងគ្រួសារផងដែរ ដូចជា បន្លែ ដំណាំមើម ពពួកត្រឡាច ល្ពៅ ននោង ផ្លែឈើ និងដំណាំមិនប្រើប្រាស់ជាអាហារផ្សេងទៀត ដូចជា ថ្នាំជក់ និងកប្បាសជាដើម។ ការចិញ្ចឹមសត្វ ជាពិសេសគោលក្របី ជ្រូក និងមាន់ ធ្វើឡើងសម្រាប់បូជា លក់ដើម្បីបានចំណូល ឬសម្រាប់ធ្វើជាអាហារ។

75. ក្នុងសម័យខ្មែរក្រហម ជនជាតិដើមភាគតិចដឹងថា បច្ចេកទេសដាំដុះស្រូវតំបន់វាលទំនាប ដែលធ្វើឡើងដោយជនជាតិខ្មែរមកពីតំបន់វាលទំនាប ដែលជាអ្នកជិតខាងរបស់ខ្លួន ផ្តល់នូវទិន្នផលខ្ពស់ជាង និងត្រូវការពលកម្មតិចជាងបច្ចេកទេស ដែលប្រើប្រាស់នៅតំបន់ខ្ពង់រាបរបស់ពួកគេ។ អ្នកភូមិមួយចំនួនបាន និងកំពុងបង្កើតវាលស្រែតំបន់វាលទំនាប ដោយមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល ឬតាមរយៈការធ្វើត្រាប់តាមប្រជាពលរដ្ឋផ្សេងទៀត។ ក្រោយឆ្នាំ ១៩៧៩ ជនជាតិដើមភាគតិចមួយចំនួន បានទម្លាប់កសិកម្មពនេចររបស់ពួកគេវិញ ដោយសារតែបញ្ហាបច្ចេកទេស ឬបញ្ហាផ្សេងទៀត។ សហគមន៍ជនជាតិដើមភាគតិចក៏បាននឹងកំពុងរិះរកជម្រើសចិញ្ចឹមជីវិតផ្សេងទៀតផងដែរ ដូចជា ដាំដើមឈើហូបផ្លែ និងដំណាំអាចលក់ប្តូរជាសាច់ប្រាក់ និងដែលកំពុងមានតម្រូវការខ្ពស់ ដូចជា កាហ្វេ គ្រាប់ស្វាយចន្ទី សណ្តែកខៀវ ខ្ទុរ និងធុរេនជាដើម។ ទោះជាយ៉ាងណាក៏ដោយ ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធដែលនៅមិនទាន់មានភាពល្អប្រសើរ និងការគាំទ្រទីផ្សារតិចតួច បានបន្ទុចបង្អាក់ដល់ទឹកចិត្តដាំដុះដំណាំទាំងនេះរបស់ពួកគេ។

76. ការចុះប្រមូលព័ត៌មាននៅក្នុងខេត្តសក្តានុពលទាំងនេះ បានរកឃើញថា ការទទួលបានទឹក គឺជាបញ្ហាធំមួយ ដែលកសិករកំពុងជួបប្រទះ ទាំងសហគមន៍មូលដ្ឋាន ទាំងជនជាតិដើមភាគតិច។ បញ្ហាប្រឈមដទៃទៀត ដែលត្រូវបានកំណត់ដោយតំណាងជនជាតិដើមភាគតិច ដែលត្រូវបានសម្ភាស រួមមានៈ

ក. បច្ចេកវិទ្យាកសិកម្មបែបប្រពលវប្បកម្ម កំពុង

ចូលមកជំនួសទម្លាប់ធ្វើកសិកម្មបែបប្រពៃណីរបស់ជនជាតិដើមភាគតិច។ លើសពីនេះក៏មានការប្រែប្រួលយ៉ាងឆាប់រហ័ស ពីការកាន់កាប់អចលនទ្រព្យជាសមូហភាពទៅជាកម្មសិទ្ធិដីឯកជន ក្រោមឥទ្ធិពលរបស់ក្រុមហ៊ុនឯកជន និងបុគ្គលដែលមានឥទ្ធពល។ បញ្ហានេះក៏កើតឡើងដោយសារតែជនជាតិដើមភាគតិចពុំបានចូលរួមក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្តទាំងនេះ។ សហគមន៍ពួកគេពុំបានដឹងពីសិទ្ធិរបស់ពួកគេ ដូចដែលបានលើកឡើងក្នុងច្បាប់របស់ប្រទេសកម្ពុជា និងអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ។

ខ. ពាក់ព័ន្ធនឹងសង្វាក់តម្លៃកសិកម្មវិញ កង្វះការយល់ដឹងអំពីទីផ្សារ និងតម្លៃកសិផល (ឧទាហរណ៍ ជាធម្មតាស្រូវមានតម្លៃ ១.២០០ រៀល ក្នុងមួយគីឡូក្រាម ប៉ុន្តែជារឿយៗជនជាតិដើមភាគតិចលក់ស្រូវក្នុងតម្លៃ ៧០០ រៀល ក្នុងមួយគីឡូក្រាម) ការបំពេញទៅតាមតម្រូវការទីផ្សារពាក់ព័ន្ធនឹងកសិផល (ឧទាហរណ៍ មិនត្រូវទំហំ ពណ៌។ល។) និងការផ្ដល់តម្លៃទាបសម្រាប់កសិផល កម្រិតនៃការចេះអក្សរ (ជនជាតិដើមភាគតិច ភាគច្រើនមិនចេះអក្សរ ដូច្នេះពុំអាចទទួលបានព័ត៌មានទីផ្សារបាន – លើកស្នើនូវដំណោះស្រាយ ប្រើប្រាស់វិទ្យុ) ការពុំមានសមត្ថភាពរៀបចំផែនការ។

គ. មានការលើកឡើងជាច្រើនលើកជាច្រើនសាថា បំណុលគឺជាការគំរាមកំហែងដ៏ធំមួយសម្រាប់ជនជាតិដើមភាគតិចទូទាំងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។ បំណុលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានការប្រាក់ ៣% ក្នុងមួយខែ ពោលគឺច្រើនជាងការប្រាក់ស្តង់ដារ ១,៨% ក្នុងមួយខែ។ ជារឿយៗ ជនជាតិដើមភាគតិចពុំបានដឹងពីបញ្ហានេះឡើយ ដោយសារតែពួកគេពុំអាចអានកិច្ចសន្យាបាន (ពុំចេះអក្សរ) ពួកគេគិតថា ៣% គឺជាអត្រាការប្រាក់ទាប។ ជនជាតិដើមភាគតិចមួយចំនួនខ្ចីពីអ្នកចងការប្រាក់ ជាមួយនឹងអត្រាការប្រាក់រហូតដល់ ១៥ ទៅ ២០% ក្នុងមួយខែ។ ជារឿយៗពួកគេសងកម្ចីទៅអ្នកចងការប្រាក់ទាំងនេះជាមួយនឹងការផ្ដល់នូវកសិផលរបស់ពួកគេ ទៅតាមតម្លៃដែលកំណត់ដោយឈ្មួញកណ្ដាល ឬដោយផ្ដល់ដីសងជំនួសវិញ ដែលធ្វើឱ្យពួកគេកាន់តែត្រូវផ្លាស់ទីឆ្ងាយចូលទៅក្នុងតំបន់ព្រៃ។

## 5.0 នីតិវិធីសម្រាប់ពិនិត្យបឋម ពិនិត្យឡើងវិញ ផ្ដល់ការអនុញ្ញាត និងអនុវត្តឧបករណ៍ការពារផលប៉ះពាល់សម្រាប់អនុគម្រោង

77. ដោយប្រើប្រាស់ជំហានសំខាន់ៗដែលបង្ហាញខាងក្រោមផ្នែកនៃ ESMF នេះ រៀបរាប់ពីដំណើរការដើម្បីធានាឱ្យមានការផ្ដល់ការយកចិត្តទុកដាក់ឱ្យបានគ្រប់ជ្រុងជ្រោយលើក្ដីបារម្ភផ្នែកបរិស្ថាន និងសង្គម តាមរយៈការរៀបចំស្ថាប័ន និងនីតិវិធី ដែលប្រើប្រាស់ដោយគម្រោងសម្រាប់គ្រប់គ្រងការកំណត់អត្តសញ្ញាណ ការរៀបចំ ការឯកភាព និងការអនុវត្តអនុគម្រោង។ នីតិវិធី ESMF ត្រូវបានផ្សារភ្ជាប់ទំនាក់ទំនងយ៉ាងច្បាស់ជាមួយនឹងវដ្តអនុគម្រោងដែលត្រូវបានកំណត់ក្នុងគម្រោង ហើយដែលអាចបញ្ចូលទៅក្នុង *សៀវភៅណែនាំស្ដីពីប្រតិបត្តិគម្រោង ឬសៀវភៅណែនាំស្ដីពីការអនុវត្តគម្រោង*។

78. ផ្នែកនៃ ESMF នេះ អាចបែងចែកជាផ្នែកតូចៗ ដូចខាងក្រោម៖ i) ការពិនិត្យបឋមលើការការពារផលប៉ះពាល់ និងការវាយតម្លៃផលប៉ះពាល់, ii) ការរៀបចំវិធានការសម្រាលផលប៉ះពាល់ និងកិច្ចពិគ្រោះយោបល់សាធារណៈ, iii) ការពិនិត្យឡើងវិញ, ការឯកភាព និងការបង្ហាញពីឧបករណ៍ការពារផលប៉ះពាល់របស់អនុគម្រោង និង iv) ការអនុវត្ត ការពិនិត្យ ការគ្រប់គ្រង និងការរៀបចំរបាយការណ៍។

79. ការរៀបចំអនុគម្រោងក្នុងអំឡុងពេលអនុវត្តគម្រោង មាន ៤ ជំហានសំខាន់ៗ ដែលផ្ដោតលើការពិនិត្យជាបឋមលើការការពារផលប៉ះពាល់ និងការវាយតម្លៃផលប៉ះពាល់។ ការពិនិត្យបឋមលើការការពារផលប៉ះពាល់ មាន ២ ជំហាន នោះគឺ ការពិនិត្យលើការបំពេញលក្ខណៈវិនិច្ឆ័យសមស្រប

និងការពិនិត្យបច្ចេកទេសសម្រាប់វាយតម្លៃលើផលប៉ះពាល់ដែលអាចកើតមានឡើង គោលនយោបាយដែលត្រូវអនុវត្ត និងឧបករណ៍ដែលត្រូវរៀបចំ។

ជំហានទី ១៖ ការពិនិត្យបឋមលើការការពារផលប៉ះពាល់ និងការវាយតម្លៃលើផលប៉ះពាល់

ជំហានទី ២៖ ការរៀបចំឯកសារស្តីពីការការពារផលប៉ះពាល់ ដូចដែលត្រូវបានតម្រូវរួមនិងការរៀបចំវិធានការសម្រាលផលប៉ះពាល់ និងកិច្ចពិគ្រោះយោបល់ជាសាធារណៈ

ជំហានទី ៣៖ ការផ្តល់ការឯកភាពដល់វិធានការការពារផលប៉ះពាល់ និងការបង្ហាញព័ត៌មានជាសាធារណៈ និង

ជំហានទី ៤៖ ការអនុវត្ត ការពិនិត្យតាមដាន និងការរៀបចំរបាយការណ៍។

80. សកម្មភាពការពារផលប៉ះពាល់ ដែលត្រូវអនុវត្តជាចម្បងតាក្នុងអំឡុងដំណើរការ ESMF ត្រូវបានបង្ហាញក្នុងតារាងលំហូររូបភាព ៣-១ ខាងក្រោម៖

*រូបភាព ៣-១ តារាងលំហូរបង្ហាញពីសកម្មភាពការពារផលប៉ះពាល់ សម្រាប់អនុគម្រោង*



ជំហានទី ១. ការពិនិត្យបឋមលើវិធានការការពារផលប៉ះពាល់ និងការវាយតម្លៃលើផលប៉ះពាល់

### *4.1.1 ការពិនិត្យបឋមលើការបំពេញតាមលក្ខណៈវិនិច្ឆ័យសមស្រប*

*81.* ជាធម្មតា គោលការណ៍បញ្ចៀសផលប៉ះពាល់ ត្រូវអនុវត្តចំពោះអនុគម្រោង ដែលអាចនាំឱ្យមានការបាត់បង់ ឬការខូចខាតគួរឱ្យកត់សម្គាល់ដល់ធនធានវប្បធម៌រូបវន្ត ដែលមានសារៈសំខាន់ចំពោះជាតិ ដែនជម្រក ធម្មជាតិសំខាន់ៗ និងព្រៃធម្មជាតិសំខាន់ៗ។ អនុគម្រោងទាំងនេះមិនទំនងជាអាចបំពេញទៅតាមលក្ខណៈវិនិច្ឆ័យសមស្រប ដើម្បីទទួលបានហិរញ្ញប្បទានក្រោមគម្រោងនេះឡើយ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ទទួលខុសត្រូវពិនិត្យបឋមលើការបំពេញលក្ខខណ្ឌវិនិច្ឆ័យសមស្របរបស់អនុគម្រោង នានា។ ទោះជាក្នុងករណីណាក៏ដោយ មិនគួរមានការប្រើប្រាស់ការពិនិត្យបឋមលើការពុំបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យសមស្រប (ineligibility criteria) ឡើយ ដើម្បីបញ្ចៀសការអនុវត្តគោលនយោបាយ។ ការពិនិត្យបឋមលើការពុំអាចបំពេញតាមលក្ខណៈវិនិច្ឆ័យសមស្រប មានគោលបំណងបញ្ចៀសផលប៉ះពាល់អវិជ្ជមានមកលើសង្គម និងបរិស្ថាន ដែលពុំអាចសម្រាលឱ្យបានគ្រប់គ្រាន់ដោយគម្រោង ឬដែលត្រូវបានហាមឃាត់ ដោយគោលនយោបាយរបស់ធនាគារ ឬដោយអនុសញ្ញាអន្តរជាតិនានា។ លក្ខណៈវិនិច្ឆ័យកំណត់ពីភាពមិនសមស្រប ដែលមានការប្រែប្រួលខុសគ្នាពីគម្រោងមួយទៅគម្រោងមួយទៀត អាចមានដូចជាៈ (i) ការហាមប្រាមក្រោមគោលនយោ-បាយរបស់ធនាគារ ឧទាហរណ៍ការរេចរិលគួរឱ្យកត់សម្គាល់ ឬការបំប្លែងដែនជម្រកធម្មជាតិសំខាន់ៗ ព្រៃធម្មជាតិ សំខាន់ៗ ។ល។, (ii) ការអនុវត្តផ្ទុយទៅនឹងកាតព្វកិច្ចរបស់ប្រទេស ក្រោមសន្ធិសញ្ញាបរិស្ថានអន្តរជាតិ ដែលពាក់ព័ន្ធ ឧទាហរណ៍ពិធីសារ Montreal ឬអនុសញ្ញា Stockholm។ល។, (iii) ផលប៉ះពាល់មកលើបរិស្ថាន និងសង្គមមានភាពស្មុគស្មាញ និងអវិជ្ជមានខ្លាំងពេកហួសពីសមត្ថភាពគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs)។ អនុគម្រោងណាមួយដែលស្ថិតក្រោមលក្ខណៈវិនិច្ឆ័យកំណត់ភាពមិនសមស្របណាមួយ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងនេះ នឹងពុំអាចទទួលបានហិរញ្ញប្បទានពីគម្រោងឡើយ។ ការពិនិត្យបឋមនេះត្រូវធ្វើឡើងផ្អែកតាមការវាយតម្លៃលើសមាសភាគរបស់គម្រោង និងភាពងាយរងផលប៉ះពាល់នៅនឹងទីតាំងជាក់ស្តែង។ បញ្ជីបង្ហាញពីសកម្មភាព ដែលពុំបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យសមស្របមានបង្ហាញក្នុង**ឧបសម្ព័ន្ធ ២.១**។

### *4.1.2 បញ្ជីត្រួតពិនិត្យសម្រាប់ពិនិត្យបឋមលើបរិស្ថាន និងសង្គម (ការកំណត់ពីប្រភេទអនុគម្រោង និងលក្ខខណ្ឌតម្រូវក្នុងឧបករណ៍ការពារផលប៉ះពាល់)*

82. ក្រោយពេលដែលអនុគម្រោងត្រូវបានកំណត់ថា បានបំពេញលក្ខណៈវិនិច្ឆ័យសមស្រប ដើម្បីទទួលបានហិរញ្ញប្បទាន នឹងមានការពិនិត្យបឋមលើផលប៉ះពាល់បរិស្ថាន និងសង្គម។ ការពិនិត្យបឋមលើបរិស្ថាន និងសង្គមនេះ មានគោលបំណងៈ (i) កំណត់ពីគោលនយោបាយការពារផលប៉ះពាល់របស់ធនាគារពិភពលោក ដែលត្រូវអនុវត្ត, (ii) បែងចែកអនុគម្រោងជាប្រភេទ B ឬ C ទៅតាមតារាងបង្ហាញពីភាពងាយរងផលប៉ះពាល់នៅតាមទីតាំងគម្រោង ក្នុងតារាងទី ១៩ និងការណែនាំដើម្បីកំណត់ពីកម្រិតនៃផលប៉ះពាល់ ដែលបង្កឡើងដោយសកម្មភាពនានារបស់អនុគម្រោង និង (iii) កំណត់ថាតើចាំបាច់ត្រូវមានការរៀបចំឧបករណ៍ការពារផលប៉ះពាល់ សម្រាប់អនុគម្រោងនេះដែរឬទេ។

83. ការពិនិត្យបឋមនេះ ក៏បង្ហាញដោយសង្ខេបពីលក្ខណៈ និងវិសាលភាពនៃផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានឡើងលើធនធានធម្មជាតិ និងបរិស្ថាន និងប្រជាពលរដ្ឋនៅមូលដ្ឋានពាក់ព័ន្ធនឹងការធ្វើលទ្ធកម្មដីធ្លី ការតាំងទីលំនៅ ការផ្តល់អំណោយដីធ្លី និង/ឬការចូលរួមរបស់ជនជាតិដើមភាគតិច។ សម្រាប់អនុគម្រោងប្រភេទ C ពុំចាំបាច់មានការរៀបចំឧបករណ៍ការពារផលប៉ះពាល់អ្វីឡើយ និងត្រូវមានការបំពេញទម្រង់តារាងទី ៣ ក្នុង**ឧបសម្ព័ន្ធទី ៥** ជាឯកសារភ្ជាប់ជាមួយនឹងសំណើអនុគម្រោងនេះ។ សម្រាប់ប្រភេទអនុគម្រោង ដែលតម្រូវឱ្យមានការធ្វើ IEE អនុគម្រោងនេះ ទំនងជាត្រូវបានចាត់ចំណាត់ថ្នាក់ថា ប្រភេទ B។ ទោះជាយ៉ាងណាក៏ដោយ សកម្មភាពអនុគម្រោង ដែលស្នើឡើងទាំងនេះ ដូចជា ការកែលម្អប្រឡាយស្រោចស្រព ការកែលម្អរោងម៉ាស៊ីនកិនស្រូវ និងឃ្លាំងរក្សាទុកស្រូវ ការកែលម្អទីកន្លែងវេចខ្ចប់បន្លែ និងរបៀបធ្វើកសិកម្មមិនទំនងជាតម្រូវឱ្យធ្វើ IEE ឡើយ។ គេត្រូវប្រើប្រាស់តារាងទី ១ **ឧបសម្ព័ន្ធទី ៥** ដើម្បីពិនិត្យលើប្រភេទ

អនុគម្រោងពាក់ព័ន្ធនឹងការធ្វើកសិកម្ម និងវាយតម្លៃលើគម្រោងនេះ ក៏ដូចជា កំណត់ពីប្រភេទឧបករណ៍ការពារផលប៉ះពាល់ ដែលចាំបាច់ត្រូវរៀបចំ និងអនុវត្តដោយអនុគម្រោង។ ត្រូវប្រើប្រាស់តារាងទី ២ **ឧបសម្ព័ន្ធទី ៥** ដើម្បីពិនិត្យលើប្រភេទគម្រោង សម្រាប់សំណើកែលម្អទីតាំងដែលប្រើប្រាស់ដើម្បីបន្ថែមតម្លៃ ដូចជា រោងម៉ាស៊ីនកិនស្រូវ ឃ្លាំងរក្សាទុក និងទីតាំងវេចខ្ចប់បន្លែជាដើម។

84. បញ្ជីត្រួតពិនិត្យដែលប្រើប្រាស់សម្រាប់ពិនិត្យបរិស្ថាន និងសង្គមសម្រាប់អនុគម្រោងនីមួយៗមានគោលបំណងដើម្បីឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធយកទៅប្រើប្រាស់ដើម្បីអាចកំណត់ពីប្រភេទសមស្របនៃឯកសារការពារផលប៉ះពាល់ ដែលធនាគារពិភពលោកតម្រូវឱ្យមាន សម្រាប់អនុគម្រោងនេះ ស្របតាម ESMF របស់គម្រោង។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ត្រូវបានលើកទឹកចិត្តឱ្យផ្ញើបញ្ជីត្រួតពិនិត្យនេះទៅកាន់ប្រធានក្រុមការងារ (TTL) របស់ធនាគារពិភពលោក ដើម្បីធានាថាធនាគារបានឯកភាពលើលទ្ធផលនៃការពិនិត្យនេះ មុនពេលអតិថិជនជួលទីប្រឹក្សាឱ្យរៀបចំឯកសារស្តីពីការការពារផលប៉ះពាល់។ បញ្ជីត្រួតពិនិត្យដែលត្រូវប្រើប្រាស់សម្រាប់ពិនិត្យបឋមលើអនុគម្រោង ត្រូវបានបង្ហាញក្នុង**ឧបសម្ព័ន្ធ ២.២**។

ជំហានទី ២. ការរៀបចំវិធានការសម្រាលផលប៉ះពាល់ និងកិច្ចពិគ្រោះយោបល់សាធារណៈ

85. ក្រោយពេលដែលការពិនិត្យបឋមលើបរិស្ថាន និងសង្គម ត្រូវបានធ្វើរួច និងមានការវាយតម្លៃផលប៉ះពាល់លម្អិតសម្រាប់អនុគម្រោងប្រភេទ B។ ការវាយតម្លៃផលប៉ះពាល់នេះមានគោលបំណងធ្វើការកំណត់ពីកម្រិតនៃផលប៉ះពាល់ និងប្រភេទនៃឧបករណ៍ការពារផលប៉ះពាល់ ដែលចាំបាច់ត្រូវរៀបចំសម្រាប់អនុគម្រោង (ឧទាហរណ៍ EIA ឬ IEE, ឬ EMP ឬ ECOP)។ ការវាយតម្លៃផលប៉ះពាល់នេះនឹងត្រូវធ្វើឡើងជាធាតុចូល ដើម្បីកំណត់ពីវិសាលភាពនៃវិធានការសម្រាលផលប៉ះពាល់។ ការវាយតម្លៃលើផលប៉ះពាល់ នឹងនាំឱ្យមានការយកចិត្តទុកដាក់លើបញ្ហាបរិស្ថាន និងសង្គមក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត តាមរយៈការវាយតម្លៃយ៉ាងជាក់ច្បាស់ពីផលវិបាកផ្នែកបរិស្ថាន និងសង្គម ដែលបង្កឡើងដោយអនុគម្រោង ដែលស្នើឡើង មុនពេលមានការអនុវត្តសកម្មភាព។ ការកំណត់ និងការបែងចែកប្រភេទផលប៉ះពាល់បរិស្ថាន និងសង្គមសំខាន់ៗពីដំបូងបែបនេះផ្តល់លទ្ធភាពឱ្យសាធារណជនទូទៅ និងរដ្ឋាភិបាលយល់ដឹងពីភាពអាចទទួលយកបានផ្នែកបរិស្ថាន និងសង្គម នៃអនុគម្រោងអភិវឌ្ឍន៍ ដែលត្រូវបានស្នើឡើង និងលក្ខខណ្ឌដែលគួរដាក់ឱ្យអនុវត្តតាមដើម្បីសម្រាល ឬកាត់បន្ថយឱ្យបានជាអតិបរមានូវហានិភ័យ និងផលប៉ះពាល់ទាំងនេះ។ វិសាលភាពនៃការវាយតម្លៃផលប៉ះពាល់មានការប្រែប្រួលទៅតាមលទ្ធផលនៃការពិនិត្យបឋមនេះ។ ការប្រមូលទិន្នន័យ ការចុះអង្កេតដល់មូលដ្ឋាន និងការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន និងប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ ក៏នឹងត្រូវធ្វើឡើងផងដែរ។

86. ក្នុងករណីដែលសកម្មភាពគម្រោងមានវិសាលភាពទាប សកម្មភាពអនុគម្រោងដែលស្នើឡើងនេះមិនទំនងជាត្រូវបានបែងចែកចំណាត់ថ្នាក់ថា ជាប្រភេទ A ដែលតម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះឡើយ។

87. ជំហានសំខាន់ៗសម្រាប់វាយតម្លៃផលប៉ះពាល់ រួមមាន៖ ការរៀបចំផែនការ ការកំណត់វិសាលភាព ការវាយតម្លៃផលប៉ះពាល់ និងកិច្ចពិគ្រោះយោបល់។ ការវាយតម្លៃលើផលប៉ះពាល់ត្រូវកំណត់ឱ្យបានច្បាស់៖ (i) តើសកម្មភាពអនុគម្រោងនឹងនាំឱ្យមានផលប៉ះពាល់ដោយរបៀបណា? (ii) តើផលប៉ះពាល់នេះទំនងជាកើតឡើងក្នុងកម្រិតណា? (iii) តើផលប៉ះពាល់នីមួយៗនឹងនាំឱ្យមានផលវិបាកអ្វីខ្លះ និង (iv) តើផលប៉ះពាល់នីមួយៗនឹងកើតឡើងនៅតំបន់ណាខ្លះ និងក្នុងរយៈពេលយូរកម្រិតណា? ការវាយតម្លៃលើផលប៉ះពាល់ ប្រែប្រួលអាស្រ័យទៅតាមវិសាលភាព និងរយៈពេលនៃការផ្លាស់ប្តូរ ចំនួនមនុស្ស ឬទំហំធនធានដែលរងផលប៉ះពាល់ និងភាពងាយរងផលប៉ះពាល់ដោយសារការផ្លាស់ប្តូររបស់មនុស្ស និងធនធានទាំងនេះ។ ផលប៉ះពាល់ដែលអាចកើតមានឡើង អាចអវិជ្ជមាន និងវិជ្ជមាន (ផ្តល់ផលប្រយោជន៍) ហើយវិធីសាស្ត្រដែលត្រូវបានកំណត់ក្នុងជំហានទី ៣ នឹងត្រូវយកមកអនុវត្តដើម្បីកំណត់ពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានដែលកើតមានឡើង និងដើម្បីលើកស្នើពីវិធានការសម្រាលផលប៉ះពាល់ទាំងនេះ។

88. គួរមានការកំណត់វិធានការសម្រាលផលប៉ះពាល់ (អវិជ្ជមាន) សមស្រប ទៅតាមលក្ខណៈ និងវិសាលភាពនៃផលប៉ះពាល់អវិជ្ជមាន ដែលអាចកើតមានឡើងនៅដំណាក់កាលនីមួយៗនៃអនុគម្រោង ដូចជា មុនពេលសាងសង់ ក្នុងអំឡុងពេលសាងសង់ ក្នុងអំឡុងពេលប្រតិបត្តិការ និងក្នុងអំឡុងពេលរុះរើសំណង់គម្រោង ទៅតាមករណីពាក់ព័ន្ធ។

89. ***លក្ខខណ្ឌតម្រូវរបស់ធនាគារពិភពលោក៖***

- ✓ សម្រាប់គម្រោងប្រភេទ A ចាំបាច់ត្រូវមានការវាយតម្លៃបរិស្ថានពេញលេញ ដែលជាធម្មតាហៅថាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ស្របទៅតាមលក្ខខណ្ឌតម្រូវជាក់លាក់ក្នុងគោលនយោបាយ និងនីតិវិធីវាយតម្លៃបរិស្ថានរបស់ធនាគារពិភពលោក សម្រាប់គម្រោងប្រភេទ A។ ការវាយតម្លៃបរិស្ថានសម្រាប់គម្រោងប្រភេទ A ធ្វើការកំណត់ពីផលប៉ះពាល់អវិជ្ជមាន និងវិជ្ជមានមកលើបរិស្ថាន ដែលអាចបង្កឡើងដោយសារគម្រោង ធ្វើការប្រៀបធៀបផលប៉ះពាល់ទាំងនេះ ជាមួយជម្រើស ដែលអាចមាន (រួមទាំងស្ថានភាព "ពុំមានគម្រោង" ផងដែរ) និងលើកអនុសាសន៍អំពីវិធានការនានា ដែលចាំបាច់ត្រូវមាន ដើម្បីបង្ការ កាត់បន្ថយជាអតិបរមា សម្រាល ឬផ្តល់សំណងដល់ផលប៉ះពាល់អវិជ្ជមាន និងកែលម្អលទ្ធផលផ្នែកបរិស្ថាន។ វិសាលភាពនៃការវាយតម្លៃបរិស្ថាន សម្រាប់គម្រោងប្រភេទ B អាចមានការប្រែប្រួលខុសគ្នាពីគម្រោងមួយទៅគម្រោងមួយទៀត ប៉ុន្តែមានវិសាលភាពតូចជាងការវាយតម្លៃបរិស្ថានសម្រាប់គម្រោងប្រភេទ A។ ដូចគ្នានឹងការវាយតម្លៃបរិស្ថានសម្រាប់គម្រោងប្រភេទ A ដែរ ការវាយតម្លៃនេះ ធ្វើការពិនិត្យលើផលប៉ះពាល់អវិជ្ជមាន និងវិជ្ជមានលើបរិស្ថាន ដែលអាចបង្កឡើងដោយសារគម្រោង និងលើកជាអនុសាសន៍អំពីវិធានការនានា ដែលចាំបាច់ត្រូវមាន ដើម្បីបង្កកាត់បន្ថយជាអតិបរមា សម្រាល ឬផ្តល់សំណងដល់ផលប៉ះពាល់អវិជ្ជមានទាំងនេះ និងកែលម្អលទ្ធផលផ្នែកបរិស្ថាន។ ក្រៅតែពីការពិនិត្យបឋម ពុំចាំបាច់មានការវាយតម្លៃបរិស្ថានបន្ថែមទៀត សម្រាប់គម្រោងប្រភេទ C ឡើយ។
- ✓ ***ផែនការគ្រប់គ្រងបរិស្ថាន (EMP)៖*** ផែនការគ្រប់គ្រងបរិស្ថានរបស់គម្រោងមួយ រួមមានវិធានការពិនិត្យតាមដាន និងវិធានការស្ថាប័ន ដែលត្រូវអនុវត្តក្នុងអំឡុងពេលអនុវត្ត និងប្រតិបត្តិការរបស់គម្រោង ដើម្បីលុបបំបាត់ផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងសង្គម កាត់កងផលប៉ះពាល់ទាំងនេះ និងកាត់បន្ថយផលប៉ះពាល់ទាំងនេះឱ្យនៅត្រឹមកម្រិតអាចទទួលយកបាន។ ផែនការនេះក៏បញ្ចូលសកម្មភាព ដែលចាំបាច់ត្រូវធ្វើ ដើម្បីអនុវត្តវិធានការទាំងនេះផងដែរ។ EMPs គឺជាសមាសភាគដ៏សំខាន់នៃរបាយការណ៍វាយតម្លៃបរិស្ថានសម្រាប់គម្រោងប្រភេទ A។ សម្រាប់គម្រោងប្រភេទ B ជាច្រើន ការវាយតម្លៃបរិស្ថានអាចនាំឱ្យមានត្រឹមតែការរៀបចំផែនការគ្រប់គ្រងតែប៉ុណ្ណោះ។ ដើម្បីរៀបចំផែនការគ្រប់គ្រង អ្នកខ្ចី និងក្រុមការងាររៀបចំការវាយតម្លៃបរិស្ថាន (ក) កំណត់ពីការឆ្លើយតបចំពោះផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានឡើង, (ខ) កំណត់ពីលក្ខខណ្ឌតម្រូវ ដើម្បីធានាឱ្យមានការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា និង (គ) រៀបរាប់ពីមធ្យោបាយ ដើម្បីបំពេញទៅតាមលក្ខខណ្ឌតម្រូវទាំងនេះ។

90. ***ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន (EMP) និងកិច្ចពិគ្រោះយោបល់ជាសាធារណៈ៖*** ផែនការគ្រប់គ្រងបរិស្ថាន ពិពណ៌នាពីគោលការណ៍ទូទៅ និងសកម្មភាពដែលត្រូវធ្វើ ដើម្បីសម្រាលផលប៉ះពាល់អវិជ្ជមាន ដែលអាចកើតមានឡើង។ EMP ត្រូវរៀបរាប់ដោយសង្ខេបពីអនុគម្រោង សារគារបរិស្ថាន និងសង្គមរបស់តំបន់អនុគម្រោង រួមនឹងផែនទីបង្ហាញពីទីតាំងអនុគម្រោង និងសកម្មភាពតាមទីតាំងគម្រោង និង/ឬដំណើរការទៅតាមការសមស្រប, ផលប៉ះពាល់ដែលអាចកើតមានឡើង និងវិធានការសម្រាលផលប៉ះពាល់ ដែលត្រូវបានស្នើឡើង ព្រមទាំងការរៀបចំការអនុវត្ត និងការពិនិត្យតាមដាន និងថវិកា។ មាតិកាទូទៅនៃផែនការគ្រប់គ្រងបរិស្ថាន ត្រូវបានបង្ហាញក្នុងឧបសម្ព័ន្ធ គ នៃ OP 4.01 និងត្រូវបានបង្ហាញក្នុងឧបសម្ព័ន្ធទី ៤ ផងដែរ។ កិច្ចពិគ្រោះយោបល់ជាសាធារណៈ ត្រូវធ្វើឡើងជាផ្នែកមួយនៃការរៀបចំផែនការគ្រប់គ្រងបរិស្ថាន។ សម្រាប់អនុគម្រោងនីមួយៗ ផែនការគ្រប់គ្រងបរិស្ថាន ត្រូវកំណត់ឱ្យបានច្បាស់លាស់ពីសកម្មភាព ដើម្បីវាយតម្លៃ

និងសម្រាលហានិភ័យដែលពាក់ព័ន្ធទាំងសម្រាលផលប៉ះពាល់ដែលអាចកើតមានឡើង ក្នុងអំឡុងពេលផ្តល់ការឯកភាពដល់ទីតាំងអនុគម្រោង និងអំឡុងពេលសាងសង់ និងកាត់បន្ថយហានិភ័យក្នុងអំឡុងពេលប្រតិបត្តិការ។ EMP ត្រូវបញ្ចូលយ៉ាងហោចណាស់នូវ ECOP ដែលមានលក្ខណៈស្តង់ដារ (ឧបសម្ព័ន្ធទី ៥) និងវិធានការសម្រាលផលប៉ះពាល់តាមទីតាំង រួមនឹងកម្មវិធីពិនិត្យតាមដានបរិស្ថានផងដែរ។ គោលការណ៍ណែនាំបច្ចេកទេស សម្រាប់រៀបចំ និងឧទាហរណ៍ដែលបង្ហាញពីផែនការគ្រប់គ្រងបរិស្ថាន មានបង្ហាញជូនក្នុងឧបសម្ព័ន្ធទី ៤។

ជំហានទី ៣៖ ការពិនិត្យឡើងវិញ, ការឯកភាព, ការពិគ្រោះយោបល់ជាសាធារណៈ និងការបង្ហាញឧបករណ៍ការពារផលប៉ះពាល់របស់អនុគម្រោងជាសាធារណៈ

91. ***ការពិនិត្យឡើងវិញ និងការឯកភាពលើឧបករណ៍ការពារផលប៉ះពាល់***

92. *ការពិនិត្យឡើងវិញ និងការឯកភាពរបស់រដ្ឋាភិបាល៖* ប្រសិនបើអនុគម្រោងតម្រូវឱ្យមានការពិនិត្យឡើងវិញ និងការឯកភាពទៅតាមអនុក្រឹត្យ និងគោលការណ៍ណែនាំស្តីពីវាយតម្លៃបរិស្ថានរបស់រដ្ឋាភិបាល នោះម្ចាស់ អនុគ្រោងត្រូវរៀបចំ និងផ្ញើរបាយការណ៍ស្តីពីការវាយតម្លៃបរិស្ថានទៅតាមលក្ខខណ្ឌតម្រូវទៅកាន់អាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធពិនិត្យ និងឯកភាព មុនពេលមានការវាយតម្លៃអនុគម្រោង។

93. *ការពិនិត្យ និងការឯកភាពរបស់ធនាគារ៖* នីតិវិធីដើម្បីឱ្យធនាគារ ពិនិត្យ និងឯកភាពលើការការពារផលប៉ះពាល់របស់អនុគម្រោង ដែលត្រូវបានរៀបចំឡើងក្នុងអំឡុងពេលអនុវត្ត ក៏ត្រូវរៀបរាប់ឱ្យបានច្បាស់លាស់បញ្ចូលទៅ ESMF។ នីតិវិធីទាំងនេះអាចមានការប្រែប្រួលពីគម្រោងមួយទៅគម្រោងមួយទៀត អាស្រ័យទៅតាមសមត្ថភាពរបស់អតិថិជន និងភាពស្មុគស្មាញនៃបញ្ហាដែលពាក់ព័ន្ធក្នុងអនុគម្រោង។ ទីប្រឹក្សា ESMF និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) គួរពិគ្រោះយោបល់ជាមួយអ្នកឯកទេសផ្នែកបរិស្ថានរបស់ធនាគារអំពីដំណើរការទាំងនេះ។ នីតិវិធីទាំងនេះត្រូវគ្របដណ្តប់លើ៖ (ក) ការពិនិត្យបឋមលើអនុគម្រោងដើម្បីកំណត់ពីផលប៉ះពាល់សង្គម និងបរិស្ថាន ដែលអាចបង្កឡើងដោយសារអនុគម្រោងទាំងនោះ, (ខ) ការបែងចែកចំណាត់ថ្នាក់បរិស្ថានសម្រាប់អនុគម្រោងនីមួយៗ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យដែលលើកឡើងក្នុង OP ៤.០១, (គ) ការរៀបចំឧបករណ៍ការពារផលប៉ះពាល់ពាក់ព័ន្ធទៅតាមគោលនយោបាយរបស់ធនាគារ និងច្បាប់ជាតិ, (ឃ) ការរៀបចំការអនុវត្ត និងសមត្ថភាពស្ថាប័ន ដែលចាំបាច់ត្រូវមានដើម្បីអនុវត្តឧបករណ៍ការពារផលប៉ះពាល់ និង (ង) តួនាទីរបស់អតិថិជន និងធនាគារ ក្នុងការពិនិត្យ និងផ្តល់ការឯកភាពដល់ឧបករណ៍ការពារផលប៉ះពាល់។

94. *កិច្ចពិគ្រោះយោបល់សាធារណៈ៖*

95. ការរៀបចំ និងការអនុវត្តឯកសារការពារផលប៉ះពាល់របស់អនុគម្រោងក្នុងអំឡុងពេលនៃការរៀបចំគម្រោងចាំបាច់ត្រូវអនុវត្តទៅតាមលក្ខខណ្ឌរបស់ធនាគារ ដែលតម្រូវឱ្យមានការរៀបចំកិច្ចពិគ្រោះយោបល់ជាសាធារណៈក្រោម OP ៤.០១។ កិច្ចពិគ្រោះយោបល់នេះមានគោលបំណងបង្កើនការយល់ដឹងជាសាធារណៈតាមរយៈការផ្តល់ព័ត៌មានអំពីអនុគម្រោងដល់គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ជាពិសេសជនដែលរងផលប៉ះពាល់ដោយសារអនុគម្រោងឱ្យបានទាន់ពេលវេលា និងផ្តល់ឱកាសឱ្យតួអង្គពាក់ព័ន្ធបញ្ចេញគំនិតយោបល់ និងលើកឡើងពីការព្រួយបារម្ភរបស់ពួកគេអំពីទិដ្ឋភាពផ្សេងៗនៃគម្រោង។ កិច្ចពិគ្រោះយោបល់បែបនេះ អាចជួយបង្កលក្ខណៈងាយស្រួល និងសម្រួលដល់ការធ្វើសេចក្តីសម្រេចចិត្ត ហើយក្នុងពេលជាមួយគ្នាអាចបង្កើននូវបរិយាកាសយោគយល់គ្នា ក្នុងចំណោមបុគ្គល ក្រុម និងអង្គការស្ថាប័ន ដែលអាចបង្កផលប៉ះពាល់ ឬទទួលរងផលប៉ះពាល់ ដោយសារអនុគម្រោង។

96. កិច្ចពិគ្រោះយោបល់ គឺជាដំណើរការដែលត្រូវបន្តអនុវត្តជាប្រចាំ ដើម្បីស្វែងយល់ពីការយល់ឃើញរបស់សាធារណជនអំពីបញ្ហាដែលបង្កផលប៉ះពាល់ដល់ពួកគេ។ គំនិតយោបល់ និងសំណូមពររបស់តួអង្គពាក់ព័ន្ធ និងជួយ PAFO

ធ្វើសេចក្តីសម្រេចចិត្តឱ្យបានសមស្របដើម្បីឱ្យការគ្រប់គ្រងបរិស្ថាន និងសង្គម របស់អនុគម្រោងអាចធ្វើទៅបានប្រកបដោយប្រសិទ្ធភាព។ កិច្ចពិគ្រោះយោបល់នឹងជួយបង្កលក្ខណៈងាយសម្រួល និងសម្រួលដល់ការធ្វើសេចក្តីសម្រេចចិត្ត ហើយក្នុងពេលជាមួយគ្នាអាចលើកកម្ពស់បរិយាកាសយោគយល់គ្នា ក្នុងចំណោមបុគ្គល ក្រុម និងអង្គការស្ថាប័ននានា ដែលអាចបង្កផលប៉ះពាល់ ឬទទួលរងផងប៉ះពាល់ដោយសារអនុគម្រោង។ គោលបំណងជាក់លាក់នៃកិច្ចពិគ្រោះយោបល់សាធារណៈរួមមាន៖

- បន្តផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់តួអង្គពាក់ព័ន្ធនានា អំពីអនុគម្រោងនៅដំណាក់កាលផ្សេងៗគ្នា នៃការអនុវត្ត
- ឆ្លើយតបចំពោះការព្រួយបារម្ភ/ផលប៉ះពាល់បរិស្ថាន និងសង្គម និងរៀបចំវិធានការសម្រាលផលប៉ះពាល់ ដោយធ្វើការពិចារណាពីគំនិតយោបល់/សំណូមពររបស់តួអង្គពាក់ព័ន្ធ
- កៀរគរ និងចងក្រងទុកជាឯកសារស្តីពីការគាំទ្ររបស់សហគមន៍ដល់អនុគម្រោង
- លើកកម្ពស់ការប្រាស្រ័យទាក់ទងគ្នាក្នុងចំណោមភាគីដែលពាក់ព័ន្ធ និង
- បង្កើតនូវយន្តការដាក់/ដោះស្រាយបណ្តឹងផ្លូវការ។

97. ចាំបាច់ត្រូវមានការរៀបចំកិច្ចពិគ្រោះយោបល់យ៉ាងហោចណាស់ ២ ដំណាក់កាល ជាមួយនឹងអ្នកដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង អ្នកទទួលផលពីគម្រោង និងតួអង្គពាក់ព័ន្ធនានា។ ចាំបាច់ត្រូវមានការរៀបចំកិច្ចពិគ្រោះយោបល់នៅដំណាក់កាលទី ១ ផ្តោតលើការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ក្នុងអំឡុងពេលពិនិត្យបឋមលើផលប៉ះពាល់បរិស្ថាន និងសង្គម របស់អនុគម្រោង។ កិច្ចពិគ្រោះយោបល់កម្រិតទី ២ គួរធ្វើឡើង បន្ទាប់ពីមានការកំណត់យ៉ាងច្បាស់លាស់អំពីផលប៉ះពាល់ និងមានការរៀបចំព្រាងផែនការគ្រប់គ្រងរួច។ ប្រសិនបើចាំបាច់គួរមានការរៀបចំកិច្ចពិគ្រោះយោបល់លើសពី ២ ដង។ ខាងក្រោមនេះ គឺជាគោលការណ៍ណែនាំសម្រាប់ការរៀបចំកិច្ចពិគ្រោះយោបល់។

*98. ការបង្ហាញព័ត៌មានអំពីឧបករណ៍ការពារផលប៉ះពាល់*

99. EAs/EMPs, RPs និង EMDPs របស់អនុគម្រោងទាំងអស់ ដែលត្រូវបានរៀបចំឡើងក្នុងអំឡុងពេលអនុវត្តគម្រោងត្រូវបង្ហាញក្នុងស្រុកឱ្យបានទាន់ពេលវេលា មុនពេលមានការឯកភាពលើអនុគម្រោងទាំងនេះ នៅទីកន្លែងដែលគេងាយស្រួលមើលឃើញ និងក្នុងទម្រង់ និងភាសាដែលតួអង្គពាក់ព័ន្ធសំខាន់ៗងាយស្រួលយល់។ ឯកសារវាយតម្លៃបរិស្ថាន ឯកសារផែនការដោះស្រាយផលប៉ះពាល់/តាំងទីលំនៅ និង EMDPs សម្រាប់អនុគម្រោងប្រភេទ A ជាភាសាអង់គ្លេសត្រូវបង្ហាញក្នុង Infoshop របស់ធនាគារ និងក្នុងប្រទេស (ឧទាហរណ៍ គេហទំព័ររបស់ទីភ្នាក់ងារអនុវត្ត)។ សេចក្តីសង្ខេបនៃរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថានសម្រាប់អនុគម្រោងប្រភេទ A (ដែលបង្ហាញពីគ្រប់ឧបករណ៍ការពារផលប៉ះពាល់ទាំងអស់ ដែលត្រូវបានរៀបចំឡើងសម្រាប់អនុគម្រោង) គួររៀបចំ និងបង្ហាញ ជាភាសាអង់គ្លេសផង និងភាសាជាតិផង។ សេចក្តីសង្ខេបអំពីការវាយតម្លៃបរិស្ថានសម្រាប់អនុគម្រោងប្រភេទ A ក៏ត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលផងដែរ មុនពេលចេញដំណើររបស់ក្រុមបេសកកម្មវាយតម្លៃ។

ជំហានទី ៤៖ ការអនុវត្ត, ការគ្រប់គ្រង, ការពិនិត្យតាមដាន និងការរៀបចំរបាយការណ៍

100. អាស្រ័យទៅតាមការរៀបចំ, គម្រោងអាចមានការអនុវត្តជា ២ កម្រិត នៅកម្រិតគម្រោង និងកម្រិតអនុគម្រោង

101. *នៅកម្រិតគម្រោង*

102. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ដែលត្រូវបានចាត់តាំងឱ្យដឹកនាំគ្រប់គ្រង និងពិនិត្យតាមដាន ការអនុវត្តគម្រោង។ អង្គភាពនេះត្រូវគ្រប់គ្រង និងពិនិត្យតាមដាន ការបំពេញការងារតាមកាលកំណត់ និងត្រូវបញ្ចូលព័ត៌មានអំពីវឌ្ឍនភាព/លទ្ធផល ដែលសម្រេចបានទៅក្នុងរបាយការណ៍វឌ្ឍនភាពគម្រោង។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ ត្រូវរាយការណ៍អំពី (ក) ភាពអនុលោមទៅតាមវិធានការដែលបានឯកភាពគ្នាជាមួយនឹងធនាគារ ផ្អែកតាមរបបគំហើញ និងលទ្ធផលនៃការវាយតម្លៃបរិស្ថាន រាប់បញ្ចូលទាំងការអនុវត្ត EMP ផងដែរ ដូចដែលត្រូវបានបង្ហាញក្នុងឯកសារគម្រោង, (ខ) ស្ថានភាពនៃវិធានការសម្រាលផលប៉ះពាល់ និង (គ) លទ្ធផលរកឃើញនៃកម្មវិធីពិនិត្យតាមដាន។

103. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ត្រូវបង្កើតអង្គភាពបរិស្ថាន និងសង្គម (ESU) ដែលទទួលខុសត្រូវលើការអនុវត្តសកម្មភាពការពារផលប៉ះពាល់ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា និងត្រូវចាត់តាំងមន្ត្រីជាន់ខ្ពស់ម្នាក់ និងយ៉ាងហោចណាស់បុគ្គលិកទទួលការការពារផលប៉ះពាល់ ដែលធ្វើការងារពេញម៉ោងម្នាក់ឱ្យទទួលការខុសត្រូវលើការគ្រប់គ្រង និងពិនិត្យតាមដានផលប៉ះពាល់បរិស្ថាន និងសង្គម ដែលបង្កឡើងដោយអនុគម្រោង ក្នុងអំឡុងរយៈពេលគម្រោង។ ការទទួលខុសត្រូវសំខាន់ៗរបស់អង្គភាពបរិស្ថាន និងសង្គម មានជាអាទិ៍ៈ (ក) ពង្រឹងភាពអនុលោមនៃគ្រប់ទិដ្ឋភាពបរិស្ថាន និងសង្គមទាំងអស់ រួមទាំងការគ្រប់គ្រង និងការពិនិត្យតាមដានផង, (ខ) ធ្វើជាតំណាងឱ្យម្ចាស់អនុគម្រោងក្នុងរាល់កិច្ចការទាំងអស់ដែលពាក់ព័ន្ធនឹងការការពារផលប៉ះពាល់របស់គម្រោង និង (គ) ទទួលខុសត្រូវសម្របសម្រួលការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់អនុគម្រោង។ ព័ត៌មានពាក់ព័ន្ធជាមួយនឹងវិធានការផលប៉ះពាល់ និងការបំពេញការងារ គួរបង្ហាញតាមកាលកំណត់ទៅកាន់សាធារណជនទូទៅ។ អាស្រ័យទៅតាមសមត្ថភាពរបស់ PCO គេអាចជួលទីប្រឹក្សាគ្រប់គ្រងបរិស្ថានម្នាក់ឱ្យជួយដល់អង្គភាពបរិស្ថាន និងសង្គម ក្នុងការបំពេញកិច្ចការនានារបស់អង្គភាពនេះ។

104. *<u>នៅកម្រិតអនុគម្រោង</u>*

105. ក្នុងអំឡុងពេលអនុវត្តគម្រោង ម្ចាស់អនុគម្រោងជាអ្នកទទួលខុសត្រូវលើអនុគម្រោងនីមួយៗ និងត្រូវធានាឱ្យមានការអនុវត្តវិធានការការពារផលប៉ះពាល់ប្រកបដោយប្រសិទ្ធភាព (EMPs/ECOP ការពិនិត្យតាមដាន គុណភាពទឹក។ល។) ដោយត្រូវមានការពិគ្រោះយោបល់ឱ្យបានជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន និងសហគមន៍ មូលដ្ឋាន។ ម្ចាស់អនុគម្រោង ត្រូវចាត់តាំងបុគ្គលិកពេញម៉ោងយ៉ាងហោចណាស់ម្នាក់ (ឱ្យធ្វើជាជនបង្គោលផ្នែកការពារផលប៉ះពាល់) ដែលទទួលបន្ទុកធានាឱ្យមានការអនុវត្ត EMP/ECOPs របស់អនុគម្រោងប្រកបដោយប្រសិទ្ធភាព។ ម្ចាស់អនុគម្រោងត្រូវទទួលខុសត្រូវបញ្ចូល EMPs/ECOPs ទៅក្នុងឯកសារដេញថ្លៃ និងឯកសារកិច្ចសន្យា។ ក្នុងអំឡុងពេលសាងសង់ ម្ចាស់អនុគម្រោងត្រូវចាត់តាំងទីប្រឹក្សាគ្រប់គ្រងបរិស្ថាន ឬទីប្រឹក្សាគ្រប់គ្រងការសាងសង់ (CSC) ឬ វិស្វករមូលដ្ឋានឱ្យទទួលខុសត្រូវលើការពិនិត្យតាមដាន និងការគ្រប់គ្រង ការអនុវត្ត EMP/ECOPs ដោយក្រុមហ៊ុនម៉ៅការជាប្រចាំថ្ងៃ **(សូមមើលលក្ខខណ្ឌប្រតិបត្តិក្នុងឧបសម្ព័ន្ធទី ៥)**។ លទ្ធផលនៃការពិនិត្យតាមដាននេះ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍វឌ្ឍនភាពរបស់អនុគម្រោង ហើយជនបង្គោលទទួលបន្ទុកការពារផលប៉ះពាល់ជាអ្នកទទួលខុសត្រូវ ធានាឱ្យមានការចងក្រងឯកសារឱ្យត្រឹមត្រូវអំពីសកម្មភាពការពារផលប៉ះពាល់នានា។

## 6.0 ការរៀបចំការអនុវត្ត

### 6.1. ការទទួលខុសត្រូវលើការអនុវត្ត ESMF

106. ការអនុវត្ត ESMF ត្រូវគោរពទៅតាមការរៀបចំការអនុវត្តគម្រោង ពោលគឺត្រូវអនុវត្តតាម "ប្រព័ន្ធរបស់រដ្ឋាភិបាល" ក្រោមការណែនាំ/ការដឹកនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) រួមទាំងអង្គភាព ឬស្ថាប័ននានា ដែលស្ថិតក្រោមចំណុះក្រសួងនេះ។ ការណែនាំអំពីការពារផលប៉ះពាល់សង្គម និង បរិស្ថាន នឹងត្រូវផ្តល់ដោយគណៈកម្មាធិការដឹកនាំគម្រោងកម្រិតខ្ពស់ ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាប្រធាន។

107. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាស្ថាប័នដែលអនុវត្តចម្បងដោយត្រូវសហការជាមួយនឹងក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទ និងនាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងទាំងពីរនេះ ដែលត្រូវបំពេញតួនាទីជា "អ្នកចូលរួមសហការអនុវត្ត" ហេដ្ឋារចនាសម្ព័ន្ធមួយចំនួន។ នៅថ្នាក់ជាតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលខុសត្រូវលើការអនុវត្តជារួម និងប្រសិទ្ធភាពនៃការសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ និងវិនិយោគិន ឬម្ចាស់ឥណទាន។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលខុសត្រូវលើការអនុវត្តវិធានការការពារផលប៉ះពាល់ជារួម និងលើប្រសិទ្ធភាពនៃការសម្របសម្រួលការគ្រប់គ្រង និងការរៀបចំរបាយការណ៍ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈពាក់ព័ន្ធ ជាមួយនឹងក្រសួងពាក់ព័ន្ធ។ លើសពីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានតែងតាំងមន្ត្រីបង្គោលទទួលបន្ទុកការការពារផលប៉ះពាល់បរិស្ថាន និងសង្គម សម្រាប់ដំណាក់កាលរៀបចំ និងអនុវត្តគម្រោង។ មន្ត្រីទាំងនេះនឹង ពិនិត្យតាមដាន ព្រមទាំងកត់ត្រាព័ត៌មានអំពីការអនុវត្ត ESMF។

108. **គណៈកម្មាធិការដឹកនាំ**[3] ត្រូវដោះស្រាយបញ្ហាគោលនយោបាយ បញ្ហាពាក់ព័ន្ធនឹងក្របខ័ណ្ឌច្បាប់ និងគតិយុត្ត និងការធ្វើសម្រេចចិត្តនានា រាប់បញ្ចូលទាំងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការការពារផលប៉ះពាល់សង្គម និងបរិស្ថានផងដែរ។ គណៈកម្មាធិការដឹកនាំ គឺជាយន្តការចុងក្រោយ ដើម្បីដោះស្រាយជម្លោះបណ្តឹងនានាពាក់ព័ន្ធនឹងការអនុវត្តការការពារផលប៉ះពាល់សង្គម និងបរិស្ថាន និងការរៀបចំរបាយការណ៍អំពីបញ្ហាទាំងឡាយដែលពុំអាចដោះស្រាយដោយក្រុមការងារបច្ចេកទេសរបស់គម្រោង ឬតាមរយៈអន្តរាគមន៍របស់ក្រុមគ្រប់គ្រងបាន។ កិច្ចប្រជុំរបស់គណៈកម្មាធិការដឹកនាំត្រូវរៀបចំឡើង ដោយមានការគាំទ្រពីក្រុមគ្រប់គ្រងគម្រោង និងក្រុមដែលផ្តល់សេវាគាំទ្រដល់គណៈកម្មាធិការនេះ។

109. **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs)** ដែលទទួលបានការគាំទ្រតាមរយៈលេខាធិការដ្ឋានរបស់ក្រុមការងារបច្ចេកទេស ត្រូវទទួលខុសត្រូវសម្របសម្រួលជារួមលើការអនុវត្ត ESMF និងការរៀបចំរបាយការណ៍ រាប់បញ្ចូលទាំងរបាយការណ៍ ដែលត្រូវដាក់ជូនធនាគារពិភពលោក ដូចដែលបានឯកភាពគ្នាផងដែរ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) នឹងបំពេញការងារដោយមានការដឹកនាំពីអ្នកសម្របសម្រួលម្នាក់មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ក៏ត្រូវបញ្ចូលមកពីអង្គភាពបច្ចេកទេសសំខាន់ៗ ដែលចូលរួមពាក់ព័ន្ធក្នុងការ អនុវត្តគម្រោង ដូចជាជនបង្គោលទទួលបន្ទុកការការពារផលប៉ះពាល់សង្គម និងបរិស្ថាន ជាដើម។ ក្រសួងកសិកម្ម

---

[3] 51. *គណៈកម្មាធិការដឹកនាំដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាប្រធាន មានសមាសភាពជាតំណាងមកពីក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សហប្រធានក្រុមការងារបច្ចេកទេស កសិកម្ម និងទឹក។ ក្នុងករណីដែលចាំបាច់គណៈកម្មាធិការនេះអាចស្នើសុំការគាំទ្រសម្រាប់ការសម្របសម្រួល និងការអនុវត្តពីអ្នកសម្របសម្រួលពីភាគីអ្នកផ្តល់ជំនួយ និងដៃគូអភិវឌ្ឍន៍, ក្រសួងសិប្បកម្ម និងឧស្សាហកម្ម, ក្រសួងពាណិជ្ជកម្ម, ក្រសួងកិច្ចការនារី, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ/ធនាគារ និងធនាគារអភិវឌ្ឍន៍ជនបទ។*

រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ត្រូវបំពេញការងារក្រោមការណែនាំផ្ទាល់របស់នាយកគម្រោង ដែលតែងតាំងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

110. មន្ត្រីបង្គោល និងទីប្រឹក្សាផ្នែកការការពារផលប៉ះពាល់បរិស្ថានសង្គម និងបរិស្ថានរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នកទទួលខុសត្រូវលើការអនុវត្ត ESMF និងអនុវត្ត តាមលក្ខខណ្ឌតម្រូវផ្នែកការការពារផលប៉ះពាល់សង្គម និងបរិស្ថាន នៃសេវាផ្តល់ប្រឹក្សាបច្ចេកទេស ដោយសមស្រប និងសហការជាមួយក្រសួង និងនាយកដ្ឋានពាក់ព័ន្ធផ្សេងទៀត ដោយមានការគ្រប់គ្រង និងការផ្តល់ការប្រឹក្សាគាំទ្រពី (លេខាធិការដ្ឋាន) នៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក។

111. មន្ត្រីបង្គោល និងទីប្រឹក្សាផ្នែកការពារផលប៉ះពាល់សង្គម និងបរិស្ថាន របស់ក្រសួងធនធានទឹក និងឧតុនិយម ទទួលបន្ទុកបញ្ចូលការការពារផលប៉ះពាល់សង្គម និងបរិស្ថាន នៅក្នុងផែនការលម្អិត និងទៅក្នុងការអនុវត្តការងារធារាសាស្ត្រដែលជាផ្នែកមួយនៃផែនការធុរកិច្ច ដែលបានទទួលការឯកភាព។

112. មន្ត្រីបង្គោល និងទីប្រឹក្សាផ្នែកការពារផលប៉ះពាល់សង្គម និងបរិស្ថាន របស់ក្រសួងអភិវឌ្ឍន៍ជនបទ ជាអ្នកទទួលបន្ទុកបញ្ចូលការការពារផលប៉ះពាល់សង្គម និងបរិស្ថាន ទៅក្នុងការងារជួសជុលកែលម្អផ្លូវភ្ជាប់ពីកសិដ្ឋានទៅទីផ្សារ និងត្រូវបញ្ចូលទីផ្សារ/ហេរដ្ឋារចនាសម្ព័ន្ធទីផ្សារ នៅកន្លែងដែលមានការសម្រេចធ្វើការងារជួសជុលកែលម្អទាំងនេះផងដែរ។

113. គម្រោងបានវិភាជន៍ថវិកាសម្រាប់ការពារផលប៉ះពាល់សង្គម និងបរិស្ថាន (៤០០ពាន់ដុល្លារ នឹងត្រូវបញ្ជាក់សាជាថ្មី) សម្រាប់ទីប្រឹក្សាការពារផលប៉ះពាល់ នឹងជួយដល់សកម្មភាពកសាងសមត្ថភាពជុំវិញការការពារផលប៉ះពាល់ដល់មន្ត្រីបង្គោលទាំងនេះ។ ទីប្រឹក្សាផ្នែកបរិស្ថាន និងសង្គម ដែលត្រូវធ្វើការងារយ៉ាងជិតស្និទ្ធជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម ត្រូវផ្តល់ការគាំទ្រដល់ការរៀបចំឧបករណ៍ពិនិត្យបឋមលើបរិស្ថាន និងសង្គម សម្រាប់អនុគម្រោងនីមួយៗ នឹងត្រូវរៀបចំឧបករណ៍ការពារផលប៉ះពាល់សមស្របសម្រាប់អនុគម្រោង ដូចជា ESMP ជាដើម។

**តារាង ៧-១៖ ការទទួលខុសត្រូវរបស់ស្ថាប័ន សម្រាប់ការអនុវត្តការការពារផលប៉ះពាល់នៅកម្រិតគម្រោង និងអនុគម្រោង**

| ***សហគមន៍/ស្ថាប័ន*** | ***ការទទួលខុសត្រូវ*** |
|---|---|
| ទីភ្នាក់ងារអនុគម្រោង និង PTs | - ទីភ្នាក់ងារអនុគម្រោងត្រូវទទួលត្រួតពិនិត្យការអនុវត្តគម្រោង រួមនឹងការអនុវត្ត ESMF និងលទ្ធផលផ្នែកបរិស្ថានរបស់គម្រោង។<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) តំណាងទីភ្នាក់ងារអនុវត្ត ទទួលខុសត្រូវពិនិត្យតាមដានការអនុវត្តគម្រោងទាំងមូល រួមទាំងភាពអនុលោមផ្នែកបរិស្ថានរបស់គម្រោងផងដែរ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ជាស្ថាប័នទទួលខុសត្រូវចុងក្រោយលើការអនុវត្ត ESMF និងលទ្ធផលផ្នែកបរិស្ថានរបស់គម្រោងទាំងអំឡុងដំណាក់កាលសាងសង់ ទាំងដំណាក់កាល ប្រតិបត្តិការ។<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ត្រូវ៖ i) ធ្វើការសម្របសម្រួលឱ្យបានជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន ដោយមានការចូលរួមពីសហគមន៍ផងដែរ ក្នុងអំឡុងពេលរៀបចំគម្រោង និងអនុវត្តគម្រោង, ii) ពិនិត្យតាមដាន និងរួមទាំងការបញ្ចូល EMP |

| | |
|---|---|
| | ទៅក្នុងឯកសាររៀបចំបច្ចេកទេសលម្អិត និងឯកសារដេញថ្លៃ និងកិច្ចសន្យាផងដែរ, iii) ធានាថាប្រព័ន្ធគ្រប់គ្រងបរិស្ថានត្រូវបានបង្កើតឡើង និងដំណើរការបានត្រឹមត្រូវ, iv) ទទួលខុសត្រូវលើការរៀបចំរបាយការណ៍ស្តីពីការអនុវត្ត EMP ដើម្បីដាក់ជូនទីភ្នាក់ងារអនុវត្ត និងធនាគារពិភពលោក។<br>- ដើម្បីឱ្យដំណើរការអនុវត្តធ្វើទៅបានប្រកបដោយប្រសិទ្ធភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ(PTs) ត្រូវបង្កើតអង្គភាពបរិស្ថានដែលមានបុគ្គលិកបរិស្ថានយ៉ាងហោចណាស់ ២ នាក់ ដើម្បីជួយបំពេញការងារពាក់ព័ន្ធបរិស្ថានគម្រោង។ |
| អង្គភាពបរិស្ថាន (EU) ឬមន្ត្រីបង្គោលទទួលបន្ទុកការពារផលប៉ះពាល់បរិស្ថាន ក្រោមចំណុះ PTs | - អង្គភាពបរិស្ថានទទួលខុសត្រូវពិនិត្យតាមដានការអនុវត្តគោលនយោបាយស្តីពីការការពារផលប៉ះផលបរិស្ថានរបស់ធនាគារពិភពលោកនៅគ្រប់ដំណាក់កាលទាំងអស់ និងគ្រប់ដំណើរការនៃគម្រោង។ អង្គភាពនេះត្រូវទទួលខុសត្រូវៈ i) ពិនិត្យបឋមលើអនុគម្រោងធៀបនឹងលក្ខណៈវិនិច្ឆ័យកំណត់ភាពសមស្រប ដើម្បីកំណត់ពីផលប៉ះពាល់បរិស្ថាន និងសង្គម គោលនយោបាយដែលត្រូវអនុវត្ត និងឧបករណ៍ដែលរៀបចំ, ii) ពិនិត្យឡើងវិញលើ EIAs/EPCs របស់អនុគម្រោង និង EMPs ដែលត្រូវបានរៀបចំឡើងដោយទីប្រឹក្សាដើម្បីធានាគុណភាពនៃឯកសារទាំងនេះ, ii) ជួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ដើម្បីបញ្ចូល EMPs ទៅក្នុងឯកសាររៀបចំបច្ចេកទេសលម្អិត និងឯកសារដេញថ្លៃ និងកិច្ចសន្យាសាងសង់, iv) ជួយដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ដើម្បីបញ្ចូលការទទួលខុសត្រូវលើការពិនិត្យតាមដាន និងការគ្រប់គ្រង EMP ទៅក្នុងលក្ខខណ្ឌប្រតិបត្តិ, ឯកសារដេញថ្លៃ និងឯកសារកិច្ចសន្យាសម្រាប់ CSC និង IEMC, v) ផ្តល់ធាតុចូលពាក់ព័ន្ធដល់ដំណើរការជ្រើសរើសទីប្រឹក្សា, v) ពិនិត្យឡើងវិញលើរបាយការណ៍ដែលដាក់ដោយ CSC និង IEMC, vi) ចុះពិនិត្យទីតាំងតាមកាលកំណត់, vii) ផ្តល់ដំបូន្មានដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) អំពីដំណោះស្រាយចំពោះបញ្ហាបរិស្ថានរបស់គម្រោង និង viii) រៀបចំផ្នែកលទ្ធផលប៉ះពាល់ក្នុងរបាយការណ៍វឌ្ឍនភាព និងរបាយការណ៍ពិនិត្យឡើងវិញ ដែលត្រូវដាក់ជូនទីភ្នាក់ងារអនុវត្ត និងធនាគារ។ |
| ទីភ្នាក់ងារអនុវត្តដែលជាម្ចាស់អនុគម្រោង | - ក្នុងនាមជាម្ចាស់អនុគម្រោង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ទទួលខុសត្រូវលើការអនុវត្តគ្រប់សកម្មភាព EMP ទាំងអស់ ដែលត្រូវធ្វើឡើងក្រោមគម្រោង រួមនឹងលើកកម្ពស់ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ ប្រកបដោយប្រសិទ្ធភាពរវាងក្រុមហ៊ុនម៉ៅការ អាជ្ញាធរមូលដ្ឋាន និងសហគមន៍មូលដ្ឋាន ក្នុងអំឡុងដំណាក់កាលសាងសង់។ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) នឹងទទួលបានជំនួយពីទីប្រឹក្សាផ្នែកបរិស្ថាន ឬទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ (CSC) ឬ វិស្វករដែលបំពេញការងារនៅនឹងមូលដ្ឋានផ្ទាល់។ |
| ទីប្រឹក្សាផ្នែកបរិស្ថាន ឬទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ (CSC) ឬ វិស្វករដែលបំពេញការងារនៅនឹងមូលដ្ឋានផ្ទាល់ | - ទីប្រឹក្សាក្រុមការងារសាងសង់ តាមរយៈការសហការជាមួយមន្ត្រីបង្គោលដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកការការពារផលប៉ះពាល់បរិស្ថានត្រូវទទួលខុសត្រូវគ្រប់គ្រង និងពិនិត្យតាមដានរាល់ការងារសាងសង់ទាំងអស់ជាប្រចាំ និងធានាយ៉ាងណាឱ្យក្រុមហ៊ុនម៉ៅការគោរពទៅតាមលក្ខខណ្ឌតម្រូវ ដែលមានចែងក្នុងកិច្ចសន្យា និងក្នុង EMP។ ទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ត្រូវជួលបុគ្គលិក ដែលមានសមត្ថភាពក្នុងចំនួនគ្រប់គ្រាន់(ឧទាហរណ៍ វិស្វករបរិស្ថាន) ដែលមានចំណេះដឹងគ្រប់គ្រាន់អំពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងសាងសង់ ដើម្បីបំពេញភារកិច្ចដែលត្រូវធ្វើ និងគ្រប់គ្រងការបំពេញការងាររបស់ក្រុមហ៊ុនម៉ៅការ។ |

| | |
|---|---|
| | - ទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ក៏ត្រូវជួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ក្នុងការរៀបចំរបាយការណ៍ និងបន្តរក្សាការសម្របសម្រួលឱ្យបានជិតស្និទ្ធជាមួយសហគមន៍មូលដ្ឋានផងដែរ។ |
| ក្រុមហ៊ុនម៉ៅការ | - ផ្អែកទៅតាម EMP ដែលបានអនុម័ត និងសេចក្តីពិពណ៌នា/លក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងបរិស្ថាន ដែលមានចែងក្នុងឯកសារដេញថ្លៃ និងឯកសារកិច្ចសន្យា ក្រុមហ៊ុនម៉ៅការទទួលខុសត្រូវក្នុងការរៀបចំ EMP សម្រាប់ការដ្ឋានសំណង់នីមួយៗ ដាក់ផែនការជូនម្ចាស់អនុគម្រោង/ទីភ្នាក់ងារអនុវត្ត និងទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ដើម្បីពិនិត្យ និងសម្រេច មុនពេលចាប់ផ្តើមសកម្មភាពសាងសង់។ លើសពីនេះ ក្រុមហ៊ុនម៉ៅការត្រូវទទួលបានគ្រប់ការអនុញ្ញាតសម្រាប់ការងារសាងសង់ទាំងអស់ (ការគ្រប់គ្រងចរាចរ និងការបញ្ចៀសចរាចរ ការកកាយដី សុវត្ថិភាពកម្មករ ។ល។ មុនពេលចាប់ផ្តើមការងារសាងសង់។) ដោយត្រូវគោរព ទៅតាមលិខិតបទដ្ឋានគតិយុត្ត ដែលកំពុងចូលជាធរមាន។<br>- ក្រុមហ៊ុនម៉ៅការត្រូវតែងតាំងបុគ្គល ដែលមានសមត្ថភាពម្នាក់ឱ្យធ្វើជាមន្រ្តីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថាន ប្រចាំការដ្ឋាន *(SEO)* ដែលជាអ្នកទទួលបន្ទុកពិនិត្យតាមដានភាពអនុលោម របស់ក្រុមហ៊ុនម៉ៅការទៅតាមលក្ខខណ្ឌតម្រូវក្នុង EMP និងទៅតាមសេចក្តីពិពណ៌នាកំណត់អំពីលក្ខខណ្ឌតម្រូវផ្នែកបរិស្ថាន។<br>- ចាត់វិធានការដើម្បីសម្រាលរាល់ផលប៉ះពាល់អវិជ្ជមានទាំងអស់ ស្របទៅតាមគោលបំណងដែលត្រូវបានលើកឡើងក្នុង EMP។<br>- ធ្វើការប្រាស្រ័យទាក់ទងឱ្យបានសកម្មជាមួយនឹងប្រជាពលរដ្ឋាននៅនឹងមូលដ្ឋាន និងចាត់វិធានការដើម្បីបង្កមិនឱ្យមានរំខានក្នុងអំឡុងពេលសាងសង់។<br>- ធានាថាបុគ្គលិក និងកម្មករទាំងអស់យល់ពីនីតិវិធី និងភារកិច្ចរបស់ពួកគេក្នុងកម្មវិធីគ្រប់គ្រងបរិស្ថាន។<br>- រាយការណ៍ទៅកាន់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) អំពីការលំបាកនានាដែលជួបប្រទះ និងដំណោះស្រាយ។<br>- រាយការណ៍ជូនអាជ្ញាធរមូលដ្ឋាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ប្រសិនបើមានគ្រោះថ្នាក់បរិស្ថានកើតមានឡើង និងសម្របសម្រួលជាមួយនឹងស្ថាប័ន និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីដោះស្រាយបញ្ហាទាំងនេះ។ |
| សហគមន៍មូលដ្ឋាន | - សហគមន៍មានសិទ្ធិ និងការទទួលខុសត្រូវពិនិត្យតាមដានជាប្រចាំលើលទ្ធផលការងារផ្នែកបរិស្ថានក្នុងអំឡុងពេលសាងសង់ដើម្បីធានាឱ្យមានការការពារសិទ្ធិ និងសុវត្ថិភាពរបស់ពួកគេឱ្យបានគ្រប់គ្រាន់ និងដើម្បីធានាថា ក្រុមហ៊ុនម៉ៅការ ព្រមទាំងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs)/ម្ចាស់អនុគម្រោង។ ក្នុងករណីដែលមានបញ្ហាកើតឡើងដោយពុំបានរំពឹងទុកជាមុន សហគមន៍ត្រូវរាយការណ៍ទៅកាន់ទីប្រឹក្សាគ្រប់គ្រងការងារសាងសង់/ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs)/ម្ចាស់អនុគម្រោង។ |
| ថ្នាក់ក្រោមជាតិ៖ ខេត្ត ស្រុក និងឃុំ | - សម្របសម្រួលជាមួយនឹងក្រុមហ៊ុនម៉ៅការ និងស្ថាប័នអនុវត្តនៅថ្នាក់ជាតិ ដើម្បីផ្សព្វផ្សាយពីវិធានសម្រាលផលប៉ះពាល់ និងធ្វើការសម្របសម្រួលដោះស្រាយបណ្តឹងរបស់សមាជិកសហគមន៍មូលដ្ឋានពាក់ព័ន្ធនឹងការអនុវត្ត EMP។ |

## 6.2 ការរៀបចំរបាយការណ៍

114. ការរៀបចំរបាយការណ៍ស្តីពីការអនុវត្ត ESMF មិនត្រូវធ្វើដាច់ដោយឡែកនោះឡើយ។ លទ្ធផលនៃការងារការពារផលប៉ះពាល់ត្រូវបញ្ចូលទៅក្នុងរបាយការណ៍វឌ្ឍនភាពរបស់អនុគម្រោង និងគម្រោង។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ក្រោមជំនួយពីទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ ត្រូវបញ្ចូលលទ្ធផលនៃការងារការពារផលប៉ះពាល់នៅកម្រិតអនុគម្រោង ទៅក្នុងរបាយការណ៍តាមកាលកំណត់ដែលដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs)។ នៅកម្រិតគម្រោងវិញ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ត្រូវរៀបចំរបាយការណ៍ស្តីពីលទ្ធផលការងារការពារផលប៉ះពាល់ ២ ដង ក្នុងមួយឆ្នាំ ដែលត្រូវបញ្ចូលទៅក្នុងរបាយការណ៍វឌ្ឍនភាព ដោយត្រូវរៀបរាប់ពីភាពអនុលោមរបស់គម្រោងទៅតាម ESMF និងលក្ខខណ្ឌតម្រូវសម្រាប់ការពារផលប៉ះពាល់ផ្សេងទៀត។

# 7.0 ការកសាងសមត្ថភាព និងការបណ្តុះបណ្តាល

115. ដើម្បីធានាថាការអនុវត្ត ESMF នឹងធ្វើឡើងប្រកបដោយប្រសិទ្ធភាព, គួរមានការវាយតម្លៃស្ថាប័នអនុវត្តដើម្បីដឹងពីសមត្ថភាពគ្រប់គ្រងផលប៉ះពាល់ និងហានិភ័យ បរិស្ថាន និងសង្គម និងសមត្ថភាពអនុវត្តច្បាប់ជាតិ ព្រមទាំងលក្ខខណ្ឌតម្រូវរបស់ធនាគារពិភពលោក។

116. ដើម្បីធានាថាស្ថាប័នមួយពិតជាមានសមត្ថភាពរៀបចំផែនការ និងអនុវត្តវិធានការការពារផលប៉ះពាល់ប្រាកដមែន ជាសំខាន់ណាស់ដែលគម្រោងត្រូវវិភាជន៍ធនធានឱ្យបានគ្រប់គ្រាន់ សម្រាប់ការបណ្តុះបណ្តាល ការកសាងសមត្ថភាព និងជំនួយបច្ចេកទេស ជាពិសេសសម្រាប់ឆ្នាំដំបូងៗ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ មិនត្រឹមតែផ្តល់ប្រយោជន៍ដល់គម្រោងរបស់ធនាគារប៉ុណ្ណោះទេ ប៉ុន្តែកក៏អាចចូលរួមកសាងសមត្ថភាពដែលនៅមូលដ្ឋានក្នុងការអនុវត្តគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ដទៃទៀត ដែលទទួលបានថវិកាក្នុងស្រុក ឬពីអ្នកផ្តល់ជំនួយផ្សេងទៀតផងដែរ។

## 7.1 ការវាយតម្លៃសមត្ថភាពស្ថាប័ន

117. ការវាយតម្លៃលើសមត្ថភាពបច្ចុប្បន្នរបស់ស្ថាប័នក្នុងការអនុវត្ត ESMF ត្រូវបានលើកយកមកបង្ហាញនៅក្នុងផ្នែកនេះ។ ផ្នែកនេះវាយតម្លៃយ៉ាងហោចណាស់លើកម្រិតគ្រប់គ្រាន់នៃ៖

- ✓ រចនាសម្ព័ន្ធស្ថាប័ននៅថ្នាក់ជាតិ និងសមត្ថកិច្ចរបស់ស្ថាប័ននេះ នៅគ្រប់កម្រិតពាក់ព័ន្ធទាំងអស់ក្នុងការឆ្លើយតបចំពោះបញ្ហាគ្រប់គ្រងបរិស្ថាន និងសង្គម ពាក់ព័ន្ធនឹងគម្រោង និងអនុគម្រោង
- ✓ ច្បាប់គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់សម្រាប់គ្រប់គ្រងបរិស្ថាន និងសង្គម រួមទាំងច្បាប់គោលនយោបាយ និងលិខិតគតិយុត្ត ដែលពាក់ព័ន្ធនឹងចាត់ចែងលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណផងដែរ
- ✓ ចំនួន និងគុណវុឌ្ឍិរបស់បុគ្គលិក (មន្ត្រីរាជការ អង្គការសហគមន៍ ទីប្រឹក្សាខាងក្រៅ) ក្នុងការអនុវត្តការទទួលខុសត្រូវរបស់ខ្លួនពាក់ព័ន្ធនឹង ESMF
- ✓ ធនធានថវិកាសម្រាប់គាំទ្រដល់បុគ្គលិក ក្នុងការបំពេញការងាររបស់ពួកគេ។

## 7.2 ការបណ្តុះបណ្តាល

118. ជាផ្នែកមួយនៃការរៀបចំគម្រោង ESMF កំណត់ថាការវាយតម្លៃលើតម្រូវការបណ្តុះបណ្តាលអាចនឹងត្រូវបានធ្វើឡើង។ ការវាយតម្លៃលើតម្រូវការបណ្តុះបណ្តាលត្រូវធ្វើការពិចារណាពីគ្រប់អ្នកចូលរួមទាំងអស់ ដែលទទួលខុសត្រូវអនុវត្ត ESMF។ ការវាយតម្លៃតម្រូវការបណ្តុះបណ្តាលនេះ

ត្រូវញែកឱ្យដាច់នូវតម្រូវបណ្តុះបណ្តាលផ្សេងៗគ្នារបស់អ្នកចូលរួម ដូចជាការបង្កើនការយល់ដឹង ការយល់ដឹងអំពីបញ្ហា និងការបណ្តុះបណ្តាលបច្ចេកទេសលម្អិតជាដើមៈ

- ***ការបង្កើនការយល់ដឹង*** ត្រូវផ្តល់អ្នកចូលរួមដែលត្រូវដឹងពីសារៈសំខាន់ ឬភាពពាក់ព័ន្ធនៃបញ្ហាបរិស្ថាន និងបញ្ហាសង្គម។
- ***ការយល់ដឹងពីបញ្ហា*** ត្រូវផ្តល់អ្នកចូលរួមដែលចាំបាច់ត្រូវយល់ឱ្យបានគ្រប់គ្រាន់ពីបញ្ហានានា ដើម្បីឱ្យពួកគេអាចដឹង និងធ្វើការស្នើសុំជំនួយបច្ចេកទេសជាក់លាក់ និង
- ***ការបណ្តុះបណ្តាលបច្ចេកទេស*** លម្អិតត្រូវផ្តល់ដល់អ្នកចូលរួមដែលចាំបាច់ត្រូវធ្វើការវិភាគពីផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថាន និងសង្គម ដែលអាចកើតមានឡើង ដើម្បីដាក់ចេញនូវវិធីសាស្ត្រ និងវិធានការសម្រាលផលប៉ះពាល់ និងរៀបចំផែនការគ្រប់គ្រង និងគ្រប់គ្រងការអនុវត្តផែនការនេះ។ ការបណ្តុះបណ្តាលនេះត្រូវផ្តោតលើបញ្ហានានា ដូចជាវិធីសាស្ត្រជំរុញឱ្យមានការចូលរួមពីសហគមន៍ ការវិភាគបរិស្ថាន ដោយប្រើប្រាស់បញ្ជីត្រួតពិនិត្យ, ការរៀបចំ EMPs, RPs, PMPs, EMDPs ។ល។, ការរៀបចំរបាយការណ៍ស្តីពីការអនុវត្ត ESMF និងការគ្រប់គ្រង និងពិនិត្យតាមដានអនុគម្រោង។

119. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) គ្រោងនឹងរៀបចំដើម្បីឆ្លើយតបចំពោះតម្រូវបណ្តុះបណ្តាលទាំង ៣ ប្រភេទខាងលើ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs)ត្រូវផ្តល់របៀបវារៈលម្អិត និងសេចក្តីពិពណ៌នាពីតម្រូវធនធាន (ទីកន្លែង អ្នកបណ្តុះបណ្តាល សម្ភារ ។ល។) សម្រាប់ប្រភេទសកម្មភាពបណ្តុះបណ្តាលនីមួយៗ។ ស្ថាប័នទាំងនេះក៏ត្រូវធ្វើការពិចារណាពីវិសាលភាពរបស់គម្រោងផងដែរ ដោយត្រូវរៀបចំផែនការអនុវត្តកាលវិភាគបណ្តុះបណ្តាល។

## 8.0 ថវិកាសម្រាប់អនុវត្ត ESMF

120. ផ្នែកនៃ ESMF នេះ បង្ហាញជារួមពីថវិកាប៉ាន់ប្រមាណដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ត្រូវការដើម្បីអនុវត្ត ESMF។ ដោយសារតែសេចក្តីលម្អិតបច្ចេកទេសរបស់អនុគម្រោងពុំទាន់ត្រូវបានបញ្ចប់រួចរាល់សម្រាប់ការវិនិយោគលើគម្រោងនេះ មានការប៉ាន់ប្រមាណពីចំនួនទឹកប្រាក់សរុបឱ្យស្របទៅតាមចំនួន IEE និង ECOP ដែលនឹងត្រូវរៀបចំឡើង ក៏ដូចទៅតាមលក្ខខណ្ឌតម្រូវពិនិត្យតាមដានសម្រាប់ ESMF។ ថវិកាអនុវត្ត ESMF រួមមានៈ

- សកម្មភាពអភិវឌ្ឍន៍ស្ថាប័ន។
- កម្មវិធីបណ្តុះបណ្តាលដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs), ទីប្រឹក្សា, សហគមន៍ និងអាជ្ញាធរមូលដ្ឋាន ដើម្បីឱ្យពួកគេអាចបំពេញការទទួលខុសត្រូវរបស់ខ្លួន ដូចដែលត្រូវបានលើកឡើងក្នុង ESMF។
- ជំនួយបច្ចេកទេសដល់អាជ្ញាធរមូលដ្ឋានប្រសិនបើចាំបាច់។
- ប្រាក់ឧបត្ថម្ភសម្រាប់ការរៀបចំ EMPs, RPs, EMDPs ។ល។ របស់អនុគម្រោង (ចំណាយសម្រាប់អនុវត្តផែនការទាំងនេះ ត្រូវបានបញ្ចូលទៅក្នុងថវិការបស់អនុគម្រោង)។
- ការពិនិត្យតាមដាន និងការចុះដល់ទីតាំងជាក់ស្តែង។
- របាយការណ៍ប្រចាំឆមាសដែលត្រូវផ្ញើជូនធនាគារ។

121. ចំណាយសម្រាប់អនុវត្ត ESMF ក៏ត្រូវបញ្ចូលការរៀបចំឧបករណ៍

ការពារផលប៉ះពាល់នៅតាមទីតាំងជាក់លាក់ផងដែរ ដូចជាចំណាយលើបុគ្គលិក, ធ្វើការដំណើរ, សិក្ខាសាលាពិគ្រោះយោបល់, ការបកប្រែ និងការបណ្តុះបណ្តាលជាដើម។ ចំណាយប៉ាន់ប្រមាណសរុប ដែលត្រូវបានពិនិត្យឡើងវិញដោយធនាគារពិភពលោក និងក្រសួងអភិវឌ្ឍន៍ជនបទ គឺប្រមាណជា ៤០០,០០០ ដុល្លារ (តារាងទី ១) ដែលនឹងត្រូវទទួលបានការគាំទ្រពី IDA និងហិរញ្ញប្បទានរបស់សមាភាគីផង ដោយយកចេញពីសមាសភាគគ្រប់គ្រងគម្រោង។

**តារាងទី ១ ចំណាយលើការអនុវត្ត ESMF**

| ល.រ | សេចក្តីពិពណ៌នា | ចំណាយប៉ាន់ស្មាន (USD) |
|---|---|---|
| ១. | អ្នកឯកទេស/ទីប្រឹក្សា ជាតិទទួលបន្ទុកការពារផលប៉ះពាល់បរិស្ថាន | 102,000 |
| ២. | អ្នកឯកទេស/ទីប្រឹក្សា ជាតិទទួលបន្ទុកការពារផលប៉ះពាល់សង្គម | 102,000 |
| ៣. | ការធ្វើដំណើរក្នុងស្រុកទៅខេត្ត | 25,000 |
| ៤. | ការធ្វើដំណើរក្នុងស្រុក ដើម្បីរៀបចំកិច្ចពិគ្រោះយោបល់សាធារណៈអំពីការការពារផលប៉ះពាល់ក្នុងខេត្ត | 10,000 |
| ៥. | ការបកប្រែឯកសារពាក់ព័ន្ធនឹងការការពារផលប៉ះពាល់ | 10,000 |
| ៦. | សិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ជាតិដែលរៀបចំនៅទីក្រុងភ្នំពេញ | 8,000 |
| ៧. | សិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ជាតិដែលរៀបចំនៅតាមបណ្តាលខេត្ត | 9,000 |
| ៨. | ថវិកាបម្រុង (១០%) | 39,000 |
| **សរុប** | | **400,000** |

## 9.0 យន្តការដោះស្រាយបណ្តឹងសាទុក្ខ (GRM)

122. ផ្នែកនេះគួររៀបរាប់ពីយន្តការសម្រាប់ទទួល និងសម្របសម្រួលការឆ្លើយតបចំពោះការព្រួយបារម្ភបណ្តឹង និងការកើតទុក្ខមិនសុខចិត្តរបស់ប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះពាល់ពាក់ព័ន្ធនឹងការបំពេញការងាររបស់គម្រោង រួមទាំងពាក់ព័ន្ធនឹងបញ្ហាផលប៉ះពាល់បរិស្ថាន និងសង្គម ផងដែរ។ យន្តការដោះស្រាយបណ្តឹងសារទុក្ខគួរឆ្លើយតបចំពោះការព្រួយបារម្ភ និងបណ្តឹងរបស់ជនដែលរងផលប៉ះពាល់ឱ្យបានទាន់ពេលវេលា ដោយប្រើប្រាស់ដំណើរការប្រកបដោយតម្លាភាព ដែលឆ្លើយតបសមស្របតាមវប្បធម៌ និងងាយស្រួលប្រើប្រាស់សម្រាប់ប្រជា ពលរដ្ឋរងផលប៉ះពាល់គ្រប់ប្រភេទទាំងអស់ ដោយមិនអស់ចំណាយ និងមិនទទួលរងការតបតសងសឹកអ្វីឡើយ។ យន្តការនេះមិនគួរបន្ទចបង្អាក់ដល់ការទទួលបានដំណោះស្រាយតាមផ្លូវតុលាការ ឬដំណោះស្រាយរដ្ឋបាលដែលផ្តល់នៅក្នុងប្រទេសឡើយ។ គួរមានការផ្សព្វផ្សាយពីយន្តការឆ្លើយតបចំពោះបណ្តឹងសារទុក្ខនេះដល់សហគមន៍ និងត្រូវបញ្ចូលទៅក្នុងឯកសារគម្រោងពាក់ព័ន្ធ (ឧទាហរណ៍ សៀវភៅណែនាំស្តីពីប្រតិបត្តិការគម្រោងជាដើម)។

123. សម្រាប់គម្រោងនេះ គម្រោងត្រូវបង្កើតគណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខនៅថ្នាក់មូលដ្ឋាន (ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ) ដែលត្រូវដឹកនាំដោយអភិបាលខេត្ត ឬអភិបាលខេត្តរង, អភិបាលស្រុក និងអភិបាលឃុំ

ទៅតាមកម្រិតនៃគណៈកម្មាធិការនេះ។
នៅថ្នាក់ឃុំយន្តការដោះស្រាយបណ្តឹងសារទុក្ខត្រូវមានការចូលរួមពីតំណាងគ្រួសារ ដែលរងផលប៉ះពាល់ដោយសារគម្រោង ដែលត្រូវជ្រើសរើសចេញពីក្នុងចំណោមអ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង។ សម្រាប់ករណីសហគមន៍ជនជាតិដើមភាគតិច និងមានការបង្កើតគណៈកម្មាធិការនៅថ្នាក់ភូមិ ដោយប្រើប្រាស់ដំណើរការពិគ្រោះយោបល់ដោយសេរីជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ និងប្រើប្រាស់យន្តការធ្វើសេចក្តីសម្រេចចិត្តពិសេសរបស់សហគមន៍ជនជាតិដើមភាគតិច ក៏ដូចជាគោរពទៅតាមលក្ខខណ្ឌដែលតម្រូវឱ្យមានតុល្យភាពយេនឌ័រ និងតុល្យភាពអន្តរជំនាន់ផងដែរ។ គណៈកម្មាធិការនឹងទទួលវាយតម្លៃ និងសម្របសម្រួលការដោះស្រាយ។ ការព្រួយបារម្ភបណ្តឹង ការកើតទុក្ខមិនសុខចិត្តរបស់ជនដែលរងផលប៉ះពាល់ដោយសារគម្រោង និងគ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោង។ គណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខ ត្រូវបំពេញភារកិច្ចដើម្បីប្រយោជន៍របស់ជនរងផលប៉ះពាល់ដោយសារគម្រោង និងគ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោង ក្នុងរយៈពេលទាំងមូលនៃអនុគម្រោង រួមទាំងរយៈពេលជានាលើកំហូចក្រោយការសាងសង់ផងដែរ។

124. បណ្តឹងសារទុក្ខរបស់ជនរងផលប៉ះពាល់ដោយសារគម្រោង និងគ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោងដែលពាក់ព័ន្ធនឹងការអនុវត្តផែនការដោះស្រាយផលប៉ះពាល់/តាំងទីលំនៅ ត្រូវដោះស្រាយតាមរយៈការចរចាក្នុងគោលបំណងឈានទៅដល់ការឯកភាពគ្នាជារួម។ ពាក្យបណ្តឹងនានាមានជម្រើសឆ្លងកាត់ ៤ ដំណាក់កាល មុនពេលបញ្ជូនទៅកាន់តុលាការជាជម្រើសចុងក្រោយ។ បន្ថែមពីលើយន្តការខាងក្រោម និងទៅតាមបុព្វសិទ្ធិរបស់ជនរងផលប៉ះពាល់ដោយសារគម្រោង និងគ្រួសាររងផលប៉ះពាល់ដោយសារគម្រោង គេអាចដាក់បណ្តឹងសារទុក្ខទៅកាន់ស្ថាប័នផ្សះផ្សាជម្លោះផ្សេងទៀត ដូចជា ក្រុមប្រឹក្សា ចាស់ព្រឹទ្ធាចារ្យ ព្រះសង្ឃនៅតាមវត្តអារាម ឬស្ថាប័នដោះស្រាយវិវាទផ្សេងទៀត ដែលទទួលស្គាល់ដោយជនរងផលប៉ះពាលដោយសារគម្រោង និងគ្រួសាររងផលប៉ះពាល់ដោយសារគម្រោង។

125. ដំណាក់កាលទី ១ កម្រិតភូមិៈ គ្រួសាររងផលប៉ះពាល់ដោយសារគម្រោងដែលកើតទុក្ខមិនសុខចិត្តអាចដាក់ពាក្យបណ្តឹងរបស់ខ្លួនទៅកាន់គណៈកម្មាធិការដោះស្រាយបណ្តឹងនៅថ្នាក់ភូមិ ដែលត្រូវបានបង្កើតឡើងក្រោម IPDP។ គណៈកម្មាធិការនេះគួរព្យាយាមដោះស្រាយបណ្តឹងនេះមិនឱ្យលើសពី ១៥ ថ្ងៃ ចាប់គិតពីកាលបរិច្ឆេទដាក់ពាក្យបណ្តឹងរបស់គ្រួសាររងផលប៉ះពាល់ ដោយសារគម្រោងដែលកើតទុក្ខមិនសុខចិត្ត។ សមាសភាពរបស់ក្រុមនេះមានការប្រែប្រួលទៅតាមភូមិ និងត្រូវប្រើប្រាស់ដំណើរការពិគ្រោះយោបល់ដោយសេរីជាមុន និងផ្អែកតាមព័ត៌មានត្រឹមត្រូវ និងប្រើប្រាស់រចនាសម្ព័ន្ធធ្វើសេចក្តីសម្រេចចិត្ត ដែលមានលក្ខណៈពិសេសរបស់សហគមន៍ជនជាតិដើមភាគតិចនីមួយៗ ព្រមទាំងត្រូវគោរពទៅតាមលក្ខខណ្ឌ ដែលតម្រូវឱ្យមានតុល្យភាពយេនឌ័រ និងតុល្យភាពអន្តរជំនាន់។ ប្រសិនបើក្រោយរយៈពេល ១៥ ថ្ងៃ គ្រួសាររងផលប៉ះពាល់ដោយសារគម្រោង ដែលកើតទុក្ខមិនសុខចិត្តពុំបានឮព័ត៌មានពីគណៈកម្មាធិការដោះស្រាយបណ្តឹងនៅថ្នាក់ភូមិ ឬប្រសិនបើគ្រួសាររងផលប៉ះពាល់ដោយសារគម្រោងពុំចិត្តជាមួយនឹងសេចក្តីសម្រេចនៅដំណាក់កាលទី ១ នេះ គេដាក់ពាក្យបណ្តឹងទៅការិយាល័យស្រុកជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។

126. ដំណាក់កាលទី ២ កម្រិតឃុំៈ គ្រួសាររងផលប៉ះពាល់ដោយសារគម្រោង ដែលកើតទុក្ខមិនសុខចិត្តអាចដាក់ពាក្យបណ្តឹងទៅកាន់មេឃុំ។ មេឃុំនឹងកោះឱ្យមានកិច្ចប្រជុំក្រុមនេះ ដើម្បីសេចក្តីសម្រេចចិត្តអំពីសកម្មភាពដែលត្រូវអនុវត្ត ដើម្បីដោះស្រាយពាក្យបណ្តឹងនេះមិនឱ្យហួសរយៈពេល ១៥ ថ្ងៃ

ចាប់ពីគិតពីកាលបរិច្ឆេទនៃការដាក់ពាក្យបណ្តឹង ដោយសារគ្រួសាររងផលប៉ះពាល់ដោយសារគម្រោងដែលកើតទុក្ខមិនសុខចិត្ត។ កិច្ចប្រជុំរបស់ក្រុមដោះស្រាយបណ្តឹងសារទុក្ខនៅថ្នាក់ឃុំគួរមានការចូលរួមពីមេឃុំតំណាងក្រុមការងារនៃអនុគណៈកម្មាធិការដោះស្រាយផលប៉ះពាល់នៅថ្នាក់ខេត្ត (PRSC-WG) ការិយាល័យស្រុក និងគ្រួសាររងផលប៉ះពាល់ដោយសារគម្រោងដែលកើតទុក្ខមិនសុខចិត្ត។ មេឃុំជាអ្នកទទួលបន្ទុកកត់កំណត់ហេតុ និងរក្សាទុកឯកសារពាក្យបណ្តឹងទាំងអស់ដែលកំពុងដោះស្រាយ។ ប្រសិនបើក្រោយរយៈពេល ១៥ ថ្ងៃ គ្រួសាររងផលប៉ះពាល់ដោយសារគម្រោងដែលកើតទុក្ខមិនសុខចិត្តពុំបានទទួលព័ត៌មានពីអាជ្ញាធរភូមិ ឬឃុំ ឬប្រសិនបើគ្រួសាររងផលប៉ះពាល់ដោយសារគម្រោងមិនពេញចិត្តជាមួយនឹងសេចក្តីសម្រេចនៅដំណាក់កាលទី ១ គេអាចដាក់ពាក្យបណ្តឹងនេះទៅការិយាល័យស្រុកជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។ ក្នុងករណីដែលគ្រួសាររងផលប៉ះពាល់ដោយសារគម្រោងដែលដាក់ពាក្យបណ្តឹងជាជនជាតិដើមភាគតិច ពួកគេត្រូវអមដំណើរដោយអ្នកសម្របសម្រួលម្នាក់ដែលគម្រោងជាអ្នករ៉ាប់រងចំណាយឱ្យ។ អ្នកសម្របសម្រួលនេះ គឺជាអ្នកចេះប្រើប្រាស់ភាសាដែលពាក់ព័ន្ធ និងត្រូវបំពេញតួនាទីជាអ្នកស្វែងរកការគាំទ្រដល់គ្រួសាររងផលប៉ះពាល់ដោយសារគម្រោងដែលកើតទុក្ខមិនសុខចិត្តក្នុងអំឡុងដំណើរការនេះ។

127. ដំណាក់កាលទី ៣ ការិយាល័យស្រុក៖ ការិយាល័យស្រុកមានរយៈពេល ១៥ ថ្ងៃ ដើម្បីដោះសារបណ្តឹងដើម្បីឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់មានការពេញចិត្ត។ ប្រសិនបើគេពុំអាចដោះស្រាយបណ្តឹងនៅដំណាក់កាលនេះបានទេ ការិយាល័យស្រុកត្រូវបញ្ជូនបណ្តឹងនេះទៅកាន់គណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខនៅថ្នាក់ខេត្ត។ ក្នុងករណីដែលគ្រួសាររងផលប៉ះពាល់ដោយសារគម្រោង ដែលដាក់ពាក្យបណ្តឹងជាជនជាតិដើមភាគតិច ពួកគេត្រូវអមដំណើរដោយអ្នកសម្របសម្រួលម្នាក់ ដែលគម្រោងជាអ្នករ៉ាប់រងចំណាយជូន។ អ្នកសម្របសម្រួលនេះ គឺជាអ្នកដែលចេះនិយាយភាសារបស់ជនជាតិដើមភាគតិចនេះនឹងត្រូវបំពេញតួនាទីជាអ្នកស្វែងរកមតិគាំទ្រដល់គ្រួសាររងផលប៉ះពាល់ដោយសារគម្រោងដែលកើតទុក្ខមិនសុខចិត្តក្នុងអំឡុងដំណើរការនេះ។

128. ដំណាក់កាលទី ៤ គណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខនៅថ្នាក់ខេត្ត៖ គណៈកម្មាធិការដោះស្រាយនៅថ្នាក់ខេត្ត ដែលមានសមាសភាពជាអភិបាលខេត្ត ឬអភិបាលខេត្តរងជាប្រធានគណៈកម្មាធិការ និងសមាជិកជាប្រធានមន្ទីរជុំវិញខេត្តពាក់ព័ន្ធ (ដែលនឹងត្រូវបង្កើតឡើងក្នុងខេត្តនីមួយៗមុន DMS) ជួយប្រជុំជាមួយភាគីកើតទុក្ខមិនសុខចិត្ត និងព្យាយាមដោះស្រាយបណ្តឹងនេះ។ គណៈកម្មាធិការនេះ អាចស្នើសុំឱ្យក្រុមការងារនៃអនុគណៈកម្មាធិការដោះស្រាយផលប៉ះពាល់រៀបចំឱ្យការពិនិត្យឡើងវិញលើ DMS ដោយទីភ្នាក់ងារពិនិត្យតាមដានពីខាងក្រៅ (EMA)។ ក្នុងអំឡុងរយៈពេល ៣០ ថ្ងៃក្រោយពេលដាក់បណ្តឹងសារទុក្ខទៅកាន់គណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខនៅថ្នាក់ខេត្ត រួចត្រូវមានការចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ហើយសំណៅចម្លងនៃសេចក្តីសម្រេចនេះត្រូវដាក់ជូនគណៈកម្មាធិការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ ក្រសួងអភិវឌ្ឍន៍ជនបទ និងគ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោង។ ក្នុងករណីដែលគ្រួសាររងផលប៉ះពាល់ដោយសារគម្រោងដែលដាក់ពាក្យបណ្តឹងជាជនជាតិដើមភាគតិច ពួកគេត្រូវអមដំណើរដោយអ្នកសម្របសម្រួលម្នាក់ដែលគម្រោងជាអ្នករ៉ាប់រងចំណាយជូន។ អ្នកសម្របសម្រួលនេះ គឺជាអ្នកដែលចេះនិយាយភាសារបស់ជនជាតិដើមភាគតិចនេះនឹងត្រូវបំពេញតួនាទីជាអ្នកស្វែងរកមតិគាំទ្រដល់គ្រួសាររងផលប៉ះពាល់ដោយសារគម្រោងដែលកើតទុក្ខមិនសុខចិត្តក្នុងអំឡុងដំណើរការនេះ។

129. ដំណាក់កាលចុងក្រោយ នីតិវិធីតុលាការ៖ ប្រសិនបើគ្រួសាររងផលប៉ះពាល់ដោយសារគម្រោងពុំពេញចិត្តជាមួយដំណោះស្រាយដែលស្នើឡើងដោយគណៈកម្មាធិការដោះស្រាយបណ្តឹងសារទុក្ខនៅថ្នាក់ខេត្ត ផ្អែកទៅតាមគោលនយោបាយដែលបានព្រមព្រៀងគ្នាក្នុង RF-RP នោះទេ គណៈកម្មាធិការនេះត្រូវផ្តួចផ្តើមអនុវត្តនីតិវិធីរដ្ឋបាលប្រឆាំងទៅនឹងគ្រួសាររងផលប៉ះពាល់ដោយសារគ

គម្រោង ដែលមានការចូលរួមពីព្រះរាជអាជ្ញាខេត្ត។ ករណីនេះនឹងត្រូវដាក់ជូនតុលាការខេត្ត ហើយការដោះស្រាយបណ្តឹងនេះត្រូវធ្វើឡើងទៅតាមនីតិវិធីរបស់តុលាការ។ ក្នុងពេលជាមួយគ្នា គ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោងអាចដាក់បណ្តឹងទៅតុលាការខេត្តផងដែរ។ ក្នុងអំឡុងពេលជំនុំជម្រះលើករណីនេះ រាជរដ្ឋាភិបាលកម្ពុជាអាចស្នើសុំឱ្យតុលាការអនុញ្ញាតឱ្យគម្រោងបន្តអនុវត្តទៀត ដោយពុំមានការរំខាន ដោយក្នុងករណីនេះកំពុងត្រូវបានដោះស្រាយ។ ប្រសិនបើភាគីណាមួយពុំពេញចិត្តជាមួយសេចក្តីសម្រេចរបស់តុលាការខេត្ត ភាគីនោះអាចបន្តបញ្ជូនករណីនេះទៅកាន់តុលាការជាន់ខ្ពស់បន្តទៀត។ រាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្តទៅតាមសេចក្តីសម្រេចរបស់តុលាការ។

## 10.0 កិច្ចពិគ្រោះយោបល់ និងបង្ហាញព័ត៌មានអំពី ESMF

130. ***កិច្ចពិគ្រោះយោបល់ក្នុងអំឡុងពេលរៀបចំ ESMF៖*** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួង អភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម បានរៀបចំកិច្ចពិគ្រោះយោបល់សាធារណៈមួយ នៅភោជនីយ-ដ្ឋានទន្លេបាសាក់ ២ កាលពីថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៨។ សូមមើលបញ្ជីឈ្មោះអ្នកចូលរួម ក្នុងឧបសម្ព័ន្ធទី ១១។ កិច្ចពិគ្រោះយោបល់ជាសាធារណៈនេះ គឺជាលក្ខខណ្ឌតម្រូវជាក់លាក់មួយ ក្នុងគោលនយោបាយស្តីពីការការពារផលប៉ះពាល់បរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក និងអនុក្រឹត្យលេខ ៧២ អនក្រ.បក របស់រដ្ឋាភិបាល ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ កិច្ចពិគ្រោះយោបល់នេះផ្តោតលើច្បាប់ និងលិខិតបទដ្ឋានរបស់ប្រទេស ពាក់ព័ន្ធនឹងដំណើរការបរិស្ថាន និងសង្គម។ យោបល់សំខាន់ៗ រួមមាន លើកទឹកចិត្តឱ្យម្ចាស់អនុគម្រោងបន្តរៀបចំកិច្ចពិគ្រោះយោបល់សាធារណៈប្រកបដោយអត្ថន័យ ការអនុវត្តល្អផ្នែកកសិកម្ម និងអនុវត្តវិធានការគ្រប់គ្រងការប្រើប្រាស់ថ្នាំកសិកម្មឱ្យបានត្រឹមត្រូវ ក្នុងអំឡុងពេលអនុវត្ត និងត្រួតពិនិត្យគម្រោង។ ការឆ្លើយតបចំពោះយោបល់ទាំងនេះ ធ្វើឡើងក្នុងផ្នែកទី ៣ ផ្នែកទី ៥ និងឧបសម្ព័ន្ធទី ៩។

131.

132. ***ការបង្ហាញ ESMF៖*** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្ហាញសេចក្តីព្រាង ESMF លើគេហទំព័ររបស់ខ្លួន *http://www.maff.gov.kh/newsletter/2269-cambodia-agricultural-sector-diversification-project.html* ១០ ថ្ងៃ មុនកិច្ចពិគ្រោះយោបល់ កាលពីថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៨។ ESMF ដែលត្រូវបានធ្វើបច្ចុប្បន្នភាព រួច ដោយមានបញ្ចូលយោបល់ ដែលទទួលបានពីកិច្ចពិគ្រោះយោបល់ ត្រូវបានបង្ហាញក្នុងគេហទំព័ររបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគេហទំព័ររបស់ធនាគារ មុនពេលមានការវាយតម្លៃគម្រោង។

## ឧបសម្ព័ន្ធទី ១៖ ការវិភាគគម្លាតរវាងក្របខ័ណ្ឌគតិយុត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយោបាយរបស់ធនាគារពិភពលោក

| **ប្រធានបទ** | OP 4.01 | **រាជរដ្ឋាភិបាលកម្ពុជា** |
|---|---|---|
| ***1. ដំណើរការវាយតម្លៃបរិស្ថាន*** | | |
| *1.1 ការវាយតម្លៃ បរិស្ថាន ធ្វើការពិចារណាលើទិដ្ឋភាពធម្មជាតិ និងសង្គមរួមគ្នា ដោយពិចារណាពីកាតព្វកិច្ចសន្ធិសញ្ញា និងកិច្ចព្រមព្រៀងក្នុងប្រទេស និងអន្តរជាតិ* | *វាយតម្លៃលើភាពគ្រប់ជ្រុងជ្រោយនៃក្របខ័ណ្ឌច្បាប់ និងស្ថាប័នដែលពាក់ព័ន្ធ រួមនឹងកិច្ចព្រមព្រៀងបរិស្ថានអន្តរជាតិដែលកំពុងចូលជាធរមាន និងធ្វើការបញ្ជាក់ថា កិច្ចព្រមព្រៀងទាំងនេះ ពិតជាបានចែងតម្រូវថា រដ្ឋាភិបាលដែលសហការជាមួយធនាគារនឹងមិនផ្តល់ហិរញ្ញ ប្បទានដល់សកម្មភាពគម្រោង ដែលផ្ទុយគ្នាទៅនឹងកាតព្វកិច្ចអន្តរជាតិទាំងនេះឡើយ។* | ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ៖<br>▪ មាត្រា ៦ – ការវាយតម្លៃហេតុប៉ះពាល់ បរិស្ថាន ត្រូវធ្វើឡើងសម្រាប់គ្រប់គម្រោង និងសកម្មភាពទាំងអស់ មិនថាឯកជន ឬសាធារណៈ និងត្រូវមានការពិនិត្យ និងវាយតម្លៃ ដោយក្រសួងបរិស្ថាន មុនពេលដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើសេចក្តីសម្រេច។<br>អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (១៩៩៩)៖<br>▪ មាត្រា ១ – ការវាយតម្លៃហេតុប៉ះពាល់ បរិស្ថាន (EIA) ត្រូវធ្វើឡើងក្នុងគ្រប់គម្រោង និងសកម្មភាពទាំងអស់ មិនថាឯកជន ឬសាធារណៈ និងត្រូវមានការពិនិត្យឡើងវិញ ដោយក្រសួងបរិស្ថាន មុនពេលដាក់ជូនរាជរដ្ឋាភិបាល ដើម្បីធ្វើសេចក្តី សម្រេច។<br>មាត្រា ៦– អ្នកគាំទ្រគម្រោង ត្រូវធ្វើការវាយតម្លៃលើហេតុប៉ះពាល់បរិស្ថានបឋម(IEIA) សម្រាប់គម្រោង ដែលចាំបាច់ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចរៀបរាប់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។ |
| *1.2 ការវាយតម្លៃលើជម្រើសផ្សេងៗរបស់គម្រោង* | *ចែងពីការវាយតម្លៃលើជម្រើសផ្សេងទៀត ដែលអាចមាន សម្រាប់ការ វិនិយោគ ជម្រើសបច្ចេកទេស និងជម្រើសទីតាំង រួមទាំងជម្រើស "ពុំធ្វើសកម្មភាពតែម្តង" ផលប៉ះពាល់ដែលអាចកើតមានឡើង លទ្ធភាពសម្រាលផលប៉ះពាល់ទាំងនេះ ចំណាយមូលធន និងចំណាយចរន្ត ដោយសារផលប៉ះពាល់ទាំងនេះ ភាពសមស្របនៃជម្រើសទាំងនេះ ក្រោមស្ថានភាពនៅមូលដ្ឋាន លក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងស្ថាប័ន ការបណ្តុះបណ្តាល និងការពិនិត្យតាមដានពាក់ព័ន្ធនឹងជម្រើសទាំងនេះ។* | ពុំបានបញ្ចូល |
| ***1. ដំណើរការវាយតម្លៃបរិស្ថាន*** | | |
| *1.3 ការរក្សាទុក ទីប្រឹក្សាគម្រោង* | *អ្នកខ្ចីកម្ចីជាធម្មតាគួរបង្កើតគណៈ កម្មាធិការប្រឹក្សាគម្រោងមួយ ដែលមានសមាសភាពជាអ្នកឯកទេសផ្នែកបរិស្ថានឯករាជ្យ និងមានការទទួលស្គាល់ជាអន្តរជាតិ ដើម្បីផ្តល់ដំបូន្មានអំពីគ្រប់ទិដ្ឋភាពទាំងអស់របស់គម្រោង ពាក់ព័ន្ធនឹងការវាយតម្លៃបរិស្ថាន។* | ពុំបានបញ្ចូល |
| ***2. កិច្ចពិគ្រោះយោបល់ជាសាធារណៈ និងការបង្ហាញព័ត៌មាន*** | | |
| *2.1 ដំណើរការវាយតម្លៃបរិស្ថាន ត្រូវបញ្ចូលការពិគ្រោះយោបល់សាធារណៈ និងការបង្ហាញព័ត៌មាន* | *ប្រសិនបើសមស្រប ធនាគារអាចតម្រូវឱ្យមានកិច្ចពិគ្រោះយោបល់ និងការបង្ហាញព័ត៌មានជាសាធារណៈ។*<br><br>*អ្នកខ្ចីកម្ចីត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រុម ដែលរងផលប៉ះពាល់ដោយសារគម្រោង និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។* | ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ៖<br>▪ មាត្រា ១ – គោលបំណងនៃច្បាប់នេះគឺ៖<br>○ លើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណៈជនចូលរួម ក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ |

| ប្រធានបទ | OP 4.01 | រាជរដ្ឋាភិបាលកម្ពុជា |
|---|---|---|
| | | ▪ មាត្រា ១៦ – បន្ទាប់ពីមានការស្នើសុំពីសាធារណជន ក្រសួងបរិស្ថានត្រូវផ្តល់ព័ត៌មានអំពីសកម្មភាពរបស់ខ្លួន និងត្រូវជំរុញឱ្យមានការចូលរួមពីសាធារណៈជនក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។<br>អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (១៩៩៩)៖<br>▪ មាត្រា ១ – លើកកម្ពស់ការចូលរួមរបស់សាធារណជនក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយត្រូវពិចារណាពីក្តីបារម្ភរបស់ពួកគេក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តរបស់គម្រោង។ |
| ***3. ការពិនិត្យតាមដាន និងវាយតម្លៃ*** | | |
| *3.1 ចាំបាច់ត្រូវមានការពិនិត្យតាមដាន ផ្ទៃក្នុង និងការពិនិត្យតាមដានដោយឯករាជ្យពីខាងក្រៅ* | *ក្នុងអំឡុងពេលអនុវត្តគម្រោង អ្នកខ្ចីត្រូវរៀបរំបាយការណ៍ស្តីពីភាពអនុលោមទៅតាមវិធានការដែលបានឯកភាពគ្នាជាមួយនឹងធនាគារ ផ្អែកទៅតាមលទ្ធផលរកឃើញ និងលទ្ធផលនៃការវាយតម្លៃ បរិស្ថាន រួមទឹងអំពីការអនុវត្ត EMP។* | អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (១៩៩៩)៖<br>មាត្រា ៣ – ក្រសួងបរិស្ថានត្រូវចាត់វិធានការរដ្ឋបាលឱ្យបានសមស្រប ធ្វើការឃ្លាំមើល និងពិនិត្យតាមដាន ដើម្បីធានាឱ្យមានការរៀបចំផែនការគ្រប់គ្រងបរិស្ថានក្នុងអំឡុងពេលសាងសង់របស់គម្រោង ប្រតិបត្តិការគម្រោង ពេលបិទគម្រោង ដែលព័ត៌មានទាំងនេះ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបានទទួលការឯកភាព ដែលត្រូវអនុវត្តដោយអ្នកគាំទ្រគម្រោង។ |

តារាងទី ២៖ ការវិភាគគម្លាតរវាងក្របខ័ណ្ឌច្បាប់/គតិយុត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយបាយ OP4.04 របស់ធនាគារពិភពលោក

| ប្រធានបទ | គោលនយោបាយ OP 4.04 | រាជរដ្ឋាភិបាលកម្ពុជា |
|---|---|---|
| ***1. លើកកម្ពស់ការអភិវឌ្ឍដែលធានាបាននូវនិរន្តរភាពបរិស្ថាន*** | | |
| *1.1 ប្រើប្រាស់វិធីសាស្ត្របម្រុងប្រយ័ត្នជាមុន ដើម្បីធានាឱ្យមានការអភិវឌ្ឍ ដែលធានាបាននូវនិរន្តរភាពបរិស្ថាន។* | *ធនាគារគាំទ្រ និងរំពឹងថាអ្នកខ្ចីនឹងអនុវត្តវិធីសាស្ត្របម្រុងប្រយ័ត្នជាមុន ចំពោះការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីធានាឱ្យមានឱកាសអភិវឌ្ឍន៍ ដែលធានាបាននូវនិរន្តរភាពបរិស្ថាន។* | ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិៈ<br>មាត្រា ១ – ច្បាប់នេះមានគោលបំណងៈ<br>○ ធានាឱ្យមានការអភិរក្ស ការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាឱ្យបានសមស្រប និងប្រកបដោយនិរន្តរភាព។<br>○ បង្ការបអំពើទាំងឡាយណា ដែលបង្កការខូចខាតដល់បរិស្ថាន។<br>មាត្រា ៣ – ផែនការជាតិស្តីពីបរិស្ថាន គឺជាផែនការស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយនិរន្តរភាព សម្រាប់អនុវត្តទូទាំងព្រះរាជាណាចក្រកម្ពុជា។ |
| *1.2 បញ្ចៀសការបំប្លែង ឬការធ្វើឱ្យរេចរឹលដែនជម្រកធម្មជាតិសំខាន់ៗ។* | *ធនាគារពុំគាំទ្រគម្រោងទាំងឡាយណាដែលបើតាមការយល់ឃើញរបស់ធនាគារ នាំឱ្យមានការបំប្លែង ឬធ្វើឱ្យរេចរឹលគួរឱ្យកត់សម្គាល់នូវដែនជម្រកធម្មជាតិឡើយ។* | ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិៈ<br>មាត្រា ៨ – តំបន់ការពារធនធានធម្មជាតិ ដែលរាប់បញ្ចូលឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព (និង) តំបន់ប្រើប្រាស់ច្រើនយ៉ាងត្រូវកំណត់ដោយព្រះរាជក្រឹត្យ។ |
| *1.3 ប្រើប្រាស់ដីធ្លីដែលត្រូវបានបំប្លែងពីដែនជម្រកធម្មជាតិរួចទៅហើយ ដើម្បីកាត់បន្ថយផលប៉ះពាល់ឱ្យនៅតិចជាអប្បបរមា។* | *ក្នុងករណីដែលអាចធ្វើទៅបាន គម្រោងដែលទទួលបានហិរញ្ញប្បទានពីធនាគារ ត្រូវមានទីតាំងស្ថិតនៅលើដី ដែលត្រូវបានបំប្លែងរួចទៅហើយ។* | ពុំត្រូវបានបញ្ចូល |
| *1.4 តម្រូវឱ្យមានប្រើប្រាស់អ្នកជំនាញសមស្របសម្រាប់រៀបចំ និងអនុវត្តផែនការសម្រាលផលប៉ះពាល់ និងពិនិត្យតាមដាន។* | *ប្រសិនបើអាចមានបញ្ហាពាក់ព័ន្ធនឹងសមត្ថភាពស្ថាប័ន គម្រោងនេះ ត្រូវបញ្ចូលសមាសភាគ ដែលអភិវឌ្ឍន៍សមត្ថភាពរបស់ស្ថាប័ននៅថ្នាក់ជាតិ និងស្ថាប័ននៅថ្នាក់មូលដ្ឋាន ដើម្បីឱ្យមានការរៀបចំផែនការ និងគ្រប់គ្រងបរិស្ថានប្រកបដោយប្រសិទ្ធភាព។ វិធានការសម្រាលផលប៉ះពាល់ ដែលត្រូវបានកំណត់សម្រាប់គម្រោងអាចប្រើប្រាស់ ដើម្បីបង្កើនសមត្ថភាពអនុវត្តការងាររបស់ស្ថាប័ននៅថ្នាក់ជាតិ និងស្ថាប័ននៅថ្នាក់ មូលដ្ឋាន។* | ពុំត្រូវបានបញ្ចូល |
| ***2. កិច្ចពិគ្រោះយោបល់ជាសាធារណៈ និងការបង្ហាញព័ត៌មានជាសាធារណៈ*** | | |
| *2.1 ពិគ្រោះយោបល់ជាមួយតួអង្គពាក់ព័ន្ធសំខាន់ៗ និងអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជា បង្ហាញជាសាធារណៈនូវពង្រាងផែនការសម្រាលផលប៉ះពាល់ឱ្យបានទាន់ពេលវេលា* | *ធនាគាររំពឹងថាអ្នកខ្ចីនឹងធ្វើការពិចារណាលើទស្សនៈយល់ឃើញ តួនាទី និងសិទ្ធិរបស់ក្រុមនានារាប់បញ្ចូលទាំងអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូល ដ្ឋាន ដែលរងផលប៉ះពាល់ដោយសារគម្រោង* | ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិៈ<br>មាត្រា ១ – គោលបំណងនៃច្បាប់នេះ រួមានៈ<br>○ ដើម្បីលើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណជនចូលរួមក្នុងការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ |

| ប្រធានបទ | គោលនយោបាយ OP 4.04 | រាជរដ្ឋាភិបាលកម្ពុជា |
|---|---|---|
| *មុនពេលដែលការវាយតម្លៃចាប់ផ្តើមធ្វើឡើងជាផ្លូវការ នៅទីកន្លែងដែលងាយស្រួលចូលរួម និងក្នុងទម្រង់ និងភាសាដែលអាចយល់បាន ចំពោះតួអង្គពាក់ព័ន្ធសំខាន់ៗ។* | *ដែលផ្តល់ហិរញ្ញប្បទានដោយធនាគារ ដែលជាប់ទាក់ទិននឹងដែនជម្រកធម្មជាតិ និងត្រូវជំរុញឱ្យមានការចូលរួមពីអ្នកទាំងនេះ ក្នុងការរៀបចំផែនការ ការគាក់តែងការអនុវត្ត ការពិនិត្យតាមដាន និងការវាយតម្លៃគម្រោងទាំងនេះ។* | មាត្រា ១៦ – ក្រសួងបរិស្ថានបន្ទាប់ពីមានការស្នើសុំពីសាធារណជន ត្រូវផ្តល់ព័ត៌មានអំពីសកម្មភាពរបស់ខ្លួន និងជំរុញឱ្យសាធារណជនបានចូលរួមក្នុងការការពារបរិស្ថាន និងធនធានធម្មជាតិ។<br>អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (ឆ្នាំ ១៩៩៩)៖<br>▪ មាត្រា ១ – លើកកម្ពស់ការចូលរួមរបស់សាធារណជនក្នុងដំណើរការវាយតម្លៃផលប៉ះពាល់ហេតុបរិស្ថាន ដោយទទួលស្គាល់ថា ការព្រួយបារម្ភរបស់ពួកគេ គួរយកមកធ្វើការពិចារណាក្នុងដំណើរការធ្វើសេចក្តីសម្រេចចិ |

តារាងទី ៣៖ ការវិភាគគម្លាតរវាងក្របខ័ណ្ឌច្បាប់/គតិយុត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយបាយ OP4.11 របស់ធនាគារពិភពលោក

| ប្រធានបទ | គោលនយោបាយ OP 4.04 | រាជរដ្ឋាភិបាលកម្ពុជា |
|---|---|---|
| ***1. ការការពារធនធានធម្មជាតិរូបវន្ត*** | | |
| *1.2 ជាផ្នែកមួយនៃការវាយតម្លៃបរិស្ថាន និងទៅតាមភាពសមស្រប ត្រូវចុះអង្កេតប្រមូលព័ត៌មាននៅមូលដ្ឋាន ដោយប្រើប្រាស់អ្នកឯកទេសដែលមានសមត្ថភាព ដើម្បីពិគ្រោះយោបល់ជាមួយអាជ្ញាធរពាក់ព័ន្ធរបស់រដ្ឋាភិបាល, អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ, អ្នកជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋ មូលដ្ឋាន ដើម្បីប្រមូលចងក្រងព័ត៍មានអំពីវត្តមាន និងសារៈសំខាន់នៃធនធានធម្មជាតិ រូបវន្ត។* | *ដើម្បីរៀបចំលក្ខខណ្ឌប្រតិបត្តិសម្រាប់ការវាយតម្លៃបរិស្ថាន អ្នកខ្ចីកម្ចីត្រូវកំណត់ពីបញ្ហាធនធានវប្បធម៌រូបវន្ត ដែលទំនងជានឹងកើតមានឡើងប្រសិនបើមាន ដែលត្រូវបញ្ចូលទៅក្នុងការវាយតម្លៃបរិស្ថាននេះ ដោយត្រូវធ្វើការពិគ្រោះយោបល់ជាមួយធនាគារ អ្នកជំនាញពាក់ព័ន្ធ និងក្រុមដែលរងផលប៉ះពាល់ដោយសារគម្រោង។* | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា៖<br>មាត្រា ៦៩ – រដ្ឋមានកាតព្វកិច្ចថែរក្សា និងការពារប្រាសាទបូរាណ សិល្បៈបូរាណ និងកែលម្អរមនីយដ្ឋានប្រវត្តិសាស្ត្រឡើងវិញ។<br>ច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌៖<br>មាត្រា ៧ – ការចុះបញ្ជីសារពើភ័ណ្ឌ គឺជាការកត់ត្រាបញ្ចូលនូវសម្បត្តិវប្បធម៌សាធារណៈ ឬឯកជន ដែលមានសារៈសំខាន់ខាងផ្នែកវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈ ឬសាសនា ទោះជាទ្រព្យសម្បត្តិទាំងនោះមិនតម្រូវឱ្យចាត់ថ្នាក់ជាប្រញាប់ក៏ដោយ។ |
| *1.2 សម្រាប់វត្ថុដែលអាចរកឃើញក្នុងអំឡុងពេលអនុវត្តគម្រោង ត្រូវមានការរៀបចំ នូវនីតិវិធីសម្រាប់ចាត់ចែង "វត្ថុដែលរកឃើញដោយចៃដន្យ" ក្នុងបរិបទនៃផែនការគ្រប់គ្រងធនធានវប្បធម៌រូបវន្ត ឬសមាសភាគធនធានវប្បធម៌រូបវន្ត នៃផែនការគ្រប់គ្រងបរិស្ថាន។* | *អ្នកខ្ចីកម្ចីត្រូវរៀបចំផែនការគ្រប់គ្រងធនធានវប្បធម៌រូបវន្ត ដែលមានបញ្ចូលវិធានការ ដើម្បីបញ្ចៀស ឬសម្រាលផលប៉ះពាល់អវិជ្ជមានលើធនធានវប្បធម៌រូបវន្ត កំណត់ពីរបៀបចាត់ចែងវត្ថុដែលរកឃើញដោយចៃដន្យ វិធានការដែលចាំបាច់ដទៃទៀត ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងប្រព័ន្ធពិនិត្យតាមដាន ដើម្បីតាមដានវឌ្ឍនភាពនៃកម្មភាពទាំងនេះ។* | ច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌៖<br>មាត្រា ៣៧ – នៅពេលកំពុងដំណើរការផ្សេងៗ ឬសកម្មភាពផ្សេងទៀត ហើយបានជួបប្រទះសម្បត្តិ វប្បធម៌ ដូចជា ប្រាសាទបែកបាក់ វត្ថុបូរាណ សំណល់ផ្ទះសម្បែងបូរាណ ទីបញ្ចុះសពបូរាណ សិលាចារឹក ឬសម្បត្តិវប្បធម៌ ដែលទាក់ទងដល់បុរេប្រវត្តិវិទ្យា បុរាណវិទ្យា ជាតិពន្ធុវិទ្យា បាសាណីភូតវិទ្យា ឬក៏សាសាដទៃទៀតនៃវិទ្យាសាស្ត្រ ដែលសិក្សាពីអតីតកាល ឬមនុស្សសាស្ត្រ, អ្នកដែលបានប្រទះឃើញសម្បត្តិទាំងនេះ និងម្ចាស់អចលនវត្ថុ ត្រូវតែបញ្ឈប់ការងារ ឬសកម្មភាពនោះ រួចរាយការណ៍ជាបន្ទាន់ជូនភ្នាក់ងារនគរបាលក្នុងតំបន់។ ភ្នាក់ងារនគរបាលនោះ ត្រូវបញ្ជូនរបាយការណ៍នេះយ៉ាងប្រញាប់ជូនទៅអភិបាលខេត្ត ក្រុង។ អភិបាលខេត្ត ក្រុង ត្រូវជូនព័ត៌មាននេះដល់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការ ដើម្បីធានាសង្គ្រោះសម្បត្តិវប្បធម៌ និងរមណីយដ្ឋានវប្បធម៌នោះ។ |
| ***2. កិច្ចពិគ្រោះយោបល់ជាសាធារណៈ និងការបង្ហាញព័ត៌មានជាសាធារណៈ*** | | |
| *2.1 បង្ហាញពង្រាងផែនការសម្រាលផលប៉ះពាល់ ជាផ្នែកមួយនៃដំណើរការវាយតម្លៃបរិស្ថាន ឬដំណើរការប្រហាក់ប្រហែល ឱ្យបានទាន់ពេលវេលា មុនពេលដែលការវាយតម្លៃចាប់ផ្តើមធ្វើជាផ្លូវការនៅទីកន្លែងដែលងាយស្រួលចូលទៅដល់ និង* | *ជាផ្នែកមួយនៃកិច្ចពិគ្រោះយោបល់សាធារណៈ ដែលត្រូវបានតម្រូវឱ្យធ្វើក្នុងដំណើរការវាយតម្លៃបរិស្ថាន ជាធម្មតា ដំណើរការពិគ្រោះយោបល់ពាក់ព័ន្ធនឹងសមាសភាគធនធានវប្បធម៌រូបវន្ត ត្រូវមានការចូលរួមពីក្រុម ដែលរងផលប៉ះពាល់ដោយសារគម្រោង អាជ្ញាធររដ្ឋាភិបាលដែលពាក់ព័ន្ធ* | ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ៖<br>មាត្រា ១ – គោលបំណងនៃច្បាប់នេះ រួមាន៖<br>○ ដើម្បីលើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណជនចូលរួមក្នុងការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។<br>មាត្រា ១៦ – ក្រសួងបរិស្ថានបន្ទាប់ពីមានការស្នើសុំពីសាធារណជន ត្រូវផ្តល់ព័ត៌មានអំពីសកម្មភាពរបស់ខ្លួន និងជំរុញឱ្យសាធារណជនបានចូលរួមក្នុងការការពារបរិស្ថាន និងធនធានធម្មជាតិ។<br>អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (ឆ្នាំ ១៩៩៩)៖ |

| ប្រធានបទ | គោលនយោបាយ OP 4.04 | រាជរដ្ឋាភិបាលកម្ពុជា | |
|---|---|---|---|
| *ក្នុងទម្រង់ និងភាសាដែលងាយស្រួលយល់ចំពោះតួអង្គពាក់ព័ន្ធសំខាន់ៗ។* | *អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធក្នុងការប្រមូលចងក្រងព័ត៌មានអំពីវត្តមាន និងសារៈសំខាន់នៃធនធានវប្បធម៌រូបវន្តវាយតម្លៃលើផលប៉ះពាល់ដែលអាចកើតមានឡើង និងស្វែងយល់ពីជម្រើសសម្រាប់បញ្ចៀសផលប៉ះពាល់និងសម្រាលផលប៉ះពាល់។*<br><br>*លទ្ធផលរកឃើញនៃសមាសភាគធនធានវប្បធម៌រូបវន្តនៃដំណើរការវាយតម្លៃបរិស្ថាននេះ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍វាយតម្លៃបរិស្ថាន និងតាមរបៀបដូចគ្នានឹងការបង្ហាញរបាយការណ៍នេះផងដែរ។* | ▪ មាត្រា ១ – លើកកម្ពស់ការចូលរួមរបស់សាធារណជនក្នុងដំណើរការវាយតម្លៃផលប៉ះពាល់ហេតុបរិស្ថាន ដោយទទួលស្គាល់ថា ការព្រួយបារម្ភរបស់ពួកគេគួរយកមកធ្វើការពិចារណាក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ | |

## ឧបសម្ព័ន្ធ ២.១៖ បញ្ជីសកម្មភាព ដែលពុំបានបំពេញតាមលក្ខណៈវិនិច្ឆ័យសមស្រប

សកម្មភាពខាងក្រោមនេះ ត្រូវបានហាមឃាត់ក្រោម LACP (សកម្មភាពពុំបានបំពេញតាមលក្ខណៈវិនិច្ឆ័យសមស្រប ឬ "បញ្ជីសកម្មភាពដែលពុំបានបំពេញតាមលក្ខណៈវិនិច្ឆ័យសមស្រប") ដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានដែលពុំអាចប្ដូរត្រឡប់មកវិញបាន លើបរិស្ថាន និងមនុស្ស ហើយសកម្មភាពខាងក្រោមនេះ ត្រូវបានផាត់ចេញយ៉ាងជាក់ច្បាស់ពីការផ្ដល់ហិរញ្ញប្បទានៈ

(i) ការផ្លាស់ប្ដូរទីតាំង និង/ឬការរំលំផ្ទះ ឬអាជីវកម្មដែលមានទីតាំងជាអចិន្ត្រៃយ៍។

(ii) ការប្រើប្រាស់ការវិនិយោគ ឬអនុគម្រោងរបស់ LACP ជាគ្រឿងលើកទឹកចិត្ត និង/ឬឧបករណ៍ដើម្បីគាំទ្រ និង/ឬអនុវត្តការផ្លាស់ប្ដូរទីលំនៅដោយមិនស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងភូមិរបស់ប្រជាពលរដ្ឋ។

(iii) លទ្ធកម្មដីធ្លីដែលបង្កផលប៉ះពាល់ដល់ប្រជាពលរដ្ឋជាង ២០០ នាក់ ឬ ២០ គ្រួសារ។

(iv) ការតាំងទីលំនៅថ្មី ឬការពង្រីកតំបន់តាំងទីលំនៅដែលមានស្រាប់ នៅក្នុង "តំបន់ការពារទាំងស្រុង" ដូចដែលត្រូវបានកំណត់នៅក្នុងច្បាប់របស់រដ្ឋាភិបាល។

(v) លទ្ធភាពនាំឱ្យមានផលប៉ះពាល់អវិជ្ជមានលើក្រុមជនជាតិភាគតិចនៅក្នុងភូមិ និង/ឬក្នុងភូមិដែលនៅក្បែរខាង ឬពុំអាចទទួលយកបានចំពោះក្រុមជនជាតិភាគតិចដែលរស់នៅក្នុងភូមិ ដែលមានជនជាតិភាគតិចតែមួយក្រុមរស់នៅជុំគ្នា ឬក្នុងភូមិដែលមានជនជាតិភាគតិចរស់នៅលាយចម្រុះគ្នា។

(vi) ការផ្ដល់គំនិត និងផ្លាស់ប្ដូរអាទិភាព ដែលត្រូវបានកំណត់ដោយសហគមន៍ និងដែលបានទទួលបានការគាំទ្រក្នុងកិច្ចប្រជុំនៅកម្រិត Kumban ដោយពុំមានការពិគ្រោះយោបល់ជាមួយសហគមន៍ ការពិនិត្យឡើងវិញជាមុន និងការឯកភាពពី PMT។

(vii) ការខូចខាត ឬការបាត់បង់សម្បត្តិវប្បធម៌ ដូចជា ទីតាំងដែលមានតម្លៃបុរាណវិទ្យា (បុរេប្រវត្តិសាស្ត្រ), បាសាណិភូតវិទ្យា, ប្រវត្តិសាស្ត្រ, សាសនា, វប្បធម៌ និងតម្លៃធម្មជាតិពិសេស។

(viii) ការរឹតត្បិតលើការប្រើប្រាស់ធនធាន ដែលពុំអាចកាត់បន្ថយបាន និងដែលបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានលើជីវភាពរស់នៅរបស់ក្រុមជនជាតិភាគតិច និងអ្នកដែលជួបការលំបាក។

(ix) ការកសាងផ្លូវថ្មី ការជួសជុលកែលម្អផ្លូវ ការក្រាលកៅស៊ូផ្លូវ ឬការកែលម្អផ្លូវតូចៗ ការសាងសង់ប្រព័ន្ធធារាសាស្ត្រថ្មីៗ នៅខាងក្នុងដែនជម្រកធម្មជាតិ ឬក្នុងតំបន់ការពារដែលកំពុងមានបច្ចុប្បន្ន ឬតំបន់ការងារដែលត្រូវបានលើកស្នើឡើង។

(x) ការទិញកាំភ្លើង, រណារអាឈើ, សារធាតុអាបេស្តូស, រំសេវផ្ទុះ, ឧបករណ៍បរបាញ់ និងនេសាទដែលនាំឱ្យមានការបំផ្លិចបំផ្លាញ និងការវិនិយោគផ្សេងទៀត ដែលបង្កការខូចខាតដល់បរិស្ថាន។

(xi) ការទិញថ្នាំកសិកម្ម, ថ្នាំបំពុលសត្វល្អិត, ថ្នាំកំចាត់ស្មៅចង្រៃ ដែលត្រូវបានហាមឃាត់ និងថ្នាំកសិកម្ម ថ្នាំបំពុលសត្វល្អិត និងថ្នាំកម្ចាត់ស្មៅចង្រៃ និងសារធាតុគីមីដែលពុំត្រូវបានហាមឃាត់ផ្សេងទៀត លើសពីបរិមាណ ដែលត្រូវការជាចាំបាច់ ដើម្បីកម្ចាត់សមាសភាគចង្រៃ សត្វល្អិត និងស្មៅចង្រៃប្រកបដោយប្រសិទ្ធភាព។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើមានការលុកលុយដោយសមាសភាគចង្រៃ ការប្រើប្រាស់ថ្នាំកសិកម្មសមស្រប ដែលមានចុះបញ្ជីត្រឹមត្រូវក្នុងបរិមាណតិចតួច ត្រូវបានអនុញ្ញាតនៅក្នុងប្រទេសឡាវ ប្រសិនបើមានការផ្ដល់ការបណ្ដុះបណ្ដាលបន្ថែមដល់កសិករ ដើម្បីធានាឱ្យមានការប្រើប្រាស់ថ្នាំកសិកម្មប្រកបដោយសុវត្ថិភាព ស្របតាមគោលនយោបាយ និងនីតិវិធីរបស់ធនាគារ (ចាំបាច់ត្រូវមានការអនុញ្ញាតពីធនាគារ)។ ថ្នាំកសិកម្ម ថ្នាំកម្ចាត់សត្វល្អិត និងថ្នាំកម្ចាត់ស្មៅចង្រៃ នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រើក្នុងដែនបម្រុងនៃតំបន់ការពារ ព្រៃការពារ និងដែនជម្រកធម្មជាតិឡើយ។

(xii) ប្រតិបត្តិការព្រៃឈើ ដូចជា ការកាប់ឈើ ការប្រមូលផល ឬការកែច្នៃឈើ និងអនុផលព្រៃឈើ។

(xiii) ការទាញប្រយោជន៍ពីធនធានធម្មជាតិ ដោយពុំមាននិរន្តរភាព

(xiv) ការនាំមកនូវពពួកសត្វរុក្ខជាតិ ដែលពុំមានប្រភពក្នុងទីតាំងនេះ លើកលែងតែសត្វរុក្ខជាតិទាំងនោះមានវត្តមានរួចទៅហើយនៅក្នុងបរិវេណជុំវិញ ឬត្រូវបានគេដឹងថាពុំមានលក្ខណៈបំផ្លិចបំផ្លាញពពួកសត្វរុក្ខជាតិដទៃទៀត ដែលស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា។

(xv) ការបំប្លែង ឬការធ្វើឱ្យរេចរឹលគួរឱ្យកត់សម្គាល់នូវដែនជម្រកធម្មជាតិ ឬនៅក្នុងករណីដែលផលចំណេញខាងការអភិរក្ស និង/ឬបរិស្ថាន ត្រូវបានរកឃើញច្បាស់ថាពុំមានលើសពីការបាត់បង់ ដែលអាចកើតមានឡើង។

(xvi) ផលិតកម្ម ឬពាណិជ្ជកម្មផលិតផល ឬសកម្មភាពដែលត្រូវបានចាត់ទុកថាពុំស្របច្បាប់ក្រោមច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តរបស់ប្រទេសឡាវ ឬអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ ឬដែលទទួលរងការហាមប្រាមជាអន្តរជាតិ។

(xvii) លក្ខខណ្ឌពលកម្ម និងលក្ខខណ្ឌការងារមានពាក់ព័ន្ធនឹងទម្រង់ពលកម្មដែនាំឱ្យមានគ្រោះថ្នាក់ ជាការកេងប្រវ័ញ្ច មិនស្ម័គ្រចិត្ត ឬការបង្ខិតបង្ខំ ពលកម្មដោយបង្ខំ[4] ពលកម្មកុមារ[5] ឬនាំឱ្យមានបញ្ហាសុខភាព និងសុវត្ថិភាពការងារគួរឱ្យកត់សម្គាល់។

(xviii) ពាណិជ្ជកម្មផលិតផលជាមួយនឹងសហគ្រាស ដែលជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិអំពើកេងប្រវ័ញ្ច ដែលនាំឱ្យមានផលប៉ះពាល់ដល់បរិស្ថាន និងសង្គម។

(xix) អនុគម្រោងដែលប្រើប្រាស់ ឬនាំឱ្យមានការប្រើប្រាស់សារធាតុបង្កគ្រោះថ្នាក់ (ដូចជាសារធាតុអាបេស្តូស) ឬសារធាតុគីមីហាមឃាត់។

**បញ្ជីអាទិភាព**

(i) ជំរុញលើកកម្ពស់ការធ្វើកសិកម្មបែបវិលជុំ និងការធ្វើកសិកម្មប្រកបដោយនិរន្តរភាព

(ii) ជំរុញលើកកម្ពស់ការអភិរក្សធនធានទឹក

(iii) ជំរុញឱ្យមានការប្រើប្រាស់ថ្នាំកសិកម្មធម្មជាតិ/សរីរាង្គ ដែលផលិតពីរុក្ខជាតិឱសថ ជៀសជាងថ្នាំកសិកម្មគីមី ក៏ដូចជា ជំរុញឱ្យមានការគ្រប់គ្រងសមាសភាគចង្រៃបែបចម្រុះ

(iv) ជំរុញឱ្យមានការអភិវឌ្ឍជំនាញ ដើម្បីបង្កើនប្រាក់ចំណូល

(v) ជំរុញឱ្យមានការកែលម្អរោងម៉ាស៊ីនកិនស្រូវ ដោយមានការបំពាក់ប្រព័ន្ធត្រួតពិនិត្យធូលី

---

[4] *ពលកម្មដោយបង្ខំ មានន័យថា រាល់ការងារ ឬសេវាដែលពុំត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត ដែលធ្វើឡើងបុគ្គលណាម្នាក់ក្រោមការគំរាមកំហែងថានឹងមានការប្រើកម្លាំង ឬការដាក់ទោស។*

[5] *ពលកម្មកុមារដែលនាំឱ្យមានគ្រោះថ្នាក់ មានន័យថា ជាការជួលកុមារឱ្យធ្វើការងារក្នុងទម្រង់កេងប្រវ័ញ្ចសេដ្ឋកិច្ច ឬការងារដែលទំនងជានាំឱ្យមានគ្រោះថ្នាក់ ឬរំខានដល់ការអប់រំរបស់កុមារ ឬបង្កគ្រោះថ្នាក់ដល់សុខភាពកុមារ ឬការអភិវឌ្ឍកាយសម្បទា បញ្ញាស្មារតី ទឹកចិត្ត ឬការអភិវឌ្ឍសង្គមរបស់កុមារ។*

## ឧបសម្ព័ន្ធ ២.២៖ បញ្ជីត្រួតពិនិត្យបឋមលើបរិស្ថាន និងសង្គមសម្រាប់អនុគម្រោង

| |
|---|
| ក្រសួងពាក់ព័ន្ធ (PTs) *ដើម្បីឱ្យក្រសួងទាំងនេះ អាចធ្វើការកំណត់ពីប្រភេទឯកសារការពារផលប៉ះពាល់ ដែលធនាគារពិភពលោកតម្រូវឱ្យមាន សម្រាប់អនុគម្រោង ស្របតាម ESMF។* |

**ឈ្មោះគម្រោង**

ឈ្មោះអនុគម្រោង៖

ទីតាំងអនុគម្រោង៖ *(ឧទាហរណ៍ ខេត្ត ស្រុក ។ល។)*

ប្រភេទសកម្មភាព៖ *(ឧទាហរណ៍ ការសាងសង់ថ្មី ការជួសជុលកែលម្អ ការថែទាំតាមកាលកំណត់)*

ម្ចាស់អនុគម្រោង និងអាសយដ្ឋាន៖

ប្រភេទបរិស្ថាននៃគម្រោងចម្បង៖ *(ឧទាហរណ៍ A ឬ B)*

1. ការពិនិត្យបឋមលើលក្ខណ:សមស្រប

1. ការពិនិត្យបឋមលើលក្ខណ:សមស្រប ត្រូវបានធ្វើឡើង ដើម្បីកំណត់ថាតើអនុគម្រោងមួយសមស្របសម្រាប់ទទួលបានហិរញ្ញប្បទាន ក្រោមគម្រោងនេះដែរឬទេ។ ដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានគួរឱ្យកត់សម្គាល់មកលើបរិស្ថាន និងសង្គម, គម្រោងមួយចំនួនអាចបញ្ចូលលក្ខណ:វិនិច្ឆ័យកំណត់ពីភាពមិនសមស្រប ឬបង្កើតជាបញ្ជីសកម្មភាពមិនសមស្រប ដែលត្រូវផាត់ចេញពីអនុគម្រោង។ លក្ខណ:វិនិច្ឆ័យទាំងនេះ ឬបញ្ជីសកម្មភាពមិនសមស្រប ត្រូវបានបញ្ចូលទៅក្នុង ESMF ហើយក្នុងអំឡុងពេលអនុវត្តគម្រោង មានការពិនិត្យលើអនុគម្រោងដោយផ្ទៀបនឹងលក្ខណ:វិនិច្ឆ័យទាំងនេះ។ សូមមើលឧបសម្ព័ន្ធ ២.១។

2. លើសពីនេះ មានអនុគម្រោងមួយចំនួន ដែលធនាគារពុំផ្តល់ហិរញ្ញប្បទានទាល់តែសោះតែម្តង (សូមពិនិត្យមើលគោលនយោបាយស្តីពីការការពារផលប៉ះពាល់របស់ធនាគារ)។

សូមកត់សម្គាល់ថាម្ចាស់អនុគម្រោង ត្រូវអនុលោមទៅតាមរាល់ច្បាប់ និងស្តង់ដារជាតិទាំងអស់ ព្រមទាំងកាតព្វកិច្ច (ដូចជា ស្តង់ដារ ការហាមប្រាម ឬលក្ខខណ្ឌស្រដៀងគ្នានេះ) របស់ប្រទេស ក្រោមអនុសញ្ញា សន្ធិសញ្ញា កិច្ចព្រមព្រៀង និងពិធីសារអន្តរជាតិនានា។

2. ការពិនិត្យបឋមបច្ចេកទេសលើបរិស្ថាន

3. ការពិនិត្យបឋមបច្ចេកទេសលើបរិស្ថាននៃអនុគម្រោង ដែលត្រូវបានលើកស្នើឡើងនីមួយៗ មានគោលបំណងកំណត់ពីវិសាលភាព និងប្រភេទសមស្របនៃការវាយតម្លៃបរិស្ថាន។ លទ្ធផលនៃការពិនិត្យបឋមនេះ នឹងត្រូវប្រើប្រាស់ ដើម្បីបែងចែកប្រភេទអនុគម្រោងជាប្រភេទណាមួយក្នុងចំណោមប្រភេទទាំងបី អាស្រ័យទៅតាមប្រភេទទីតាំង ភាពងាយរងផលប៉ះពាល់ និងវិសាលភាពនៃអនុគម្រោង និងលក្ខណ: ព្រមទាំងវិសាលភាពនៃផលប៉ះពាល់ ដែលអាចកើតមានឡើងលើបរិស្ថាន (កថាខណ្ឌ ៨ នៃ OP 4.01)។

(ក) ប្រភេទ A៖ អនុគម្រោងដែលត្រូវបានស្នើឡើង ត្រូវបានបែងចែកជាគម្រោងប្រភេទ A ប្រសិនបើគម្រោងនេះ ទំនងជាបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានគួរឱ្យកត់សម្គាល់មកលើបរិស្ថាន ដែលមានលក្ខណ:រសើប ចម្រុះ និងដែលពុំធ្លាប់មានកន្លងមក។ ផលប៉ះពាល់ទាំងនេះ អាចប៉ះពាល់ដល់តំបន់មួយ ដែលមានទំហំធំជាងទីតាំង ឬទីកន្លែង

ដែលត្រូវមានការអនុវត្តការងារជាក់ស្តែង។

(ខ) ប្រភេទ B៖ អនុគម្រោងដែលត្រូវបានស្នើឡើងមួយត្រូវបានចាត់ថ្នាក់ថាជាប្រភេទ B ប្រសិនបើគម្រោងនេះបង្កផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថាន របស់ប្រជាពលរដ្ឋ ឬតំបន់ដែលមានសារៈសំខាន់ផ្នែកបរិស្ថាន ដូចជា តំបន់ដីសើម ព្រៃឈើ ដីស្មៅ ឬដែនជម្រកដទៃទៀត ដែលផលប៉ះពាល់ទាំងនេះ មានលក្ខណៈអវិជ្ជមានតិចតួចជាងគម្រោងប្រភេទ A។ ផលប៉ះពាល់ទាំងនេះ កើតឡើងតែនៅតាមទីតាំងជាក់លាក់ ហើយមានផលប៉ះពាល់មួយចំនួន អាចជាផលប៉ះពាល់ដែលពុំអាចប្តូរត្រលប់មកស្ថានភាពដើមវិញបាន ហើយនៅក្នុងករណីមួយចំនួន គេអាចរៀបចំវិធានការសម្រាលផលប៉ះពាល់បានស្រួលជាងគម្រោងប្រភេទ A។

(គ) ប្រភេទ C៖ គម្រោងដែលត្រូវបានស្នើឡើងណាមួយ ត្រូវបានបែងចែកថាជាប្រភេទ C ប្រសិនបើគម្រោងនេះទំនងជានាំឱ្យមានផលប៉ះពាល់អវិជ្ជមានតិចតួច ឬពុំមានផលប៉ះពាល់អវិជ្ជមានសោះ។ ក្រៅតែពីការពិនិត្យបឋម ពុំចាំបាច់មានការវាយតម្លៃបរិស្ថានសម្រាប់គម្រោងប្រភេទ C ឡើយ។

**2.1** លក្ខណៈវិនិច្ឆ័យសម្រាប់ពិនិត្យបឋមលើគម្រោងប្រភេទ **A**

4. សំណួរសម្រាប់ពិនិត្យបឋមខាងក្រោម គឺសម្រាប់កំណត់ថាតើអនុគម្រោងអាចបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានគួរឱ្យកត់សម្គាល់ដែរឬទេ (ពោលថាតើអនុគម្រោងនេះ ត្រូវបានចាត់ថ្នាក់ថាជាអនុគម្រោងប្រភេទ A ដែរឬទេ)។

| **តារាងទី ១. លក្ខណៈវិនិច្ឆ័យសម្រាប់ពិនិត្យបឋមលើគម្រោងប្រភេទ** A | | | |
|---|---|---|---|
| **សំណួរពិនិត្យបឋម** | **មាន** | **ពុំមាន** | **យោបល់** |
| **1. តើអនុគម្រោងនេះ អាចបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានគួរឱ្យកត់សម្គាល់ដល់ដែនជម្រកធម្មជាតិ ឬដែនជម្រកធម្មជាតិសំខាន់ៗដែរឬទេ?** | | | |
| នាំឱ្យមានការបាត់បង់ ឬការរេចរឹលដែនជម្រកធម្មជាតិ ដែលងាយរងផលប៉ះពាល់ ដូចជា៖ តំបន់ដីគោក និងតំបន់ទឹក ដែល (i) សហគមន៍ជីវសាស្ត្រនៃប្រព័ន្ធបរិស្ថាន ត្រូវបានបង្កើតឡើងដោយពពួករុក្ខជាតិ និងពពួកសត្វព្រៃដែលមានដើមកំណើតក្នុងតំបន់នោះ និង (ii) សកម្មភាពរបស់មនុស្សពុំបានធ្វើឱ្យមានការប្រែប្រួលដល់មុខងារអេកូឡូស៊ីចម្បងរបស់តំបន់នោះ។ ដែនជម្រកធម្មជាតិសំខាន់ៗ អាចមាននៅក្នុងតំបន់ព្រៃត្រូពិច សើម ស្ងួត និងសំបូរដោយពពក, ព្រៃtemperate និង boreal, ដីដែលមានគុម្ពោតព្រៃប្រភេទមេឌីទែរ៉ាណេ, ដីធម្មជាតិស្ងួត និងពាក់កណ្តាលស្ងួត, វាលភក់ព្រៃកោងកាង, តំបន់ដីសើមនៅតាមតំបន់ឆ្នេរ និងតំបន់ដីសើមដទៃទៀត, តំបន់ estuaries, តំបន់សម្បូរស្មៅបាតសមុទ្ទ, តំបន់ដែលសំបូរដោយផ្កាថ្ម, បឹងទឹកសាប និងទន្លេ, បរិស្ថានស្រល់ និងបរិស្ថានស្រល់តូចៗ រួមនឹងតំបន់ដែលសំបូរដោយរុក្ខជាតិឱសថ វាលស្មៅ និងតំបន់ paramos, និងតំបន់ដីស្មៅត្រូពិច និង temperate។ | | | បង្ហាញពីទីតាំង និងប្រភេទដែនជម្រកធម្មជាតិ និងប្រភេទផលប៉ះពាល់ដែលអាចកើតមានឡើង ឧទាហរណ៍ ការបាត់បង់ដែនជម្រក និងទំហំនៃការបាត់បង់ ការបាត់បង់សេវាប្រព័ន្ធបរិស្ថាន ផលប៉ះពាល់លើគុណភាពនៃដែនជម្រក។ លើកឡើងពីមូលហេតុ ដែលផលប៉ះពាល់ទាំងនេះ សំខាន់ ឬមិន សំខាន់។<br>សូមកត់សម្គាល់ថា ធនាគារមិនគាំទ្រគម្រោង ទាំងឡាយណាដែលពាក់ព័ន្ធនឹងការបំប្លែងដែនជម្រកធម្មជាតិក្នុងកម្រិតគួរឱ្យកត់សម្គាល់ឡើយ លើកលែងតែពុំមានជម្រើសផ្សេងទៀត សម្រាប់គម្រោង និងទីតាំងរបស់គម្រោង ហើយការវិភាគគ្រប់ជ្រុងជ្រោយ បង្ហាញថា អត្ថប្រយោជន៍ជារួម ដែលបាន |

| | | | |
|---|---|---|---|
| | | | ពីគម្រោងនេះ មានលើសពី ការខាតបង់ ចំពោះបរិស្ថាន ក្នុងកម្រិតមួយ ច្រើន។ |
| នាំឱ្យមានការបាត់បង់ ឬការរេចរឹល ដែនជម្រកធម្មជាតិ សំខាន់ៗ ដូចជា ដែនជម្រក ដែលត្រូវបានការពារដោយច្បាប់ ដែនជម្រកដែលត្រូវបានស្នើឡើងជាផ្លូវការ ដើម្បីទទួលបានការការពារ ឬដែនជម្រកដែលពុំបានទទួលការការពារ ប៉ុន្តែត្រូវបានដឹងថាមានតម្លៃខ្ពស់ផ្នែកអភិរក្ស។ ដែនជម្រក សំខាន់ៗរួមមាន តំបន់ការពារដែលមានស្រាប់ និងតំបន់ដែលត្រូវបានរដ្ឋាភិបាលស្នើជាផ្លូវការ ឱ្យធ្វើជាតំបន់ការពារ (ឧទាហរណ៍ ដែនបម្រុង ដែលបំពេញទៅតាមលក្ខណៈ វិនិច្ឆ័យនៃចំណាត់ថ្នាក់របស់សហព័ន្ធអភិរក្សពិភពលោក [IUCN], តំបន់ដែលត្រូវបានទទួលស្គាល់បឋមថាជា តំបន់ការពារដោយសហគមន៍មូលដ្ឋានបែបប្រពៃណី (ឧទាហរណ៍ ព្រៃអារក្ស) និងទីតាំងដែលរក្សាបាននូវស្ថានភាព ដែលមានសារៈសំខាន់សម្រាប់ និរន្តរភាពនៃតំបន់ការពារទាំងនេះ។ ទីតាំងនេះ អាចរួមមាន តំបន់ដែលគេដឹងថាមានភាពសមស្រប កម្រិតខ្ពស់សម្រាប់ការអភិរក្សជីវៈចម្រុះ និងទីតាំង ដែលមានសារៈសំខាន់សម្រាប់ពពួកសត្វកម្រ ពពួកសត្វងាយរងគ្រោះ ពពួកសត្វពនេចរ ឬពពួក សត្វដែលជិតដាច់ពូជ។ | | | សម្គាល់ថា ធនាគារពុំអាចផ្តល់ ហិរញ្ញប្បទានដល់គម្រោងទាំងឡាយណា ដែលនាំឱ្យមានការបំប្លែង ឬការ រេចរឹលគួរឱ្យកត់សម្គាល់នូវដែនជម្រក ធម្មជាតិសំខាន់ៗឡើយ។<br><br>សូមបង្ហាញពីទីតាំង និងប្រភេទ ដែនជម្រកធម្មជាតិសំខាន់ៗ និងបញ្ជាក់ពីមូលហេតុដែល ដែនជម្រកទាំងនេះ មានសារៈសំខាន់ ឬពុំមានសារៈសំខាន់។ |
| **2. តើអនុគម្រោងនេះមានសក្តានុពលនាំឱ្យមានផលប៉ះពាល់អវិជ្ជមានគួរឱ្យកត់សម្គាល់មកលើធនធាន វប្បធម៌រូបវន្តដែរឬទេ?** | | | |
| នាំឱ្យមានការបាត់បង់ឬការរេចរឹលធនធានធម្មជាតិ រូបវន្ត ដូចជាចលនវត្ថុ ឬអចលនវត្ថុ ទីតាំង សំណង់ ក្រុមសំណង់ និងទេសភាពធម្មជាតិ ដែល មានសារៈសំខាន់ផ្នែកបូរាណវិទ្យា បាសាណិភូតវិទ្យា ប្រវត្តិសាស្ត្រ ស្ថាបត្យកម្ម សាសនា សោភ័ណ្ឌភាព ឬ សារៈសំខាន់ផ្នែកវប្បធម៌ដទៃទៀត។ ធនធានទាំងនេះ អាចមានទីតាំងនៅតំបន់ប្រជុំជន ឬតំបន់ជនបទ នៅខាងលើ ឬខាងក្រោមដី ឬក្រោមទឹក។ ធនធានទាំងនេះ អាចផ្តល់នូវប្រយោជន៍ វប្បធម៌នៅថ្នាក់មូលដ្ឋាន ថ្នាក់ខេត្ត ឬថ្នាក់ជាតិ ឬក្នុង សហគមន៍អន្តរជាតិ។ | | | រៀបរាប់ពីទីតាំង ឬប្រភេទ ធនធានវប្បធម៌ និងប្រភេទ ផលប៉ះពាល់ដែលអាចកើតមានឡើង។ សូមបញ្ជាក់ពីកម្រិតនៃការការពារ (កម្រិតមូលដ្ឋាន ខេត្ត ជាតិ ឬអន្តរជាតិ)។ តើមានទីតាំងណាក្នុងចំណោមទីតាំង ទាំងនេះត្រូវបានចាត់ទុកថា មានសារៈសំខាន់សម្រាប់ការ ការពារនៅនឹងកន្លែងដែរឬទេ មានន័យថា គេមិនគួរយក ធនធានទាំងនេះចេញពីទីតាំង បច្ចុប្បន្នរបស់វាឡើយ?<br><br>សូមបញ្ជាក់ពីមូលហេតុដែល ផលប៉ះពាល់ទាំងនេះជាផលប៉ះពាល់ សំខាន់ ឬមិនសំខាន់។ |
| អាចនាំឱ្យមានការប្រព្រឹត្តិផ្ទុយទៅនឹងច្បាប់ជាតិ ឬកាតព្វកិច្ចជាតិ ក្រោមសន្ធិសញ្ញា និងកិច្ចព្រមព្រៀងបរិស្ថានអន្តរជាតិ ពាក់ព័ន្ធ ដូចជា អនុសញ្ញា បេតិកភ័ណ្ឌពិភពលោករបស់ យូណេស្កូ ឬមានផលប៉ះពាល់លើទីតាំងដែល គេដឹងថាមានតម្លៃផ្នែកវប្បធម៌ ឬវិទ្យាសាស្ត្រ។ | | | រៀបរាប់ពីផលប៉ះពាល់នានា ដែលអាច ផ្ទុយទៅនឹងច្បាប់ជាតិ ឬអន្តរជាតិពាក់ព័ន្ធនឹង ធនធានធម្មជាតិ។ ប្រសិនបើចាត់ទុកថាមិនសំខាន់ សូមពន្យល់ពីមូលហេតុ។ |
| **3. តើអនុគម្រោងអាចបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានគួរឱ្យកត់សម្គាល់លើដីធ្លី និងធនធានធម្មជាតិ ពាក់ព័ន្ធ ដែលប្រើប្រាស់ដោយជនជាតិភាគតិចដែរឬទេ?** | | | |
| នាំឱ្យមានផលប៉ះពាល់លើដីធ្លី ឬដែនដីដែលជាកម្មសិទ្ធិ របស់សហគមន៍ប្រពៃណី ឬដែលត្រូវបានប្រើប្រាស់ | | | រៀបរាប់ពីប្រភេទ និងវិសាលភាពនៃ ផលប៉ះពាល់ និងសារៈសំខាន់នៃការ |

| | | | |
|---|---|---|---|
| ឬកាន់កាប់ជាទំនៀមទម្លាប់ និងដែលការទទួលបានធនធានធម្មជាតិ មានសារៈសំខាន់ចំពោះការធានានូវនិរន្តរភាពវប្បធម៌ និងជីវភាពរស់នៅរបស់ជនជាតិភាគតិច។ អាចបង្កផលប៉ះពាល់ដល់តម្លៃវប្បធម៌ និងការគោរពបូជានៃដៃ និងធនធានទាំងនេះ ឬបង្កផលប៉ះពាល់ដល់ការគ្រប់គ្រងធនធានធម្មជាតិ និងនិរន្តរភាពរយៈពេលវែងនៃធនធានដែលរងផលប៉ះពាល់។ | | | ផ្លាស់ប្តូរធនធានរបស់ជនជាតិភាគតិចដែលរងផលប៉ះពាល់។<br>សូមកត់សម្គាល់ថា ចាំបាច់ត្រូវមានការរៀបចំផែនការអភិវឌ្ឍន៍ជនជាតិភាគតិច ស្របតាមគោលនយោបាយ OP 4.10 របស់ធនាគារពិភពលោក។ |
| **4. តើអនុគម្រោងអាចបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានគួរឱ្យកត់សម្គាល់មកលើប្រជាពលរដ្ឋដែលងាយនឹងបាត់បង់ទីលំនៅដែរឬទេ?** | | | |
| នាំឱ្យមានការបាត់បង់ទីលំនៅរបស់ប្រជាពលរដ្ឋដែលពឹងអាស្រ័យលើដីធ្លី ឬប្រើប្រាស់ធនធានជាក់លាក់ ដែលពិបាកនឹងជំនួស ឬស្តារឡើងវិញ បើមិនដូច្នោះ បង្កឱ្យមានបញ្ហាលំបាកដល់អនុគម្រោង ក្នុងការស្តារជីវភាពរស់នៅឡើយវិញ ដែរឬទេ? | | | បញ្ជាក់ពីចំនួនគ្រួសារដែលរងផលប៉ះពាល់ និងធនធាន ដែលពិបាកនឹងជំនួស ដើម្បីស្តារជីវភាពរស់នៅឡើងវិញ។<br>សូមកត់សម្គាល់ថា ចាំបាច់ត្រូវមានការរៀបចំផែនការសកម្មភាពដោះស្រាយផលប៉ះពាល់/តាំងទីលំនៅ ស្របទៅតាមគោលនយោបាយ OP 4.12 របស់ធនាគារពិភពលោក។ |
| **5. តើអនុគម្រោងនេះ តម្រូវឱ្យមានការសាងសង់ទំនប់ធំដែរឬទេ?** | | | |
| តើគម្រោងនេះ តម្រូវឱ្យមានការសាងសង់ទំបន់ដែលៈ<br>• មានកម្ពស់ចាប់ពី ១៥ ម៉ែត្រឡើងទៅ<br>• កម្ពស់ចន្លោះពី ១០ ទៅ ១៥ ម៉ែត្រ ដោយការរៀបចំមានលក្ខណៈពិសេស ស្មុគស្មាញ ឧទាហរណ៍តម្រូវការស្តុកទឹកក្នុងទ្រង់ទ្រាយធំ មានទីតាំងនៅក្នុងតំបន់ដែលងាយទទួលរងគ្រោះរញ្ជួយដី គ្រឹះដែលស្មុគស្មាញ និងពិបាករៀបចំ ឬតម្រូវឱ្យមានការរក្សាទុកសារធាតុពុល។<br>• មានកម្ពស់ក្រោម ១០ ម៉ែត្រ ប៉ុន្តែរំពឹងថានឹងក្លាយជាទំនប់ធំ ក្នុងអំឡុងពេលប្រតិបត្តិការរបស់អនុគម្រោង? | | | សូមរៀបរាប់ពីបញ្ហា និងកត់សម្គាល់ពីលក្ខខណ្ឌតម្រូវនៃគោលនយោបាយ OP 2.37 ពាក់ព័ន្ធនឹងការតែងតាំគណៈកម្មាធិការជំនាញឯករាជ្យ។ |
| តើប្រតិបត្តិការនៃអនុគម្រោងពឹងអាស្រ័យលើដំណើរការនៃៈ<br>• ទំនប់ដែលមានស្រាប់ ឬទំនប់ដែលកំពុងសាងសង់ (DUC)<br>• ស្ថានីយថាមពល ឬប្រព័ន្ធផ្គត់ផ្គង់ទឹកដែលយកទឹកផ្ទាល់ចេញពីអាងស្តុកទឹក ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទំនប់ដែលមានស្រាប់ ឬទំនប់ដែលកំពុងសាងសង់<br>• ទំនប់បង្វែទិសទឹក ឬសំណង់ជលសាស្ត្រនៅខ្សែទឹកខាងក្រោម នៃទំនប់ដែលមានស្រាប់ ឬទំនប់ដែលកំពុងសាងសង់ ដែលការខូចខាតទំនប់នៅខ្សែទឹកខាងលើ អាចនាំឱ្យមានការខូចខាតក្នុងទ្រង់ទ្រាយធំ ឬធ្វើឱ្យប៉ះពាល់ដល់ដំណើរការនៃសំណង់ ឬគម្រោងធារាសាស្ត្រ ឬគម្រោងផ្គត់ផ្គង់ទឹកដែលទទួលបានហិរញ្ញប្បទានពីធនាគារ ដែលពឹងអាស្រ័យលើការស្តុកទឹក និងប្រតិបត្តិការនៃទំនប់ដែលមានស្រាប់ ឬទំនប់ដែលកំពុងសាងសង់ សម្រាប់ផ្គត់ផ្គង់ទឹក និងពុំអាចដំណើរការទៅបាន ប្រសិនបើទំនប់នោះលែងដំណើរការ។ | | | ប្រសិនបើមាន នេះមិនមែនមានន័យថា ចាំបាច់ត្រូវតម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងប្រភេទ A នោះឡើយ ប៉ុន្តែចាំបាច់ត្រូវមានការប្រុងប្រយ័ត្នជាពិសេស ដោយហេតុថា ធនាគារមានលក្ខខណ្ឌតម្រូវជាក់លាក់ ដើម្បីធានានូវសុវត្ថិភាពប្រតិបត្តិការគម្រោងដែលមានស្រាប់ គឺគម្រោងដែលកំពុងសាងសង់។ ធនាគារតម្រូវឱ្យមានការពិនិត្យ និងវាយតម្លៃលើទំនប់ ឬទំនប់ដែលកំពុងសាងសង់ នីតិវិធីដំណើរការ និងប្រតិបត្តិការ និងតំហែទាំរបស់ទំនប់នោះ ព្រមទាំងអនុសាសន៍សម្រាប់កែលម្អ ឬវិធានការពាក់ព័ន្ធនឹងសុវត្ថិភាព។ គេក៏អាចពិនិត្យផ្ទៀងផ្ទាត់លើការវាយតម្លៃដែលធ្វើកន្លងមកផងដែរ។ |

| | | | |
|---|---|---|---|
| **6. តើអនុគម្រោងនេះ តម្រូវឱ្យមានការធ្វើលទ្ធកម្ម ឬការប្រើប្រាស់ថ្នាំកសិកម្មដែរឬទេ?** | | | |
| តើរូបមន្តផលិតផលិតផលស្ថិតនៅក្រោមចំណាត់ថ្នាក់ IA និង IB របស់អង្គការសុខភាពពិភពលោក ឬតើមានការប្រើប្រាស់រូបមន្តផលិតផលក្នុងប្រភេទ II ដែរឬទេ? | | | ប្រសិនបើមាន នេះមិនមែនមានន័យថា ចាំបាច់ត្រូវតម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងប្រភេទ A នោះឡើយ ប៉ុន្តែចាំបាច់ត្រូវមានការប្រុងប្រយ័ត្នជាពិសេស។ ធនាគារនឹងមិនផ្តល់ហិរញ្ញប្បទានដល់ផលិតផលទាំងនេះឡើយ ប្រសិនបើ (ក) ប្រទេសពុំបានហាមឃាត់ការចែកចាយ និងការប្រើប្រាស់ផលិតផលទាំងនេះ ឬ (ខ) ផលិតផលទាំងនេះ ទំនងជានឹងត្រូវប្រើប្រាស់ ឬចូលប្រើប្រាស់ដោយបុគ្គលធម្មតា កសិករ ឬមនុស្សផ្សេងទៀតដែលពុំបានទទួលការបណ្តុះបណ្តាល ពុំមានឧបករណ៍ ឬបរិក្ខារសម្រាប់ទុកដាក់ ស្តុកទុក និងប្រើប្រាស់ផលិតផលទាំងនេះឱ្យបានត្រឹមត្រូវ។ |
| **7. តើអនុគម្រោងនេះ អាចនាំឱ្យមានផលប៉ះពាល់ដែលពុំអាចប្តូរត្រលប់ក្រោយវិញ ឬផលប៉ះពាល់ដែលពុំងាយសម្រាលដែលឬទេ?** | | | |
| នាំឱ្យមានការបាត់បង់តំបន់បញ្ចេញទឹក ប៉ះពាល់ដល់គុណភាពនៃការស្តុកទុកទឹក និងតំបន់រងទឹកភ្លៀង សម្រាប់ផ្គត់ផ្គង់ទឹកស្អាតដល់តំបន់ ដែលមានប្រជាពលរដ្ឋរស់នៅភាគច្រើន។ | | | សូមរៀបរាប់ពីដែនទឹកដែលរងផលប៉ះពាល់ និងរៀបរាប់ពីវិសាលភាពនៃផលប៉ះពាល់។ |
| នាំឱ្យមានផលប៉ះពាល់នានា ដូចជា រយៈពេលនៃផលប៉ះពាល់ និងមានជាអចិន្ត្រៃយ៍ ប៉ះពាល់ដល់តំបន់ភូមិសាស្ត្រ ឬផលប៉ះពាល់មានកម្រិតអាំងតង់ស៊ីតេខ្ពស់។ | | | រៀបរាប់ពីផលប៉ះពាល់ដែលនៅមានជាអចិន្ត្រៃយ៍ ប៉ះពាល់ដល់តំបន់ភូមិសាស្ត្រធំ (សូមកំណត់) និងផលប៉ះពាល់មានកម្រិតអាំងតង់ស៊ីតេខ្ពស់។ |
| **8. តើអនុគម្រោងអាចនាំឱ្យមានផលប៉ះពាល់អវិជ្ជមានគួរឱ្យកត់សម្គាល់ច្រើនប្រភេទដែរឬទេ?** | | | |
| តំបន់ជាច្រើន ដែលស្ថិតនៅតាមទីតាំងខុសៗគ្នា ដែលការរងផលប៉ះពាល់របស់តំបន់ទាំងនេះ អាចនាំឱ្យមានការបាត់បង់គួរឱ្យកត់សម្គាល់នូវដែនជម្រកធនធាន ដីធ្លី ឬធ្វើឱ្យប៉ះពាល់ដល់គុណភាពធនធាន។ | | | សូមកំណត់ និងរៀបរាប់ពីទីតាំងដែលរងផលប៉ះពាល់ទាំងអស់។ |
| ផលប៉ះពាល់អវិជ្ជមានគួរឱ្យកត់សម្គាល់ ទំនងជាសាយភាពលើសពីទីតាំង ឬទីកន្លែងដែលត្រូវមានការធ្វើការងាររូបវន្តជាក់ស្តែង។ | | | សូមកំណត់ និងរៀបរាប់ពីប្រភេទផលប៉ះពាល់ ដែលសាយភាយលើសពីទីតាំង ឬទីកន្លែង ដែលមានការអនុវត្តការងារជាក់ ស្តែង។ |
| ផលប៉ះពាល់ឆ្លងដែន (ក្រៅតែពីបម្រែបម្រួលតិចតួចចំពោះសកម្មភាពផ្លូវទឹក ដែលកំពុងមាន)។ | | | សូមរៀបរាប់ពីវិសាលភាពនៃផលប៉ះពាល់ឆ្លងដែន។ |
| ត្រូវការផ្លូវ រូង ប្រឡាយ របៀងបញ្ជូនចរន្តអគ្គិសនី បំពង់ប្រេង ឬរណ្តៅរូង និងតំបន់សម្រាប់ប្រើប្រាស់នៅកន្លែងដែល ពុំមានការអភិវឌ្ឍគ្រប់គ្រាន់នាពេលបច្ចុប្បន្ន។ | | | រៀបរាប់ពីគ្រប់សកម្មភាពទាំងអស់ដែលជាសកម្មភាពថ្មី ដែលចាំបាច់ត្រូវមាន ដើម្បីឱ្យសកម្មភាពចម្បងអាចដំណើរការទៅបាន។ |
| ការរំខានដល់បែបផែននៃការធ្វើពនេចររបស់សត្វព្រៃ ហ្វូងសត្វ ឬក្រុមគង្វាលសត្វលើវាលស្មៅ ក្រុមសហគមន៍ពនេចរ ឬ ក្រុមសហគមន៍ពាក់កណ្តាលពនេចរ។ | | | សូមរៀបរាប់ពីរបៀបដែលការធ្វើចំណាកស្រុករបស់មនុស្ស និងសត្វទាំងនេះ ត្រូវរងផលប៉ះពាល់។ |

| | | | |
|---|---|---|---|
| **9. តើអនុគម្រោងនេះ គឺជាអនុគម្រោងដែលពុំធ្លាប់មានកន្លងមកឬ?** | | | |
| ពុំធ្លាប់មាននៅថ្នាក់ជាតិ? | | | រៀបរាប់ពីមូលហេតុដែល គម្រោងនេះពុំធ្លាប់មានកន្លងមក និង ផ្នែកនៃគម្រោងដែល ពុំធ្លាប់មានកន្លងមក។ |
| ពុំធ្លាប់មាននៅថ្នាក់ខេត្ត? | | | រៀបរាប់ពីមូលហេតុដែល គម្រោងនេះពុំធ្លាប់មានកន្លងមក និង ផ្នែកនៃគម្រោងដែល ពុំធ្លាប់មានកន្លងមក។ |
| **10. តើគម្រោងនេះមានភាពចម្រូងចម្រាស់កម្រិតខ្ពស់ និងទំនងជាទាក់ទាញការចាប់អារម្មណ៍ពីអង្គការមិនមែនរដ្ឋាភិបាល ឬសង្គមស៊ីវិលនៅថ្នាក់ជាតិ ឬអន្តរជាតិដែរឬទេ?** | | | |
| ត្រូវបានចាត់ទុកថាជាគម្រោងដែលមានហានិភ័យ ឬ ទំនងជាមានភាពចម្រូងចម្រាសខ្ពស់។ | | | រៀបរាប់ពីហានិភ័យ និងទិដ្ឋភាព ចម្រូង ចម្រាស់ដែលអ្នកយល់ថាមាន |
| ទំនងជានាំឱ្យមានការតវ៉ា ឬមនុស្សចង់តវ៉ា ឬ បង្អាក់សកម្មភាពសាងសង់។ | | | រៀបរាប់ពីមូលហេតុដែលអនុគម្រោង នេះមិនទទួលការស្វាគមន៍ក្នុងកម្រិតខ្ពស់។ |

5. ប្រសិនបើចម្លើយ មាន ចំពោះសំណួរសម្រាប់ពិនិត្យបឋមខាងលើ អនុគម្រោងនេះ ទំនងជាត្រូវបានចាត់ទុកថាជាអនុគម្រោងប្រភេទ A និងតម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីបំពេញទៅតាមស្តង់ដាររបស់ធនាគារពិភពលោក រួមនឹង EMP ផងដែរ។ PCO ត្រូវធ្វើការពិភាក្សាពីលទ្ធផលនៃការពិនិត្យបឋមនេះ ជាមួយនឹងប្រធានក្រុមការងារ (TTL) មុនពេលចាប់ផ្តើមធ្វើការសិក្សាបរិស្ថាន និងសង្គមរបស់អនុគម្រោងនេះ។ លក្ខខណ្ឌតម្រូវរបស់ធនាគារពិភពលោក និងរបស់រដ្ឋាភិបាលមានចំណុចខុសគ្នាខ្លះ សម្រាប់គម្រោងប្រភេទ A ជុំវិញការរៀបចំលក្ខខណ្ឌប្រតិបត្តិ ការពិគ្រោះយោបល់ មាតិកា និងរចនាសម្ព័ន្ធនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ចាំបាច់ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដាច់ដោយឡែកចំនួនពីរ ដើម្បីបំពេញទៅតាមលក្ខខណ្ឌតម្រូវរបស់ធនាគារ និងរបស់រដ្ឋាភិបាល។

6. ***កំណត់សម្គាល់៖*** *ប្រសិនបើគម្រោងមេពុំត្រូវបានចាត់ចំណាត់ថ្នាក់ជាប្រភេទ A នោះអនុគម្រោងដែលមានចម្លើយ "មាន" ចំពោះសំណួរពិនិត្យបឋមទាំងនេះ ពុំអាចអនុវត្តបានឡើយ។*

**2.2** លក្ខណៈវិនិច្ឆ័យសម្រាប់ពិនិត្យបឋមលើអនុគម្រោងប្រភេទ **C**

7. សំណួរពិនិត្យបឋមខាងក្រោមនេះ មានគោលបំណងធ្វើការកំណត់ថាតើអនុគម្រោងមួយ អាចបង្កឱ្យមានផលប៉ះពាល់តិចតួច ឬពុំមានផលប៉ះពាល់សោះដែរឬទេ (ដែលចាត់ទុកថាជាគម្រោងប្រភេទ C)។

| **តារាងទី ២. លក្ខណៈវិនិច្ឆ័យសម្រាប់ពិនិត្យបឋមលើអនុគម្រោងប្រភេទ C** | | | |
|---|---|---|---|
| **សំណួរសម្រាប់ពិនិត្យបឋម** | **មាន** | **មិនមាន** | **យោបល់** |
| 1. សកម្មភាពរបស់អនុគម្រោង មានត្រឹមតែជាការបណ្តុះបណ្តាល ជំនួយបច្ចេកទេស និងការកសាងសមត្ថភាព | | | សូមរៀបរាប់ពីសកម្មភាព |
| 2. ការបណ្តុះបណ្តាល ជំនួយបច្ចេកទេស និងការកសាងសមត្ថភាព ពុំតម្រូវឱ្យមានការប្រើប្រាស់សារធាតុគីមី សារធាតុជីវសាស្ត្រ ថ្នាំកសិកម្ម | | | សូមរកឯកសារគាំទ្រ ការលើកឡើងនេះ |
| 3. ពុំមានហេដ្ឋារចនាសម្ព័ន្ធដែលត្រូវរំលំចោល ឬសាងសង់ឡើយ | | | សូមរកឯកសារគាំទ្រ ការលើកឡើងនេះ |

| | | | | |
|---|---|---|---|---|
| 4. | ពុំមានអន្តរាគមន៍ ដែលអាច បង្កផលប៉ះពាល់ដល់ដី ទឹក ខ្យល់ រុក្ខជាតិ សត្វ ឬមនុស្សឡើយ | | | សូមរកឯកសារគាំទ្រ ការលើកឡើងនេះ |
| 5. | ប្រសិនបើកំពុងមានការស្រាវជ្រាវវិទ្យាសាស្ត្រ ការស្រាវជ្រាវ ដែលមានលក្ខណៈបែបនេះ ដែលពុំមានការផ្តើតនូវកាកសំណល់គ្រោះថ្នាក់ ឬកាកសំណល់ដែលមានជាតិពុល ហើយការស្រាវជ្រាវនេះ ពុំមានប្រើប្រាស់ DNA ដែលត្រូវយកមកបញ្ចូលផ្សំគ្នាសាជាថ្មី ឬការស្រាវជ្រាវផ្សេងទៀត ដែលអាចបង្កើតឱ្យមានសារធាតុគ្រោះថ្នាក់ ប្រសិនបើសារធាតុទាំងនេះត្រូវបានបញ្ចេញពីមន្ទីរពិសោធន៍ ដែលបិទជិត។ | | | ប្រសិនបើមាន សូមធ្វើការពិភាក្សាជាមួយអ្នកឯកទេសផ្នែកបរិស្ថានរបស់ធនាគារពិភពលោក |

**2.3** ការពិនិត្យបឋមលើអនុគម្រោងប្រភេទ **B**

8. អនុគម្រោងជាច្រើនដែលត្រូវលើកស្នើ គឺជាអនុគម្រោងប្រភេទ B។ អនុគម្រោងនេះ អាចមានផលប៉ះពាល់ស្រដៀងគ្នានឹងអនុគម្រោងប្រភេទ A ដែរ ប៉ុន្តែផលប៉ះពាល់ទាំងនេះ ពុំអាចប្តូរត្រលប់មកវិញបានឡើយ ហើយមិនសូវជាមានវិសាលភាពធំទូលាយ ពុំសូវខ្លាំងក្លា ពុំសូវអវិជ្ជមានងាយសម្រួលសម្រាល និងមិនទំនងជានាំឱ្យមានភាពចម្រូងចម្រាស ហើយមិនមែនជាអនុគម្រោងដែលពុំធ្លាប់មាននោះឡើយ។

9. បន្ទាប់ពីពិនិត្យបឋមលើប្រភេទ A និងប្រភេទ C រួច និងប្រសិនបើមានការសន្និដ្ឋានថា អនុគម្រោងនេះ មិនមែនជាប្រភេទ A និងមិនមែនជាប្រភេទ C នោះអនុគម្រោងនេះ គួរចាត់ថ្នាក់ជាអនុគម្រោងប្រភេទ B។

10. អនុគម្រោងប្រភេទ B ក៏តម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬឧបករណ៍វាយតម្លៃបរិស្ថានដទៃទៀត ស្របតាមគោលនយោបាយ OP 4.01 របស់ធនាគារពិភពលោក។ PCO ត្រូវប្រើប្រាស់លក្ខណៈវិនិច្ឆ័យ ដែលមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តជាតិ ដើម្បីកំណត់ថាតើត្រូវរៀបចំ EIA ឬ EPC ស្របតាមច្បាប់ស្តីពីការការពារបរិស្ថាន និងអនុក្រឹត្យ និងសារាចរពាក់ព័ន្ធនឹងការវាយតម្លៃបរិស្ថាន។ នៅក្នុងករណីភាគច្រើន ចាំបាច់ត្រូវមានការរៀបចំ EMP ស្របតាមគោលនយោបាយរបស់ធនគារពិភពលោក (សូមមើលឧបសម្ព័ន្ធទី ៤)។ សម្រាប់ករណីផ្សេងទៀត EMP ឬ ECOP ដែលមានលក្ខណៈសាមញ្ញ គឺគ្រប់គ្រាន់។

11. បញ្ហាដែលចាំបាច់ត្រូវលើកយកមកបញ្ជាក់ក្នុងឯកសារការពារផលប៉ះពាល់សម្រាប់អនុគម្រោងប្រភេទ B មានការប្រែប្រួលខុសៗគ្នា អាស្រ័យទៅតាមប្រភេទអនុគម្រោង ទីតាំងរបស់អនុគម្រោង និងការប្រើប្រាស់ដីធ្លីជុំវិញ និងប្រភេទសំណង់ និងនីតិវិធីប្រតិបត្តិការ ដែលត្រូវប្រើប្រាស់។

**2.4** បញ្ជីត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន និងសង្គម

12. តារាងទី ៣ បង្ហាញពីបញ្ជីត្រួតពិនិត្យ ដើម្បីជួយដល់អ្នកខ្ចីកម្ចីក្នុងការរៀបចំឧបករណ៍វាយតម្លៃបរិស្ថាន រួមនឹង EMP។

**តារាងរាងទី ៣. ផលប៉ះពាល់បរិស្ថាន និងសង្គម ដែលអាចកើតមានឡើង និងដែលត្រូវធ្វើការដោះស្រាយ**

| | **តើអនុគម្រោងនេះ នាំឱ្យមានផលប៉ះពាល់បរិស្ថានទាំងនេះដែរឬទេ?** | **ពុំមាន** | **កម្រិតទាប** | **កម្រិតមធ្យម** | **ខ្ពស់** | **ពុំដឹង** | **យោបល់** |
|---|---|---|---|---|---|---|---|
| 1. | ការទន្ទ្រានលើតំបន់ប្រវត្តិសាស្ត្រ/តំបន់វប្បធម៌ | | | | | | |
| 2. | ការទន្ទ្រានលើប្រព័ន្ធអេកូឡូស៊ី (ឧទាហរណ៍ ដែនជម្រកធម្មជាតិ ដែលងាយរងផលប៉ះពាល់ ឬ | | | | | | *សូមរៀបរាប់ និងវាយតម្លៃដោយសង្ខេប* |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | តំបន់ការពារ ឧទ្យានជាតិ ដែនបម្រុងធម្មជាតិ។ល។) | | | | | | *ពីកម្រិតនៃផលប៉ះពាល់* |
| 3. | ធ្វើឱ្យខូចខាតដល់តំបន់ទេសភាព និងនាំឱ្យមានការបង្កើតសំណល់កាន់តែច្រើនជាងមុន | | | | | | |
| 4. | ការបំផ្លាញគម្របរុក្ខជាតិ ឬមានការកាត់ដើមឈើក្នុងអំឡុងពេលសម្អាតទីតាំងសម្រាប់ធ្វើការសាងសង់ | | | | | | |
| 5. | ការផ្លាស់ប្តូរគុណភាពទឹកលើដី ឬលំហូរទឹក (ឧទាហរណ៍ បង្កើនភាពល្អក់នៃទឹក ដោយសារទឹកភ្លៀងដែលហូរ ទឹកសំណល់ដែលហូរចេញពីទីតាំងជំរំសាងសង់ និងការហូរច្រោះដី និងសំណល់ពីការសាងសង់ ឬ ផលប៉ះពាល់រយៈពេលវែង | | | | | | *បង្ហាញពីរបៀបដែលផលប៉ះពាល់នេះកើតមានឡើង និងពេលដែលផលប៉ះពាល់នេះកើតមានឡើង* |
| 6. | បង្កើនកម្រិតធូលី ឬបន្ថែមសារធាតុពុលចូលទៅក្នុងខ្យល់ក្នុងអំឡុងពេលសាងសង់ | | | | | | *បង្ហាញពីរបៀបដែលផលប៉ះពាល់នេះកើតមានឡើង និងពេលដែលផលប៉ះពាល់នេះកើតមានឡើង* |
| 7. | បង្កើនកម្រិតសំឡេងរំខាន និង/ឬរំញ័រ | | | | | | *បង្ហាញពីរបៀបដែលផលប៉ះពាល់នេះកើតមានឡើង និងពេលដែលផលប៉ះពាល់នេះកើតមានឡើង* |
| 8. | ការផ្លាស់ប្តូរទីលំនៅរបស់គ្រួសារ? ប្រសិនបើមាន តើមានប្រជាពលរដ្ឋប៉ុន្មានគ្រួសារ? | | | | | | |
| 9. | ការប្រើប្រាស់ទីតាំងតាំងទីលំនៅជាថ្មីដែលបរិស្ថាន និង/ឬវប្បធម៌ងាយទទួលរងផលប៉ះពាល់ | | | | | | *សូមរៀបរាប់ដោយសង្ខេបពីផលប៉ះពាល់ដែល អាចកើតមានឡើង* |
| 10. | ហានិភ័យនៃការសាយភាពជំងឺពីកម្មករសំណង់ទៅប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋាន (និងឆ្លងត្រលប់មកវិញ)? | | | | | | *សូមបង្ហាញពីចំនួនប៉ាន់ស្មាននៃកម្មករដែលត្រូវជួលសម្រាប់ការងារសាងសង់របស់គម្រោង នៅក្នុងឃុំ/ស្រុក និងប្រភេទជំងឺដែលពួកគេអាចនាំមក ឬឆ្លង។* |
| 11. | លទ្ធភាពដែលនាំឱ្យមានជម្លោះកើតឡើងរវាងកម្មករសំណង់ និងប្រជាពលរដ្ឋនៅមូលដ្ឋាន? | | | | | | |
| 12. | ការប្រើប្រាស់ជាតិផ្ទុះ និងសារធាតុគីមីដែលអាចមានគ្រោះថ្នាក់ | | | | | | |
| 13. | ការប្រើប្រាស់ទីតាំងដែលកន្លងមកធ្លាប់មានគ្រោះថ្នាក់កើ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | តមានឡើង ដោយសារគ្រាប់មីន ឬជាតិផ្ទុះ ដែលបន្សល់ទុកពី សង្គ្រាម | | | | | | |
| 14. | ការសាងសង់ដែលអាចបង្ក ឱ្យមានការរំខានដល់ការដឹកជញ្ជូន ផ្លូវ ធ្វើចរាចរ ឬការដឹកជញ្ជូនតាមផ្លូវទឹក? | | | | | | |
| 15. | ការសាងសង់ដែលអាចបង្កឱ្យមានការ ខូចខាតដល់ផ្លូវ ដែលមានស្រាប់ ក្នុងមូលដ្ឋាន ស្ពាន ឬហេដ្ឋារចនាសម្ព័ន្ធ ជនបទផ្សេងទៀត? | | | | | | |
| 16. | ការកកាយដីក្នុងអំឡុងពេលសាងសង់ របស់អនុគម្រោង ដែលអាចនាំ ឱ្យមានការហូរច្រោះដី | | | | | | |
| 17. | ចាំបាច់ត្រូវបើកផ្លូវ សម្រាប់ឆ្លងកាត់ថ្មីបណ្ដោះអាសន្ន ឬអាចិន្ត្រៃយ៍? | | | | | | *ប៉ាន់ប្រមាណពីចំនួន និងប្រវែងផ្លូវ ដែលឆ្លងកាត់ បណ្ដោះអាសន្ន ឬអចិន្ត្រៃយ៍ និងទីតាំងផ្លូវទាំងនោះ* |
| 18. | ការបំបែក ឬការធ្វើឱ្យបែកខ្ញែកនូវ ដែនជម្រករបស់រុក្ខជាតិ និងសត្វ? | | | | | | *រៀបរាប់ថាកើតឡើងដោយរបៀបណា* |
| 19. | ផលប៉ះពាល់រយៈពេលវែងលើគុណភាព ខ្យល់ | | | | | | |
| 20. | ហានិភ័យនាំឱ្យមានគ្រោះថ្នាក់ ដល់កម្មករ និងសហគមន៍ក្នុងអំឡុងដំណាក់កាល សាងសង់ | | | | | | |
| 21. | ការប្រើប្រាស់សារធាតុមានគ្រោះថ្នាក់ ឬ សារធាតុពុល និងការបង្កើតសំណល់គ្រោះថ្នាក់ | | | | | | |
| 22. | ហានិភ័យចំពោះសុវត្ថិភាព និងសុខភាព | | | | | | *រៀបរាប់ ថានឹងកើតឡើង ដោយរបៀបណា* |
| **តើអនុគម្រោងនេះ តម្រូវឱ្យមានការលទ្ធកម្មដីធ្លី ឬការរឹតបន្តឹងលើការប្រើប្រាស់ធនធានដែរឬទេ?** | | | | | | | |
| 23. | ការធ្វើលទ្ធកម្មដីធ្លី (សាធារណៈ ឬឯកជន) (បណ្ដោះអាសន្ន ឬ អចិន្ត្រៃយ៍) សម្រាប់ការអភិវឌ្ឍ | | | | | | *សូមរៀបរាប់ពីតំបន់ដែលនាំ ឱ្យមានការធ្វើលទ្ធកម្មដីធ្លីជា អចិន្ត្រៃយ៍ និងបណ្ដោះ អាសន្នប្រភេទដី រយៈពេល និងគោលបំណងនៃ ការធ្វើលទ្ធកម្ម* |
| 24. | ប្រើប្រាស់ដីដែលកំពុង មានការកាន់កាប់នាពេលបច្ចុប្បន្ន ឬ ប្រើប្រាស់ជាប្រចាំសម្រាប់គោលបំណង ផលិតកម្ម (ឧទាហរណ៍ សួនបន្លែ ការធ្វើ កសិកម្ម វាលស្មៅ ទីតាំងនេសាទ ព្រៃឈើ) | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 25.. | ការធ្វើឱ្យបាត់បង់ទីលំនៅបុគ្គល គ្រួសារ ឬអាជីវកម្ម | | | | | | |
| 26. | ការបាត់បង់ដំណាំ ដើមឈើហូបផ្លែ ឬ សំណង់របស់គ្រួសារ ជាបណ្ដោះអាសន្ន ឬអចិន្ត្រៃយ៍ | | | | | | |
| 27. | ការរឹតបន្តឹងការចូល របស់ប្រជាពលរដ្ឋទៅក្នុងឧទ្យាន និងតំបន់ការពារ ដែលត្រូវបាន បង្កើតឡើងដោយច្បាប់ | | | | | | |
| *ប្រសិនបើចម្លើយចំពោះសំណួរ ២៣-២៧ គឺ "មាន" សូមយោង ESMF។ ទំនងជាចាំបាច់ត្រូវមានការរៀបចំផែនការដោះស្រាយផលប៉ះពាល់/តាំងទីលំនៅ (RP)។* | | | | | | | |
| **តើអនុគម្រោងនេះ មានបង្កផលប៉ះពាល់ដល់ជនជាតិភាគតិចដែរឬទេ?** | | | | | | | |
| 28. | ក្រុមជនជាតិភាគតិចកំពុងរស់នៅក្នុងព្រំប្រទល់ ឬនៅជិតតំបន់អនុគម្រោង | | | | | | |
| 29. | សមាជិកក្រុម ជនជាតិភាគតិចនៅក្នុងតំបន់នេះ អាចទទួលបានប្រយោជន៍ពីគម្រោង ឬអាចនឹងទទួលរងផលប៉ះពាល់ ដោយសារគម្រោង | | | | | | |
| *ប្រសិនបើចម្លើយចំពោះសំណួរ ២៨-២៩ គឺ "មាន" សូមយោង ESMF។ ទំនងជាចាំបាច់ត្រូវមានការរៀបចំផែនការអភិវឌ្ឍន៍ជនជាតិភាគតិច (EMDP)។* | | | | | | | |
| **តើអនុគម្រោងនេះ តម្រូវឱ្យមានការសាងសង់ទំនប់ ឬពឹងអាស្រ័យលើទំនប់ដែរឬទេ?** | | | | | | | |
| 30. | មានការសាងសង់ទំនប់ធំមួយ? | | | | | | *សូមមើលតារាងទី ១ អំពីនិយមន័យទំនប់ធំ* |
| 31. | ពឹងអាស្រ័យលើការផ្គត់ផ្គង់ទឹកពីទំនប់ ដែលមានស្រាប់ ឬទំនប់ទាបៗ (weir) ឬទំនប់ដែលកំពុងសាងសង់? | | | | | | *រៀបរាប់ពីទំនាក់ទំនងផ្លូវការរវាងអនុគម្រោង និង ទំនប់ដែលមានស្រាប់ ឬ ទំនប់ដែលកំពុងសាងសង់* |
| *ប្រសិនបើចម្លើយចំពោះសំណួរ ៣០-៣១ គឺ "មាន" សូមយោង ESMF។ ទំនងជាចាំបាច់ត្រូវមានការរៀបចំរបាយការណ៍ការសុវត្ថិភាពទំនប់ (DSR)។* | | | | | | | |
| **តើអនុគម្រោងនេះតម្រូវឱ្យមានការធ្វើលទ្ធកម្ម ឬការប្រើប្រាស់ថ្នាំកសិកម្មដែរឬទេ?** | | | | | | | |
| 32. | *តើថ្នាំកសិកម្ម ដែលត្រូវប្រើប្រាស់នេះ បំពេញទៅតាមចំណាត់ថ្នាក់របស់អង្គការសុខភាពពិភពលោក?* | | | | | | *សូមមើលតារាងទី ១ សម្រាប់ព័ត៌មានបន្ថែម អំពីថ្នាំកសិកម្ម។ ដើម្បីដោះស្រាយបញ្ហានេះ គេត្រូវដឹងពីប្រភេទថ្នាំកសិកម្ម ដែលត្រូវបានលើស្នើឡើង* |
| *ប្រសិនបើចម្លើយចំពោះសំណួរ ៣២ គឺ "មាន" សូមយោង ESMF។ ទំនងជាចាំបាច់ត្រូវមានការរៀបចំផែនការគ្រប់គ្រងសមាសភាគចង្រៃ (PMP)។* | | | | | | | |

13. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ចាំបាច់ត្រូវធ្វើរបាយការណ៍

ពិនិត្យបឋមជូនធនាគារពិភពលោក ដើម្បីពិនិត្យឡើងវិញពាក់ព័ន្ធជាមួយនឹងការបែងចែកប្រភេទអនុគម្រោង។

## ឧបសម្ព័ន្ធទី ៣៖ ការរៀបចំ EMP ឬ ESMP

### ក. សេចក្តីផ្តើម

1. ផែនការគ្រប់គ្រងបរិស្ថាន (EMP) គឺជាផ្នែកមួយនៃដំណើរការវាយតម្លៃបរិស្ថាន (EA) ក្នុងគម្រោងដែលទទួលបានហិរញ្ញប្បទានពីធនាគារពិភពលោក។ នីតិវិធីក្នុងគោលនយោបាយ OP 4.01, ឧបសម្ព័ន្ធ គ ដែលរៀបរាប់ពី EMP គឺជានីតិវិធីដែលត្រូវតែអនុវត្ត។

2. "ផែនការគ្រប់គ្រងបរិស្ថាន (EMP) របស់អនុគម្រោង រួមមាន **វិធានការសម្រាលផលប៉ះពាល់ វិធានការ ពិនិត្យតាមដាន និងវិធានការស្ថាប័ន** ដែលត្រូវអនុវត្តក្នុងអំឡុងពេលអនុវត្ត និង ប្រតិបត្តិការ ដើម្បីលុបបំបាត់ផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងសង្គម កាត់កងផលប៉ះពាល់ទាំងនោះ ឬកាត់បន្ថយផលប៉ះពាល់ទាំងនោះឱ្យមកនៅត្រឹមកម្រិតដែលអាចទទួលបាន។ ផែនការនេះក៏មានបញ្ចូលសកម្មភាព ដែលចាំបាច់សម្រាប់អនុវត្តវិធានការទាំងនេះផងដែរ"។

3. ផែនការគ្រប់គ្រងបរិស្ថាន បង្ហាញព័ត៌មានអំពីទំនាក់ទំនងយ៉ាងសំខាន់ ជាមួយនឹងឧបករណ៍ផ្សេងៗ ស្របទៅតាមការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោងប្រភេទ A, B, និង FI ឬ ESMF នៅពេលដែលគេមិនដឹងពីអនុគម្រោងជាមុន, ទំនាក់ទំនងរវាងផលប៉ះពាល់ ដែលព្យាករណ៍ទុកជាមុន និងវិធានការសម្រាលផលប៉ះពាល់ដែលត្រូវបានកំណត់ក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសកម្មភាពសាងសង់ និងសកម្មភាពប្រតិបត្តិការ។ EMP រៀបរាប់ពីផលប៉ះពាល់លើបរិស្ថាន ដែលគេរំពឹងថា កើតចេញពីគម្រោង វិធានការត្រូវអនុវត្ត ដើម្បីសម្រាលផលប៉ះពាល់ទាំងនេះ ការទទួលខុសត្រូវលើការសម្រាលផលប៉ះពាល់ ពេលវេលា ការចំណាយលើការសម្រាលផលប៉ះពាល់ និងប្រភពថវិកា។ លើសពីនេះ EMP ដាក់ចេញនូវក្របខ័ណ្ឌសម្រាប់បន្តវាយតម្លៃផលប៉ះពាល់ ដែលអាចកើតឡើង តាមរយៈការពិនិត្យតាមដាន និងការធ្វើសវនកម្ម និងការពិចារណាពីវិធានការស្ថាប័នដែលសមស្រប ដើម្បីសម្រេច EMP នេះ។

4. ឯកសារណែនាំនេះ មានគោលបំណងផ្តល់នូវព័ត៌មានយោង សម្រាប់រៀបចំ EMPs សម្រាប់គម្រោង/អនុគម្រោងអភិវឌ្ឍន៍ច្រើនប្រភេទ ដែលមានវិសាលភាពខុសៗគ្នា ក្នុងបរិបទជីវៈរូបវន្ត សង្គម សេដ្ឋកិច្ច និងអភិបាលកិច្ចខុសគ្នា។ ឯកសារណែនាំនេះ បង្ហាញពីក្របខ័ណ្ឌគោលនយោបាយសម្រាប់រៀបចំ EMPs សម្រាប់សកម្មភាពដែលទទួលបានហិរញ្ញប្បទានពីធនាគារ រៀបរាប់ដោយសង្ខេបពីផ្នែកសំខាន់ៗនៃ EMPs និងធ្វើការពិភាក្សាពីមធ្យោបាយដើម្បីធានាយ៉ាងណាឱ្យមានការបន្តការប្តេជ្ញាចិត្តអនុវត្តតាម EMP រហូតដល់ពេលអនុវត្ត និងប្រតិបត្តិការ។ ឯកសារណែនាំនេះពុំមានគោលបំណងជំនួសឱ្យគោលនយោបាយស្តីពីការការពារផលប៉ះពាល់ ឬគោលនយោបាយស្តីពីការការពារផលប៉ះពាល់របស់ធនាគារពិភពលោក ឬលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋាភិបាលឡើយ។

5. ឯកសារណែនាំនេះ ផ្តោតលើទីភ្នាក់ងារអនុវត្តគម្រោង ដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs), ទីប្រឹក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន អ្នកឯកទេសបរិស្ថាន អ្នកលើកស្នើគម្រោង ស្ថាប័នហិរញ្ញវត្ថុ និងភាគីផ្សេងទៀត ដែលចាប់អារម្មណ៍ ឬទទួលរងផលប៉ះពាល់ដោយសារដំណើរការ EMP។

### ខ. តើ **EMP** ចាំបាច់ត្រូវមាននៅពេលណា (ប្រភេទ **A, B, FI)**

6. លិខិតបទដ្ឋានគតិយុត្តស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់រដ្ឋាភិបាល ពុំតម្រូវឱ្យអ្នកលើកស្នើគម្រោងរៀបចំ EMP ដោយឡែកនោះឡើយ ប៉ុន្តែត្រូវរៀបចំកម្មវិធីគ្រប់គ្រង និងពិនិត្យតាមដានបរិស្ថាន (EMMP) ជាផ្នែកមួយនៃ EIA។ EMMP ត្រូវបញ្ចូលព័ត៌មានអំពីដំណាក់កាលអនុវត្តគម្រោង សកម្មភាពគម្រោង ផលប៉ះពាល់បរិស្ថានពាក់ព័ន្ធ វិធានការសម្រាលផលប៉ះពាល់ ចំណាយសម្រាប់អនុវត្តវិធានការសម្រាលផលប៉ះពាល់ ក្របខ័ណ្ឌពេលវេលាសម្រាប់អនុវត្តវិធានការនានា ការរៀបចំការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រង។ EMMP ក៏បញ្ចូលកម្មវិធីពិនិត្យតាមដាន ការបញ្ចេញសំណល់ គុណភាពបរិស្ថានទូទៅ និងផលប៉ះពាល់ផ្សេងទៀត ដែលបង្កឡើងដោយសារគម្រោងផងដែរ។ គេពុំត្រូវការ EMMP សម្រាប់ការប្តេជ្ញាចិត្តការពារបរិស្ថាន (EPC) ដាក់លាក់ណាមួយនោះឡើយ ប៉ុន្តែចាំបាច់ត្រូវមានវិធានការសម្រាលផលប៉ះពាល់ បរិក្ខារសម្អាតសំណល់ និងកម្មវិធី

ពិនិត្យ តាមដានបរិស្ថាន។

7. ផែនការគ្រប់គ្រងបរិស្ថានរបស់ធនាគារ (EMP) គឺជាឧបករណ៍មួយដែលបង្ហាញលម្អិតអំពីៈ ក) ផលប៉ះពាល់អវិជ្ជមានលើបរិស្ថានទាំងអស់ ដែលរំពឹងថានឹងកើតមានឡើង (រាប់បញ្ចូលទាំងផលប៉ះពាល់ដែលពាក់ព័ន្ធនឹងជនជាតិដើមភាគតិច ឬការផ្លាស់ប្តូរទីលំនៅដោយមិនស្ម័គ្រចិត្តផងដែរ), ខ) វិធានការសម្រាលផលប៉ះពាល់ ដែលត្រូវធ្វើឡើងក្នុងអំឡុងពេលអនុវត្ត ឬប្រតិបត្តិការគម្រោង ដើម្បីលុបបំបាត់ ឬកាត់កងផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថាន ឬកាត់បន្ថយផលប៉ះពាល់ទាំងនេះឱ្យមកនៅត្រឹមកម្រិតដែលអាចទទួលយកបាន, គ) គោលបំណងនៃការពិនិត្យតាមដាន និងប្រភេទនៃការពិនិត្យតាមដាន ដោយមានការផ្សារភ្ជាប់ទំនាក់ទំនងជាមួយផលប៉ះពាល់ដែលត្រូវបានវាយតម្លៃរកឃើញ ក្នុងរបាយការណ៍វាយតម្លៃបរិស្ថាន និងវិធានការសម្រាលផលប៉ះពាល់ ដែលត្រូវបានបរិយាយក្នុង EMP, ឃ) សកម្មភាពដែលចាំបាច់ត្រូវធ្វើឡើង រួមទាំងការរៀបចំស្ថាប័នដើម្បីអនុវត្តវិធានការទាំងនេះផងដែរ, ង) ការអភិវឌ្ឍសមត្ថភាព និងការបណ្តុះបណ្តាល ដើម្បីគាំទ្រដល់ការអនុវត្តសមាសភាគបរិស្ថានរបស់គម្រោង និងវិធានការសម្រាលផលប៉ះពាល់ឱ្យបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព, ច) កាលវិភាគអនុវត្ត ដោយមានការប៉ាន់ប្រមាណចំណាយសម្រាប់អនុវត្ត EMP និង ឆ) ការបញ្ចូល EMP ទៅក្នុងគម្រោង។ បើធៀបជាមួយនឹង EMMP របស់រដ្ឋាភិបាល ផ្នែកនានាក្នុង EMP ត្រូវបានលើកមកបង្ហាញលម្អិតជាង ដូចជា ការកសាង សមត្ថភាព ការបញ្ចូល EMP ទៅក្នុងការរៀបចំផែនការជារួម ការតាក់តែង ការរៀបចំថវិកា និងការអនុវត្តរបស់គម្រោង។

8. EMP គឺជាផ្នែកមួយដ៏សំខាន់នៃការវាយតម្លៃបរិស្ថាន សម្រាប់គម្រោងប្រភេទ A (ដោយមិនគិតពីឧបករណ៍ដទៃទៀត ដែលត្រូវប្រើប្រាស់)។ ការវាយតម្លៃបរិស្ថានសម្រាប់គម្រោងប្រភេទ B ក៏អាចនាំឱ្យមានការរៀបចំ EMP ផងដែរ។ EMP គឺជាឧបករណ៍ដ៏មានតម្លៃ ដើម្បីៈ i) កំណត់ឱ្យបានលម្អិតពីអ្នកណាខ្លះ អ្វីខ្លះ ទីកន្លែង និងពេលដែលត្រូវអនុវត្តវិធានការគ្រប់គ្រង និងសម្រាលផលប៉ះពាល់បរិស្ថាន, ii) ផ្តល់ឱ្យស្ថាប័នរដ្ឋាភិបាល និងក្រុមហ៊ុនម៉ៅការ ក្រុមហ៊ុនអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធដទៃទៀតនូវការគ្រប់គ្រងបរិស្ថាននៅនឹងកន្លែងបានកាន់តែល្អប្រសើរជាងមុន នៅក្នុងវដ្តគម្រោងទាំងមូល, iii) ផ្តល់លទ្ធភាពឱ្យអ្នកលើកស្នើគម្រោងធានាថា ក្រុមហ៊ុនម៉ៅការរបស់ពួកគេពិតជាបានបំពេញទៅតាមកាតព្វកិច្ចបរិស្ថាន ក្នុងនាមតំណាងឱ្យពួកគេពិតប្រាកដមែន និង iv) បង្ហាញពីការផ្ទៀងផ្ទាត់ត្រឹមត្រូវ។ លើសពីនេះ EMP ជារឿងចាំបាច់ត្រូវរៀបចំជាផ្នែកមួយនៃការដេញថ្លៃគម្រោងផងដែរ។

9. ជាធម្មតាការប្រើប្រាស់ EMP អនុវត្តចំពោះគម្រោងតូចៗ ដែលពុំបង្កផលប៉ះពាល់ដល់តំបន់ដែលងាយរងគ្រោះផ្នែកបរិស្ថានតែប៉ុណ្ណោះ ដែលបញ្ហាបរិស្ថានមានវិសាលភាពតូច ត្រូវបានកំណត់យ៉ាងជាក់ច្បាស់ និងដែលត្រូវបានយល់យ៉ាងច្បាស់លាស់។ សម្រាប់អនុគម្រោងតូច ឬអនុគម្រោងតូចខ្លាំង ដែលបង្កផលប៉ះពាល់ផ្នែកបរិស្ថានតិចតួច ការប្រើប្រាស់វិធានការសម្រាលផលប៉ះពាល់ទូទៅបែបសាមញ្ញ ដូចជា ក្រមប្រតិបត្តិបរិស្ថាន (ECOP) (សូមមើលឧបសម្ព័ន្ធទី ៥ អំពីប្រភេទ ECOP) តែមួយមុខ គឺគ្រប់គ្រាន់សម្រាប់ឆ្លើយតបចំពោះផលប៉ះពាល់បរិស្ថាន។ គេអាចប្រើប្រាស់ ECOP រួមជាមួយនឹង EMP ដើម្បីឆ្លើយតបចំពោះផលប៉ះពាល់ទូទៅតិចតួច ដែលបង្កឡើងដោយសារសកម្មភាពសាងសង់។

10. EMP គឺជា “ឯកសាររស់” ដែលគួរផ្តោតលើការបន្តកែលម្អ និងគួរធ្វើបច្ចុប្បន្នភាពនៅពេលមានការផ្លាស់ប្តូរការរៀបចំគម្រោង ឬនៅពេលដែលមានការលើកឡើងនូវបញ្ហាបរិស្ថានថ្មីៗ។

## គ. គោលបំណងនៃ **EMP**

11. EMP រៀបរាប់ពីវិធានការសម្រាលផលប៉ះពាល់ វិធានការពិនិត្យតាមដាន និងវិធានស្ថាប័នដែលត្រូវអនុវត្តក្នុងអំឡុងពេលអនុវត្ត និងប្រតិបត្តិការគម្រោង ដើម្បីបញ្ចៀស ឬត្រួតពិនិត្យផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថាន និងសកម្មភាពដែលចាំបាច់ ដើម្បីអនុវត្តវិធានការទាំងនេះ។ EMP បង្ហាញពីទំនាក់ទំនងរវាងជម្រើសវិធានការសម្រាលផលប៉ះពាល់ ដែលត្រូវបានវាយតម្លៃ និងរៀបរាប់ក្នុងរបាយការណ៍ EIA/EPC និងធានាថានឹងមានការអនុវត្តវិធានការទាំងនេះ ខណៈពេលដែលការរៀបចំគម្រោង គួរបញ្ចូលនិរន្តរភាពផ្នែកបរិស្ថានឱ្យបានទូលំទូលាយបំផុតតាមដែលអាចធ្វើទៅបាន EMP ផ្តោតលើបញ្ហាបរិស្ថាន ដែលពុំអាចចៀសរួចក្នុងអំឡុងពេលតាក់តែងគម្រោង។ ដូច្នេះ EMP

គួរមានគោលបំណងដូចតទៅៈ

- ✓ ធានាឱ្យមានភាពអនុលោមទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត ស្តង់ដារ និងគោលការណ៍ណែនាំនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ដែលកំពុងចូលជាធរមាន
- ✓ ធានាថាមានការវិភាជន៍ធនធានគ្រប់គ្រាន់ក្នុងថវិកាគម្រោង សម្រាប់អនុវត្តសកម្មភាពពាក់ព័ន្ធនឹង EMP
- ✓ ធានាថាហានិភ័យបរិស្ថាន ដែលពាក់ព័ន្ធជាមួយនឹងគម្រោង ត្រូវបានគ្រប់គ្រងត្រឹមត្រូវ
- ✓ ឆ្លើយតបចំពោះបញ្ហាបរិស្ថាន ដែលកើតឡើងថ្មីៗ ឬដែលពុំបានរំពឹងទុក និងពុំត្រូវបានកំណត់រកឃើញក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោង និង
- ✓ ផ្តល់ព័ត៌មានត្រលប់ ដើម្បីបន្តកែលម្អលទ្ធផលបរិស្ថាន។

12. EMP គឺជាមូលដ្ឋានសម្រាប់ធ្វើការចរចា និងឈានដល់កិច្ចព្រមព្រៀងរវាងធនាគារ និងអ្នកខ្ចីអំពីលទ្ធផលសង្គម និងបរិស្ថានសំខាន់ៗរបស់គម្រោង។ ការអនុវត្ត EMP ក្លាយជាកាតព្វកិច្ចផ្លូវច្បាប់មួយរបស់អ្នកខ្ចីកម្ចី (ក្នុងកិច្ចព្រមព្រៀងស្តីពីហិរញ្ញប្បទានកម្ចី) និងអ្នកម៉ៅការ (ក្នុងកិច្ចសន្យា)។

13. EMP អាចជាផែនការសម្រាប់ទីតាំង ឬសម្រាប់គម្រោង ដែលត្រូវបានរៀបចំឡើង ដើម្បីធានាឱ្យមានការគោរពតាមការអនុវត្តការគ្រប់គ្រងបរិស្ថានឱ្យបានសមស្រប ក្នុងអំឡុងដំណាក់កាលសាងសង់ ឬដំណាក់កាលប្រតិបត្តិការរបស់គម្រោង។ EMP របស់គម្រោង ត្រូវបានរៀបចំដោយអតិថិជន ខណៈពេលដែល EMP សម្រាប់ទីតាំង ឬ EMP សម្រាប់ការសាងសង់ ជាធម្មតារៀបចំដោយក្រុមហ៊ុនម៉ៅការ ស្របទៅតាមលក្ខខណ្ឌតម្រូវ ដែលមានចែងក្នុងឯកសារដេញថ្លៃ (ជាការអនុវត្តល្អ គួរមានភ្ជាប់ EMP របស់គម្រោង)។ ឯកសារណែនាំនេះ លើកឡើងពី EMP របស់គម្រោង។

### ឃ. តើអ្នកណាគួររៀបចំ **EMP**

14. អ្នកលើកស្នើគម្រោងជាអ្នកទទួលខុសត្រូវចម្បងលើលទ្ធផលបរិស្ថាននៃគម្រោងរបស់ខ្លួន។ ដូច្នេះ អ្នកលើកស្នើគម្រោង ត្រូវទទួលខុសត្រូវធានាឱ្យមានការរៀបចំ និងការអនុវត្ត EMP សម្រាប់គម្រោងដែលអាចទទួលយកបាន មិនថាសម្រាប់ដំណាក់កាលសាងសង់ ឬដំណាក់កាលប្រតិបត្តិការនោះទេ។ ក្នុងករណីភាគច្រើន ក្នុងអំឡុងពេលរៀបចំគម្រោង ធនាគារគួរផ្តល់ឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) និង ទីប្រឹក្សា EMP អ្នកជំនួយបច្ចេកទេសសម្រាប់រៀបចំ EMP។ ក្នុងអំឡុងពេលវាយតម្លៃ ធនាគារធ្វើការពិនិត្យឡើងវិញលើ EMP ជាមួយអ្នកខ្ចីកម្ចី ដើម្បីវាយតម្លៃពីភាពគ្រប់គ្រាន់របស់ស្ថាប័នដែលទទួលខុសត្រូវលើការគ្រប់គ្រងបរិស្ថាន ដើម្បីធានាឱ្យមានការវិភាជន៍ថវិកាឱ្យបានគ្រប់គ្រាន់ សម្រាប់ EMP និងធ្វើការកំណត់ថាតើវិធានការសម្រាលផលប៉ះពាល់ត្រូវបានបញ្ចូលយ៉ាងសមស្របទៅក្នុងការតាក់តែងគម្រោង និងការវិភាគសេដ្ឋកិច្ចដែរឬទេ?

15. ក្នុងអំឡុងពេលអនុវត្តគម្រោង នឹងមានការរៀបចំ EMPs ឬ ECOPs របស់អនុគម្រោង ស្របទៅតាមគោលការណ៍ណែនាំ និងលក្ខខណ្ឌតម្រូវក្នុង ESMF របស់គម្រោង។ ESMF របស់គម្រោងរៀបរាប់លម្អិត និងពន្យល់ពីតួនាទី និងភាពចាំបាច់សម្រាប់រៀបចំ EMP របស់អនុគម្រោង ក្នុងអំឡុងពេលអនុវត្ត។

16. ក្នុងអំឡុងពេលសាងសង់ និង/ឬប្រតិបត្តិការរបស់គម្រោង ជារឿយៗភារកិច្ចអនុវត្ត EMP របស់គម្រោង ឬរបស់អនុគម្រោង ត្រូវបានផ្ទេរទៅឱ្យក្រុមហ៊ុនម៉ៅការ តាមរយៈការបញ្ជាក់ក្នុងកិច្ចសន្យា ឬតាមរយៈការកំណត់ជាលក្ខខណ្ឌតម្រូវ។ ខណៈពេលដែល EMP អាចត្រូវបានអនុវត្តដោយក្រុមហ៊ុនម៉ៅការ ការទទួលខុសត្រូវលើការអនុវត្តលក្ខខណ្ឌសម្រាប់ផ្តល់ការឯកភាពដោយគម្រោង (ពោលគឺចាំបាច់ត្រូវមានការឯកភាពលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពីសំណាក់អាជ្ញាធរពាក់ព័ន្ធសិន ដែលនេះជាលក្ខខណ្ឌសម្រាប់ផ្តល់ការឯកភាពលើគម្រោង) គឺជាការទទួលខុសត្រូវរបស់អ្នកលើកស្នើគម្រោង។

17. ក្នុងអំឡុងពេលអនុវត្តគម្រោង ធនាគារធ្វើការត្រួតពិនិត្យលើទិដ្ឋភាពបរិស្ថានរបស់គម្រោង

ផ្អែកតាមលទ្ធផលរកឃើញ និងអនុសាសន៍ចេញពីការវាយតម្លៃបរិស្ថាន រួមនឹងវិធានការដែលត្រូវបានដាក់ចេញក្នុងកិច្ចព្រមព្រៀងកម្ចី EMP និងឯកសារគម្រោងផ្សេងទៀត។ សម្រាប់គម្រោងដែលមានហានិភ័យទាប ធនាគារអាចធ្វើការពិនិត្យក្រោយពេលរៀបចំ (post review) លើ EMPs របស់អនុគម្រោង ក្នុងអំឡុងពេលអនុវត្ត។

ង. ផ្នែកនានានៃ **EMP**

18. ដើម្បីសម្រេចគោលបំណងខាងលើ EMP គួរបញ្ចូលចំណុចដូចខាងក្រោម៖

- ✓ ការកំណត់គោលបំណងនៃការគ្រប់គ្រងបរិស្ថាន ដែលត្រូវសម្រេចឱ្យបានក្នុងអំឡុងវដ្តនៃគម្រោង (ដូចជា មុនដំណាក់កាលសាងសង់ ក្នុងអំឡុងដំណាក់កាលសាងសង់ ដំណាក់កាលប្រតិបត្តិការ និង/ឬដំណាក់កាលរុះរើសំណង់របស់គម្រោង) ដើម្បីបង្កើនអត្ថប្រយោជន៍ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថានឱ្យនៅជាអប្បបរមា។
- ✓ សេចក្តីពិពណ៌នាអំពីសកម្មភាពលម្អិត ដែលចាំបាច់ត្រូវអនុវត្តដើម្បីសម្រេចគោលបំណងទាំងនេះ រួមទាំងរបៀបសម្រេចគោលបំណងទាំងនេះ ដូចជា ដោយអ្នកណា នៅពេលណា ដោយប្រើប្រាស់ធនធានអ្វីខ្លះ និងមានការពិនិត្យតាមដាន/ការពិនិត្យផ្ទៀងផ្ទាត់អ្វីខ្លះ និងគោលដៅ និងកម្រិតនៃការអនុវត្ត។ លើសពីនេះក៏ចាំបាច់ត្រូវមានការបង្កើតយន្តការ ដើម្បីផ្តោតការយកចិត្តទុកដាក់ ដើម្បីឆ្លើយតបចំពោះការផ្លាស់ប្តូរនានា ដែលកើតមានក្នុងការអនុវត្តគម្រោង ស្ថានភាពបន្ទាន់ ឬព្រឹត្តិការណ៍ដែលកើតឡើងដោយពុំមានការរំពឹងទុកជាមុន និងដំណើរការផ្តល់ការឯកភាពដែលពាក់ព័ន្ធ។
- ✓ ការបញ្ជាក់ពីរចនាសម្ព័ន្ធស្ថាប័ន តួនាទី ការប្រាស្រ័យទាក់ទង និងដំណើរការនៃការរៀបចំរបាយការណ៍ ដែលចាំបាច់ ជាផ្នែកមួយនៃការអនុវត្ត EMP។
- ✓ សេចក្តីពិពណ៌នាអំពីទំនាក់ទំនងរវាង EMP និងលក្ខខណ្ឌតម្រូវក្នុងច្បាប់ដែលពាក់ព័ន្ធ។
- ✓ សេចក្តីពិពណ៌នាពីលក្ខខណ្ឌតម្រូវសម្រាប់រក្សាទុកឯកសារ រៀបចំរបាយការណ៍ពិនិត្យឡើងវិញ សវនកម្ម និងធ្វើបច្ចុប្បន្នភាព EMP។

19. ពុំមានទម្រង់ស្តង់ដារសម្រាប់ EMPs ឡើយ។ ទម្រង់នេះចាំបាច់ត្រូវទៅតាមកាលៈទេសៈ ដែល EMP ត្រូវបានរៀបចំឡើង និងទៅតាមលក្ខខណ្ឌតម្រូវ ដែល EMP ត្រូវបានរៀបចំឡើងដើម្បីបំពេញ។ សម្រាប់វិធានការសម្រាលផលប៉ះពាល់នីមួយៗ ជារឿយៗគួរមានការសង្ខេបវិធានការទាំងនេះ ក្នុងតារាងដោយបង្ហាញសម្រាប់វិធានការនីមួយៗពីអ្នកដែលត្រូវទទួលខុសត្រូវ ទីតាំង ឬផ្នែកនៃគម្រោង ដែលត្រូវអនុវត្តតាមវិធានការនេះ ពេលវេលា ថវិកា និងការពិនិត្យតាមដាន ដើម្បីផ្ទៀងផ្ទាត់បញ្ជាក់ថា វិធានការនេះពិតជាសម្រេចទៅតាមគោលដៅ ដែលចង់បានពិតប្រាកដមែន។ លើសពីនេះក៏ចាំបាច់ត្រូវមានការពិនិត្យតាមដានបន្ថែមផងដែរ (មិនពាក់ព័ន្ធជាមួយនឹងថាតើវិធានការសម្រាលផលប៉ះពាល់កំពុងដំណើរការទៅទៅតាមការគ្រោងទុក ឬអត់នោះទេ)។ ព័ត៌មានទាំងនេះក៏អាចបញ្ចូលទៅក្នុងតារាងសង្ខេប ដែលបង្ហាញពីអ្នកដែលទទួលខុសត្រូវ មូលហេតុដែលនាំឱ្យមានវិធានការនេះ និងផ្នែកនៃគម្រោងដែលត្រូវអនុវត្តវិធានការនេះ ពេលវេលា ការរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងការពិនិត្យតាមដាន និងការចំណាយ។ កម្រិតលម្អិតនៅក្នុង EMP អាចមានការប្រែប្រួលពីពីរបីទំព័រ សម្រាប់គម្រោងដែលមានហានិភ័យបរិស្ថានទាប រហូតដល់ច្រើនទំព័រសម្រាប់គម្រោងប្រភេទ A ដែលមានលក្ខណៈស្មុគស្មាញ និងមានវិសាលភាពធំ និងដែលអាចបង្កហានិភ័យបរិស្ថាន ក្នុងកម្រិតខ្ពស់។

20. ការរៀបចំ EMP គួរធ្វើឡើង ដើម្បីងាយស្រួលប្រើប្រាស់។ ព័ត៌មានយោងនានានៅក្នុងផែនការនេះ គួរកំណត់ឱ្យបានច្បាស់លាស់ និងងាយស្រួលស្វែងរក។ លើសពីនេះ អត្ថបទចម្បងនៃ EMP ចាំបាច់ត្រូវតែមានភាពច្បាស់លាស់ និងកាត់ខ្លីបំផុតតាមដែលអាចធ្វើទៅបាន ហើយព័ត៌មានលម្អិត ត្រូវ

យកទៅដាក់នៅក្នុងឧបសម្ព័ន្ធ។ EMP គួរបង្ហាញពីទំនាក់ទំនងជាមួយផែនការពាក់ព័ន្ធដទៃទៀតទាក់ទិននឹងគម្រោង ដូចជា ផែនការសម្រាប់ឆ្លើយតបចំពោះបញ្ហាតាំងទីលំនៅ ឬបញ្ហាជនជាតិភាគតិចជាដើម។

21. បើទោះបីជាវិសាលភាព និងខ្លឹមសាររបស់ EMP អាចមានការប្រែប្រួលទៅតាមភាពគួរឱ្យកត់សម្គាល់នៃផលប៉ះពាល់ ដែលអាចបង្កឡើងដោយសារគម្រោង និងទីតាំងរបស់គម្រោងយ៉ាងណាក៏ដោយ មានសមាសភាគរួមមួយចំនួន ដែលគួរបញ្ចូលទៅក្នុងគ្រប់ EMP ទាំងអស់។ សមាសភាគទាំងនេះ ដែលត្រូវបានលើកជាឧទាហរណ៍បង្ហាញសម្រាប់គម្រោងដែលមានហានិភ័យពីមធ្យមទៅខ្ពស់ ត្រូវបានរៀបរាប់លម្អិតដូចខាងក្រោម៖

**ប្រអប់ទី ១. សមាសភាគរួមនៃ EMP និងខ្លឹមសាររបស់វា**

22. ***សេចក្តីផ្តើម*** *- បង្ហាញព័ត៌មានដោយសង្ខេបខ្លីងាយស្រួលយល់អំពី*

*(i) បរិបទ EMP៖ រៀបរាប់ពីថាតើ EMP សមស្របទៅនឹងដំណើរការនៃការរៀបចំផែនការជារួមរបស់គម្រោងដោយរបៀបណា រៀបរាប់ពីការសិក្សាបរិស្ថាននៅកម្រិតគម្រោង/អនុគម្រោង ដូចជា EIA/EPC ឯកសារសម្រាប់ទទួលបានការឯកភាព។*

*(ii) ទំនាក់ទំនងរវាង EMP ជាមួយនឹង ESMF (ប្រសិនបើពាក់ព័ន្ធ) និងជាមួយគម្រោង។*

*(iii) គោលបំណងនៃ EMP៖ រៀបរាប់ពីអ្វីដែល EMP ព្យាយាមសម្រេចឱ្យបាន។ គោលបំណងនេះគួរមានភាពជាក់លាក់ទៅតាមគម្រោង ពុំមែនជាការរៀបរាប់គោលនយោបាយបែបទូលំទូលាយនោះឡើយ។ EMP សម្រាប់គម្រោង ត្រូវជាផ្នែកមួយនៃសេចក្តីពិពណ៌នាក្នុងកិច្ចសន្យាគម្រោង។*

23. *ក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌរដ្ឋបាល*

- *2.1 លិខិតបទដ្ឋានគតិយុត្តិរបស់រដ្ឋាភិបាល - រៀបរាប់ដោយសង្ខេបពីលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋាភិបាល ពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងលិខិតបទដ្ឋានគតិយុត្ត និងស្តង់ដារបច្ចេកទេស ដែលត្រូវអនុវត្តចំពោះអនុគម្រោងនេះ។*
- *2.2 គោលនយោបាយស្តីពីការការពារផលប៉ះពាល់របស់ធនាគារពិភពលោក – រៀបរាប់ពីគោលនយោបាយការពារផលប៉ះពាល់របស់ធនាគារពិភពលោក ដែលត្រូវអនុវត្ត។*

24. *សេចក្តីពិពណ៌នាអំពីគម្រោង* – គោលបំណង និងសេចក្តីពិពណ៌នារបស់គម្រោង/អនុគម្រោងគួរចែងឱ្យបានលម្អិតគ្រប់គ្រាន់ ដើម្បីកំណត់ពីលក្ខណៈ និងវិសាលភាពរបស់គម្រោង។ សេចក្តីពិពណ៌នារបស់គម្រោងត្រូវរៀបរាប់ពី៖

(i) ទីតាំងគម្រោង៖ គួរមានការរៀបរាប់ពីទីតាំង សកម្មភាព រួមនឹងផែនទីទីតាំងដែលបង្ហាញពីទីតាំងរបស់តំបន់គម្រោង និងព័ត៌មានលម្អិតនៅកម្រិតអនុគម្រោង។

(ii) សកម្មភាពសាងសង់/ប្រតិបត្តិការ៖ សេចក្តីពិពណ៌នានេះ អាចរៀបរាប់ដោយសង្ខេបពីដំណើរការសាងសង់ និងប្រតិបត្តិការ, ម៉ោងធ្វើការ ឬម៉ោងប្រតិបត្តិការ រួមនឹងសេចក្តីលម្អិតអំពីសកម្មភាពនានា ដែលចាំបាច់ត្រូវធ្វើក្រៅម៉ោងធ្វើការ, ចំនួនអ្នកធ្វើការ និងប្រភេទអ្នកធ្វើការ, រោងចក្រ និងបរិក្ខារដែលនឹងត្រូវប្រើប្រាស់, ទីតាំង និងសម្ភារៈរូបវន្តនៅទីតាំង និងជំរំរបស់កម្មករ, ឯកសារដែលបង្ហាញអំពីបរិមាណការងារសាងសង់។

(iii) ពេលវេលា និងកាលវិភាគ៖ គួរមានការបញ្ជាក់ពីកាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់រំពឹងទុក។ ប្រសិនបើគម្រោងនេះ ត្រូវបញ្ចប់ជាដំណាក់កាលៗ នោះគួរមានការបង្ហាញពីកាលបរិច្ឆេទដាច់ដោយឡែក សម្រាប់ដំណាក់កាលនីមួយៗ។

25. ទិន្នន័យដើមគ្រា – ផ្តល់ព័ត៌មានសំខាន់អំពីសាវតារបរិស្ថានរបស់អនុគម្រោង ព្រមទាំងទំនាក់ទំនងរបស់វាជាមួយតំបន់គម្រោង រាប់បញ្ចូលទាំងផែនទីផងដែរ។ គួរមានការផ្តោត

ការយកចិត្តទុកដាក់ ដើម្បីបង្ហាញព័ត៌មានឱ្យបានច្បាស់លាស់ អំពីឋានលេខាសាស្ត្រ ការប្រើប្រាស់ដីធ្លី និងការប្រើប្រាស់ធនធានទឹកសំខាន់ៗ ប្រភេទដី លំហូរទឹក និងគុណភាពទឹក/ការបំពុលទឹក។ លើសពីនេះក៏គួរមានការបញ្ចូលសេចក្តីពិពណ៌នាដោយសង្ខេបអំពីស្ថានភាពសង្គមសេដ្ឋកិច្ច និង EM ផងដែរ (ប្រសិនបើពាក់ព័ន្ធ)។ គួរបញ្ចូលរូបថតដែលបង្ហាញពីស្ថានភាពបច្ចុប្បន្ននេះរបស់ទីតាំងគម្រោងផងដេរ។

26. **ផលប៉ះពាល់ដែលអាចកើតមានឡើង និងវិធានការសម្រាលផលប៉ះពាល់៖** ផ្នែកនេះសង្ខេបពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន ដែលគេព្យាករណ៍ថានឹងកើតឡើង ដោយសារគម្រោង/អនុគម្រោងដែលត្រូវបានលើកស្នើឡើង ជាពិសេសគម្រោង/អនុគម្រោងដែលបង្កផលប៉ះពាល់ ដែលមានសារៈសំខាន់ចាប់ពីកម្រិតមធ្យម ដល់កម្រិតខ្ពស់។ គួរមានការបង្ហាញដោយសង្ខេបអំពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន ដែលគេព្យាករណ៍ថានឹងកើតឡើងដោយសារគម្រោងដែលត្រូវបានលើកស្នើឡើងនេះ ដែលទាមទារឱ្យមានការចាត់វិធានការគ្រប់គ្រង (ឧទាហរណ៍ ការសម្រាលផលប៉ះពាល់អវិជ្ជមាន ឬការបង្កើនផលប៉ះពាល់វិជ្ជមានជាដើម)។ គេគួរទទួលបានព័ត៌មានដែលចាំបាច់សម្រាប់ផ្នែកនេះ ពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន និងរបាយការណ៍ EPC។

27. គួរមានការរៀបរាប់ពីផលប៉ះពាល់សម្រាប់ដំណាក់កាលមុនសាងសង់ ដំណាក់កាលសាងសង់ និងដំណាក់កាលប្រតិបត្តិការ។ ការប្រើប្រាស់តារាងម៉ាទ្រីកអាចជួយឱ្យគេយល់កាន់តែច្បាស់ពីទំនាក់ទំនងរវាងផលប៉ះពាល់ និងវិធានការសម្រាលផលប៉ះពាល់។ គួរមានការផ្ទៀងផ្ទាត់ជាមួយនឹងរបាយការណ៍ EIA/EPCs ឬឯកសារផ្សេងទៀត ដើម្បីងាយស្រួលដឹងពីព័ត៌មានលម្អិតបន្ថែមនានា។ ខណៈពេលដែលផលប៉ះពាល់ និងហានិភ័យសង្គម និងបរិស្ថាន ដែលគេដឹងជាទូទៅថាកើតចេញពីសកម្មភាពសាងសង់ អាចឆ្លើយតប តាមរយៈក្រមប្រតិបត្តិបរិស្ថាន (ECOP) ក៏គួរមានការលើកស្នើនូវវិធានការសម្រាលផលប៉ះពាល់ ដើម្បីឆ្លើយតបចំពោះផលប៉ះពាល់ជាក់លាក់នៅកម្រិតអនុគម្រោងផ្អែកទៅតាមស្ថានភាពរបស់ទីតាំង និងប្រភេទនៃការវិនិយោគផងដែរ។ គេអាចលើកស្នើនូវវិធានការមួយចំនួន សម្រាប់បញ្ចូលទៅក្នុងការរៀបចំវិស្វកម្ម ដើម្បីឆ្លើយតបចំពោះផលប៉ះពាល់/ហានិភ័យ ដែលអាចកើតមានឡើង និង/ឬផ្តល់តម្លៃបន្ថែមដល់ការងារ ដែលត្រូវធ្វើនៅក្នុងអនុគម្រោង (ឧទាហរណ៍ ការកែលម្អផ្លូវថ្នល់/ផ្លូវភ្ជាប់ រួមជាមួយនឹងការចាក់បេតុងប្រឡាយ)។ វិធានការសម្រាលផលប៉ះពាល់ គួរបញ្ចូលកម្មវិធីអប់រំផ្សព្វផ្សាយ និងយន្តការឆ្លើយតបចំពោះបណ្តឹងសារទុក្ខ ដើម្បីឆ្លើយតបចំពើផលប៉ះពាល់សង្គម។ ត្រូវធានាថា ផ្នែកនេះអាចឆ្លើយតបចំពោះសំណូមពរសមស្រប និងឆ្លើយតបឱ្យបានគ្រប់គ្រាន់ចំពោះបញ្ហា និងការព្រួយបារម្ភនានា ដែលលើកឡើងដោយសហគមន៍ ដូចដែលត្រូវបានកត់ត្រាទុកក្នុងឯកសារសង្ខេបអំពីការពិគ្រោះយោបល់ ដែលបង្ហាញក្នុងផ្នែកទី ៨។ សូមមើលតារាងទី ១ គំរូតារាងម៉ាទ្រីក បង្ហាញពីវិធានការសម្រាលផលប៉ះពាល់។

តារាងទី ១៖ ឧទាហរណ៍ដែលបង្ហាញពីតារាងម៉ាទ្រីកវិធានការសម្រាលផលប៉ះពាល់

| ដំណាក់កាល | បញ្ហា | វិធានការសម្រាលផលប៉ះពាល់ | ទីតាំងសម្រាប់អនុវត្តវិធានការសម្រាល | ស្តង់ដារដែលត្រូវយកមកអនុវត្ត (ឧទាហរណ៍ ស្តង់ដាររបស់ប្រទេស ស្តង់ដាររបស់ធនាគារពិភពលោក សហភាពអឺរ៉ុប) | ការចំណាយលើការសម្រាលផលប៉ះពាល់ | ភាគីទទួលខុសត្រូវ | ការផ្ទៀតផ្ទាត់ដែលចាំបាច់ត្រូវមានដើម្បីកំណត់ពីប្រសិទ្ធភាពនៃវិធានការទាំងនេះ |
|---|---|---|---|---|---|---|---|
| **ដំណាក់កាលរៀបចំ/ មុនពេលសាងសង់** | | | | | | | |
| **ដំណាក់កាលសាងសង់** | | | | | | | |
| **ដំណាក់កាលប្រតិបត្តិការ** | | | | | | | |

| ដំណាក់កាលរុះរើសំណង់របស់គម្រោង | | | | | | | |
|---|---|---|---|---|---|---|---|

អាស្រ័យទៅតាមផលប៉ះពាល់របស់គម្រោង គោលនយោបាយស្តីពីធនធានវប្បធម៌រូបវន្ត (OP 4.11) ឬគោលនយោបាយស្តីពីការគ្រប់គ្រងសមាសភាគចង្រៃ (OP 4.09) អាចយកមកអនុវត្ត ហើយប្រហែលជាចាំបាច់ត្រូវរៀបចំផែនការស្តីពីធនធានវប្បធម៌រូបវន្ត និងផែនការគ្រប់គ្រងសមាសភាគចង្រៃ និងបញ្ចូលផែនការទាំងនេះទៅក្នុង EMP។

28. **ការពិនិត្យតាមដាន** – ការពិនិត្យតាមដាន ការអនុវត្ត EMP ត្រូវគ្របដណ្តប់លើការពិនិត្យតាមដាន ភាពអនុលោមផ្នែកបរិស្ថាន និងការពិនិត្យតាមដានបរិស្ថាន ក្នុងអំឡុងពេលអនុវត្តគម្រោង ដូចរៀបរាប់លម្អិតខាងក្រោម៖

(i) ការពិនិត្យតាមដានលើភាពអនុលោមផ្នែកបរិស្ថាន រួមមានប្រព័ន្ធសម្រាប់តាមដានភាពអនុលោមផ្នែកបរិស្ថានរបស់ក្រុមហ៊ុនម៉ៅការ ដូចជាការពិនិត្យការអនុវត្តការងាររបស់ក្រុមហ៊ុនម៉ៅការ ឬស្ថាប័នរដ្ឋាភិបាលធៀបនឹងការប្តេជ្ញា ដែលលើកឡើងក្នុងឯកសារផ្លូវការ ដូចជា សេចក្តីពិពណ៌នាក្នុងកិច្ចសន្យា ឬក្នុងកិច្ចព្រមព្រៀងផ្តល់កម្ចីជាដើម។

(ii) ការពិនិត្យតាមដានបរិស្ថានមានគោលបំណង៖ ក) វាស់វែងប្រសិទ្ធភាពនៃវិធានការសម្រាលផលប៉ះពាល់ (ឧទាហរណ៍ ប្រសិនបើវិធានការសម្រាលផលប៉ះពាល់មានគោលបំណងត្រួតពិនិត្យលើសំឡេងរំខានក្នុងអំឡុងពេលសាងសង់ នោះផែនការពិនិត្យតាមដានគួរបញ្ចូលការវាស់វែងកម្រិតសំឡេងរំខានក្នុងអំឡុងពេលសាងសង់), ខ) បំពេញទៅតាមលក្ខខណ្ឌតម្រូវផ្នែកបរិស្ថានរបស់អ្នកខ្ចី និង គ) ឆ្លើយតបចំពោះការព្រួយបារម្ភនានា ដែលអាចលេចឡើងក្នុងអំឡុងពេលពិគ្រោះយោបល់ជាសាធារណៈ (ឧទាហរណ៍សំឡេងរំខាន កម្តៅ ក្លិន។ល។) បើទោះបីជាការពិនិត្យតាមដាននេះពុំពាក់ព័ន្ធជាមួយនឹងបញ្ហាបរិស្ថានពិតប្រាកដយ៉ាងណាក៏ដោយ (វាជាការបង្ហាញពីសុច្ឆន្ទៈរបស់អ្នកខ្ចី)។ កម្មវិធីពិនិត្យតាមដាន គួរបង្ហាញឱ្យបានច្បាស់ពីទំនាក់ទំនងរវាងផលប៉ះពាល់ ដែលត្រូវបានកំណត់ក្នុងរបាយការណ៍វាយតម្លៃបរិស្ថាន សូចនាករដែលត្រូវវាស់វែង វិធីសាស្ត្រដែលត្រូវប្រើប្រាស់ សកម្មភាពប្រមូលសំណាកគំរូ ភាពញឹកញាប់នៃការវាស់វែងកម្រិតកំណត់នៃការរកឃើញបញ្ហា (ក្នុងករណីដែលសមស្រប) និងការកំណត់កម្រិតកំណត់ដែលបង្ហាញសញ្ញាថាចាំបាច់ត្រូវមានការអនុវត្តវិធានការកែតម្រូវ។ល។ គួរមានការប៉ាន់ប្រមាណចំណាយសម្រាប់ពិនិត្យតាមដានបរិស្ថាន និងបញ្ចូលវាទៅក្នុងចំណាយវិនិយោគសរុបរបស់អនុគម្រោង។ ការពិនិត្យតាមដាន និងការប្រមូលទិន្នន័យមានសារៈសំខាន់យ៉ាងខ្លាំង ហើយទិន្នន័យទាំងនេះ ត្រូវយកមកប្រើប្រាស់ជាក់ស្តែង។ វាពុំមានតម្លៃអ្វីឡើយ ប្រសិនបើគេចំណាយលុយ ដើម្បីប្រមូលទិន្នន័យ ហើយបែរជាមិនត្រូវបានយកមកធ្វើការវិភាគឱ្យបានត្រឹមត្រូវ និងពុំមានរៀបចំជារបាយការណ៍ ហើយប្រសិនបើមានការរៀបចំជារបាយការណ៍ដែរ ប៉ុន្តែគេពុំអាចឬនឹងមិនអនុវត្តសកម្មភាពនោះ។ គោលការណ៍ដែលត្រូវចងចាំគឺត្រូវដឹងពីប្រភេទនៃការវិភាគដែលត្រូវធ្វើលើទិន្នន័យ មុនពេលប្រមូលទិន្នន័យ ដើម្បីធានាថា គេអាចដឹងជាមុនពីការវិភាគទិន្នន័យដែលត្រូវធ្វើ។

29. សូមមើលតារាងទី ២ ខាងក្រោម ស្តីពីឧទាហរណ៍អំពីរបៀបរៀបចំការពិនិត្យតាមដាន។

***តារាងទី ២៖ ឧទាហរណ៍ដែលបង្ហាញពីផែនការពិនិត្យតាមដាន***

| ដំណាក់កាល | **តើត្រូវពិនិត្យតាមដានលើប៉ារ៉ាម៉ែត្រអ្វីខ្លះ? (**សូមបញ្ជាក់ប្រសិនបើការពិនិត្យតាមដាននេះធ្វើឡើងធៀបនឹងស្តង់ដារអ្វីមួយ) | **តើការពិនិត្យតាមដាន**ប៉ារ៉ាម៉ែត្រនេះត្រូវធ្វើនៅកន្លែងណា? | **តើការពិនិត្យតាមដាន**ប៉ារ៉ាម៉ែត្រនេះ ត្រូវធ្វើដោយរបៀបណា/ប្រភេទនៃឧបករណ៍ពិនិត្យតាមដាន? | **តើការពិនិត្យតាមដាន**ប៉ារ៉ាម៉ែត្រនេះត្រូវធ្វើឡើងនៅពេលណា/ភាពញឹកញាប់នៃការវាស់វែងឬការវាស់វែងជាប់ជាប្រចាំ? | **ភាគីទទួលខុសត្រូវ** |
|---|---|---|---|---|---|
| **មុនពេលសាងសង់** | | | | | |
| **ដំណាក់កាលសាងសង់** | | | | | |
| **ដំណាក់កាលប្រតិបត្តិការ** | | | | | |
| **ដំណាក់កាលរុះរើសំណង់របស់គម្រោង** | | | | | |

30. ***ការរៀបចំការអនុវត្ត EMP៖*** *គួរបញ្ចូលផ្នែកខាងក្រោម។*

(ក) ការទទួលខុសត្រូវលើការអនុវត្ត EMP៖ រៀបរាប់ពីរបៀបដែលទីភ្នាក់ងារអនុវត្តគ្រោងនឹងបែងចែកការទទួលខុសត្រូវ ដើម្បីធានាឱ្យមានលំហូរព័ត៌មានបរិស្ថាន និងការប្រើប្រាស់ព័ត៌មានបរិស្ថានឱ្យបានសមស្រប ដើម្បីឱ្យការគ្រប់គ្រងបរិស្ថានអាចធ្វើទៅបាន ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ សម្រាប់គម្រោងដែលទទួលបានហិរញ្ញប្បទានពីធនាគារ អ្នកពាក់ព័ន្ធដែលចូលរួមក្នុងការអនុវត្ត និងការពិនិត្យតាមដាន EMP ជាធម្មតារួមមាន ទីភ្នាក់ងារអនុវត្តគម្រោង PCO ក្រុមហ៊ុនម៉ៅការសំណង់ ទីប្រឹក្សាគ្រប់គ្រងការសាងសង់ ទីប្រឹក្សាពិនិត្យតាមដានបរិស្ថានឯករាជ្យ (IEMC) អាជ្ញាធរគ្រប់គ្រងបរិស្ថាននៅមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាលនៅសហគមន៍។ គួរមានការបែងចែកការទទួលខុសត្រូវទៅឱ្យតួអង្គពាក់ព័ន្ធនីមួយៗ។ ការសម្របសម្រួលល្អរវាងតួអង្គពាក់ព័ន្ធទាំងនេះ នឹងធានាឱ្យមានការអនុវត្ត EMP ប្រកបដោយប្រសិទ្ធភាព។ ការទទួលខុសត្រូវរបស់ទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ និងទីប្រឹក្សាពិនិត្យតាមដានបរិស្ថានឯករាជ្យក្នុងការពិនិត្យតាមដាន និងការគ្រប់គ្រងភាពអនុលោមទៅតាម EMP ក្នុងអំឡុងដំណាក់កាលសាងសង់ និងដំណាក់កាលគ្រប់គ្រង ការសាងសង់គួរផ្តល់នូវព័ត៌មានលម្អិតមួយចំនួន។ លក្ខខណ្ឌប្រតិបត្តិទូទៅសម្រាប់ទីប្រឹក្សា គ្រប់គ្រងការសាងសង់ និងទីប្រឹក្សាពិនិត្យតាមដានបរិស្ថានឯករាជ្យគួរបញ្ចូលជាឧបសម្ព័ន្ធទៅក្នុង EMP។

(ខ) ការបញ្ជូន EMP ទៅក្នុងឯកសាររៀបចំបច្ចេកទេសលម្អិត ឯកសារដេញថ្លៃ និងកិច្ចសន្យា៖ ឯកសារដេញថ្លៃ និងឯកសារកិច្ចសន្យា គួរបញ្ចូលឯកសារដែលចែងពីលក្ខខណ្ឌតម្រូវនៃ EMP ដើម្បីធានាឱ្យមានការផ្តល់ព័ត៌មានឱ្យបានច្បាស់លាស់ អំពីកាតព្វកិច្ច ដែលត្រូវបំពេញដល់ក្រុមហ៊ុនម៉ៅការ។ ឯកសារដេញថ្លៃក៏អាចបញ្ចូលលក្ខណៈវិនិច្ឆ័យបរិស្ថានផងដែរ ជាមូលដ្ឋានសម្រាប់ធ្វើការជ្រើសរើសក្រុមហ៊ុនម៉ៅការ។ ក្រុមហ៊ុនម៉ៅការក៏គួរមានកាតព្វកិច្ចអនុវត្តទៅតាមស្តង់ដារបរិស្ថាន ស្តង់ដារសុខភាព និងសុវត្ថិភាពឱ្យបានសមស្រប ដើម្បីកាត់បន្ថយហានិភ័យពាក់ព័ន្ធក្នុងអំឡុងដំណាក់កាលសាងសង់ និងដំណាក់កាលប្រតិបត្តិការផងដែរ។ ដូច្នេះ ផ្នែកនេះក៏គួររៀបរាប់ពីរបៀបដែល PCO និងបុគ្គលិករបស់ការិយាល័យនេះ បញ្ចូល EMP ទៅក្នុងការតាក់តែងលម្អិតរបស់គម្រោង និងឯកសារដេញថ្លៃ។ ត្រូវបន្ថែមការមាន បទពិសោធន៍ជាមួយនឹងការរៀបចំ EMP សម្រាប់កំណត់ពីគុណវុឌ្ឍិ។

(គ) ក្របខ័ណ្ឌអនុលោមផ្នែកបរិស្ថានក្នុងអំឡុងពេលអនុវត្តគម្រោង៖ អ្នកខ្ចីកម្ចីត្រូវរាយការណ៍ពីភាពអនុលោមទៅតាមការប្តេជ្ញាចិត្តផ្នែកបរិស្ថាន ស្ថានភាពនៃការអនុវត្តវិធានការសម្រាលផលប៉ះពាល់ និងលទ្ធផលរកឃើញនៃកម្មវិធីពិនិត្យតាមដាន ដូចដែលត្រូវបាន

បញ្ជាក់ក្នុងឯកសារគម្រោង។ ធនាគារធ្វើការពិនិត្យតាមដានទិដ្ឋភាពបរិស្ថានរបស់គម្រោង ផ្អែកទៅតាម EMP ដូចដែលត្រូវបានលើកឡើងក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់សម្រាប់គម្រោង។ ផ្នែករងនេះ រៀបរាប់ពីភារកិច្ចបរិស្ថានរបស់ក្រុមហ៊ុនម៉ៅការ និងភារកិច្ចរបស់មន្ត្រីសុវត្ថិភាព និងបរិស្ថានរបស់ក្រុមហ៊ុនម៉ៅការ ភាពអនុលោមទៅតាមលក្ខខណ្ឌតម្រូវ ដែលមានចែង នៅក្នុងច្បាប់ និងក្នុងកិច្ចសន្យា និងការពិនិត្យផ្នែកបរិស្ថាន ក្នុងអំឡុងពេលពិនិត្យលើការសាងសង់ និងក្របខ័ណ្ឌសម្រាប់ដាក់ទោសទណ្ឌ។

(ឃ) នីតិវិធីសម្រាប់រៀបចំរបាយការណ៍៖ នីតិវិធីដើម្បីផ្តល់ព័ត៌មានអំពីវឌ្ឍនភាព និងលទ្ធផលនៃការអនុវត្តវិធានការសម្រាលផលប៉ះពាល់ និងវិធានការពិនិត្យតាមដាន គួរត្រូវបានបញ្ជាក់ឱ្យបានច្បាស់លាស់។ អ្នកទទួលព័ត៌មាននេះ យ៉ាងហោចណាស់គួរដឹងពីការទទួលខុសត្រូវក្នុងការធានាឱ្យមានការអនុវត្តវិធានការសម្រាលផលប៉ះពាល់ឱ្យបានទាន់ពេលវេលា និងចាត់វិធានការកែតម្រូវជាការឆ្លើយតបចំពោះការបំពានកម្រិតកំណត់នៃការពិនិត្យតាមដាន។ លើសពីនេះ រចនាសម្ព័ន្ធរបាយការណ៍ ខ្លឹមសាររបាយការណ៍ និងពេលដែលត្រូវរៀបចំរបាយការណ៍ដាក់ជូនធនាគារ គួររៀបចំឱ្យបានច្បាស់លាស់ ដើម្បីបង្កភាពងាយស្រួលដល់ការចុះពិនិត្យ។ លើសពីនេះក៏គួរមានការបញ្ជាក់ឱ្យបានច្បាស់ពីការទទួលខុសត្រូវរបស់តួអង្គនានា លើការរាយការណ៍ និងប្រភេទរបាយការណ៍ផងដែរ។

31. ***ផែនការពង្រឹងស្ថាប័ន៖*** រៀបរាប់ពីតម្រូវការស្ថាប័ន ដើម្បីធានាឱ្យមានការអនុវត្តផែនការសម្រាលផលប៉ះពាល់ និងផែនការពិនិត្យតាមដានឱ្យបានជោគជ័យ។ នេះអាចរួមមានការទិញឧបករណ៍សម្ភារៈ ការបណ្តុះបណ្តាល សេវារបស់ទីប្រឹក្សា និងការសិក្សាពិសេស។ គម្រោងភាគច្រើនតម្រូវឱ្យមានការពង្រឹងសមត្ថភាព ផ្នែកការអនុវត្ត EMP តាមរយៈការផ្តល់ការបណ្តុះបណ្តាលដល់តួអង្គពាក់ព័ន្ធនានា។

32. រាល់តួអង្គពាក់ព័ន្ធទាំងអស់គួរឆ្លងកាត់ការបណ្តុះបណ្តាលបង្កើនការយល់ដឹងជាទូទៅអំពីបរិស្ថាន និងការបណ្តុះបណ្តាលអំពីការទទួលខុសត្រូវរបស់ពួកគេ ក្រោមក្របខ័ណ្ឌ EMP។ ការបណ្តុះបណ្តាលនេះគួរធានាយ៉ាងណាឱ្យពួកគេអាចយល់ពីកាតព្វកិច្ចរបស់ពួកគេក្នុងការគ្រប់គ្រងបរិស្ថានឱ្យបានត្រឹមត្រូវ ក្នុងអំឡុងពេលអនុវត្តគម្រោង។ ការបណ្តុះបណ្តាលបរិស្ថានគួរបញ្ចូល៖ ការណែនាំអំពីទីតាំង, ការយល់ដឹងអំពីលក្ខខណ្ឌតម្រូវក្នុង EMP, ការបណ្តុះបណ្តាលអំពីការឆ្លើយតបចំពោះស្ថានភាពអាសន្នផ្នែកបរិស្ថាន, ការយល់ដឹងអំពីការគ្រប់គ្រងបរិស្ថាននៅនឹងកន្លែង, ការបណ្តុះបណ្តាលបរិស្ថានផ្តោតលើបុគ្គលិកមួយចំនួន ដូចជា បុគ្គលិកបរិស្ថានរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs), មន្ត្រីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថានរបស់ក្រុមហ៊ុនម៉ៅការ, វិស្វករគ្រប់គ្រងការងារសាងសង់ជាដើម។

33. គួរមានការកំណត់ពីតម្រូវការផ្តល់ការបណ្តុះបណ្តាលបន្ថែម ឬការបណ្តុះបណ្តាលឡើងវិញ និងអនុវត្តការបណ្តុះបណ្តាលទាំងនេះ ផ្អែកទៅតាមលទ្ធផលនៃការពិនិត្យតាមដាន និងការពិនិត្យឡើងវិញលើ EMP។ គួរមានការរក្សាទុករាល់ឯកសារនៃការបណ្តុះបណ្តាលទាំងអស់ ដោយត្រូវបញ្ជាក់ពី៖ តើអ្នកណាខ្លះ ដែលបានទទួលការបណ្តុះបណ្តាល ពេលដែលអ្នកនោះបានទទួលការបណ្តុះបណ្តាល ឈ្មោះអ្នកបណ្តុះបណ្តាល និងសេចក្តីពិពណ៌នាទូទៅអំពីខ្លឹមសារនៃការបណ្តុះបណ្តាល។

34. ***ការប៉ាន់ប្រមាណថវិកាសម្រាប់ការអនុវត្ត EMP -*** គួរមានការបញ្ជាក់ពីថវិកាសម្រាប់ការវិនិយោគដំបូងៗផង និងសម្រាប់ចំណាយចរន្តលើការអនុវត្តរាល់វិធានការទាំងអស់ ដែលត្រូវបានលើកឡើងក្នុង EMP ដោយត្រូវបញ្ចូលទៅក្នុងចំណាយសរុបរបស់គម្រោង និងក្នុងការចរចាអំពីកម្ចី។ ជាការសំខាន់ណាស់ដែលត្រូវបញ្ចូលរាល់ចំណាយទាំងអស់ ដូចជា ចំណាយរដ្ឋបាល ចំណាយលើការបណ្តុះបណ្តាល ចំណាយលើការពិនិត្យ និងតាមដានបរិស្ថាន ចំណាយលើការអនុវត្តវិធានការសម្រាលផលប៉ះពាល់ ដែលត្រូវអនុវត្តដោយក្រុមហ៊ុនម៉ៅការ ចំណាយលើការសិក្សាបរិស្ថានបន្ថែម ចំណាយលើប្រតិបត្តិការ និងតំហែទាំ។ គោលបំណងចម្បង គឺដើម្បីកាត់សម្រាលផលប៉ះពាល់អវិជ្ជមានក្នុងកម្រិតជាទីពេញចិត្ត ដោយអស់ចំណាយតិចបំផុត។ ចំណាយសម្រាប់រៀបចំ EMP ដែលត្រូវរ៉ាប់រងដោយអ្នកខ្ចីកម្ចី មានការប្រែប្រួលអាស្រ័យទៅតាមកត្តានានា ដូចជា ភាពស្មុគស្មាញនៃផលប៉ះពាល់ដែលអាចកើតមានឡើង

កម្រិតនៃការប្រើប្រាស់ទីប្រឹក្សាអន្តរជាតិ និងភាពចាំបាច់ក្នុងការរៀបចំ EMP ដោយឡែក សម្រាប់អនុគម្រោងខុសៗគ្នា។

### *កិច្ចពិគ្រោះយោបល់*

35. EMP គួររៀបរាប់ឱ្យបានច្បាស់លាស់ និងបង្ហាញហេតុផលពីវិធានការសម្រាលផលប៉ះពាល់ដែលត្រូវបានលើកស្នើឡើង ដើម្បីសម្រួលដល់កិច្ចពិគ្រោះយោបល់ជាសាធារណៈ។ កិច្ចពិគ្រោះយោបល់ជាមួយអ្នកដែលរងផលប៉ះពាល់ និងអង្គការមិនមែនរដ្ឋាភិបាល មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់គ្រប់គម្រោងប្រភេទ A និង B ទាំងអស់ ដើម្បីស្វែងយល់ពីភាពអាចទទួលយកបាននៃវិធានការសម្រាលផលប៉ះពាល់ ដែលត្រូវបានលើកស្នើឡើងចំពោះក្រុមដែលរងផលប៉ះពាល់។ ក្នុងស្ថានភាពមួយចំនួន ការបង្កើនការយល់យល់ដឹងអំពីបរិស្ថានដល់គួអង្គពាក់ព័ន្ធ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីធានាឱ្យមានការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាពអំពី EMP។ ក្នុងករណីដែលតម្រូវឱ្យមានការធ្វើការលទ្ធកម្ម ឬការដោះស្រាយផលប៉ះពាល់/ការតាំងទីលំនៅក្នុងគម្រោង បញ្ហាទាំងនេះគួរទទួលបានការឆ្លើយតបឱ្យបានពេញលេញក្នុងផែនការសកម្មភាពដោះស្រាយផលប៉ះពាល់/តាំងទីលំនៅ (RAP) និងក្នុងផែនការអភិវឌ្ឍន៍ជនជាតិភាគតិច (EMDP) ឱ្យបានសមស្រប។

36. គេក៏អាចប្រើប្រាស់ដំណើរការពិគ្រោះយោបល់ ដើម្បីកាត់តែងវិធានការសម្រាលផលប៉ះពាល់ដែលអាចសម្រេចទៅបានផងដែរ។ ដំណើរការនេះមានសារៈសំខាន់ជាពិសេស អាស្រ័យទៅតាមការឯកភាពរបស់អ្នកដែលរងផលប៉ះពាល់ ជាពិសេសនៅក្នុងករណីដែលជោគជ័យនៃការអនុវត្តវិធានការទាំងនេះ ពឹងអាស្រ័យលើការគាំទ្រ ឬការអនុវត្តសកម្មភាពពីអ្នកទាំងនេះ (re-write this sentence)។ នៅក្នុងករណីដែលសមស្រប ការងារនេះអាចទទួលបានការគាំទ្រ តាមរយៈការបញ្ចូលលក្ខខណ្ឌតម្រូវផ្លូវការ ទៅក្នុងលក្ខខណ្ឌប្រតិបត្តិស្តីពីការចូលរួមជាសាធារណៈនៅក្នុងការរៀបចំ EMP។

37. កិច្ចពិគ្រោះយោបល់ជាសាធារណៈអំពី EMP គួរជាផ្នែកមួយដ៏សំខាន់នៃកិច្ចពិគ្រោះយោបល់អំពី EIA/EPC។ ក្នុងករណីដែលពុំមានការពិគ្រោះយោបល់ ឬការពិគ្រោះយោបល់ពុំត្រូវបានធ្វើឡើងឱ្យបានគ្រប់គ្រាន់ ក្នុងដំណើរការរៀបចំ EIA/EPC ត្រូវមានការរៀបចំកិច្ចពិគ្រោះយោបល់ ដើម្បីប្រមូលព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋ និងសហគមន៍ ដែលរងផលប៉ះពាល់។

38. ផ្នែកនេះបង្ហាញដោយសង្ខេបអំពីសកម្មភាពពិគ្រោះយោបល់ ជាមួយតួអង្គពាក់ព័ន្ធ ជាពិសេសគ្រួសារដែលរងផលប៉ះពាល់អំពីសេចក្តីព្រាងចុងក្រោយនៃ EMP នៅកម្រិតគម្រោង/អនុគម្រោង។ ព័ត៌មានសង្ខេបនេះគួរបង្ហាញពីកាលបរិច្ឆេទ និងទីតាំងដែលកិច្ចប្រជុំពិគ្រោះយោបល់ត្រូវបានធ្វើឡើង ចំនួនអ្នកចូលរួមមកពីគ្រួសារដែលរងផលប៉ះពាល់/ចំនួនអ្នកចូលរួមជាស្ត្រី និងជនជាតិភាគតិច និងសំណូមពរការព្រួយបារម្ភនានា ដែលត្រូវបានលើកឡើង និងការឆ្លើយតប។ គួរមានការផ្តល់ព័ត៌មានអំពីទីតាំង និងកាលបរិច្ឆេទនៃការបង្ហាញ EMP ជាសាធារណៈ។

### *ការបង្ហាញ EMP ជាសាធារណៈ*

39. ការបង្ហាញព័ត៌មាន៖ បើតាមគោលនយោបាយរបស់ធនាគារស្តីពីលទ្ធភាពទទួលបានព័ត៌មានរាល់សេចក្តីព្រាង ឧបករណ៍ការពារផលប៉ះពាល់ទាំងអស់ រាប់បញ្ចូលទាំង EMP ផង ត្រូវបង្ហាញជាសាធារណៈនូវមូលដ្ឋាននៅកន្លែងដែលគេងាយស្រួលចូលដល់ និងក្នុងទម្រង់ និងភាសាដែលអាចយល់បានចំពោះតួអង្គពាក់ព័ន្ធសំខាន់ៗ និងជាភាសាអង់គ្លេសនៅក្នុង InfoShop មុនពេលមានបេសកកម្មវាយតម្លៃ។ ត្រូវមានការបង្ហាញ EMP នៅនឹងមូលដ្ឋាន។

ច. សង្ខេប

40. អ្នកប្រើប្រាស់ គួរប្រើប្រាស់ឯកសារណែនាំនេះ រួមជាមួយនឹងកញ្ចប់ឧបករណ៍ ESMF, ESMF របស់គម្រោង, និងឧបករណ៍ការពារផលប៉ះពាល់បរិស្ថាន និងសង្គមផ្សេងទៀតរបស់គម្រោង។ ជាការសំខាន់ណាស់ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ព្រមទាំងទីប្រឹក្សា EMP ត្រូវធ្វើការងារឱ្យបានជិតស្និទ្ធជាមួយទីប្រឹក្សាការពារផលប៉ះពាល់គម្រោងដទៃទៀត ប្រធានក្រុមការងារ (Task Team Leader) នៃគម្រោងរបស់ធនាគារ និងបុគ្គលិកទទួលបន្ទុកការការពារ

ផលប៉ះពាល់របស់ធនាគារ នៅពេលរៀបចំ EMP និងធានាថា EMP នេះមានគុណភាពដល់កម្រិតដែលចាំបាច់។

## ឧបសម្ព័ន្ធទី ៤៖ ក្រមប្រតិបត្តិបរិស្ថាន (ECOPs) សម្រាប់ការងារសាងសង់ ឬការវិនិយោគហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

1. គោលបំណង

ក្រមប្រតិបត្តិបរិស្ថាន (ECOP) នេះ ត្រូវបានរៀបចំ ដើម្បីគ្រប់គ្រងផលប៉ះពាល់បរិស្ថានតូចតាចដែលកើតមានក្នុងអំឡុងដំណាក់កាលសាងសង់។ ECOP ត្រូវអនុវត្តសម្រាប់គ្រប់គ្រងអនុគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច។ ECOP គឺជាលក្ខខណ្ឌតម្រូវមួយ ក្នុងកិច្ចសន្យាសាងសង់ ឬឯកសារដេញថ្លៃ ដើម្បីឱ្យក្រុមហ៊ុនម៉ៅការ គោរពទៅតាមកិច្ចព្រមព្រៀងបរិស្ថាន។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងក្រសួងពាក់ព័ន្ធ (PTs) ព្រមទាំងមន្ត្រីគ្រប់គ្រងការងារសាងសង់ជាអ្នកទទួលខុសត្រូវលើការពិនិត្យតាមដានភាពអនុលោមទៅតាម ECOP និងរៀបចំរបាយការណ៍ ទៅតាមការតម្រូវ។

2. ការទទួលខុសត្រូវ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសា និងក្រសួងពាក់ព័ន្ធ (PTs) និងក្រុមហ៊ុនម៉ៅការ គឺជាស្ថាប័នសំខាន់ៗ ដែលទទួលខុសត្រូវលើការអនុវត្ត ECOP នេះ។ ការទទួលខុសត្រូវសំខាន់ៗរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) និងក្រុមហ៊ុនម៉ៅការមានដូចខាងក្រោម៖

***(ក) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs)***

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ទទួលខុសត្រូវធានាឱ្យការអនុវត្ត ECOP ដំណើរការទៅប្រកបដោយប្រសិទ្ធភាព។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ត្រូវចាត់តាំងបុគ្គលិកដែលមានសមត្ថភាពម្នាក់ឱ្យទទួលខុសត្រូវពិនិត្យលើភាពអនុលោមរបស់ក្រុមហ៊ុនម៉ៅការ ដូចជា៖ (ក) ពិនិត្យតាមដានភាពអនុលោមរបស់ក្រុមហ៊ុនម៉ៅការ ជាមួយនឹងផែនការបរិស្ថាន, (ខ) ចាត់វិធានការកែតម្រូវក្នុងករណីដែលមានភាពមិនអនុលោម និង/ឬផលប៉ះពាល់អវិជ្ជមានកើតមានឡើង, (គ) ស៊ើបអង្កេតលើពាក្យបណ្តឹង វាយតម្លៃ និងកំណត់ពីសកម្មភាពកែតម្រូវ, (ឃ) ផ្តល់ដំបូន្មានដល់ក្រុមហ៊ុនម៉ៅការអំពីវិធានការកែលម្អបរិស្ថាន បង្កើនការយល់ដឹង និងផ្តួចផ្តើមបង្ការការបំពុល និង (ង) ពិនិត្យតាមដានសកម្មភាពរបស់ក្រុមហ៊ុនម៉ៅការ ក្នុងការឆ្លើយតបចំពោះពាក្យបណ្តឹងនានា។

***(ខ) ក្រុមហ៊ុនម៉ៅការ***

- ក្រុមហ៊ុនម៉ៅការទទួលខុសត្រូវលើការងារសាងសង់ និងផ្តល់ព័ត៌មានដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) អាជ្ញាធរមូលដ្ឋាន និងសហគមន៍អំពីផែនការសាងសង់ និងហានិភ័យ ពាក់ព័ន្ធនឹងការងារសាងសង់។ ដូច្នេះ ក្រុមហ៊ុនម៉ៅការទទួលខុសត្រូវលើការអនុវត្តវិធានការ ដែលបានព្រមព្រៀងគ្នា ដើម្បីសម្រាលហានិភ័យបរិស្ថានពាក់ព័ន្ធនឹងការងារសាងសង់របស់ខ្លួន។
- ក្រុមហ៊ុនម៉ៅការត្រូវគោរពទៅតាមលិខិតបទដ្ឋានគតិយុត្ត និងច្បាប់ជាតិដែលពាក់ព័ន្ធដទៃទៀត។

ផ្នែកទី ១ – ការទទួលខុសត្រូវរបស់អ្នកក្រុមហ៊ុនម៉ៅការ

នេះគ្រាន់តែជាឧទាហរណ៍តែប៉ុណ្ណោះ និងពុំមែនជាការរៀបរាប់ពីគ្រប់លក្ខខណ្ឌតម្រូវទាំងអស់សម្រាប់គម្រោងជាក់លាក់ណាមួយនោះឡើយ។ ឧទាហរណ៍អាចមានហេតុផលដែលក្រុមហ៊ុនម៉ៅការត្រូវចាត់ចែង STDs, សំណល់វិជ្ជសាស្ត្រ និងសំណល់គ្រោះថ្នាក់ (ដូចជា ប្រេងដែលហូរចេញពីយានយន្ត និងការជួសជុលឡ និងការលេចធ្លាយប្រេងស្រដៀងគ្នានេះជាដើម)។

| **បញ្ហា/ហានិភ័យ** | **វិធានការសម្រាលផលប៉ះពាល់** |
|---|---|
| **១) ការបង្កើតធូលី /ការបំពុលខ្យល់** | • ក្រុមហ៊ុនម៉ៅការអនុវត្តវិធានការគ្រប់គ្រងការបំភាយធូលី ដើម្បីធានាឱ្យមានការកាត់បន្ថយការបង្កើតធូលីឱ្យនៅតិចបំផុតជាអប្បបរមា និងមិនបង្កការរំខានដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន រក្សាបរិយាកាសការងារប្រកបដោយសុវត្ថិភាព ដូចជា៖<br>- ស្រោចទឹកលើផ្លូវ និងការដ្ឋានសាងសង់ ដែលមានធូលីហុយ<br>- គ្របគំនរសម្ភារៈ<br>- គ្រប និងធានាសុវត្ថិភាពសម្ភារៈដែលដឹកតាមផ្លូវ ដើម្បីបង្ការមិនឱ្យមានការធ្លាក់ដី ខ្សាច់ សម្ភារៈ ឬធូលីរាយប៉ាយពេញផ្លូវ<br>- ដី និងគំនរសម្ភារៈ ដែលទុកចោល ត្រូវមានការការពារ ដើម្បីកុំឱ្យហុយតាមខ្យល់។ |
| **២) សំឡេងរំខាន និងរំញ័រ** | • រាល់យានជំនិះទាំងអស់ ត្រូវតែមាន *"វិញ្ញាបនបត្រអនុលោមភាព ដែលបានពីការត្រួតពិនិត្យលើគុណភាព សុវត្ថិភាពបច្ចេកទេស និងការការពារបរិស្ថាន"* ស្របតាមសេចក្ដីសម្រេចលេខ 35/2005/QD-BGTVT ដើម្បីបញ្ចៀសមិនឱ្យមានការបញ្ចេញសំឡេងរំខានលើសលុបពីម៉ាស៊ីន ដែលពុំមានការជួសជុលថែទាំឱ្យបានត្រឹមត្រូវ។ |
| **៣) ការបំពុលទឹក** | • ត្រូវផ្ដល់បង្គន់ចល័ត ឬបង្គន់ដែលសង់នៅនឹងកន្លែងដល់កម្មករសំណង់។ ទឹកស្អុយដែលហូរចេញពីបង្គន់ ក៏ដូចជា ពីផ្ទះបាយ កន្លែងងូតទឹក កន្លែងលាងដៃ។ល។ ត្រូវបញ្ចេញទៅក្នុងអាងស្ដុក ដើម្បីឱ្យមានការបូមចេញពីទីតាំង ឬបង្ហូរចូលទៅក្នុងប្រព័ន្ធលូរបស់ក្រុង។ ពុំគួរមានការបង្ហូរទឹកស្អុយផ្ទាល់ទៅក្នុងដែនទឹកនោះឡើយ។<br>• ទឹកស្អុយដែលលើសពីកម្រិតដែលអាចអនុញ្ញាតឱ្យបាន ដែលកំណត់ដោយស្តង់ដារបច្ចេកទេស/បទដ្ឋានគតិយុត្តក្នុងប្រទេសដែលពាក់ព័ន្ធ ត្រូវស្តុកទុកក្នុងអាងស្តុក និងបូមចេញពីទីតាំង ដោយក្រុមហ៊ុនប្រមូលសំណល់ ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ។<br>• នៅពេលដែលបញ្ចប់ការងារសាងសង់ ធុងស្តុកទឹកស្អុយ និងធុងស្តុកលាមក ត្រូវគ្របឱ្យបានត្រឹមត្រូវ និងបិទឱ្យជិតល្អ។ |
| **៤) ប្រព័ន្ធលូ និងកំណល្បាប់** | • ក្រុមហ៊ុនម៉ៅការត្រូវគោរពទៅតាមការរៀបចំប្រព័ន្ធលូឱ្យបានលម្អិត ដូចបញ្ជាក់ក្នុងផែនការសាងសង់ ដើម្បីធានាឱ្យមានការថែទាំឱ្យបានត្រឹមត្រូវ នូវប្រព័ន្ធលូ ដើម្បីកុំឱ្យមានភក់ និងវត្ថុដែលនាំឱ្យស្ទះដទៃទៀត។<br>• បរិវេណទីតាំង ដែលពុំទទួលការរំខានដោយសារកម្មភាពសាងសង់ ត្រូវរក្សាទុកឱ្យស្ថិតនៅក្នុងស្ថានភាពដើមរបស់វា។ |
| **៥) សំណល់រឹង** | • នៅគ្រប់កន្លែងធ្វើការទាំងអស់ ក្រុមហ៊ុនម៉ៅការត្រូវផ្ដល់ធុងសំរាម ធុង និងកន្លែងប្រមូលសំរាម។ គេអាចរក្សាទុកសំណល់រឹងជាបណ្ដោះអាសន្ន នៅនឹងទីតាំងផ្ទាល់ នៅកន្លែងដែលបានកំណត់ ដោយមានការឯកភាពពីទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ មុនពេលប្រមូល និងចោល។<br>• សំណល់រឹង អាចរក្សាទុកជាបណ្ដោះអាសន្ននៅនឹងទីតាំង ក្នុងកន្លែងដែលបានកំណត់ ដែលបានឯកភាពដោយទីប្រឹក្សាគ្រប់គ្រងការសាងសង់ និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ មុនពេលមានការមកប្រមូល យកទៅចោល។<br>• ធុងរក្សាទុកសំណល់ត្រូវគ្របឱ្យបានជិត មានគម្របធន់អាកាសធាតុ និងបង្ការការរើកកាយ។<br>• ពុំត្រូវដុត កប់នៅនឹងកន្លែង ឬចោលសំណល់រឹងពាសវាលពាសកាលឡើយ។<br>• សម្ភារៈដែលអាចកែច្នៃប្រើឡើងវិញបាន ដូចជា បន្ទះឈើសម្រាប់ចាក់ពុំ ដែក រនាឈើសម្រាប់ទប់លំនឹង សម្ភារៈវេចខ្ចប់។ល។ ត្រូវប្រមូល និងញែកនៅនឹងកន្លែងពីប្រភពសំណល់ដទៃទៀត សម្រាប់ប្រើប្រាស់ឡើងវិញ សម្រាប់បំពេញ ឬសម្រាប់លក់។<br>• ប្រសិនបើសំណល់រឹង ឬកំម្ទេចកម្ទីសំណង់ពុំត្រូវបានយកចេញពីទីតាំងនោះទេ សំណល់ និងកម្ទេចកម្ទីទាំងនេះ ត្រូវចោលតែនៅទីតាំងដែលត្រូវបានកំណត់ និងឯកភាពដោយទីប្រឹក្សាគ្រប់គ្រង់ការងារសាងសង់ និងដែលត្រូវបានបញ្ចូលក្នុងផែនការសំណល់រឹងតែប៉ុណ្ណោះ។ ទោះជាក្នុងកាលៈទេសៈណាក៏ដោយ ក្រុមហ៊ុនម៉ៅការមិនត្រូវចោលសម្ភារៈក្នុងតំបន់ ដែលបរិស្ថានងាយរងផលប៉ះពាល់ ដូចជា តំបន់ដែនជម្រកធម្មជាតិ ឬនៅក្នុងប្រភពទឹកឡើយ។ |

| បញ្ហា/ហានិភ័យ | វិធានការសម្រាលផលប៉ះពាល់ |
|---|---|
| **៦) សំណល់គីមី ឬសំណល់គ្រោះថ្នាក់** | • ប្រេង និងខ្លាញ់ដែលប្រើហើយ ត្រូវយកចេញពីទីតាំង និងលក់ទៅឱ្យក្រុមហ៊ុនកែច្នៃប្រេងប្រើរួច ដែលមានការអនុញ្ញាតត្រឹមត្រូវ។<br>• ប្រេង ប្រេងរំអិល សារធាតុសម្អាត ដែលប្រើរួច។ល។ ដែលចេញពីការជួសជុលថែទាំរថយន្ត និងគ្រឿងម៉ាស៊ីន ត្រូវប្រមូលដាក់ក្នុងធុង និងយកចេញពីតាំងដោយក្រុមហ៊ុនកែច្នៃប្រេងឯកទេស ដើម្បីយកទៅចោលនៅទីតាំងចោលសំណល់គ្រោះថ្នាក់ ដែលមានការឯកភាពត្រឹមត្រូវ។<br>• ដ៏រ ឬផលិតផលកៅស៊ូបេទីមីនី ដែលពុំត្រូវបានប្រើប្រាស់ ឬដែលបដិសេធចោល ត្រូវប្រគល់ត្រលប់ទៅឱ្យរោងចក្រផលិតរបស់អ្នកផ្គត់ផ្គង់វិញ។<br>• រក្សាទុកសារធាតុគីមីប្រកបដោយសុវត្ថិភាព ដូចជា ដាក់ក្រោមដំបូល មានរបងព័ទ្ធជុំវិញ និងស្លាកសម្គាល់សមស្រប។ |
| **៧) ការសំខានគម្របរុក្ខជាតិ និងធនធានអេកូឡូស៊ី** | • គួរមានការកាត់បន្ថយទំហំតំបន់ ដែលត្រូវសម្អាត ឱ្យបានច្រើនបំផុតតាមលទ្ធភាពដែលអាចធ្វើទៅបាន<br>• ក្រុមហ៊ុនម៉ៅការត្រូវកកាយដីខាងលើពីគ្រប់តំបន់ទាំងអស់ ដែលដីស្រទាប់ខាងលើនិងរងផលប៉ះពាល់ ដោយសារសកម្មភាពស្តារឡើងវិញ រាប់បញ្ចូលទាំងសកម្មភាពបណ្តោះអាសន្ន ដូចជា ការរក្សាទុក និងការគរទុកជាដើម។ ដីស្រទាប់ខាងលើដែលកកាយនេះ ត្រូវគរក្នុងតំបន់ដែលបានព្រមព្រៀងគ្នាជាមួយនឹងទីប្រឹក្សាគ្រប់គ្រងការងារសាងសង់សម្រាប់ប្រើប្រាស់នៅពេលក្រោយ នៅពេលដាំរុក្ខជាតិឡើងវិញ និងត្រូវមានការការពារឱ្យបានគ្រប់គ្រាន់។<br>• ការប្រើប្រាស់សារធាតុគីមីសម្រាប់សម្អាតរុក្ខជាតិ ពុំត្រូវបានអនុវត្តឡើយ។<br>• ហាមឃាត់ការកាប់ដើមឈើណាមួយ លើកលែងតែមានការអនុញ្ញាតជាក់ច្បាស់នៅក្នុងផែនការសម្អាតរុក្ខជាតិ។<br>• នៅពេលចាំបាច់ ត្រូវសង់របងការពារបណ្តោះអាសន្ន ដើម្បីការពារដើមឈើ ដែលត្រូវការពារមុនពេលចាប់ផ្តើមការងារអ្វីមួយនៅក្នុងទីតាំងនោះ។<br>• ក្រុមហ៊ុនម៉ៅការត្រូវធានាថា ពុំមានការបរបាញ់ ការដាក់អន្ទាក់ ការបាញ់ ការដាក់ថ្នាំបំពុលសត្វឡើយ។ |
| **៨) ការគ្រប់គ្រងចរាចរ** | • មុនពេលសាងសង់ រៀបចំកិច្ចពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន សហគមន៍ និងជាមួយប៉ូលីសចរាចរ។<br>• ការកើនឡើងគួរឱ្យកត់សម្គាល់នូវចំនួនដងនៃការធ្វើដំណើររបស់យានយន្ត ត្រូវបញ្ចូលទៅក្នុងផែនការសាងសង់ ដែលត្រូវបានឯកភាពកន្លងមក។ ច្រកផ្លូវ ជាពិសេសសម្រាប់យានយន្តធនធ្ងន់ ចាំបាច់ត្រូវគិតពីទីតាំង ដែលងាយរងផលប៉ះពាល់នានា ដូចជា សាលារៀន មន្ទីរពេទ្យ និងផ្សារជាដើម។<br>• ការដំឡើងភ្លើងបំភ្លឺនៅពេលយប់ ត្រូវធ្វើឡើង ប្រសិនបើចាំបាច់ ដើម្បីធានាឱ្យមានការធ្វើចរាចរប្រកបដោយសុវត្ថិភាព។<br>• ដាក់ស្លាកនៅជុំវិញទីតាំងសាងសង់ ដើម្បីសម្រួលការធ្វើចរាចរ បង្ហាញទិសដៅទៅកាន់ទីតាំងផ្សេងៗ និងផ្តល់ដំបូន្មាន និងព័ត៌មានអំពីសុវត្ថិភាព។<br>• ប្រើប្រាស់វិធានការគ្រប់គ្រងចរាចរប្រកបដោយសុវត្ថិភាព ដូចជា ដាក់ស្លាកសញ្ញាតាមផ្លូវ/ដងទន្លេ/ប្រឡាយ និងមានមនុស្សគ្រវីទង់ ដើម្បីប្រាប់ឱ្យដឹងជាមុន ពីស្ថានភាពគ្រោះថ្នាក់។<br>• ជៀសវាងការដឹកជញ្ជូនសម្ភារៈសាងសង់ក្នុងអំឡុងម៉ោង ដែលចរាចរមមាញឹកខ្លាំង។<br>• ត្រូវដំឡើងសញ្ញាចរាចរឱ្យបានសមស្រប ទាំងផ្លូវទឹក ទាំងផ្លូវគោលនៅកន្លែងដែលចាំបាច់។ |
| **៩) ការរំខានសេវាទឹកភ្លើង** | • ផ្តល់ព័ត៌មានដល់គ្រួសារដែលរងផលប៉ះពាល់អំពីកាលវិភាគការងារ និងការអាក់ខានការផ្គត់ផ្គង់ទឹក/អគ្គិសនី ដែលគ្រោងនឹងធ្វើឡើងឱ្យបានយ៉ាងហោចណាស់ ២ ថ្ងៃជាមុន។<br>• ត្រូវរាយការណ៍ពីការខូចខាតប្រព័ន្ធសេវាទឹក អគ្គិសនី ដែលមានស្រាប់ ទៅកាន់អាជ្ញាធរ និងត្រូវជួសជុលឱ្យបានឆាប់តាមលទ្ធភាពដែលអាចធ្វើទៅបាន។ |
| **១០) ការស្តារតំបន់ដែលរងផលប៉ះពាល់ឡើងវិញ** | • តំបន់ដែលត្រូវបានសម្អាត ដូចជា តំបន់សម្រាប់ចោលសំណល់សំណង់នៅនឹងទីតាំងជំរំរបស់កម្មករ តំបន់គរសម្ភារៈ កន្លែងធ្វើការ និងតំបន់ដែលត្រូវបានកាន់កាប់បណ្តោះអាសន្នក្នុងអំឡុងពេលសាងសង់របស់គម្រោង ត្រូវស្តារឱ្យដូចស្ថានភាពដើមវិញ ដោយប្រើប្រាស់ការរៀបចំទេសភាព ការបំពាក់ប្រព័ន្ធលូឱ្យបានគ្រប់គ្រាន់ និងការដាំរុក្ខជាតិឡើងវិញ។<br>• ត្រូវដាំដើមឈើនៅលើដីដែលងាយបាក់ និងនៅលើទីជម្រាល ដើម្បីបង្ការ ឬកាត់បន្ថយបញ្ហាបាក់ដី និងរក្សាទីជម្រាលឱ្យនៅមានលំនឹង។ |

<table>
<tr><th>បញ្ហា/ហានិភ័យ</th><th>វិធានការសម្រាលផលប៉ះពាល់</th></tr>
<tr><td></td><td>• ដីដែលមានប្រឡាក់ប្រឡូកជាមួយនឹងសារធាតុគីមី ឬសារធាតុគ្រោះថ្នាក់ ត្រូវដកចេញ និង ដឹកជញ្ជូនយកទៅកប់នៅកន្លែងចោលសំរាម។</td></tr>
<tr><td>១១) សុវត្ថិភាពរបស់កម្មករ និងសុវត្ថិភាពសាធារណៈ</td><td>• បណ្តុះបណ្តាលកម្មករអំពីបទបញ្ហាសុវត្ថិភាពការងារ និងផ្តល់សម្លៀកបំពាក់ការពារខ្លួន ឱ្យបានគ្រប់គ្រាន់ដល់កម្មករ ស្របទៅតាមច្បាប់ជាតិ ដែលកំពុងចូលជាធរមាន។<br>• សង់របង របាំង សញ្ញាព្រមានពីគ្រោះថ្នាក់/តំបន់ហាមឃាត់ នៅជុំវិញ បរិវេណដែលមានការសាងសង់ ដែលបង្ហាញឱ្យសាធារណជនដឹងពីគ្រោះថ្នាក់ ដែលអាចកើតមានឡើង។<br>• ក្រុមហ៊ុនម៉ៅការត្រូវអនុវត្តវិធានការសុវត្ថិភាព ដូចជា សង់របង របាំង សញ្ញាព្រមានពីគ្រោះថ្នាក់ ប្រព័ន្ធភ្លើងបំភ្លឺ ដើម្បីបង្ការគ្រោះថ្នាក់ចរាចរ ក៏ដូចជា ហានិភ័យដទៃទៀត ចំពោះមនុស្ស និងទីតាំងដែលងាយរងផលប៉ះពាល់។<br>• ប្រសិនបើការវាយតម្លៃកន្លងមកបង្ហាញថា អាចមានគ្រាប់មិនទាន់ផ្ទុះ នោះត្រូវមានការសម្អាតយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះទាំងនេះ ដោយបុគ្គលិកដែលមានសមត្ថភាព និងស្របទៅតាមផែនការលម្អិត ដែលត្រូវបានអនុម័តដោយវិស្វករសំណង់។</td></tr>
<tr><td>១២) ការប្រាស្រ័យទាក់ទងជាមួយសហគមន៍មូលដ្ឋាន</td><td>• ក្រុមហ៊ុនម៉ៅការ ត្រូវសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន (អ្នកដឹកនាំឃុំនៅមូលដ្ឋាន អ្នកដឹកនាំភូមិ) អំពីកាលវិភាគដែលបានឯកភាពសម្រាប់សកម្មភាពសាងសង់ នៅក្នុងតំបន់ដែលនៅជិតទីកន្លែងដែលងាយរងផលប៉ះពាល់ ឬនៅពេលដែលការសាងសង់ធ្វើឡើងនៅជិតពេលសំខាន់ៗ (ឧទាហរណ៍ បុណ្យសាសនាជាដើម)។<br>• ផ្សព្វផ្សាយព័ត៌មានគម្រោងដល់ភាគីដែលរងផលប៉ះពាល់ (ឧទាហរណ៍ ដល់អាជ្ញាធរមូលដ្ឋាន សហគ្រាស និងគ្រួសារដែលរងផលប៉ះពាល់។ល។) តាមរយៈកិច្ចប្រជុំជាមួយសហគមន៍ មុនពេលដែលសកម្មភាពសាងសង់ចាប់ផ្តើម។<br>• ផ្តល់ព័ត៌មានសម្រាប់ទាក់ទងទៅកាន់សហគមន៍ ដើម្បីឱ្យភាគីពាក់ព័ន្ធអាចទទួលបាន ព័ត៌មានអំពីសកម្មភាពនៅនឹងទីតាំង ស្ថានភាពរបស់គម្រោង និងលទ្ធផលនៃការ អនុវត្តគម្រោង។<br>• ផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋនៅមូលដ្ឋានអំពីកាលវិភាគសាងសង់ និងកាលវិភាគការងារ ការអាក់ខានការផ្តល់សេវា ផ្លូវវៀងសម្រាប់ចរាចរ និងផ្លូវបណ្តោះអាសន្នសម្រាប់រថយន្តក្រុង ការបំផ្ទុះ និងការរំលំអគារទៅតាមស្ថានភាពសមស្រប។<br>• ត្រូវមានការដំឡើងក្តារខៀនព័ត៌មាននៅគ្រប់ទីតាំងសាងសង់ទាំងអស់ ដើម្បីផ្តល់ព័ត៌មានអំពីគម្រោង ក៏ដូចជា ព័ត៌មានទំនាក់ទំនងអ្នកគ្រប់គ្រងការដ្ឋាន បុគ្គលិកទទួលបន្ទុកបរិស្ថាន បុគ្គលិកទទួលបន្ទុកសុខភាព និងសុវត្ថិភាព លេខទូរសព្ទ និងព័ត៌មានទំនាក់ទំនងផ្សេងទៀត ដើម្បីឱ្យអ្នកដែលរងផលប៉ះពាល់អាចមានច្រក លើកឡើងពីការព្រួយបារម្ភ និងសំណូមពររបស់ពួកគេ។</td></tr>
<tr><td>១៣) នីតិវិធីសម្រាប់ចាត់ចែងវត្ថុដែលរកឃើញដោយចៃដន្យ</td><td>ប្រសិនបើក្រុមហ៊ុនម៉ៅការរកឃើញទីតាំងបូរាណវិទ្យា ទីតាំងប្រវត្តិសាស្ត្រ វត្ថុបូរាណ រួមនឹងផ្នូររួម និង/ឬផ្នូរខ្មោចម្នាក់ៗ ក្នុងអំឡុងពេលកាយដី ឬក្នុងអំឡុងពេលសាងសង់ ក្រុមហ៊ុនម៉ៅការត្រូវ៖<br>• បញ្ឈប់សកម្មភាពសាងសង់ក្នុងតំបន់ដែលមានរកឃើញវត្ថុទាំងនោះ។<br>• កំណត់ព្រំដែន ទីតាំង ឬតំបន់ដែលរកឃើញវត្ថុទាំងនោះ។<br>• រក្សាសុវត្ថិភាពទីតាំង ដើម្បីបង្ការមិនឱ្យមានការខូចខាត ឬការបាត់បង់វត្ថុ ដែលគេអាចយកចេញបាន។ ក្នុងករណីដែលមានវត្ថុបូរាណ ដែលអាចយកចេញបាន ឬវត្ថុដែលងាយរងការបាត់បង់ ត្រូវមានការរៀបចំអ្នកយាមនៅពេលយប់ រហូតដល់ពេល អាជ្ញាធរមូលដ្ឋានទទួលបន្ទុក ឬមន្ទីរវប្បធម៌ និងព័ត៌មានមកទទួលខុសត្រូវបន្ត។<br>• ជូនដំណឹងដល់ទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ ដែលត្រូវបន្ត ជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាន ឬអាជ្ញាធរជាតិទទួលខុសត្រូវលើបេតិកភ័ណ្ឌវប្បធម៌ (មិនឱ្យលើសពី ២៤ ម៉ោង)។<br>• អាជ្ញាធរមូលដ្ឋាន ឬអាជ្ញាធរជាតិពាក់ព័ន្ធ ត្រូវទទួលខុសត្រូវការពារ និងរក្សាទីតាំងនេះ មុនពេលធ្វើការសម្រេចចិត្តអំពីនិតិវិធីសមស្រប ដែលត្រូវអនុវត្ត។ នេះតម្រូវ ឱ្យមានការវាយតម្លៃជាបឋមលើវត្ថុដែលបានរកឃើញ។ គួរមានការវាយតម្លៃលើសារៈសំខាន់នៃវត្ថុដែលបានរកឃើញ ទៅតាមលក្ខណៈវិនិច្ឆ័យនានា ពាក់ព័ន្ធនឹងបេតិកភ័ណ្ឌវប្បធម៌។ លក្ខណៈវិនិច្ឆ័យទាំងនេះ រួមមាន តម្លៃផ្នែកសោភ័ណ្ឌភាព ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ ឬការស្រាវជ្រាវ តម្លៃសង្គម និងសេដ្ឋកិច្ច។<br>• ការសម្រេចអំពីរបៀបចាត់ចែងវត្ថុដែលរកឃើញ ត្រូវធ្វើឡើងដោយអាជ្ញាធរទទួលខុសត្រូវ។ នេះអាចរួមមានការផ្លាស់ប្តូរប្លង់ (ដូចជា នៅពេលដែលមានការរកឃើញវត្ថុបូរាណ ដែល មិនអាចយកចេញបាន ហើយដែលមានសារៈសំខាន់ផ្នែកវប្បធម៌ ឬសារៈសំខាន់ផ្នែក បូរាណវិទ្យា) ការអភិរក្ស ការការពារ ការស្តារឡើងវិញ និងការសង្គ្រោះ។<br>• ប្រសិនបើទីតាំងវប្បធម៌ និង/វត្ថុបូរាណមានតម្លៃខ្ពស់ ហើយអ្នកជំនាញលើកជាអនុសាសន៍ ឱ្យមានការការពារទីតាំងនេះ និងមានការតម្រូវដោយអាជ្ញាធរទទួលបន្ទុក</td></tr>
</table>

| បញ្ហា/ហានិភ័យ | វិធានការសម្រាលផលប៉ះពាល់ |
|---|---|
| | បេតិកភ័ណ្ឌវប្បធម៌ផងនោះ ម្ចាស់គម្រោងត្រូវធ្វើការផ្លាស់ប្តូរការរៀបចំដែលចាំបាច់នានា ដើម្បីបំពេញទៅតាមសំណើនេះ និងដើម្បីការពារទីតាំងនេះ។<br>• ការសម្រេចចិត្តពាក់ព័ន្ធនឹងការគ្រប់គ្រងវត្ថុដែលរកឃើញ ត្រូវផ្សព្វផ្សាយជាលាយលក្ខណ៍អក្សរ ដោយអាជ្ញាធរពាក់ព័ន្ធ។<br>• ការងារសាងសង់អាចចាប់ផ្តើមតែនៅពេលដែលមានការផ្តល់ការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន ដែលទទួលខុសត្រូវ ពាក់ព័ន្ធនឹងការការពារបេតិកភ័ណ្ឌតែប៉ុណ្ណោះ។ |

ផ្នែកទី ២ – ក្រមប្រតិបត្តិផ្នែកបរិស្ថាន សម្រាប់កម្មកររបស់ក្រុមហ៊ុនម៉ៅការ

នេះគឺជាឧទាហរណ៍សម្រាប់គម្រោងធម្មតា ប៉ុន្តែសម្រាប់គម្រោងជាក់លាក់ណាមួយ លក្ខខណ្ឌតម្រូវពាក់ព័ន្ធផ្សេងទៀត ក៏អាចមានភាពពាក់ព័ន្ធផងដែរ។ ឧទាហរណ៍ ការណែនាំអំពីការលាងសម្អាតដៃ ការយល់ព្រមចូលរួមក្នុងសិក្ខាសាលាស្តីពីជំងឺកាមរោគ។

| អ្វីដែលត្រូវធ្វើ | អ្វីដែលមិនត្រូវធ្វើ |
|---|---|
| • ប្រើប្រាស់បង្គន់ដែលផ្តល់ឱ្យ – រាយការណ៍ពីករណីបង្គន់កខ្វក់ ឬបង្គន់ដែលពេញ<br>• សម្អាតបរិវេណធ្វើការរបស់អ្នកមិនឱ្យមានសំរាម និងកម្ទេចកម្ទីពីការសាងសង់នៅចុងថ្ងៃនីមួយៗ – ប្រើប្រាស់ធុងសំរាមដែលផ្តល់ឱ្យ និងធានាថាសំរាមមិនហុយរាយប៉ាយឡើយ<br>• រាយការណ៍ពីការកំពប់គ្រឿងឥន្ធនៈ ឬប្រេងទាំងអស់ជាបន្ទាន់ និងបញ្ឈប់មិនឱ្យមានកំពប់បន្តទៀត<br>• ជក់បារីតែនៅតំបន់ដែលបានកំណត់សម្រាប់ការជក់បារីតែប៉ុណ្ណោះ និងចោលកន្ទុយបារី និងឈើគូសដោយប្រុងប្រយ័ត្ន។ (ការចោលសំរាមពាសវាលពាសកាលគឺជាបទល្មើស)<br>• ធ្វើការងារ និងរក្សាទុកឧបករណ៍តែនៅក្នុងបរិវេណការងារតែប៉ុណ្ណោះ។<br>• ប្រើប្រាស់គ្រប់ឧបករណ៍សុវត្ថិភាពទាំងអស់ និងត្រូវគោរពទៅតាមនីតិវិធីសុវត្ថិភាព។<br>• បង្ការមិនឱ្យមានការកខ្វក់ ឬការបំពុលស្ទឹង និងប្រភពទឹក។<br>• ធានាថាមានបំពង់ពន្លត់អគ្គីភ័យ ដែលអាចប្រើប្រាស់បានភ្លាមៗ ប្រសិនបើមាន ការធ្វើការងារ "ដែលបំភាយកម្តៅ" ការផ្សារ ការកិន ឬការកាត់ដោយប្រើឧស្ម័នជាដើម។ល។<br>• រាយការណ៍ពីករណីរបួសកម្មករ ឬរបួសសត្វ | • យករុក្ខជាតិចេញ ឬធ្វើឱ្យប៉ះពាល់ដល់រុក្ខជាតិ ដោយពុំមានការណែនាំផ្ទាល់។<br>• បង្កឱ្យមានភ្លើងឆេះ។<br>• បរបាញ់ ធ្វើឱ្យរងរបួស ដាក់អន្ទាក់ ផ្តល់ចំណី ឬបង្កគ្រោះថ្នាក់ដល់សត្វណាមួយ – ដូចជា បក្សី កង្កែប ពស់។ល។<br>• ចូលទៅក្នុងបរិវេណដែលមានរបង ឬមានដាក់ស្លាកសម្គាល់មិនឱ្យចូល។<br>• បើកបរដោយធ្វេសប្រហែស ឬបើកបរលើសល្បឿនកំណត់។<br>• អនុញ្ញាតឱ្យមានសំណល់ សំរាម ប្រេង ឬវត្ថុនានាចូលទៅក្នុងស្ទឹង<br>• ចោលសំរាម ឬទុកម្ហូបអាហារឱ្យនៅពាសវាលពាសកាល។<br>• កាត់ដើមឈើ ដោយសារមូលហេតុផ្សេង ក្រៅពីតំបន់សាងសង់ដែលបានទទួលបានការឯកភាព។<br>• ទិញសត្វព្រៃធ្វើជាអាហារ។<br>• ប្រើប្រាស់សារធាតុពុល ដែលពុំមានការឯកភាព ដូចជាពពួកថ្នាំលាប ដែលធ្វើពីសារធាតុសំណ សារធាតុអាបេស្តូស។ល។<br>• បង្កការរំខានដល់អ្វីៗគ្រប់បែបយ៉ាង ដែលមានតម្លៃផ្នែកបុរាណវិទ្យា ឬតម្លៃប្រវត្តិសាស្ត្រ។<br>• ប្រើប្រាស់អាវុធយុទ្ធភ័ណ្ឌ (លើកលែងតែសន្តិសុខ ដែលទទួលបានការអនុញ្ញាត)។<br>• ការប្រើប្រាស់ជាតិស្រវឹង ដោយកម្មករ ក្នុងអំឡុងម៉ោងធ្វើការ។<br>• លាងរថយន្ត ឬគ្រឿងម៉ាស៊ីននៅក្នុងស្ទឹង ឬព្រែក។<br>• ធ្វើការងារជួសជុល (ប្តូរប្រេង និងតម្រង់) របស់ឡាន និងឧបករណ៍ក្រៅតំបន់ ដែលបានទទួលការអនុញ្ញាត។<br>• ចោលសំរាមនៅកន្លែងដែលពុំមានការអនុញ្ញាត។<br>• ចិញ្ចឹមសត្វព្រៃ (ជាពិសេសបក្សី) ក្នុងទ្រុង នៅក្នុងជំរំការងារ។<br>• ធ្វើការងារដោយពុំមានឧបករណ៍សុវត្ថិភាព (ដូចជាស្បែកជើង និងមួកសុវត្ថិភាពជាដើម)។<br>• បង្កការរំខានក្នុង ឬនៅជិតសហគមន៍។ |

| | |
|---|---|
| ◆ បើកបរតែនៅលើផ្លូវ ដែលត្រូវបានកំណត់តែប៉ុណ្ណោះ។<br>◆ បង្ការមិនឱ្យមានការហុយធូលី និងការបង្កសំឡេងរំខានលើសលុបពេក។ | ◆ ប្រើប្រាស់ទន្លេ និងស្ទឹងសម្រាប់បោកសម្លៀកបំពាក់។<br>◆ ចោលសំរាម ឬសំណល់ ឬ កម្ទេចកម្ទីថ្មពីការសាងសង់ពាសវាលពាលកាល។<br>◆ ធ្វើឱ្យកំពប់សារធាតុពុល ដូចជា ផលិតផលប្រេងជាដើម។<br>◆ ប្រមូលអុស។<br>◆ ប្រើប្រាស់ជាតិផ្ទុះ និងសារធាតុគីមី ដើម្បីនេសាទ។<br>◆ ប្រើប្រាស់បង្គន់នៅខាងក្រៅកន្លែងដែលបានកំណត់ និង<br>◆ ដុតសំរាម និង/ឬរុក្ខជាតិដែលបានសម្អាតរួច។ |

## ឧបសម្ព័ន្ធ ៥៖ ឧទាហរណ៍អំពីសេចក្តីពិពណ៌នាបរិស្ថាន សម្រាប់គម្រោង/អនុគម្រោងប្រភេទ B

1. លក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងបរិស្ថានក្នុងការសាងសង់នៃ (កញ្ចប់ដេញថ្លៃ ABC) ត្រូវបានកំណត់ និងបង្ហាញយ៉ាងជាក់ច្បាស់ក្នុង EMP (រៀបរាប់លម្អិតក្នុងឧបសម្ព័ន្ធទី ៣, EMP – វិធានការសម្រាលផលប៉ះពាល់បរិស្ថាន)។ ក្រុមហ៊ុនម៉ៅការចាំបាច់ត្រូវអានដោយយកចិត្តទុកដាក់ និងស្វែងយល់ឱ្យបានពេញលេញពីរាល់លក្ខខណ្ឌតម្រូវទាំងអស់ ដែលត្រូវបានបញ្ចូលក្នុងឯកសារដេញថ្លៃរបស់ក្រុមហ៊ុនម៉ៅការ៖ (ឈ្មោះកញ្ចប់ការងារសាងសង់) របស់គម្រោង។

**I.** ទិដ្ឋភាពរួមទូទៅ

2. ដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានចំពោះបរិស្ថាន និងសហគមន៍មូលដ្ឋាន ក៏ដូចជា កាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ដែលបង្កការខូចខាតដល់បរិស្ថាន ក្នុងអំឡុងដំណាក់កាលសាងសង់ និងដំណាក់កាលប្រតិបត្តិការរបស់គម្រោង ក្រុមហ៊ុនម៉ៅការ និងកម្មករត្រូវគោរពតាមវិធានការសម្រាលផលប៉ះពាល់ ដូចលើកឡើងខាងក្រោម៖

- "ផែនការគ្រប់គ្រងបរិស្ថានសម្រាប់គម្រោង..."។
- ពិពណ៌នាបច្ចេកទេស នីតិវិធី និងការអនុវត្តដែលពេញនិយមជាងគេ ត្រូវបានលើកមកបង្ហាញក្នុងឧបសម្ព័ន្ធនេះ។

**II.** លក្ខខណ្ឌតម្រូវជារួមផ្នែកការគ្រប់គ្រងបរិស្ថាន ដែលត្រូវបំពេញដោយក្រុមហ៊ុនម៉ៅការ

3. ក្រុមហ៊ុនម៉ៅការត្រូវបញ្ចូលការទទួលខុសត្រូវជាអាទ៍៖

- អនុលោមទៅតាមលិខិតបទដ្ឋានគតិយុត្តស្តីពីបរិស្ថានបច្ចុប្បន្ននៅថ្នាក់ជាតិ។
- ធ្វើការងារ ក្រោមវិសាលភាពវិសាលភាពនៃលក្ខខណ្ឌតម្រូវក្នុងកិច្ចសន្យា និងលក្ខខណ្ឌក្នុងឯកសារដេញថ្លៃ។
- ចាត់តាំងតំណាងក្រុមការងារសាងសង់ឱ្យចូលរួមក្នុងប្រតិបត្តិការត្រួតពិនិត្យការដ្ឋាន ដែលធ្វើឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs), CSC ឬ DONRE ក៏ដូចជា ត្រូវអនុវត្តរាល់សកម្មភាពកែតម្រូវទាំងអស់ ដើម្បីដោះស្រាយបញ្ហាបរិស្ថានស្របតាមការណែនាំដែលផ្តល់ដោយវិស្វករគ្រប់គ្រងការងារសាងសង់។
- ផ្តល់ព័ត៌មាន និងធ្វើបច្ចុប្បន្នភាពជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) អំពីសកម្មភាពនានា ការងារដែលអាចរួមចំណែក ឬបន្តបង្កឱ្យមានផលប៉ះពាល់ ដែលបង្កការខូចខាតគួរឱ្យកត់សម្គាល់ដល់បរិស្ថាន។
- ក្នុងករណីមានការណែនាំដោយវិស្វករគ្រប់គ្រងការងារសាងសង់ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs), ក្រុមហ៊ុនម៉ៅការត្រូវបញ្ឈប់សកម្មភាពសាងសង់ ដែលបង្កផលប៉ះពាលអវិជ្ជមាន លើកស្នើ និងធ្វើកម្មភាពកែតម្រូវបរិស្ថាន និងអនុវត្តវិធីសាស្ត្រសាងសង់ផ្សេងទៀត (ប្រសិនបើចាំបាច់) ដើម្បីកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន។
- បង្កើត និងរក្សានូវគណៈកម្មាធិការបរិស្ថាន និងសុវត្ថិភាព មានសមាសភាពជាប្រធានក្រុមការងារសាងសង់ ឬអនុប្រធានក្រុមការងារសាងសង់ និងមន្ត្រីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថាន ក្នុងគោលបំណងទទួល និងឆ្លើយតបចំពោះពាក្យបណ្តឹង ការជំទាស់ ការតវ៉ា និងការមិនសប្បាយចិត្តរបស់សហគមន៍មូលដ្ឋាន ដែលបង្កឡើងដោយប្រតិបត្តិការសាងសង់។ មន្ត្រីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថាន ទទួលខុសត្រូវកត់ត្រាទុករាល់ពាក្យបណ្តឹងទាំងអស់ វិធីសាស្ត្រដែលប្រើប្រាស់សម្រាប់ធ្វើការដោះស្រាយ និងលទ្ធផលទៅក្នុងបញ្ជីកត់ត្រាពាក្យបណ្តឹង។ បញ្ជីនេះត្រូវរក្សាទុកនៅក្នុងការិយាល័យសាងសង់ និងអាចពិនិត្យមើលបានដោយវិស្វករគ្រប់គ្រងការងារសាងសង់ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ

(PTs)។

**III.** ការទទួលខុសត្រូវរបស់ក្រុមហ៊ុនម៉ៅការនៅក្នុងការអនុវត្ត **EMP**៖

4. ក្រុមហ៊ុនម៉ៅការសំណង់ទទួលខុសត្រូវគោរពទៅតាមសេចក្តីពិពណ៌នាបច្ចេកទេសនៃ EMP (សូមបញ្ចូលឈ្មោះគម្រោងនៅត្រង់នេះ) និងលិខិតបទដ្ឋានគតិយុត្តនានា អំពីការគ្រប់គ្រងបរិស្ថាននាពេលបច្ចុប្បន្ន ជាអាទ៍ចំណុចខាងក្រោម៖

i) វិធានការសម្រាលផលប៉ះពាល់ ដែលត្រូវបានបង្ហាញក្នុងផ្នែក **៨.០។ វិធានការសម្រាលផលប៉ះពាល់បរិស្ថាន**នៃ EMP និងរៀបចំថវិកាសម្រាប់អនុវត្តវិធានការសម្រាលផលប៉ះពាល់ទាំងនេះ។

ii) ផ្អែកលើតាម EMP, ក្រុមហ៊ុនម៉ៅការបានរៀបចំនូវផែនការលម្អិតសម្រាប់អនុវត្តការគ្រប់គ្រងបរិស្ថាន។ ផែនការលម្អិតនេះ មានសមាសភាគដូចខាងក្រោម៖

- ផែនការគ្រប់គ្រងសម្រាប់ជំរំរបស់កម្មករ។
- ផែនការគ្រប់គ្រងសម្រាប់ប្រតិបត្តិការសាងសង់ជារួម។
- ផែនការសម្រាប់គ្រប់គ្រង និងរក្សាទុកសម្ភារៈសាងសង់ (រាប់បញ្ចូលទាំងសារធាតុគីមីគ្រោះថ្នាក់ផងដែរ)។
- ផែនការគ្រប់គ្រងសំណល់រឹង និងសំណល់រាវ (រាប់បញ្ចូលទាំងសំណល់ពីការសាងសង់ និងសំណល់តាមគ្រួសារ)។
- ផែនការគ្រប់គ្រង និងកាត់បន្ថយសំឡេងរំខាន និងធូលី។
- ផែនការសម្រាប់គ្រប់គ្រង និងសម្រាលផលប៉ះពាល់ចំពោះរុក្ខជាតិ និងសត្វព្រៃ។
- ផែនការសម្រាប់ស្តារទេសភាពបរិស្ថានឡើងវិញ។
- ផែនការធានាសុខភាព និងសុវត្ថិភាពនៅការដ្ឋានសំណង់។
- ផែនការគ្រប់គ្រងការច្រោះដី និងការធ្វើឱ្យដីផុស (soil aggrandizement)។
- ផែនការសុវត្ថិភាព ក្នុងអំឡុងដំណាក់កាលសាងសង់ និងការបណ្តុះបណ្តាលកម្មករអំពីការគ្រប់គ្រងបរិស្ថាន និងទំនាក់ទំនងសហគមន៍។
- វិធាន និងបទបញ្ជាអំពីសកម្មភាពរស់នៅរបស់បុគ្គលិក និងកម្មករ ក្នុងការដ្ឋានសំណង់។
- ផែនការដោះស្រាយបញ្ហាបន្ទាន់។
- ផែនការគ្រប់គ្រង និងពិនិត្យតាមដានសម្រាប់ដំណើរការនៃការរៀបចំរបាយការណ៍។

**5. វិធានការលម្អិតនៅក្នុងផែនការ ចាំបាច់ត្រូវបំពេញទៅតាមលក្ខខណ្ឌតម្រូវ ដូចតទៅ៖** ដើម្បីអនុវត្តវិធានការសម្រាលផលប៉ះពាល់ជាក់លាក់៖ អ្នកណាដែលត្រូវអនុវត្ត (មនុស្ស ក្រុម។ល។), ត្រូវអនុវត្តដោយរបៀបណា (កម្លាំងពលកម្ម គ្រឿងម៉ាស៊ីន ឧបករណ៍។ល។) និងចំណាយ? (ក្រុមហ៊ុនម៉ៅការគួរជ្រើសរើសកថាខណ្ឌ និងដូក្រោម ដែលបង្ហាញពីការអនុវត្តល្អនាពេលអនាគត)។ **ផែនការនេះគួរបំពេញ និងផ្ញើរមកគ្នា ជាមួយនឹងឯកសារដេញថ្លៃ។**

ក) ធានាឱ្យមានអ្នកគ្រប់គ្រងយ៉ាងហោចណាស់ម្នាក់ គោរពតាម EMP មុន និងក្នុងអំឡុងពេលសាងសង់។

ខ) ធានារាល់សកម្មភាពសាងសង់ទាំងអស់នឹងទទួលបានការឯកភាពក្នុង ឯកសាររបស់អាជ្ញាធរពាក់ព័ន្ធ។

គ) ធានាថា បុគ្គលិក និងកម្មករទាំងអស់យល់ពីដំណើរការ និងភារកិច្ចរបស់ខ្លួន។

ឃ) ស្របតាមលក្ខខណ្ឌតម្រូវអំពីការពិនិត្យតាមដាន និងការរៀបចំរបាយការណ៍អំពីការគ្រប់គ្រងបរិស្ថាន ក្នុង EMP និងផ្តល់ព័ត៌មានដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) អំពីការលំបាក និងដំណោះស្រាយនានា។

ង) ផ្ដល់ព័ត៌មានដល់អាជ្ញាធរមូលដ្ឋាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ក្នុងករណីដែលមានបញ្ហាបរិស្ថានកើតមានឡើង និងធ្វើការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងតួអង្គពាក់ព័ន្ធនានា ដើម្បីធ្វើការដោះស្រាយបញ្ហាទាំងនោះ។

**IV.** មន្ត្រីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថានរបស់ក្រុមហ៊ុនម៉ៅការៈ

6. ក្រុមហ៊ុនម៉ៅការនីមួយៗត្រូវតែងតាំងមន្ត្រីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថាន (SEO) ឱ្យធ្វើការងារពេញម៉ោងនៅការដ្ឋានសំណង់។ លក្ខខណ្ឌតម្រូវសម្រាប់មន្ត្រីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថាន រួមមាន មានសញ្ញាបត្របរិញ្ញាបត្រខាងផ្នែកបរិស្ថាន និងមានបទពិសោធន៍យ៉ាងហោចណាស់បីឆ្នាំខាងការងារគ្រប់គ្រងបរិស្ថាន ការបណ្តុះបណ្តាល និងការពិនិត្យតាមដានក្នុងគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។ លើសពីនេះមន្ត្រីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថានគួរមានចំណេះដឹងជ្រៅជ្រះអំពីលិខិតបទដ្ឋានគតិយុត្តផ្នែកបរិស្ថានរបស់ជាតិ និងបានចូលរួមក្នុងថ្នាក់បណ្តុះបណ្តាលអំពីសុវត្ថិភាព និងអនាម័យការងារ ដែលរៀបចំដោយក្រសួងការងារអតីតយុទ្ធជន និងយុវនីតិសម្បទា និងទទួលបានវិញ្ញាបនបត្រផ្នែកសុវត្ថិភាព និងអនាម័យការងារ។

7. មន្ត្រីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថានទទួលខុសត្រូវអនុវត្ត និងគ្រប់គ្រង EMP របស់ក្រុមហ៊ុនម៉ៅការ។ ភារកិច្ចរបស់មន្ត្រីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថានមានជាអាទិ៍ៈ

ក. បណ្តុះបណ្តាល និងបង្កើនការយល់ដឹងអំពីបរិស្ថាន ដល់កម្មកររបស់ក្រុមហ៊ុនម៉ៅការក្នុងអំឡុងពេល ២ សប្តាហ៍ បន្ទាប់ពីក្រុមហ៊ុនម៉ៅការចាប់ផ្តើមដំណើរការការងាររបស់ខ្លួន។ ការបណ្តុះបណ្តាលនេះ ត្រូវធ្វើម្តងទៀតរៀងរាល់ ៦ ខែម្តង។ ការបណ្តុះបណ្តាលបន្ថែមនឹងត្រូវអនុវត្ត ក្រោមការណែនាំរបស់វិស្វករគ្រប់គ្រងបរិស្ថាន។

ខ. ធ្វើការពិនិត្យតាមដានបរិស្ថានផ្ទៃក្នុងនៅនឹងការដ្ឋាន ដើម្បីពិនិត្យមើលការអនុវត្តសកម្មភាពសាងសង់របស់ក្រុមហ៊ុនម៉ៅការ ឧបករណ៍ និងវិធីសាស្ត្រអនុវត្ត ដើម្បីគ្រប់គ្រងការបំពុលបរិស្ថាន និងវាយតម្លៃលើប្រសិទ្ធភាពនៃវិធានការសម្រាលផលប៉ះពាល់លើបរិស្ថាន។

គ. ពិនិត្យតាមដានផ្ទៃក្នុងលើការអនុវត្តវិធានការសម្រាលផលប៉ះពាល់លើបរិស្ថាន និងលើភាពអនុលោមរបស់ក្រុមហ៊ុនម៉ៅការជាមួយនឹងវិធានការការពារបរិស្ថាន ដើម្បីការពារ និងទប់ស្កាត់ការបំពុលបរិស្ថាន, លក្ខខណ្ឌដែលតម្រូវក្នុងកិច្ចសន្យា, គោលការណ៍ណែនាំរបស់ក្រុមហ៊ុនម៉ៅការស្តីពីការកែលម្អបរិស្ថាន, ការបង្កើនការយល់ដឹងអំពីបរិស្ថាន និងវិធានការផ្តួចផ្តើមជាមុន ដើម្បីបង្ការការបំពុលបរិស្ថាន។

ឃ. ធ្វើការស៊ើបអង្កេត និងលើកស្នើវិធានការសម្រាលផលប៉ះពាល់ដល់ក្រុមហ៊ុនម៉ៅការក្នុងករណីដែលពុំមានភាពអនុលោម/ការបំពាន EMP, ការពិនិត្យតាមដាន និងការអនុវត្តវិធានការសម្រាលផលប៉ះពាល់បរិស្ថាន។

ង. វាយតម្លៃលើជោគជ័យនៃការអនុវត្ត EMP ដើម្បីប៉ាន់ប្រមាណពីចំណាយ និងភាពគ្រប់ជ្រុងជ្រោយនៃវិធានការសម្រាលផលប៉ះពាល់ដែលត្រូវបានអនុវត្ត។

ច. ធ្វើការអង្កេតបន្ទាប់ពីទទួលបានពាក្យបណ្តឹង បន្ទាប់មកធ្វើការវាយតម្លៃ និងជ្រើសរើសកម្មភាពកែតម្រូវ។

ឆ. អនុវត្តសកម្មភាពពិនិត្យតាមដានបន្ថែម ផ្អែកតាមគោលការណ៍ណែនាំជាក់លាក់របស់វិស្វករពិនិត្យតាមដាន និង/ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs), និង

ជ. ទំនាក់ទំនង និងអនុវត្តរាល់សកម្មភាពទាំងអស់ក្រោមការសម្របសម្រួល ឬការណែនាំរបស់ប្រធាន ក្រុមហ៊ុនម៉ៅការ, វិស្វករគ្រប់គ្រងបរិស្ថាន, វិស្វករគ្រប់គ្រងទូទៅ, PCO, តំណាងការិយាល័យគ្រប់គ្រងបរិស្ថាននៅថ្នាក់ខេត្ត, អាជ្ញាធរមូលដ្ឋានអំពី

គ្រប់បញ្ហាបរិស្ថានទាំងអស់ ប្រសិនបើចាំបាច់។

ឈ. រៀបចំរបាយការណ៍ជាប្រចាំអំពីការអនុវត្តកញ្ចប់បរិស្ថានទៅតាមភាពញឹកញាប់ ដែលលើកឡើងក្នុង EMP។

ញ. រាល់ការពិនិត្យតាមដានផ្ទៃក្នុងទាំងអស់ ព្រមទាំងសកម្មភាពដទៃទៀតរបស់មន្ត្រីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថាន គួរកត់ត្រាទុកក្នុងកំណត់ហេតុ និងធ្វើបច្ចុប្បន្នភាពជាញឹកញាប់បញ្ចូលទៅក្នុង**សៀវភៅកត់ត្រាការពិនិត្យតាមដានការអនុវត្តបរិស្ថានរបស់ក្រុមហ៊ុនម៉ៅការ។** សៀវភៅកត់ត្រានេះត្រូវប្រើប្រាស់សម្រាប់ការត្រួតពិនិត្យជាធម្មតាដោយវិស្វករគ្រប់គ្រង ដើម្បីវាយតម្លៃលើប្រសិទ្ធភាពនៃការបំពេញការងាររបស់មន្ត្រីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថាន។

## V. ការពិនិត្យតាមដានលើការអនុវត្តបរិស្ថានរបស់ក្រុមហ៊ុនម៉ៅការៈ

8. អតិថិជនត្រូវចុះកិច្ចសន្យាជាមួយទីប្រឹក្សាដើម្បីបំពេញភារកិច្ចជាវិស្វករគ្រប់គ្រង។ ទីប្រឹក្សានេះត្រូវអនុវត្តសកម្មភាពពិនិត្យតាមដាន និងបរិស្ថានជាកញ្ចប់។ វិស្វករពិនិត្យតាមដានបរិស្ថានរបស់ទីប្រឹក្សាពិនិត្យតាមដានការសាងសង់/ការអនុវត្ត ទទួលខុសត្រូវពិនិត្យតាមដានការអនុវត្តវិធានការនានាជាប្រចាំថ្ងៃ ដើម្បីកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់មកលើបរិស្ថាន និងសុវត្ថិភាពរបស់ក្រុមហ៊ុនម៉ៅការ។ ទីប្រឹក្សាពិនិត្យតាមដានការសាងសង់ ត្រូវបំពេញភារកិច្ចសំខាន់ៗដូចខាងក្រោមៈ

- ✓ មុនដំណាក់កាលសាងសង់ ធានាថារាល់ដំណើរការផ្តល់សំណងដីធ្លី សំណង់នៅលើដី និងការផ្លាស់ប្តូរទីតាំង និង/ឬការស្តារឡើងវិញ ឬការផ្តល់អំណោយដី ក៏ដូចជា ការសម្អាតមីន និងគ្រាប់មិនទាន់ផ្ទុះ ត្រូវបានបញ្ចប់រួចរាល់។
- ✓ ពិនិត្យឡើងវិញ និងអនុម័តលើផែនការលម្អិតសម្រាប់អនុវត្ត EMP ដោយក្រុមហ៊ុនម៉ៅការមុនពេលចាប់ផ្តើមដំណើរការសាងសង់។
- ✓ ក្នុងអំឡុងដំណើរការសាងសង់ ធ្វើការពិនិត្យតាមដានឱ្យបានជិតស្និទ្ធលើភាពអនុលោមទៅតាមការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន និងសុវត្ថិភាព។
- ✓ បញ្ជាក់ពីភាពអនុលោមជាមួយនឹង EMP របស់ក្រុមហ៊ុនម៉ៅការ និងពិនិត្យមើលផលប៉ះពាល់អវិជ្ជមាន ឬការខូចខាតដែលបង្កឡើងដោយក្រុមហ៊ុនម៉ៅការ។ ប្រសិនបើចាំបាច់ ដាក់សំណើរទៅក្រុមហ៊ុនម៉ៅការឱ្យផ្តល់សំណង/ស្តារការដ្ឋានសាងសង់ឡើងវិញទៅតាមអ្វីដែលមានចែងក្នុងកិច្ចសន្យា។ ការអនុវត្តការគ្រប់គ្រងបរិស្ថានរបស់ក្រុមហ៊ុនម៉ៅការត្រូវលើកឡើងក្នុងរបាយការណ៍វឌ្ឍនភាពរបស់អនុគម្រោង។

## VI. ក្របខ័ណ្ឌអនុលោមភាពៈ

ក. ក្រុមហ៊ុនម៉ៅការពុំត្រូវបានអនុញ្ញាតអនុវត្តសកម្មភាពសាងសង់ ដូចជា ការរៀបចំការងារសាងសង់ក្នុងក្របខ័ណ្ឌគម្រោង មុនពេលមានការពិនិត្យ និងអនុម័តលើផែនការលម្អិតនៃ EMP ដោយទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ និងមន្ត្រីបរិស្ថានរបស់អតិថិជនឡើយ។

ខ. អតិថិជនត្រូវតម្រូវឱ្យក្រុមហ៊ុនម៉ៅការអនុលោមទៅតាមបញ្ញត្តិក្នុងកិច្ចសន្យា ដូចជា ភាពអនុលោមទៅតាម EMP និងផែនការអនុវត្តលម្អិតរបស់ EMP។ ក្នុងករណីពុំមានភាពអនុលោមទៅតាម EMP អតិថិជនត្រូវតម្រូវឱ្យក្រុមហ៊ុនម៉ៅការចាត់វិធានការឱ្យបានសមស្រប។

គ. ដើម្បីធានាភាពអនុលោមទៅតាមស្តង់ដារបរិស្ថានរបស់អនុគម្រោង អតិថិជនត្រូវបានអនុញ្ញាតឱ្យជួលភាគីទី ៣ ដើម្បីដោះស្រាយបញ្ហា ក្នុងករណីដែលក្រុមហ៊ុនម៉ៅការពុំអាចអនុវត្តដំណោះស្រាយបានទាន់ពេលវេលា ដែលនាំឱ្យមានផលប៉ះពាល់អវិជ្ជមានលើបរិស្ថានដូចតទៅៈ

- សម្រាប់កំហុសមិនសំខាន់ (ដូចជា ផលប៉ះពាល់/ការខូចខាតតិចតួច

ដែលមានលក្ខណៈបណ្ដោះអាសន្ន និងអាចជួសជុលឡើងវិញ), អតិថិជន ឬតំណាងអតិថិជន (ទីប្រឹក្សាគ្រប់គ្រង) ត្រូវជូនដំណឹងដល់ក្រុមហ៊ុនម៉ៅការឱ្យធ្វើការកែតម្រូវបញ្ហាទាំងនេះ ដូចដែលត្រូវបានកំណត់ក្នុង EMP មិនឱ្យហួសពី ៤៨ ម៉ោង បន្ទាប់ពីបានទទួលរបាយការណ៍ផ្លូវការ។ ប្រសិនបើកំហុសនេះត្រូវបានដោះស្រាយជាទីពេញចិត្តក្នុងអំឡុងពេលនេះ នោះនឹងពុំមានការអនុវត្តសកម្មភាពអ្វីបន្ថែមទៀតឡើយ។ ទីប្រឹក្សាគ្រប់គ្រងមានសិទ្ធិពន្យារពេលថែម ២៤ ម៉ោងនៅក្នុងករណីដែលពេលវេលាសម្រាប់ស្តារឡើងវិញមានកំណត់ ក្រោមលក្ខខណ្ឌថា ក្រុមហ៊ុនម៉ៅការបានអនុវត្តសកម្មភាពទាំងអស់ដែរ ប៉ុន្តែពុំបានបញ្ចប់សកម្មភាពទាំងនេះ ក្នុងពេលវេលាដែលបានកំណត់ ដោយសារស្ថានភាពពុំអាចដោះស្រាយបាន ដូចដែលបានលើកឡើងក្នុងកិច្ចសន្យា។

- សម្រាប់ការបំពានធំៗ ចាំបាច់ត្រូវមានការជួសជុលឱ្យរួចរាល់ក្នុងរយៈពេល ៧២ ម៉ោង ដោយអតិថិជន តាមរយៈទីប្រឹក្សាគ្រប់គ្រង ត្រូវប្រកាសពីការបំពាននេះ និងតម្រូវឱ្យក្រុមហ៊ុនម៉ៅការធ្វើការកែតម្រូវក្នុងក្របខ័ណ្ឌពេលវេលាដែលបានកំណត់ ដោយប្រើប្រាស់ថវិការបស់ពួកគេ។ ប្រសិនបើក្រុមហ៊ុន ម៉ៅការខកខានពុំបានបញ្ចប់ការងារកែតម្រូវទៅតាមពេលវេលា ដែលបានកំណត់នោះទេ ពួកគេនឹងទទួលទណ្ឌកម្មហិរញ្ញវត្ថុ (ការដាក់ទណ្ឌកម្មហិរញ្ញវត្ថុត្រូវបានគណនា តាមរយៈការចំណាយទូទាត់ការខូចខាត)។

- បើតាមការវាយតម្លៃរបស់ទីប្រឹក្សាគ្រប់គ្រង ប្រសិនបើក្រុមហ៊ុនម៉ៅការខកខានពុំបានដោះស្រាយបញ្ហាក្នុងការគ្រប់គ្រងបរិស្ថាន ឬក្រុមហ៊ុនម៉ៅការធ្វើការជួសជុលពុំបានដល់កម្រិតជាទីពេញចិត្តក្នុងពេលវេលាដែលបានកំណត់ (៤៨ ម៉ោង ឬ ៧២ ម៉ោង) អ្នកវិនិយោគទុនមានសមត្ថភាពរៀបចំឱ្យក្រុមហ៊ុនម៉ៅការមួយទៀត (ភាគីទី ៣ អនុវត្តវិធានការសមស្រប និងកាត់ប្រាក់សម្រាប់ការងារនេះ ពីកិច្ចសន្យាជាមួយក្រុមហ៊ុនម៉ៅការ នៅក្នុងការទូទាត់បន្ទាប់។

## ឧបសម្ព័ន្ធទី ៦៖ ការណែនាំអំពីការគ្រប់គ្រងការអនុវត្ត EMP

### I. គោលការណ៍

1. *តួនាទីរបស់អ្នកខ្ចី៖* អ្នកខ្ចីកម្ចីរៀបចំគម្រោង ដើម្បីស្នើសុំហិរញ្ញប្បទានលើគម្រោងវិនិយោគ។ វិសាលភាព គោលបំណងរបស់គម្រោង ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចក្នុងកិច្ចសន្យារបស់អ្នកខ្ចីកម្ចី ត្រូវបានចែងក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ជាមួយធនាគារ។ កាតព្វកិច្ចទាំងនេះរាប់បញ្ចូលលក្ខខណ្ឌតម្រូវឱ្យមានការអនុវត្តគម្រោង ជាមួយនឹងការពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ រក្សាការរៀបចំសមស្របសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្ត និងអនុលោមទៅតាមកាតព្វកិច្ចពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ ការបើកប្រាក់ និងកាតព្វកិច្ចសង្គម និងបរិស្ថាន។ អ្នកខ្ចីកម្ចីធ្វើការវាស់វែង និងរាយការណ៍ពីគោលបំណងការអភិវឌ្ឍ និងលទ្ធផលរបស់គម្រោង និងត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មទៅតាមការព្រមព្រៀងគ្នា។ អ្នកខ្ចីកម្ចីត្រូវដោះស្រាយបញ្ហា ឬការរំលោភបំពានជាក់ស្តែង ឬបញ្ហា ឬការរំលោភបំពានដែលត្រូវបានលើកឡើងឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ពាក់ព័ន្ធនឹងផ្នែកខាងលើនេះ (មិនថាបញ្ហា ឬការរំលោភបំពានទាំងនេះ ជាលក្ខណៈបុគ្គល ឬកើតឡើងក្នុងលក្ខខណៈជាប្រព័ន្ធនោះឡើយ)។

2. *តួនាទីរបស់ធនាគារ៖* ក្នុងអំឡុងពេលអនុវត្តគម្រោង ធនាគារធ្វើការពិនិត្យតាមដានភាពអនុលោមរបស់អ្នកខ្ចីកម្ចីទៅតាមកាតព្វកិច្ចរបស់អ្នកខ្ចីកម្ចី ដូចមានចែងក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ និងផ្តល់ការគាំទ្រដល់ការអនុវត្តដល់អ្នកខ្ចីកម្ចី តាមរយៈការពិនិត្យលើព័ត៌មាន ដែលផ្តល់ដោយអ្នកខ្ចីកម្ចី អំពីវឌ្ឍនភាពនៃការអនុវត្តគម្រោង វឌ្ឍនភាពក្នុងការឈានទៅសម្រេចគោលបំណងនៃការអភិវឌ្ឍ និងលទ្ធផលពាក់ព័ន្ធរបស់គម្រោង និងធ្វើបច្ចុប្បន្នភាពហានិភ័យ និងវិធានការគ្រប់គ្រងដែលពាក់ព័ន្ធ។ ការគាំទ្រ និងការពិនិត្យតាមដានការអនុវត្ត ដែលធ្វើឡើងដោយធនាគារក្នុងអំឡុងរយៈពេលនៃការអនុវត្ត បញ្ចប់នៅពេលដែលគម្រោងបញ្ចប់។ ការគាំទ្រដល់ការអនុវត្តគម្រោងគ្របដណ្តប់លើការពិនិត្យតាមដាន ការវាយតម្លៃ ការរៀបចំរបាយការណ៍ និងសកម្មភាពផ្តល់ជំនួយបច្ចេកទេស។

3. ធនាគារធ្វើការត្រួតពិនិត្យលើទិដ្ឋភាពបរិស្ថានរបស់គម្រោង ផ្អែកតាមលទ្ធផលរកឃើញ និងអនុសាសន៍នៃការវាយតម្លៃបរិស្ថាន រួមនឹងវិធានការនានា ដែលត្រូវបានលើកឡើងក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ EMP និងឯកសារគម្រោងដទៃទៀត។

### II. គោលបំណងនៃការត្រួតពិនិត្យ៖

4. គោលបំណងនៃការត្រួតពិនិត្យលើការការពារផលប៉ះពាល់បរិស្ថាន ឬការអនុវត្ត EMP ក្នុងអំឡុងពេល អនុវត្តគម្រោង ត្រូវបានបញ្ចូលទៅក្នុងគោលបំណងនៃការត្រួតពិនិត្យការអនុវត្តគម្រោងដូចខាងក្រោម៖

ក. ធានាថាគម្រោងត្រូវបានអនុវត្តដោយមានការពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ ដើម្បីសម្រេចគោលបំណងនៃការអភិវឌ្ឍរបស់គម្រោង ដោយអនុលោមទៅតាមកិច្ចព្រមព្រៀងផ្លូវច្បាប់ រួមនឹងកិច្ចព្រមព្រៀងផ្នែកបរិស្ថាន

ខ. កំណត់ពីបញ្ហាសង្គម និងបរិស្ថានជាបន្ទាន់ ខណៈពេលដែលបញ្ហាទាំងនេះកើតមានឡើងក្នុងអំឡុងពេលនៃការអនុវត្ត និងរិះរកវិធីដើម្បីដោះស្រាយបញ្ហាទាំងនេះ

គ. លើកស្នើទៅកាន់ធនាគារ អំពីការផ្លាស់ប្តូរការរៀបចំគម្រោងឱ្យបានសមស្រប ខណៈពេលដែលគម្រោងបន្តមានការវិវត្ត ឬការផ្លាស់ប្តូរកាលៈទេសៈបរិស្ថាននានា

ឃ. កំណត់ពីហានិភ័យបរិស្ថានសំខាន់ៗ ដែលប៉ះពាល់ដល់និរន្តរភាពរបស់គម្រោង និងលើកស្នើយុទ្ធសាស្រ្ត និងសកម្មភាពគ្រប់គ្រងហានិភ័យឱ្យបានសមស្របជូនធនាគារ និង

ង. រៀបចំរបាយការណ៍បញ្ចប់ការអនុវត្តរបស់អ្នកខ្ចីកម្ចី ដោយបញ្ចូលផ្នែកមួយស្តីពីភាពអនុលោម

ចំពោះវិធានការការពារផលប៉ះពាល់ និងប្រមូលចងក្រងមេរៀន ដើម្បីកែលម្អការរៀបចំគម្រោងនាពេលអនាគត ដើម្បីសម្រេចលទ្ធផលបរិស្ថានកាន់តែល្អប្រសើរជាងមុន។

## III. ដំណាក់កាលមុនពេលសាងសង់

### *3.1. ការបញ្ចូល EMP ទៅក្នុងសៀវភៅណែនាំស្តីពីប្រតិបត្តិការគម្រោង*

5. ការបញ្ចូល EMP ទៅក្នុងសៀវភៅណែនាំស្តីពីប្រតិបត្តិការគម្រោង ត្រូវបានធ្វើឡើងនៅកម្រិតគម្រោង ពោលគឺមិនមែននៅកម្រិតអនុគម្រោងឡើយ។ ជាធម្មតាសៀវភៅណែនាំស្តីពីប្រតិបត្តិការគម្រោង (POM) ត្រូវរៀបចំឡើង ក្នុងអំឡុងពេលវាយតម្លៃគម្រោង និងមុនពេលធ្វើការចរចា។ សៀវភៅណែនាំស្តីពីប្រតិបត្តិការគម្រោង ត្រូវបញ្ចូលផ្នែកមួយស្តីពីការការពារផលប៉ះពាល់បរិស្ថាន។ ចំណុចដែលសំខាន់បំផុតគឺមិនត្រូវចម្លងផ្នែកក្នុង EMP មកដាក់ក្នុងផ្នែក ឬឧបសម្ព័ន្ធនៃសៀវភៅណែនាំស្តីពីប្រតិបត្តិការគម្រោងឡើយ។ កន្លងមក ការធ្វើបែបនេះ ពុំមានប្រសិទ្ធភាពឡើយ។ ផ្ទុយទៅវិញអ្នករៀបចំ EMP ឬបុគ្គលិកបរិស្ថានរបស់ PCO គួរសហការជាមួយនឹងគម្រោង និងកែសម្រួល EMP ដើម្បីផលិតចេញជា POM។ គេគួរពិនិត្យមើល POM ផ្សេងទៀតដែលមាននៅក្នុងប្រទេស និងក្នុងគម្រោងស្រដៀងគ្នាផ្សេងទៀតរបស់ធនាគារ និងរក POM ណាដែលមានសមាសភាគពាក់ព័ន្ធនឹងការការពារផលប៉ះពាល់ ដែលអាចយកមកអនុវត្តនៅក្នុងគម្រោងនេះបាន។ មាតិកាដែលត្រូវបានលើកស្នើសម្រាប់ POM ត្រូវបានបង្ហាញក្នុងប្រអប់ខាងក្រោម។

**មាតិកាដែលត្រូវបានលើកស្នើឡើងសម្រាប់សៀវភៅណែនាំស្តីពីប្រតិបត្តិការគម្រោង**

**សេចក្តីពិពណ៌នាដោយសង្ខេបអំពីគម្រោង**

- ទិដ្ឋភាពរួមទូទៅ/គោលបំណង
- បរិបទបរិស្ថាន
- កត្តាគោលនយោបាយ
- សមាសភាគគម្រោង (ត្រូវបញ្ជាក់ពីប្រវែងផ្លូវ ការដ្ឋានអភិវឌ្ឍន៍។ល។)
- ការគ្រប់គ្រងគម្រោង៖ ការសម្របសម្រួល/ការរៀបចំការអនុវត្ត

**ផលប៉ះពាល់បរិស្ថាន ដែលអាចបង្កឡើងដោយសមាសភាគនានារបស់គម្រោង**

- លំដាប់លំដោយជារួមទៅតាមវិសាលភាព/ឥទ្ធិពល
- ផលប៉ះពាល់ផ្ទាល់ ផលប៉ះពាល់ប្រយោល និងផលប៉ះពាល់សរុប
- បញ្ហាបរិស្ថាន សង្គមសរុបសំខាន់ៗ

**ការការពារផលប៉ះពាល់បរិស្ថាន**

- គោលបំណង (បញ្ញាបភាពអនុលោម)
- ការការពារផលប៉ះពាល់ ដែលត្រូវអនុវត្តតាមសមាសភាគគម្រោង ការផ្ទៀងផ្ទាត់ជាមួយនឹងផែនការគ្រប់គ្រងសមាសភាគចង្រៃ ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់/តាំងទីលំនៅ។ល។)
- ការពិនិត្យតាមដាន/ការវាយតម្លៃលើការអនុវត្ត វិធានការការពារផលប៉ះពាល់ - ច្បាប់/លិខិតបទដ្ឋានគតិយុត្ត បរិស្ថាន ដែលពាក់ព័ន្ធក្នុងប្រទេស។
- តួនាទីរបស់ទីភ្នាក់ងារបរិស្ថានជាតិ ឧទាហរណ៍ផ្តល់ការអនុម័តលើអនុគម្រោង ពិនិត្យតាមដាន/ត្រួតពិនិត្យ។ល។

**ផែនការគ្រប់គ្រងបរិស្ថាន ឬឯកសារប្រហាក់ប្រហែលនេះ**

- វិធានការសម្រាលផលប៉ះពាល់
- លក្ខខណ្ឌតម្រូវសម្រាប់ការពិនិត្យតាមដាន បញ្ហា/សកម្មភាពសំខាន់ៗ សូចនាករលទ្ធផលការងារសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ
- ការរៀបចំស្ថាប័ន/ការទទួលខុសត្រូវ រួមនឹងការសម្របសម្រួលបុគ្គលិក និងការពង្រឹងសមត្ថភាព
- កាលវិភាគអនុវត្តវិធានការ/ការរៀបចំរបាយការណ៍
- ចំណាយ

**ផែនការពិនិត្យតាមដាន/រៀបចំរបាយការណ៍**

- បញ្ហា/សកម្មភាពសំខាន់ៗសម្រាប់ការគ្រប់គ្រង
- របាយការណ៍ប្រចាំត្រីមាស/ប្រចាំឆ្នាំ
- សូចនាករលទ្ធផលការងារសម្រាប់ការពិនិត្យតាមដាន និងការវាយតម្លៃ

**ការរៀបចំស្ថាប័ន**

- ការរៀបចំស្ថាប័ន

### 3.2. ការបណ្តុះបណ្តាលអំពីការគ្រប់គ្រងបរិស្ថាន បន្ទាប់ពីកិច្ចព្រមព្រៀងផ្តល់កម្ចីចូលជាធរមាន

6. ជាការអនុវត្តល្អភ្លាមៗ បន្ទាប់ពីកិច្ចព្រមព្រៀងផ្តល់កម្ចីចូលជាធរមាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ត្រូវរៀបចំសិក្ខាសាលាប្រកាសចាប់ផ្តើមអនុវត្តគម្រោង។ ក្នុងសិក្ខាសាលានេះ ធនាគារត្រូវផ្តល់ការបណ្តុះបណ្តាលខ្លី អំពីការគ្រប់គ្រងគម្រោង រួមនឹងការការពារផលប៉ះពាល់បរិស្ថាន ដែលបង្កឡើងដោយសារគម្រោង។ បុគ្គលិកបរិស្ថានរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) និងទីប្រឹក្សាដែលពាក់ព័ន្ធ ប្រសិនបើបានជ្រើសរើសរួចទៅហើយនោះ ចាំបាច់ត្រូវចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ ដើម្បីដឹងពីរបៀបអនុវត្ត EMP ក្នុងអំឡុងពេលអនុវត្តគម្រោង។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) គួររៀបចំវគ្គបណ្តុះបណ្តាលខ្លី អំពី EMP សម្រាប់អនុគម្រោងនីមួយៗនៅកម្រិតមូលដ្ឋាន សម្រាប់សហគមន៍មូលដ្ឋាន ដែលរងផលប៉ះពាល់ អាជ្ញាធរ និងក្រុមហ៊ុនម៉ៅការ។

### 3.3. ប្រព័ន្ធគ្រប់គ្រងបរិស្ថានរបស់គម្រោង

7. ជាធម្មតាប្រព័ន្ធគ្រប់គ្រងបរិស្ថានរបស់គម្រោង ត្រូវយកមកធ្វើការពិចារណា និងបញ្ចូលក្នុង EMP ដើម្បីធានាយ៉ាងណាឱ្យគម្រោងអនុលោមទៅតាមលក្ខខណ្ឌតម្រូវការការពារផលប៉ះពាល់បរិស្ថាន។ ប្រព័ន្ធនេះដែលត្រូវបានរៀបចំសម្រាប់កម្រិតគម្រោង និងកម្រិតអនុគម្រោង រួមមានអង្គភាពគ្រប់គ្រងបរិស្ថានមួយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs), មន្ត្រីទទួលបន្ទុកបរិស្ថាន (EO) របស់ទីប្រឹក្សាគ្រប់គ្រងការងារសាងសង់/វិស្វករគ្រប់គ្រង (CSC), មន្ត្រីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថាន (SEO) របស់ក្រុមហ៊ុនម៉ៅការ, និងទីប្រឹក្សាពិនិត្យតាមដានបរិស្ថានឯករាជ្យ (IEMC), អាជ្ញាធរពាក់ព័ន្ធ និងសហគមន៍។ អាស្រ័យទៅតាមកម្រិតនៃហានិភ័យបរិស្ថានរបស់គម្រោង គេប្រហែលជាពុំត្រូវការទីប្រឹក្សាពិនិត្យតាមដានបរិស្ថានឯករាជ្យនោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ មិនថាហានិភ័យនៅកម្រិតណានោះទេ មន្ត្រីទទួលបន្ទុកបរិស្ថានរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs), មន្ត្រីទទួលបន្ទុកបរិស្ថាន, និងមន្ត្រីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថាន បំពេញតួនាទីសំខាន់ក្នុងការធានាភាពអនុលោមរបស់គម្រោងទៅតាមវិធានការការពារផលប៉ះពាល់។

8. គួរមានការបញ្ជាក់ឱ្យបានច្បាស់លាស់ពីការទទួលខុសត្រូវរបស់តួអង្គទាំងនេះក្នុង EMP។ PCO ចាំបាច់ត្រូវអនុវត្តតាម EMP និងត្រូវធានាយ៉ាងណាឱ្យប្រព័ន្ធនេះមានដំណើរការនៅពេលជ្រើសរើសទីប្រឹក្សា និងក្រុមហ៊ុន ម៉ៅការដែលពាក់ព័ន្ធ។

### 3.4. ក្នុងអំឡុងពេលរៀបចំលម្អិត

9. គោលបំណងមួយក្នុងចំណោមគោលបំណងនានានៃដំណើរការ EA គឺត្រូវកំណត់ពីបញ្ហាបរិស្ថានដែលអាចបញ្ចូលទៅក្នុងការរៀបចំគម្រោងនៅដំណាក់កាលដំបូងនៃការរៀបចំគម្រោង ដើម្បីបង្កើនផលវិជ្ជមាន និងបញ្ចៀស កាត់បន្ថយឱ្យនៅជាអប្បបរមា ឬសម្រាលផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានឡើង។ ក្នុងអំឡុងពេលអនុវត្តគម្រោង ដែលចាប់ផ្តើមបន្ទាប់ពីកិច្ចព្រមព្រៀងផ្តល់កម្ចីចូលជាធរមាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ចាំបាច់ត្រូវធានាថា វិធានការសម្រាលផលប៉ះពាល់ដែលពាក់ព័ន្ធក្នុង EMP ត្រូវបានយកមកធ្វើការពិចារណា និងបញ្ចូលក្នុងឯកសាររៀបចំបច្ចេកទេសលម្អិតទៅតាមការសមស្រប។ ជំហានដើម្បីធ្វើបែបនេះ រួមមាន៖

ក. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) បញ្ចូលលក្ខខណ្ឌតម្រូវសម្រាប់ពិចារណាក្នុង EMP ទៅក្នុងលក្ខខណ្ឌការងារសម្រាប់ទីប្រឹក្សារៀបចំបច្ចេកទេសលម្អិត

ខ. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) បញ្ចូល EMP ទៅក្នុងឯកសារដេញថ្លៃសម្រាប់ការងាររៀបចំបច្ចេកទេសលម្អិត

គ. ទីប្រឹក្សារៀបចំបច្ចេកទេសលម្អិត យោងលទ្ធផលរកឃើញក្នុង EMP ក្នុងអំឡុងដំណើរការរៀបចំ

និង

ឃ. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ធ្វើការពិនិត្យតាមដាន ដើម្បីធានាថា វិធានការសម្រាលផលប៉ះពាល់ ដែលពាក់ព័ន្ធក្នុង EMP ត្រូវបានយកទៅធ្វើការពិចារណាក្នុងការរៀបចំបច្ចេកទេស។

## 3.5. ការរៀបចំឯកសារដេញថ្លៃ និងឯកសារកិច្ចសន្យាសម្រាប់ការងារសាងសង់

10. EMP ពុំមានតម្លៃអ្វីឡើយ លើកលែងតែមានការអនុវត្តតាមផែនការនេះ ទៅតាមអ្វីដែលបានគ្រោងទុក។ នេះអាចសម្រេចទៅបានតែប្រសិនបើ EMP ត្រូវបានភ្ជាប់ជាមួយនឹងឯកសារដេញថ្លៃ និងឯកសារកិច្ចសន្យា ជាផ្នែកមួយនៃការពិពណ៌នាដែលត្រូវបំពេញដោយក្រុមហ៊ុនម៉ៅការ និងបានទទួលការយកចិត្តទុកដាក់ពីក្រុមហ៊ុនម៉ៅការក្នុងអំឡុងពេលដេញថ្លៃតែប៉ុណ្ណោះ។ ការធ្វើបែបនេះផ្តល់លទ្ធភាពឱ្យគេអាចបញ្ចូល EMP ទៅក្នុងដំណើរការដេញថ្លៃ និងដំណើរការចុះកិច្ចសន្យា និងធានាថា៖

ក. EMP ត្រូវបានចាត់ទុកថាជាលក្ខខណ្ឌមួយនៃកិច្ចសន្យា

ខ. មានការប៉ាន់ប្រមាណចំណាយសមស្រប សម្រាប់ការអនុវត្ត EMP និង

គ. ប្រព័ន្ធគ្រប់គ្រងត្រូវបានបង្កើតឡើង ដើម្បីធានាឱ្យមានភាពអនុលោមទៅតាម EMP។

11. ប្រសិនបើ EMP ត្រូវបានបញ្ចូលឱ្យបានត្រឹមត្រូវទៅក្នុងឯកសារដេញថ្លៃ និងឯកសារកិច្ចសន្យានោះទេ ក្រុមហ៊ុនម៉ៅការអាចអះអាងថា ភាពអនុលោមទៅតាម EMP នេះពុំមែនជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវក្នុងការងាររបស់ពួកគេឡើយ។ ការបញ្ចូល EMP ទៅក្នុងឯកសារដេញថ្លៃ និងឯកសារកិច្ចសន្យា គឺជាលក្ខខណ្ឌតម្រូវជាមុន។ បើមិនដូច្នោះទេ បន្ទាប់ពីមានការផ្តល់កិច្ចសន្យារួចវាអាចយឺតពេលពេកក្នុងការពង្រឹងការអនុវត្តតាមខ្លឹមសារនៃ EMP។

12. ធនាគារប្រើប្រាស់ឯកសារដេញថ្លៃស្តង់ដាររបស់សហព័ន្ធអន្តរជាតិនៃវិស្វករពិគ្រោះយោបល់ (FIDIC) សម្រាប់កញ្ចប់ការងារសាងសង់។ នៅក្នុងឯកសារនេះមានកន្លែងចំនួនពីរ ដែលគេអាចបញ្ចូលលក្ខខណ្ឌតម្រូវសម្រាប់គ្រប់គ្រង និងពិនិត្យតាមដានបរិស្ថាន៖ ផ្នែក B នៃលក្ខខណ្ឌពិសេស ជាលក្ខខណ្ឌតម្រូវបន្ថែមក្រោម ខរង ៤.១៨ – ការការពារបរិស្ថាន, សេចក្តីពិពណ៌នាក្នុងទម្រង់ជាសេចក្តីពិពណ៌នាអំពីបរិស្ថាន (ជាធម្មតាត្រូវបានដាក់កូដសម្គាល់ថា សេចក្តីពិពណ៌នា ០១៧០០ – ផែនការគ្រប់គ្រងបរិស្ថាន)។

13. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ពុំអាចធ្វើការផ្លាស់ប្តូរខ្លឹមសារនៃលក្ខខណ្ឌទូទៅក្នុងកិច្ចសន្យានោះឡើយ ដោយសារតែវាមានខចែង និងភាសាដែលត្រូវបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិ។ ប៉ុន្តែនៅក្នុងករណីដែលមានការមិនឯកភាពគ្នារវាងផ្នែកក្នុងលក្ខខណ្ឌទូទៅ និងលក្ខខណ្ឌ ឬសេចក្តីពិពណ៌នាពិសេស នៅលក្ខខណ្ឌ និងសេចក្តីពិពណ៌នាពិសេសត្រូវយកជាបានការ។

14. ផ្នែកលក្ខខណ្ឌពិសេស ចែងលម្អិតពីលក្ខខណ្ឌតម្រូវសម្រាប់ការរៀបចំគម្រោង។ ដូច្នេះឧទាហរណ៍ប្រសិនបើមានលក្ខខណ្ឌតម្រូវពិសេសពាក់ព័ន្ធនឹងការរៀបចំតំបន់ទេសភាព ដូចជាការដាំដើមឈើលើទីជម្រាល ឬតម្រូវឱ្យមានការរៀបចំពិសេសសម្រាប់អាងស្តុកដីល្បាប់ព័ត៌មានលម្អិតនេះ ជាធម្មតាត្រូវបានកំណត់ក្នុងសេចក្តីពិពណ៌នាលម្អិត។ ផ្នែកនេះក៏អាចបញ្ចូលស្តង់ដារអនុវត្តការងារផងដែរ ដូច្នេះប្រសិនបើមានការតម្រូវឱ្យបង្កើតប្រព័ន្ធសម្អាតទឹកសំណល់ក្នុងអំឡុងដំណាក់កាលសាងសង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) អាចបញ្ចូលប៉ារ៉ាម៉ែត្រនៃការបញ្ចេញទឹកសំណល់ ដែលអាចទទួលយកបាន ពីប្រព័ន្ធនេះ។

15. ខចែងអំពីបរិស្ថានគួរមានភាពច្បាស់លាស់ និងចែងពីអ្វីដែលត្រូវធ្វើ ចាំបាច់ត្រូវធ្វើនៅកន្លែងណា នៅពេលណា និងថាតើសកម្មភាពទាំងនេះនឹងធ្វើឡើងដោយរបៀបណា និងអ្នកដែលទទួលខុសត្រូវ។ PCO ដោយសហការជាមួយនឹងអ្នកឯកទេសផ្នែកបរិស្ថាននៃអង្គភាពគ្រប់គ្រងបរិស្ថាន វិស្វករ និងអ្នកបច្ចេកទេស គួរប្រើប្រាស់លក្ខខណ្ឌ និងសេចក្តីពិពណ៌នាក្នុងកិច្ចសន្យា

ដើម្បីធានាថា ក្រុមហ៊ុនម៉ៅការពិតជាបានអនុវត្តវិធានការសម្រាលផលប៉ះពាល់ប្រកបដោយប្រសិទ្ធភាពពិតប្រាកដមែន។

16. ការសហការយ៉ាងជិតស្និទ្ធរវាងក្រុមការងារបរិស្ថាន និងក្រុមការងារបច្ចេកទេស ធានាឱ្យមានការបញ្ចូលវិធានការសម្រាលផលប៉ះពាល់ទៅក្នុងការរៀបចំគម្រោង។ វិស្វករៀបចំគម្រោង គួរបញ្ចូលវិធានការសម្រាលផលប៉ះពាល់ទៅក្នុងឯកសារបច្ចេកទេសរបស់ខ្លួន (ឧទាហរណ៍ ដូចជា ឯកសារបង្ហាញពីបរិមាណ (bill of quantities), គំនូសប្លង់ និងសេចក្តីពិពណ៌នាបច្ចេកទេស) ប៉ុន្តែគួរមានការកត់សម្គាល់ថា ឯកសារមួយចំនួនអាចលើកឡើងពីវិធានការសម្រាលផលប៉ះពាល់ទូទៅ ដែលត្រូវអនុវត្តតាមដោយក្រុមការងារបច្ចេកទេស និងក្រុមហ៊ុនម៉ៅការ។

17. ដើម្បីធានាឱ្យមានការអនុវត្តលក្ខខណ្ឌតម្រូវបរិស្ថានឱ្យបានល្អប្រសើរ គេអាចភ្ជាប់ឯកសារ EMP ឬឯកសារប្រហាក់ប្រហែលនេះជាលក្ខខណ្ឌច្បាប់ ក្នុងឯកសារកិច្ចសន្យា ឬគេអាចរៀបចំជាខចែងស្តីពីបរិស្ថាន និងបញ្ចូលវាដោយផ្ទាល់ទៅក្នុងឯកសារកិច្ចសន្យា។

18. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ក៏ចាំបាច់ត្រូវធានាឱ្យមានការបញ្ចូលការដាក់ទោសទណ្ឌទៅក្នុងកិច្ចសន្យាផងដែរ សម្រាប់ភាពមិនអនុលោមទៅតាមកម្រិតខុសៗគ្នា។

19. ខាងក្រោមនេះ គឺជាកម្រិតនៃភាពអនុលោម ដែលត្រូវបានលើកស្នើឡើង៖

- ភាពអនុលោមកម្រិតទី I៖ ស្ថានភាពនៃភាពមិនអនុលោម ពុំសមស្របទៅតាមលក្ខខណ្ឌតម្រូវក្នុងកិច្ចព្រមព្រៀងសម្បទាន ប៉ុន្តែពុំត្រូវបានគេជឿថា អាចបង្កហានិភ័យភ្លាមៗ ឬធ្ងន់ធ្ងរដល់បរិស្ថាន ឬសង្គមឡើយ។ ភាពមិនអនុលោមជាច្រើនលើកជាច្រើនសានៅកម្រិតទី I អាចក្លាយជាភាពអនុលោមនៅកម្រិតទី II ប្រសិនបើទុកចោល ដោយពុំមានការកែតម្រូវ។
- ភាពអនុលោមកម្រិតទី II៖ ស្ថានភាព និងភាពអនុលោម ដែលពុំទាន់បានក្លាយជាការខូចខាតដែលគេអាចកំណត់ដឹងច្បាស់ ឬផលប៉ះពាល់ដែលពុំអាចផ្លាស់ប្តូរត្រឡប់មកវិញបាននៅឡើយ ប៉ុន្តែមានកម្រិតគួរឱ្យកត់សម្គាល់ ដែលតម្រូវឱ្យមានការចាត់វិធានការកែតម្រូវជាបន្ទាន់ និងត្រូវមានការយកចិត្តទុកដាក់ជាក់លាក់ចំពោះទីតាំង ដើម្បីបង្ការមិនឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរកើតឡើង។ ភាពអនុលោមនៅកម្រិតទី II ជាច្រើនលើកជាច្រើនសារ អាចក្លាយជាភាពអនុលោមនៅកម្រិតទី III ប្រសិនបើទុកចោល ដោយពុំមានការយកចិត្តទុកដាក់។
- ភាពអនុលោមកម្រិតទី III៖ ស្ថានភាព និងភាពមិនអនុលោមដ៏ធ្ងន់ធ្ងរ ជាធម្មតាស្តែងចេញតាមរយៈការខូចខាតបរិស្ថាន ឬសង្គមគួរឱ្យកត់សម្គាល់ ដែលគេអាចសង្កេតឃើញ ឬដែលគេរំពឹងដោយហេតុផលសមស្របថានឹងបង្កឱ្យមានការខូចខាតធ្ងន់ធ្ងរ។ ការមានចេតនាមិនយកចិត្តទុកដាក់ចំពោះការហាមប្រាមជាក់លាក់ ក៏ត្រូវបានចាត់ចំណាត់ថ្នាក់ថាជាភាពមិនអនុលោមនៅកម្រិតទី III ផងដែរ។

21. ជម្រើសផ្សេងទៀត រួមមាន ខចែងដែលផ្តល់ឱ្យម្ចាស់គម្រោង នូវជម្រើសធ្វើសកម្មភាពកែតម្រូវ និងឱ្យក្រុមហ៊ុនម៉ៅការជាអ្នកចេញថ្លៃបូកនឹង ១៥% បន្ថែម។

22. នៅពេលធ្វើការវាយតម្លៃសំណើដេញថ្លៃ PCO ចាំបាច់ត្រូវពិនិត្យលើវិធីសាស្ត្រដែលក្រុមហ៊ុនម៉ៅការនឹងប្រើប្រាស់សម្រាប់ការគ្រប់គ្រងបរិស្ថាន ក្នុងអំឡុងដំណាក់កាលសាងសង់ បទពិសោធន៍ដែលក្រុមហ៊ុនម៉ៅការមានកន្លងមក និងចំណាយសម្រាប់ការសម្រាលផលប៉ះពាល់បរិស្ថាន។

IV. ដំណាក់កាលសាងសង់

24. ក្នុងអំឡុងដំណាក់កាលសាងសង់នៃគម្រោង ការតាមដាន និងពិនិត្យការអនុវតត EMP ត្រូវធ្វើឡើងដោយតួអង្គពាក់ព័ន្ធ។

*<u>ក្រុមហ៊ុនម៉ៅការ៖</u>*

25. ក្នុងអំឡុងដំណាក់កាលសាងសង់ ក្រុមហ៊ុនម៉ៅការទទួលខុសត្រូវអនុលោមទៅតាម

សេចក្តីពិពណ៌នាបច្ចេកទេស ក្នុង EMP និងលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងបរិស្ថាន និងលិខិតបទដ្ឋានគតិយុត្តបច្ចេកទេស ដែលពាក់ព័ន្ធ។ ផ្អែកតាមលក្ខខណ្ឌតម្រូវផ្នែកបរិស្ថានក្នុងកិច្ចសន្យា ក្រុមហ៊ុនម៉ៅការត្រូវរៀបចំផែនការគ្រប់គ្រងបរិស្ថានលម្អិតសម្រាប់ទីតាំងនីមួយៗ (SEMP) ដើម្បីឆ្លើយតបចំពោះផលប៉ះពាល់ពាក់ព័ន្ធនឹងការសាងសង់។ SEMP ទាំងនេះ អាចមាន ដូចជា ផែនការគ្រប់គ្រងសម្រាប់ជំរកម្មករ, ផែនការគ្រប់គ្រងសម្រាប់ប្រតិបត្តិការសាងសង់ទាំងមូល ផែនការគ្រប់គ្រងសំណល់រឹង និងទឹកស្អុយ, ផែនការសម្រាប់គ្រប់គ្រងសម្រាលសំឡេងរំខាន និងធូលី, ផែនការសម្រាប់គ្រប់គ្រង និងសម្រាលផលប៉ះពាល់ចំពោះរុក្ខជាតិ និងសត្វព្រៃ, ផែនការសម្រាប់ស្តារតំបន់ទេសភាពបរិស្ថាន និងផែនការដទៃទៀត។ SEMP ទាំងនេះ ត្រូវពិនិត្យ និងអនុម័តដោយទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ និងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) មុនពេលចាប់ផ្តើមការសាងសង់។

26. ក្រុមហ៊ុនម៉ៅការត្រូវតែងតែមន្ត្រីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថាន (SEO) ដោយធ្វើការងារពេញម៉ោងនៅការដ្ឋានសាងសង់ ដើម្បីពិនិត្យតាមដានការអនុវត្តផែនការទាំងនេះផ្ទាល់។ មន្ត្រីទទួលបន្ទុកសុវត្ថិភាព និងបរិស្ថានចាំបាច់ត្រូវបង្កើតសៀវភៅកត់ត្រាសម្រាប់ពិនិត្យតាមដាន និងត្រួតពិនិត្យផ្ទៃក្នុង និងត្រូវរាយការណ៍ជាប់ជាប្រចាំអំពីលទ្ធផលផ្នែកបរិស្ថានរបស់ក្រុមហ៊ុនម៉ៅការដូចដែលត្រូវបានតម្រូវនៅក្នុងកិច្ចសន្យា។

*ទីប្រឹក្សាគ្រប់គ្រងការងារសាងសង់៖*

27. ទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ត្រូវពិនិត្យលើការងារជាក់ស្តែង ដូចជា ការពិនិត្យតាមដានជាប្រចាំថ្ងៃ លើវឌ្ឍនភាពនៃការងារសាងសង់ ការអនុវត្តតាមលក្ខខណ្ឌតាមកិច្ចសន្យា ការអនុវត្តតាមសេចក្តីពិពណ៌នាកំណត់ការវាស់វែងការងារជាមួយនឹងតំណាងរបស់របស់ក្រុមហ៊ុនម៉ៅការ ការត្រួតពិនិត្យគុណភាពនៅក្នុងទម្រង់ជាការធ្វើតេស្តលើសម្ភារៈក្នុងមន្ទីរពិសោធន៍ និងក្នុងការដ្ឋានជាក់ស្តែង ការចេញលិខិតបញ្ជាក់លើការងារដែលបានធ្វើហើយ ការរៀបចំវិញ្ញាបនបត្របញ្ជាក់ការទូទាត់អន្តរកាល ការត្រួតពិនិត្យលើសម្ភារៈ និងឧបករណ៍នៅនឹងការដ្ឋាន ការចេញការណែនាំនៅនឹងការដ្ឋាន និងបញ្ជាផ្លាស់ប្តូរការងារ និងការដោះស្រាយវិវាទនានា (ដោយមជ្ឈត្តិការដោយការផ្សះផ្សា។ល។)។

28. ទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ ទទួលខុសត្រូវពិនិត្យលើការអនុវត្តវិធានការសម្រាលផលប៉ះពាល់នានា ដែលធ្វើឡើងដោយក្រុមហ៊ុនម៉ៅការជាប្រចាំថ្ងៃ ដូចដែលត្រូវបានតម្រូវដោយលក្ខខណ្ឌក្នុងកិច្ចសន្យា។ អ្នកឯកទេសផ្នែកបរិស្ថាននៃទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ ត្រូវរៀបចំវិធីសាស្ត្រ និងបង្កើតឧបករណ៍សមស្របសម្រាប់ពិនិត្យលើភាពអនុលោមតាម EMP។ កាន់តែជាក់លាក់ទៅទៀតនោះ ទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ ត្រូវពិនិត្យលើការរៀបចំ និងការអនុវត្ត SEMP។ ទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ ក៏ត្រូវរក្សាសៀវភៅកត់ត្រាការពិនិត្យលើបរិស្ថានជាប្រចាំថ្ងៃផងដែរ។ បន្ថែមពីលើសការពិនិត្យ EMP ទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ អាចទទួលភារកិច្ចអនុវត្តសកម្មភាពផ្សេងទៀត ក្នុងអំឡុងដំណាក់កាលសាងសង់ ដើម្បីបង្កើតសមត្ថភាពគ្រប់គ្រងបរិស្ថានរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) និងក្រុមហ៊ុនម៉ៅការ។

### ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs)៖

29. ម្ចាស់គម្រោងជាអ្នកទទួលខុសត្រូវចុងក្រោយលើលទ្ធផលផ្នែកបរិស្ថានរបស់គម្រោង។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) តំណាងម្ចាស់គម្រោង ជាអ្នកទទួលខុសត្រូវលើការពិនិត្យតាមដាន ការអនុវត្តគម្រោងទាំងមូល ដូចជា ភាពអនុលោមផ្នែកបរិស្ថានរបស់គម្រោងក្នុងអំឡុងដំណាក់កាលសាងសង់ជាដើម។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ត្រូវទទួលខុសត្រូវចុងក្រោយ លើការអនុវត្ត EMP និងលទ្ធផលបរិស្ថានរបស់គម្រោង ក្នុងអំឡុងដំណាក់កាលសាងសង់ និងដំណាក់កាលប្រតិបត្តិការ។

30. កាន់តែជាក់លាក់ទៅទៀតនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ត្រូវ៖ i) ធ្វើការសម្របសម្រួលឱ្យបានជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន

ដែលមានការចូលរួមពីសហគមន៍ក្នុងអំឡុងពេលអនុវត្តគម្រោង, ii) ពិនិត្យតាមដាន និងពិនិត្យលើការអនុវត្ត EMP រួមនឹងការបញ្ចូល EMP ទៅក្នុងការរៀបចំបច្ចេកទេសលម្អិត និងឯកសារដេញថ្លៃ និងឯកសារកិច្ចសន្យានានា, iii) ធានាថាប្រព័ន្ធគ្រប់គ្រងបរិស្ថាន ត្រូវបានបង្កើតឡើង និងដំណើរការបានត្រឹមត្រូវ, iv) ទទួលខុសត្រូវរៀបចំរបាយការណ៍ស្តីពីការអនុវត្ត EMP ដាក់ជូនម្ចាស់គម្រោង និងធនាគារពិភពលោក។

31. ដើម្បីឱ្យអនុវត្តដំណើរការទៅប្រកបដោយប្រសិទ្ធភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ត្រូវបង្កើតអង្គភាពបរិស្ថាន (EU) មួយ ដូចលើកឡើងខាងលើ ដោយត្រូវមានបុគ្គលិកបរិស្ថានយ៉ាងហោចណាស់ពីរនាក់ ដើម្បីជួយការងារបរិស្ថានរបស់គម្រោង។ អង្គភាពបរិស្ថានទទួលខុសត្រូវពិនិត្យតាមដានលើការអនុវត្តគោលនយោបាយការពារផលប៉ះពាល់បរិស្ថានរបស់ធនាគារពិភពលោក ក្នុងដំណាក់កាលសាងសង់។ កាន់តែជាក់លាក់ទៅទៀតនោះ អង្គភាពនេះ ត្រូវទទួលខុសត្រូវលើះ i) ពិនិត្យឡើងវិញលើរបាយការណ៍ ដែលដាក់ដោយក្រុមហ៊ុនម៉ៅការ ទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ និងទីប្រឹក្សាពិនិត្យតាមដានបរិស្ថានឯករាជ្យ ដើម្បីធានាគុណភាពនៃរបាយការណ៍ទាំងនេះ និងចាត់វិធានការ ដូចដែលត្រូវបានលើកជាអនុសាសន៍ក្នុងរបាយការណ៍ទាំងនេះ, ii) ចុះពិនិត្យដល់ការដ្ឋានតាមកាលកំណត់, iii) ផ្តល់ដំបូន្មានដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) អំពីដំណោះស្រាយចំពោះបញ្ហាបរិស្ថានរបស់គម្រោង និង iv) រៀបចំផ្នែកលទ្ធផលបរិស្ថានក្នុងរបាយការណ៍វឌ្ឍនភាព និងរបាយការណ៍ពិនិត្យឡើងវិញ ដើម្បីដាក់ជូនម្ចាស់គម្រោង និងធនាគារ។

32. អង្គភាពបរិស្ថានអាចប្រើប្រាស់ទម្រង់ពិនិត្យលើ EMP របស់ទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ ដើម្បីរៀបចំទម្រង់សរុបរួម សម្រាប់ពិនិត្យតាមដានលើការអនុវត្ត EMP។

## V. ការរៀបចំរបាយការណ៍

### *5.1. ការរៀបចំរបាយការណ៍ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs)*

34. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ទទួលខុសត្រូវធ្វើការពិនិត្យឱ្យបានល្អិតល្អន់លើរបាយការណ៍ទាំងនេះ និងធានាគុណភាពរបាយការណ៍ទាំងនេះ មុនដាក់ជូនធនាគារ ដើម្បីសុំការមិនជំទាស់។ កន្លងមកមានការអនុវត្តមិនល្អដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធមួយចំនួន (PTs) គ្រាន់តែបន្តបញ្ជូនរបាយការណ៍របស់ទីប្រឹក្សាទៅកាន់ធនាគារ ដោយពុំបានពិនិត្យលើរបាយការណ៍នោះឡើយ។ ជាការសំខាន់ណាស់ដែល PCO ត្រូវពិនិត្យលើលទ្ធផលរកឃើញក្នុងរបាយការណ៍ ដើម្បីចាត់វិធានការ និងធ្វើការតាមដានបន្តលើបញ្ហាការពារផលប៉ះពាល់នានា និងភាពមិនអនុលោមទៅតាម EMP ដោយក្រុមហ៊ុន ម៉ៅការចាំបាច់ត្រូវចាត់វិធានការកែតម្រូវ។

*<u>របាយការណ៍ប្រចាំឆមាស</u>*

38. ក្នុងអំឡុងពេលអនុវត្តគម្រោង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ត្រូវរាយការណ៍អំពីភាពអនុលោមទៅតាមវិធានការ ដែលបានឯកភាពជាមួយនឹងធនាគារ ផ្អែកតាមលទ្ធផលរកឃើញ និងលទ្ធផលនៃការវាយតម្លៃបរិស្ថាន រួមនឹងការអនុវត្ត EMP ដូចដែលត្រូវបានលើកឡើងក្នុងឯកសារគម្រោង, (ខ) ស្ថានភាពនៃវិធានការសម្រាលផលប៉ះពាល់ និង (គ) លទ្ធផលរកឃើញនៃកម្មវិធីពិនិត្យតាមដាន។

39. កាន់តែជាក់លាក់ទៅទៀតនោះនោះ របាយការណ៍វឌ្ឍនភាព ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ផ្ញើជូនធនាគារ មុនពេលចុះការបេសកកម្មរបស់ធនាគារ ត្រូវបញ្ចូលព័ត៌មានឱ្យបានគ្រប់គ្រាន់អំពីះ

i) ការរៀបចំ និងការបង្ហាញឧបករណ៍ការពារផលប៉ះពាល់បរិស្ថានសម្រាប់អនុគម្រោង

ii) ការបញ្ចូល EMP របស់អនុគម្រោងថ្មីៗទៅក្នុងឯកសារដេញថ្លៃ និងឯកសារកិច្ចសន្យា

iii) ការតាមដាន និងការពិនិត្យលើការអនុវត្ត EMP ដោយក្រុមហ៊ុនម៉ៅការ វិស្វករគ្រប់គ្រងការសាសងសង់ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs)

iv) ស្ថានភាពនៃភាពអនុលោមទៅតាមវិធានការសម្រាលផលប៉ះពាល់ក្នុង EMP និង

v) បញ្ហាប្រឈមនានាដែលជួបប្រទះក្នុងការអនុវត្តការការពារផលប៉ះពាល់ ដំណោះស្រាយ និងមេរៀនដែលទទួលបាន។

*ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ*

40. ក្នុងអំឡុងពេលពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ (MTR), ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ត្រូវៈ

- ✓ វាយតម្លៃលើផលប៉ះពាល់ ដែលកើតឡើងដោយសារការផ្លាស់ប្តូរការរៀបចំគម្រោង ឬសមាសភាគថ្មីៗ ដែលត្រូវបានដាក់ឱ្យអនុវត្ត បន្ទាប់ពីការកែសម្រួលរចនាសម្ព័ន្ធគម្រោងរួច និងប្រសិនបើចាំបាច់ ត្រូវឯកភាពលើផែនការគ្រប់គ្រងការការពារផលប៉ះពាល់ ដែលបានកែសម្រួលលក្ខខណ្ឌតម្រូវសម្រាប់ពិនិត្យតាមដាន និងសម្រាប់រៀបចំរបាយការណ៍។
- ✓ យកចិត្តទុកដាក់ជាពិសេស (MTR) ចំពោះបញ្ហានៃភាពមិនអនុលោម។ ក្នុងករណីដែលមានភាពមិនអនុលោម ឬបញ្ហាការពារផលប៉ះពាល់ដែលពុំបានដោះស្រាយ ត្រូវលើកស្នើវិធានការបន្ថែមជូនធនាគារ។
- ✓ ឯកភាពលើការកែសម្រួលផែនការគ្រប់គ្រងវិធានការការពារផលប៉ះពាល់ លក្ខខណ្ឌតម្រូវសម្រាប់ការពិនិត្យតាមដាន និងការរៀបចំរបាយការណ៍ ប្រសិនបើពាក់ព័ន្ធ។
- ✓ ចងក្រងទុកជាឯកសារនូវបញ្ហាទាំងនេះ ក្នុងរបាយការណ៍វឌ្ឍនភាពសម្រាប់ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិសម្រាប់ដាក់ជូនធនាគារ។

*របាយការណ៍ស្តីពីការបញ្ចប់ការអនុវត្តគម្រោង និងរបាយការណ៍លទ្ធផល*

41. បន្ទាប់ពីបញ្ចប់គម្រោង ឬនៅក្នុងករណីមានការផ្តល់ហិរញ្ញប្បទានបន្ថែមមួយចំនួន ឬក្នុងករណីគម្រោងអនុវត្តជាសេរីបន្តបន្ទាប់ មុនពេលបញ្ចប់គម្រោង ធនាគាររៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការបញ្ចប់គម្រោង (ICR)។ របាយការណ៍លទ្ធផលនៃការបញ្ចប់គម្រោងលើកឡើងពីកម្រិតនៃការសម្រេចបាន នូវគោលបំណងនៃការអភិវឌ្ឍគម្រោង និងលទ្ធផលគម្រោង និងលទ្ធផលជារួមរបស់គម្រោងដោយធ្វើការពិចារណាពីបរិយាកាស ដែលគម្រោងប្រតិបត្តិការ។ របាយការណ៍លទ្ធផលបញ្ចប់គម្រោងបញ្ចូលការវាយតម្លៃរបស់អ្នកខ្ចីកម្ចីលើគម្រោង លទ្ធផលការងារផ្ទាល់របស់អ្នកខ្ចីកម្ចី និងលទ្ធផលការងាររបស់ធនាគារប្រសិនបើមាន។

42. អ្នកខ្ចីកម្ចីទទួលខុសត្រូវលើការរៀបចំរបាយការណ៍បញ្ចប់គម្រោង និងការដាក់របាយការណ៍នេះជូនធនាគារ។ របាយការណ៍បញ្ចប់គម្រោង ឬរបាយការណ៍សង្ខេប ត្រូវបញ្ចូលផ្នែកមួយស្តីពីភាពអនុលោមទៅតាមវិធានការការពារផលប៉ះពាល់ រួមនឹងផ្នែកដទៃទៀត។ គោលបំណងជារួមនៃផ្នែកនេះគឺដើម្បីពិនិត្យលើលទ្ធផលនៃការការពារផលប៉ះពាល់ និងមេរៀនដែលទទួលបាន។ ផ្នែកនេះសង្ខេបពីៈ

(១) បញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការពារផលប៉ះពាល់នៅក្នុងប្រតិបត្តិការគម្រោង

(២) ភាពអនុលោមទៅតាមគោលនយោបាយស្តីពីការការពារផលប៉ះពាល់របស់ធនាគារ និងលក្ខខណ្ឌតម្រូវផ្នែកនីតិវិធីរបស់ធនាគារ

(៣) បញ្ហាដែលកើតមានឡើង និងដំណោះស្រាយដែលពាក់ព័ន្ធ និង

(៤) ការដាកចេញគួរឱ្យកត់សម្គាល់ ឬការលើកលែងចេញពីគោលនយោបាយ និងនីតិវិធីស្តីពីការការពារផលប៉ះពាល់/ហានិភ័យនៃការប្រើប្រាស់ថវិកាមិនចំគោលដៅ (fiduciary risk) របស់ ធនាគារ។

### 5.2. ការរៀបចំរបាយការណ៍ដោយទីប្រឹក្សាគ្រប់គ្រងការងារសាងសង់

35. លក្ខខណ្ឌតម្រូវសម្រាប់រៀបចំរបាយការណ៍ រួមនឹងរបាយការណ៍ស្តីពីការចាប់ផ្តើមគម្រោង និងរបាយការណ៍ពិនិត្យគម្រោង ព្រមទាំងមាតិកា និងភាពញឹកញាប់ក្នុងការដាក់របាយការណ៍នេះ ដែលទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ត្រូវបំពេញ គួរបញ្ជាក់ឱ្យបានច្បាស់ក្នុងលក្ខខណ្ឌការងារ (TORs) សម្រាប់ទីប្រឹក្សា។ ខុសពីទីប្រឹក្សាគ្រប់គ្រងបរិស្ថានឯករាជ្យ ទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ទទួលខុសត្រូវពិនិត្យលើការអនុវត្ត EMP ជាប្រចាំថ្ងៃរបស់ក្រុមហ៊ុនម៉ៅការ។ ដូច្នេះជាធម្មតាទីប្រឹក្សានេះត្រូវផ្ញើរបាយការណ៍ប្រចាំសប្តាហ៍ និងប្រចាំខែ ទៅកាន់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs)។ លើសពីនេះ ទីប្រឹក្សាគ្រប់គ្រងការងារសាងសង់អាចរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ទៅតាមករណីជាក់ស្តែងអំពីភាពមិនអនុលោម ដែលត្រូវការការយកចិត្តទុកដាក់ជាបន្ទាន់ពីម្ចាស់គម្រោង។

36. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ (PTs) ត្រូវយកចិត្តទុកដាក់ជាពិសេសក្នុងការពិនិត្យលើលទ្ធផលរកឃើញ ដែលត្រូវបានបញ្ចូលក្នុងរបាយការណ៍របស់ទីប្រឹក្សាគ្រប់គ្រងការងារសាងសង់ស្តីពីការអនុវត្ត EMP សម្រាប់ចាត់វិធានការ និងការតាមដានបន្តលើបញ្ហាការពារផលប៉ះពាល់ និងភាពមិនអនុលោមតាម EMP ដែលក្រុមហ៊ុនម៉ៅការចាំបាច់ត្រូវធ្វើការកែតម្រូវ។

### 5.3. ការរៀបចំរបាយការណ៍ដោយក្រុមហ៊ុនម៉ៅការ

37. ក្រុមហ៊ុនម៉ៅការរៀបចំរបាយការណ៍ធៀបនឹងលក្ខខណ្ឌនានា ដែលត្រូវបានដាក់ចេញនៅក្នុងកិច្ចសន្យា ដែលក្នុងនោះក៏មានបញ្ចូលការរៀបចំរបាយការណ៍ស្តីពីការអនុវត្ត និងភាពអនុលោមទៅតាម EMP ផងដែរ។

ឧបសម្ព័ន្ធទី ៧៖ លក្ខខណ្ឌការងារសម្រាប់ទីប្រឹក្សាគ្រប់គ្រងការការពារផលប៉ះពាល់បរិស្ថាន និងទីប្រឹក្សាគ្រប់គ្រងការការពារផលប៉ះពាល់សង្គម

A. លក្ខខណ្ឌការងារ

ទីប្រឹក្សាគ្រប់គ្រងការការពារផលប៉ះពាល់បរិស្ថាន ឬទីប្រឹក្សាគ្រប់គ្រងការងារសាងសង់

គោលបំណងនៃការងារនេះ

1. ការងារនេះមានគោលបំណងជានាឱ្យមានការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) របស់គម្រោងប្រកដោយជោគជ័យ និងផ្តល់ឱ្យទីភ្នាក់ងារអនុវត្តៈ ដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម និងការគាំទ្រសម្រាប់ការអនុវត្ត ESMF ការពិនិត្យតាមដាន ការរៀបចំរបាយការណ៍ និងការបំពេញតម្រូវការកសាងសមត្ថភាពនានា។

តួនាទី និងការទទួលខុសត្រូវ

**2. ទីប្រឹក្សាត្រូវ**ជួយគាំទ្រដល់គ្រប់សកម្មភាពទាំងអស់ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវ ដែលត្រូវបានកំណត់ក្នុង ESMF។ ទីប្រឹក្សាត្រូវផ្តល់សេវាបច្ចេកទេសកម្រិតវិជ្ជាជីវៈ ដើម្បីជានាឱ្យមានភាពអនុលោមទៅតាមការការពារផលប៉ះពាល់បរិស្ថាន ក្នុងអំឡុងដំណាក់កាលរៀបចំ និងអនុវត្តគម្រោងកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ។ កាន់តែជាក់លាក់ទៅទៀតនោះ ទីប្រឹក្សាត្រូវទទួលខុសត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- ក. ជានាថា ខ្លឹមសារក្នុង ESMF ត្រូវបានបញ្ចូលទៅក្នុងការរៀបចំ ការអនុវត្ត ការពិនិត្យតាមដាន និងការរៀបចំរបាយការណ៍របស់អនុគម្រោង និងសម្របសម្រួលជាមួយនឹងក្រុមការងារ (task team) របស់ធនាគារពិភពលោក ដើម្បីផ្តួចផ្តើមជានាឱ្យមានការបញ្ចូលកត្តាការពារផលប៉ះពាល់បរិស្ថានឱ្យបានគ្រប់ជ្រុងជ្រោយ។
- ខ. ផ្តល់ការត្រួតពិនិត្យបច្ចេកទេស សម្រាប់ពិនិត្យលើអនុគម្រោង ដែលត្រូវបានកំណត់ក្រោមគម្រោងនេះ ដោយជានាយ៉ាងណាឱ្យដំណើរការពិនិត្យគម្រោងគោរពទៅតាម ESMF និងផ្តល់ដំបូន្មានអំពីឧបករណ៍ការពារផលប៉ះពាល់សម្រាប់ទីតាំងជាក់លាក់ ដែលតម្រូវឱ្យមានដូចជា ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) សម្រាប់អនុគម្រោងជាដើម។
- គ. ផ្តល់ការត្រួតពិនិត្យបច្ចេកទេស ការណែនាំ និងការត្រួតពិនិត្យគុណភាពសម្រាប់រៀបចំបំពេញទៅតាមលក្ខខណ្ឌតម្រូវផ្នែកការពារផលប៉ះពាល់បរិស្ថានសម្រាប់អនុគម្រោង។
- ឃ. ជួយដល់ទីភ្នាក់ងារអនុវត្ត ពិនិត្យឡើងវិញលើសំណើរបស់ក្រុមហ៊ុនម៉ៅការពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវផ្នែកការពារផលប៉ះពាល់បរិស្ថាន និងកំណត់ពីចំណុចខ្វះខាតដែលពុំត្រូវបានបញ្ចូលទៅក្នុងវិធានការ និង/ឬចរិកាសម្រាប់អនុវត្តវិធានការសម្រាលផលប៉ះពាល់បរិស្ថាន ដែលត្រូវបានលើកស្នើឡើង។
- ង. វាយតម្លៃលើសមត្ថភាពពិនិត្យបឋមលើការការពារផលប៉ះពាល់ ការអនុវត្ត និងការពិនិត្យ/តាមដានដែលធ្វើឡើងដោយមន្ត្រីបង្គោលទទួលបន្ទុកការពារផលប៉ះពាល់ និងបុគ្គលិកពាក់ព័ន្ធដទៃទៀតរបស់ទីភ្នាក់ងារអនុវត្ត, រៀបចំផែនការបណ្តុះបណ្តាលដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ, ផ្តល់ការបណ្តុំបណ្តាល និងការពិនិត្យការងារ ជាពិសេសក្នុងការរៀបចំ និងការអនុវត្តឧបករណ៍ការពារផលប៉ះពាល់បរិស្ថានឱ្យបានគ្រប់ជ្រុងជ្រោយរាប់បញ្ចូលទាំង ESMP ផងដែរ។
- ច. គាំទ្រដល់ការរៀបចំ និងការអនុវត្តកម្មវិធីបណ្តុះបណ្តាលស្តីពីការការពារផលប៉ះពាល់បរិស្ថានសម្រាប់គម្រោងដែលត្រូវសម្របសម្រួលជាមួយនឹងគំនិតផ្តួចផ្តើមកសាងសមត្ថភាព ស្តីពីការការពារផលប៉ះពាល់ផ្សេងទៀត។

ឆ. ជួយដល់ទីភ្នាក់ងារអនុវត្តក្នុងការជំរុញឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ និងសហគមន៍ ដូចជា ជួយបង្កើតយន្តការដោះស្រាយបណ្តឹងសារទុក្ខ (GRM) ដើម្បីធានាឱ្យយន្តការនេះដំណើរការទៅប្រកបដោយប្រសិទ្ធភាព។

ជ. ធានាថា អនុសាសន៍របស់ធនាគារពិភពលោកស្តីពីការអនុវត្តការការពារផលប៉ះពាល់បរិស្ថាន ត្រូវបានយកទៅអនុវត្ត និងមានការរៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសាសន៍ទាំងនេះ។

ឈ. សម្របសម្រួលជាមួយនឹងមន្ត្រីបង្គោល និងវិស្វករទទួលបន្ទុកការការពារផលប៉ះពាល់បរិស្ថាន ដើម្បីពិនិត្យ និងផ្តល់ការអនុម័តដល់ ESMP សម្រាប់អនុគម្រោងរបស់ក្រុមហ៊ុនម៉ៅការ។

ញ. ពិនិត្យលើលទ្ធផលនៃការបំពេញការងាររបស់ក្រុមហ៊ុនម៉ៅការ និងដោះស្រាយបញ្ហាបរិស្ថាន និងសង្គមដែលកើតមាននៅតាមទីតាំងជាក់ស្តែង និងផ្តល់ការណែនាំកែតម្រូវ ប្រសិនបើចាំបាច់។

ដ. រៀបចំរបាយការណ៍ពិនិត្យតាមដានបរិស្ថានតាមកាលកំណត់ ដូចជា របាយការណ៍ស្តីពីស្ថានភាព និងការអនុវត្ត ESMP និងរៀបចំរបាយការណ៍ពិនិត្យលើការអនុវត្តការការពារបរិស្ថាន ក្នុងអំឡុងដំណាក់កាលអនុវត្ត និង

ឋ. បំពេញភារកិច្ចផ្សេងទៀត ដែលតម្រូវដោយគម្រោង។

លក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការជ្រើសរើស

ក. យ៉ាងហោចណាស់មានសញ្ញាបត្របរិញ្ញាបត្រផ្នែកការគ្រប់គ្រងបរិស្ថាន វិស្វកម្មបរិស្ថាន វិទ្យាសាស្ត្រសង្គម ឬនគរូបនីយកម្ម ឬជំនាញពាក់ព័ន្ធ។

ខ. យ៉ាងហោចណាស់មានបទពិសោធន៍រយៈពេល ៥ ឆ្នាំ ពាក់ព័ន្ធនឹងភាពអនុលោម ទៅតាមគោលនយោបាយស្តីពីការពារផលប៉ះពាល់បរិស្ថាន រួមនឹងការគ្រប់គ្រង ហានិភ័យបរិស្ថាន។

គ. មានបទពិសោធន៍សម្របសម្រួលការពិភាក្សាក្រុម ដោយអាទិភាពនឹងផ្តល់ដល់បេក្ខជន ដែលមានបទពិសោធន៍បែបនេះ ក្នុងវិស័យសាធារណៈ។

ឃ. មានជំនាញទំនាក់ទំនងជាលក្ខណៈសំណេរ និងផ្ទាល់មាត់ ភាសអង់គ្លេស និងភាសាខ្មែរ បានស្ទាត់ជំនាញ

ង. មានចំណេះដឹង និងបទពិសោធន៍ការងារជាមួយនឹងគោលនយោបាយការពារផលប៉ះពាល់ បរិស្ថានរបស់ធនាគារពិភពលោក និង/ឬធនាគារអភិវឌ្ឍន៍អាស៊ី ជាគុណសម្បត្តិ។

ពេលវេលា

3. ការងារនេះមានរយៈពេល ១២ ខែ ដោយអាចបន្តទៀត អាស្រ័យទៅតាមការវាយតម្លៃលើ លទ្ធផលការងារ។

ការរៀបចំការអនុវត្ត

4. ទីប្រឹក្សាត្រូវរាយការណ៍ផ្ទាល់ទៅកាន់ប្រធានគម្រោង/អាជ្ញាធរ ដែលបានទទួលប្រតិភូកម្ម និងត្រូវ ធ្វើការងារយ៉ាងជិតស្និទ្ធជាមួយនឹងមន្ត្រីទទួលបន្ទុកការពារផលប៉ះពាល់បរិស្ថាន និងសង្គមរបស់ទីភ្នាក់ងារអនុវត្ត ក៏ដូចជា ទីប្រឹក្សាការពារផលប៉ះពាល់សង្គម ដែលនឹងត្រូវជ្រើសរើស។ ទីប្រឹក្សានេះ ត្រូវធ្វើការងារនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តល់ការិយាល័យ ព្រមទាំងការភ្ជាប់អ៊ីនធឺណែត។ល។ ទីប្រឹក្សាត្រូវមានកុំព្យូទ័រផ្ទាល់ខ្លួន ដើម្បីធ្វើការងារនេះ។

## B. លក្ខខណ្ឌការងារ ទីប្រឹក្សាគ្រប់គ្រងផលប៉ះពាល់សង្គម

គោលបំណងនៃការងារនេះ

1. ការងារនេះមានគោលបំណងធានាឱ្យមានការអនុវត្តការការពារផលប៉ះពាល់សង្គម រាប់បញ្ចូលទាំងក្របខ័ណ្ឌគោលនយោបាយស្តីពីការដោះស្រាយផលប៉ះពាល់/ការតាំងទីលំនៅ (RPF) និងក្របខ័ណ្ឌគោលនយោបាយជនជាតិដើមភាគតិច (IPPF) របស់គម្រោងប្រកដោយជោគជ័យ។ ការងារនេះក៏មានគោលបំណងផ្តល់ឱ្យទីភ្នាក់ងារអនុវត្តៈ ដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម និងការគាំទ្រសម្រាប់ការអនុវត្ត RPF ការពិនិត្យតាមដាន ការរៀបចំរបាយការណ៍ និងការបំពេញតម្រូវការកសាងសមត្ថភាពនានា។

តួនាទី និងការទទួលខុសត្រូវ

**2.** **ទីប្រឹក្សាត្រូវ**ជួយគាំទ្រដល់គ្រប់សកម្មភាពទាំងអស់ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវ ដែលត្រូវបានកំណត់ក្នុង RPF។ ទីប្រឹក្សាត្រូវផ្តល់សេវាបច្ចេកទេសកម្រិតវិជ្ជាជីវៈ ដើម្បីធានាឱ្យមានភាពអនុលោមទៅតាមការការពារផលប៉ះពាល់បរិស្ថាន ក្នុងអំឡុងដំណាក់កាលរៀបចំ និងអនុវត្តគម្រោងកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ។ កាន់តែជាក់លាក់ទៅទៀតនោះ ទីប្រឹក្សាត្រូវទទួលខុសត្រូវបំពេញភារកិច្ចដូចខាងក្រោមៈ

ក. ធានាថា ខ្លឹមសារក្នុង RPF ត្រូវបានបញ្ចូលទៅក្នុងការរៀបចំ ការអនុវត្ត ការពិនិត្យតាមដាន និងការរៀបចំរបាយការណ៍របស់អនុគម្រោង និងសម្របសម្រួលជាមួយនឹងក្រុមការងារ (task team) របស់ធនាគារពិភពលោក ដើម្បីផ្តួចផ្តើមធានាឱ្យមានការបញ្ចូលកត្តាការពារផលប៉ះពាល់បរិស្ថានឱ្យបានគ្រប់ជ្រុងជ្រោយ។

ខ. ផ្តល់ការត្រួតពិនិត្យបច្ចេកទេស សម្រាប់ពិនិត្យលើអនុគម្រោង ដែលត្រូវបានកំណត់ក្រោមគម្រោងនេះ ដោយធានាយ៉ាងណាឱ្យដំណើរការពិនិត្យគម្រោងគោរពទៅតាម RPF និងផ្តល់ដំបូន្មានអំពីឧបករណ៍ការពារផលប៉ះពាល់សម្រាប់ទីតាំងជាក់លាក់ ដែលតម្រូវឱ្យមាន ដូចជា ផែនការគ្រប់គ្រងការការពារផលប៉ះពាល់សង្គម សម្រាប់អនុគម្រោងជាដើម។

គ. ផ្តល់ការត្រួតពិនិត្យបច្ចេកទេស ការណែនាំ និងការត្រួតពិនិត្យគុណភាពសម្រាប់រៀបចំ បំពេញទៅតាមលក្ខខណ្ឌតម្រូវផ្នែកការពារផលប៉ះពាល់សង្គម សម្រាប់អនុគម្រោង។

ឃ. ជួយដល់ទីភ្នាក់ងារអនុវត្ត ពិនិត្យឡើងវិញលើសំណើរបស់ក្រុមហ៊ុនម៉ៅការពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវផ្នែកការពារផលប៉ះពាល់សង្គម និងកំណត់ពីចំណុចខ្វះខាត ដែលពុំត្រូវបានបញ្ចូលទៅក្នុងវិធានការ និង/ឬថវិកាសម្រាប់អនុវត្តវិធានការសម្រាលផលប៉ះពាល់សង្គម ដែលត្រូវបានលើកស្នើឡើង។

ង. វាយតម្លៃលើសមត្ថភាពពិនិត្យបឋមលើការការពារផលប៉ះពាល់ ការអនុវត្ត និងការពិនិត្យ/តាមដានដែលធ្វើឡើងដោយមន្ត្រីបង្គោលទទួលបន្ទុកការពារផលប៉ះពាល់ និងបុគ្គលិកពាក់ព័ន្ធដទៃទៀតរបស់ទីភ្នាក់ងារអនុវត្ត, រៀបចំផែនការបណ្តុះបណ្តាល ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ, ផ្តល់ការបណ្តុំបណ្តាល និងការពិនិត្យការងារ ជាពិសេសក្នុងការរៀបចំ និងការអនុវត្តឧបករណ៍ការពារផលប៉ះពាល់សង្គមឱ្យបានគ្រប់ជ្រុងជ្រោយ រាប់បញ្ចូលទាំង ESMP ផងដែរ។

ច. គាំទ្រដល់ការរៀបចំ និងការអនុវត្តកម្មវិធីបណ្តុះបណ្តាលស្តីពីការការពារផលប៉ះពាល់សង្គម សម្រាប់គម្រោងដែលត្រូវសម្របសម្រួលជាមួយនឹងគំនិតផ្តួចផ្តើមកសាងសមត្ថភាព ស្តីពីការការពារផលប៉ះពាល់ផ្សេងទៀត។

ឆ. ជួយដល់ទីភ្នាក់ងារអនុវត្តក្នុងការជំរុញឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ និងសហគមន៍ ដូចជា ជួយបង្កើតយន្តការដោះស្រាយបណ្តឹងសារទុក្ខ (GRM) ដើម្បីធានាឱ្យយន្តការនេះដំណើរការ

ទៅប្រកបដោយប្រសិទ្ធភាព។

ជ. ធានាអនុសាសន៍របស់ធនាគារពិភពលោកស្តីពីការអនុវត្តការការពារផលប៉ះពាល់សង្គម ត្រូវបានយកទៅអនុវត្ត និងមានការរៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសាសន៍ទាំងនេះ។

ឈ. សម្របសម្រួលជាមួយនឹងមន្ត្រីបង្គោល និងវិស្វករទទួលបន្ទុកការការពារផលប៉ះពាល់សង្គម ដើម្បីពិនិត្យ និងផ្តល់ការអនុម័តដល់ ESMP សម្រាប់អនុគម្រោងរបស់ក្រុមហ៊ុនម៉ៅការ។

ញ. ពិនិត្យលើលទ្ធផលនៃការបំពេញការងាររបស់ក្រុមហ៊ុនម៉ៅការ និងដោះស្រាយបញ្ហាបរិស្ថាន និងសង្គមដែលកើតមាននៅតាមទីតាំងជាក់ស្តែង និងផ្តល់ការណែនាំកែតម្រូវ ប្រសិនបើចាំបាច់។

ដ. រៀបចំរបាយការណ៍ពិនិត្យតាមដានបរិស្ថានតាមកាលកំណត់ ដូចជា របាយការណ៍ស្តីពីស្ថានភាព និងការអនុវត្ត ESMP និងរៀបចំរបាយការណ៍ពិនិត្យលើការអនុវត្តការការពារបរិស្ថាន ក្នុងអំឡុងដំណាក់កាលអនុវត្ត និង

ឋ. បំពេញភារកិច្ចដទៃទៀត ដែលតម្រូវដោយគម្រោង។

លក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការជ្រើសរើស

ក. យ៉ាងហោចណាស់មានសញ្ញាបត្របរិញ្ញាបត្រផ្នែកការគ្រប់គ្រងសង្គម វិស្វកម្មសង្គម វិទ្យាសាស្ត្រសង្គម ឬ នគរូបនីយកម្ម ឬជំនាញពាក់ព័ន្ធ។

ខ. យ៉ាងហោចណាស់មានបទពិសោធន៍រយៈពេល ៥ ឆ្នាំ ពាក់ព័ន្ធនឹងភាពអនុលោមទៅតាមគោលនយោបាយស្តីពីការពារផលប៉ះពាល់សង្គម រួមនឹងការគ្រប់គ្រងហានិភ័យសង្គម។

គ. មានបទពិសោធន៍សម្របសម្រួលការពិភាក្សាក្រុម ដោយអាទិភាពនឹងផ្តល់ដល់បេក្ខជនដែលមានបទពិសោធន៍បែបនេះ ក្នុងវិស័យសាធារណៈ។

ឃ. មានជំនាញទំនាក់ទំនងជាលក្ខណៈសំណេរ និងផ្ទាល់មាត់ ភាសអង់គ្លេស និងភាសាខ្មែរបានស្ទាត់ជំនាញ។

ង. មានចំណេះដឹង និងបទពិសោធន៍ការងារជាមួយនឹងគោលនយោបាយការពារផលប៉ះពាល់សង្គមរបស់ធនាគារពិភពលោក និង/ឬធនាគារអភិវឌ្ឍន៍អាស៊ី ជាគុណសម្បត្តិ។

ពេលវេលា

3. ការងារនេះមានរយៈពេល ១២ ខែ ដោយអាចបន្តទៀត អាស្រ័យទៅតាមការវាយតម្លៃលើលទ្ធផលការងារ។

ការរៀបចំការអនុវត្ត

4. ទីប្រឹក្សាត្រូវរាយការណ៍ផ្ទាល់ទៅកាន់ប្រធានគម្រោង/អាជ្ញាធរដែលបានទទួលប្រតិភូកម្ម និងត្រូវធ្វើការងារយ៉ាងជិតស្និទ្ធជាមួយនឹងមន្ត្រីទទួលបន្ទុកការពារផលប៉ះពាល់បរិស្ថាន និងសង្គមរបស់ទីភ្នាក់ងារអនុវត្ត ក៏ដូចជា ទីប្រឹក្សាការពារផលប៉ះពាល់សង្គម ដែលនឹងត្រូវជ្រើសរើស។ ទីប្រឹក្សានេះ ត្រូវធ្វើការងារនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តល់ការិយាល័យ ព្រមទាំងការភ្ជាប់អ៊ិនធឺណែត។ល។ ទីប្រឹក្សាត្រូវមានកុំព្យូទ័រផ្ទាល់ខ្លួន ដើម្បីធ្វើការងារនេះ។

ឧបសម្ព័ន្ធទី ៨៖ ផែនការគ្រប់គ្រងសមាសភាគចង្រៃ

1. ផែនការគ្រប់គ្រងសមាសភាគចង្រៃ (ដែលហៅកាត់ថា PMP) មានគោលផ្តល់ចំណេះដឹងជាមូលដ្ឋានដល់រដ្ឋាភិបាលនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុក។ ក្រុមការងារនៃគម្រោង CASDP, ទីប្រឹក្សា, មន្ត្រីភូមិ, ទីភ្នាក់ងារវិស័យឯកជន និងវិស័យសាធារណៈ អមជាមួយនឹងការណែនាំគ្រប់ជ្រុងជ្រោយអំពីរបៀបឆ្លើយតបចំពោះបញ្ហាការពារផលប៉ះពាល់ ប្រកបដោយប្រសិទ្ធភាព ស្របតាមគោលនយោបាយ OP 4.09។ ដំណើរការនេះត្រូវអនុវត្តជាផ្នែកមួយនៃវដ្តគម្រោង CASDP និងត្រូវបញ្ចូលឱ្យបានពេញលេញទៅក្នុងដំណើរការនៃការជ្រើសរើស អនុម័ត ការអនុវត្ត និងការពិនិត្យតាមដាន និងការវាយតម្លៃអនុគម្រោង។ គម្រោង CASDP ពុំបានបញ្ចូលកិច្ចលទ្ធកម្មថ្នាំកសិកម្មឡើយ ប៉ុន្តែ ESMF កំណត់រកឃើញបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការប្រើប្រាស់ថ្នាំកសិកម្ម និងជីគីមីដែលកំពុងមានស្រាប់ និងបានកំណត់ពីវិធានការសម្រាលផលប៉ះពាល់ដែលចាំបាច់ សម្រាប់សារជាតុហាមឃាត់ ការបណ្តុះបណ្តាល និងគោលការណ៍ណែនាំស្តីពីការប្រើប្រាស់ និងការចោលថ្នាំកសិកម្មប្រកបដោយសុវត្ថិភាព។ PMP ត្រូវអនុវត្តចំពោះគ្រប់សកម្មភាពទាំងអស់របស់គម្រោង CASDP ដែលពាក់ព័ន្ធភាគច្រើនជាមួយនឹង៖

2. សមាសភាគ ក៖ បង្កើនប្រសិទ្ធភាព និងនិរន្តរភាពកសិកម្ម ដែលគាំទ្រដល់ (ក) ការប្រើប្រាស់ពូជល្អៗ និងគ្រាប់ពូជដែលមានគុណភាព, (ខ) លើកកម្ពស់ការអនុវត្តល្អផ្នែកសិកម្ម, (គ) ផ្តល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និង (ឃ) ពង្រឹងការផ្តល់សេវាសាធារណៈ។

3. នៅក្នុងករណីដែលសកម្មភាពក្រោមសមាសភាគ ខ អាចបង្កផលប៉ះពាល់ដោយសារការប្រើប្រាស់ថ្នាំកសិកម្ម និងការកាត់បន្ថយការប្រើប្រាស់ថ្នាំកសិកម្ម ផែនការគ្រប់គ្រងសមាសភាគចង្រៃ ក៏ត្រូវអនុវត្តចំពោះ៖

4. សមាសភាគ ខ៖ លើកកម្ពស់ពាណិជ្ជភាវូបនីយកម្មកសិកម្ម ដែលគាំទ្រដល់៖ (ក) ការបង្កើតកម្មវិធីសង្វាក់តម្លៃកសិកម្ម (AVCF), (ខ) ការភ្ជាប់ទំនាក់ទំនងកសិករជាមួយនឹងទីផ្សារ និង (គ) ការលើកកម្ពស់បរិយាកាសអំណោយផល។

5. ការចុះតាមភូមិបង្ហាញថា បច្ចុប្បន្ននេះកំពុងមានការប្រើប្រាស់ជីគីមី និងថ្នាំកសិកម្មក្នុងតំបន់គម្រោង ជាពិសេស នៅតាមតំបន់ដែលមានការដាំដុះដំណាំតែមួយមុខ។

6. ទីភ្នាក់ងារទទួលខុសត្រូវ៖ បុគ្គលិករបស់គម្រោង CASDP នៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ត្រូវទទួលខុសត្រូវលើការអនុវត្តផែនការគ្រប់គ្រងសមាសភាគចង្រៃ និងត្រូវធានាឱ្យមានការអនុលោមឱ្យបានពេញលេញ រួមនឹងត្រូវរក្សាទុកឯកសារឱ្យបានត្រឹមត្រូវ ក្នុងសំណុំឯកសាររបស់គម្រោង ដើម្បីឱ្យធនាគារពិភពលោកពិនិត្យឡើងវិញក្នុងករណីដែលមានការពិនិត្យឡើងវិញបែបនេះ។

7. ឯកសារនេះត្រូវបានចាត់ទុកថាជាឯកសាររស់ និងអាចកែសម្រួល និងធ្វើការផ្លាស់ប្តូរទៅតាមការសមស្រប។ លើសពីនេះក៏ចាំបាច់ត្រូវមានកិច្ចពិគ្រោះយោបល់ឱ្យបានជិតស្និទ្ធជាមួយធនាគារពិភពលោក និងចាំបាច់ត្រូវមានការអនុម័តលើផែនការគ្រប់គ្រងសមាសភាគចង្រៃ ដែលត្រូវបានកែសម្រួលរួចផងដែរ។

ផ្នែកទី I. គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

**គោលនយោបាយការពារផលប៉ះពាល់របស់ធនាគារពិភពលោក ដែលផ្តោតលើការគ្រប់គ្រងសមាសភាគចង្រៃ (OP 4.09)**

8. គោលនយោបាយ OP 4.09 (ការគ្រប់គ្រងសមាសភាគចង្រៃ)៖ គោលនយោបាយនេះតម្រូវឱ្យគម្រោងដែលត្រូវធ្វើលទ្ធកម្មថ្នាំកសិកម្មឱ្យរៀបចំ និងអនុវត្តផែនការគ្រប់គ្រងសមាសភាគចង្រៃ ដើម្បីធានាថា ការទុកដាក់ ការដឹកជញ្ជូន ការប្រើប្រាស់ និងការចោលថ្នាំកសិកម្ម ធ្វើឡើងប្រកបដោយសុវត្ថិភាពចំពោះមនុស្ស និងបរិស្ថាន។ គម្រោង CASDP មិនលើកទឹកចិត្តឱ្យមានការធ្វើលទ្ធកម្មថ្នាំកសិកម្ម ឬថ្នាំកម្ចាត់ស្មៅចង្រៃ ដែលផ្សំពីសារធាតុគីមីឡើយ។ ទោះជាយ៉ាងណាក៏ដោយ

ប្រសិនបើមានការរាតត្បាតដោយសមាសភាគចង្រៃ មានការអនុញ្ញាតឱ្យប្រើប្រាស់ថ្នាំកសិកម្ម ដែលបំពេញទៅតាមលក្ខណៈសមស្រប និងបានចុះបញ្ជីត្រឹមត្រូវក្នុងបរិមាណតិចតួចក្នុងខេត្ត គោលដៅរបស់គម្រោង ប្រសិនបើមានការបំពេញបន្ថែមដោយការបណ្តុះបណ្តាលកសិករ ដើម្បីឱ្យពួកគេអាចប្រើប្រាស់ថ្នាំកសិកម្មប្រកបដោយសុវត្ថិភាព ស្របតាមគោលនយោបាយរបស់ធនាគារពិភពលោក (OP 4.09)។ លើសពីនេះ ដោយសារតែគម្រោងនេះ ត្រូវបានរៀបចំឡើយ ដើម្បីជំរុញឱ្យមានការកាត់បន្ថយការប្រើប្រាស់ថ្នាំកសិកម្ម និងជីគីមីលើដីកសិដ្ឋានដែលមានស្រាប់ តាមរយៈការលើកកម្ពស់ការអនុវត្តការដាំដុះប្រកបដោយនិរន្តរភាព ផែនការគ្រប់គ្រងសមាសភាគចង្រៃក្នុងទម្រង់សាមញ្ញនេះ ត្រូវបានរៀបចំឡើង រួមនឹងបញ្ជីអវិជ្ជមានមួយ។ ខណៈពេលដែលគម្រោងនេះនឹងមិនធ្វើលទ្ធកម្ម និងជំរុញឱ្យមានការប្រើប្រាស់ថ្នាំកសិកម្ម និងជីគីមី ដែលត្រូវបានបញ្ចូលក្នុងបញ្ជីសារធាតុដែលពុំបំពេញតាមលក្ខណៈសមស្រប ការហាមឃាត់កសិករទាំងអស់មិនឱ្យប្រើប្រាស់សារធាតុគីមីសោះតែម្តង អាចមិនមែនជាអ្វីដែលអាចធ្វើបាននោះឡើយ។ កាន់តែជាក់លាក់ទៅទៀតនោះ ការងារស្តារប្រព័ន្ធស្រោចស្រព ការសាងសង់ប្រព័ន្ធស្រោចស្រពខ្នាតតូច/ផលិតកម្មកសិកម្ម និង/ឬការត្រួតពិនិត្យការចម្លងជំងឺ ប្រហែលជាទាមទារឱ្យមានការប្រើប្រាស់ថ្នាំកសិកម្ម ថ្នាំកម្ចាត់ស្មៅចង្រៃ និងថ្នាំកម្ចាត់សត្វល្អិត។ ដើម្បីកាត់បន្ថយផលប៉ះពាល់ដែលអាចកើតមានឡើងពីការប្រើប្រាស់សារធាតុទាំងនេះ ផែនការគ្រប់គ្រងសមាសភាគចង្រៃក្នុងទម្រង់សាមញ្ញបែបនេះ ត្រូវបានរៀបចំឡើងដោយបង្ហាញពីបទដ្ឋានគតិយុត្ត និងនីតិវិធីច្បាស់លាស់សម្រាប់គ្រប់គ្រងថ្នាំកសិកម្ម និង/ឬសារធាតុគីមីពុល ក៏ដូចជា ផ្តល់នូវចំណេះដឹង និងការបណ្តុះបណ្តាលអំពីផលប៉ះពាល់លើសុខភាព និងការប្រើប្រាស់ថ្នាំកសិកម្មប្រកបដោយសុវត្ថិភាព និង/ឬនៅក្នុងករណីដែលអាចធ្វើទៅបាន ជំរុញឱ្យមានការប្រើប្រាស់ជម្រើសផ្សេងទៀត ក្រៅពីការប្រើប្រាស់សារធាតុគីមី ដូចជា ការធ្វើសកម្មបែបសរីរាង្គជាដើម។ ផែនការគ្រប់គ្រងសមាសភាគចង្រៃក្នុងទម្រង់សាមញ្ញបែបនេះ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលិខិតបទដ្ឋានគតិយុត្តស្តីពីការត្រួតពិនិត្យថ្នាំកសិកម្មក្នុងប្រទេសកម្ពុជា (២០១៤) ក៏ដូចជា គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសមាសភាគចង្រៃចម្រុះ (IPM) ដែលផ្តល់ដោយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO)។

9. គម្រោង CASDP នឹងធ្វើការងារយ៉ាងជិតស្និទ្ធជាមួយវិស័យកសិកម្ម ដើម្បីអនុវត្តបច្ចេកវិទ្យាអភិរក្សកសិកម្ម ដែលអនុម័តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឆ្នាំ ២០០៦ សម្រាប់សកម្មភាពកសិកម្ម។ ផែនការគ្រប់គ្រងសមាសភាគចង្រៃនេះ ត្រូវបានអនុម័ត និងសម្រួលឱ្យស្រួលយល់ចេញពីផែនការគ្រប់គ្រងសមាសភាគចង្រៃ ដែលត្រូវបានរៀបចំឡើងសម្រាប់គម្រោង PRF III។

**លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងការគ្រប់គ្រងសមាសភាគចង្រៃ**

10. ការអនុវត្តការគ្រប់គ្រងសមាសភាគចង្រៃនៅក្នុងប្រទេសកម្ពុជា ត្រូវបានជំរុញ តាមរយៈការពង្រីកកម្មវិធីជាតិគ្រប់គ្រងសមាសភាគចង្រៃចម្រុះ (IPM) ដែលអនុវត្តដោយរដ្ឋាភិបាលផង និងអង្គការមិនមែនរដ្ឋាភិបាលផង។ ស្ថាប័នទាំងនេះបានសហការគ្នាបង្កើតបណ្តាញកាត់បន្ថយការប្រើប្រាស់ថ្នាំកសិកម្ម ដើម្បីបង្កើនការយល់ដឹងអំពីហានិភ័យពាក់ព័ន្ធនឹងការប្រើប្រាស់ថ្នាំកសិកម្មដល់កសិករ។

11. លើសពីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចូលរួមពិនិត្យ និងអនុវត្តគោលការណ៍ណែនាំ និងលិខិតុបករណ៍ច្បាប់អន្តរជាតិនានា ពាក់ព័ន្ធនឹងការធ្វើនិយតកម្មពាណិជ្ជកម្ម ការចែកចាយ និងការប្រើប្រាស់ថ្នាំកសិកម្មនៅកម្ពុជា។ ការអនុវត្តទាំងនេះ ក៏រាប់បញ្ចូលការសន្យា គោរពតាមក្រមសីលធម៌របស់ FAO ស្តីពីការចែកចាយ និងការប្រើប្រាស់ថ្នាំកសិកម្ម, អនុសញ្ញា Stockholm ស្តីពីការបន្តប្រើប្រាស់សារធាតុពុលសរីរាង្គ និងវិធានការអនាម័យ និងភូតគាមអនាម័យរបស់អង្គការពាណិជ្ជកម្មពិភពលោកផងដែរ។

12. បន្ទាប់ពីច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីគីមីត្រូវបានប្រកាសដាក់ឱ្យអនុវត្តតាមរយៈព្រះរាជក្រមលេខ ០១១២/០០៥ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១២ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំប្រកាសចំនួនប្រាំ ពាក់ព័ន្ធនឹងនីតិវិធីសម្រាប់ចុះបញ្ជី និងដំណើរការធុរកិច្ច ដូចខាងក្រោម៖

- ប្រកាសលេខ ៤១៥/កសក ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ស្តីពីនីតិវិធី និងលក្ខខណ្ឌតម្រូវស្តង់ដារសម្រាប់ការចុះបញ្ជីជីគីមី។
- ប្រកាសលេខ ៤៥៦/កសក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ស្តីពីនីតិវិធី និងលក្ខខណ្ឌតម្រូវស្តង់ដារសម្រាប់ការចុះបញ្ជីថ្នាំកសិកម្ម។
- ប្រកាសលេខ ៤៨៤/កសក ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ស្តីពីបញ្ជីថ្នាំកសិកម្មក្នុងព្រះរាជាណាចក្រកម្ពុជា។
- ប្រកាសលេខ ១១៩/កសក ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ស្តីពីនីតិវិធីសម្រាប់គ្រប់គ្រងជីគីមីសម្រាប់ដំណើរការអាជីវកម្ម។
- ប្រកាសលេខ ១២០/កសក ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ស្តីពីនីតិវិធីសម្រាប់គ្រប់គ្រងថ្នាំកសិកម្មសម្រាប់ដំណើរការអាជីវកម្ម។
- នាយកដ្ឋាននីតិកម្មកសិកម្ម និងអគ្គនាយកដ្ឋានកសិកម្មក្រោមចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចត្រួតពិនិត្យលើរាល់ការប្រើប្រាស់ថ្នាំកសិកម្មទាំងអស់។

**ការរៀបចំការអនុវត្ត និងថវិកា**

(ក) ការរៀបចំផែនការ និងការអនុវត្ត

13. បុគ្គលិករបស់គម្រោង CASDP នៅថ្នាក់ជាតិទទួលខុសត្រូវផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកគម្រោង CASDP នៅថ្នាក់ខេត្ត និងអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានក្នុងអំឡុងដំណាក់កាលពិគ្រោះយោបល់ និងរៀបចំផែនការ។ ថវិកាសម្រាប់ការបណ្តុះបណ្តាលនឹងត្រូវបញ្ចូលទៅក្នុងចំណាយរបស់អនុគម្រោង និងមានការកសាងសមត្ថភាពទៅតាមការសមស្រប។

(ខ) ការពិនិត្យតាមដាន

**14.** បុគ្គលិករបស់គម្រោង CASDP នឹង ក) ធានាថា ថ្នាំកសិកម្មដែលត្រូវបានធ្វើលទ្ធកម្មពុំមាននៅក្នុងបញ្ជីសារធាតុមិនសមស្រប ដូចបង្ហាញក្នុងឧសម្ព័ន្ធទី ១ ឡើយ, ខ) ធានាថាថ្នាំកសិកម្ម ដែលត្រូវបានធ្វើលទ្ធកម្ម ត្រូវបានរក្សាទុកយ៉ាងត្រឹមត្រូវ និងដឹកជញ្ជូនទៅកាន់តំបន់គោលដៅ, គ) ធានាឱ្យមានការផ្តល់ការបណ្តុះបណ្តាលដល់អ្នកប្រើប្រាស់មុនពេលចែកចាយ និង គ) ពិនិត្យតាមដានលើភាពអនុលោមនៃការប្រើប្រាស់ថ្នាំកសិកម្មទៅតាមបទបញ្ជារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ ២៨៦០/កសក **(ក្នុងឧបសម្ព័ន្ធទី ២)។** ក្រុមការងារធនាគារពិភពលោក និងក្រុមការងារគម្រោង CASDP នៅថ្នាក់កណ្តាល និងចុះបេសកកម្មគាំទ្រការអនុវត្តរួមគ្នារៀងរាល់ ៦ ខែម្តង ដើម្បីពិនិត្យលើភាពអនុលោម។ ធនាគារពិភពលោកនឹងប្រើប្រាស់សៀវភៅណែនាំស្តីពីការគ្រប់គ្រងសមាសភាគចង្រៃរបស់ខ្លួន ជាស្តង់ដារសម្រាប់ពិនិត្យតាមដានភាពអនុលោមនៃការប្រើប្រាស់ថ្នាំកសិកម្ម ដែលត្រូវបានធ្វើលទ្ធកម្ម ក្រោមគម្រោង។

## ឧបសម្ព័ន្ធទី ៩៖ ការគ្រប់គ្រងសមាសភាគចង្រៃចម្រុះ

1. ការគ្រប់គ្រងសមាសភាគចង្រៃចម្រុះ (IPM) សំដៅលើការពិចារណាល្អិតល្អន់អំពីគ្រប់បច្ចេកទេសត្រួតពិនិត្យសមាសភាគចង្រៃ ដែលមានទាំងអស់ និងការបញ្ចូលគ្នានូវវិធានការសមស្រប ដើម្បីបង្ការមិនឱ្យមានការកើនឡើងនូវចំនួនសមាសភាគចង្រៃ និងរក្សាការប្រើប្រាស់ថ្នាំកសិកម្ម និងអន្តរាគមន៍ដទៃទៀត ក្នុងកម្រិតដែលមានហេតុផលសមស្របផ្នែកសេដ្ឋកិច្ច និងកាត់បន្ថយ ឬកាត់បន្ថយឱ្យនៅជាអប្បបរមានូវហានិភ័យចំពោះសុខភាពមនុស្ស និងបរិស្ថាន។ IPM ផ្តោតការយកចិត្តទុកដាក់លើការបង្កើនដំណាំ ដែលមានសុខភាពល្អ និងបង្កការរំខានតិចតួចបំផុតដល់ប្រព័ន្ធអេកូឡូស៊ី និងលើកទឹកចិត្តឱ្យមានការប្រើប្រាស់យន្តការត្រួតពិនិត្យសមាសភាគចង្រៃបែបធម្មជាតិ។

2. ក្រោមចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មជ្ឈមណ្ឌលការពាររុក្ខជាតិ និងសាខានៅតាមបណ្តាខេត្ត ក៏ដូចជា មជ្ឈមណ្ឌលផ្សព្វផ្សាយកសិកម្មនៅថ្នាក់ស្រុក គឺជាអាជ្ញាធរដែលមានភារកិច្ចសម្របសម្រួល និងអនុវត្តកម្មវិធីគ្រប់គ្រងសមាសភាគចង្រៃចម្រុះ។ កម្មវិធីជាតិ IPM ត្រូវបានផ្តួចផ្តើមបង្កើតឡើងក្រោមជំនួយរបស់ FAO, DANIDA និងអ្នកផ្តល់ជំនួយដទៃទៀត ចាប់តាំងពីដើមទសវត្សរ៍ ១៩៩០ មកម្លេះ ហើយបច្ចុប្បន្ននេះ កំពុងអនុវត្តបន្តដោយប្រើប្រាស់ធនធានរបស់រដ្ឋាភិបាល។

3. សកម្មភាព IPM ដែលត្រូវបានអនុវត្តដោយអាជ្ញាធរមូលដ្ឋាន និងមានការគាំទ្របច្ចេកទេសពីអ្នកជំនាញមកពីអគ្គនាយកដ្ឋានកសិកម្ម រួមមាន ការចុះអង្កេតតាមមូលដ្ឋាន ការរៀបចំការព្យាករណ៍ ការពិនិត្យតាមដាន និងការពិនិត្យលើវឌ្ឍនភាពនៃការរីករាលសមាសភាគចង្រៃ នៅទីវាលផ្ទាល់។ ដោយប្រើប្រាស់ការព្យាករណ៍ ផ្អែកតាមពេលវេលា វិសាលភាព និងកម្រិតនៃការខូចខាត ដែលសមាសភាគចង្រៃសំខាន់ៗ អាចបង្កឱ្យមាន អាជ្ញាធរការពារុក្ខជាតិនៅថ្នាក់ខេត្ត ផ្តល់អនុសាសន៍ឱ្យមានការរៀបចំគោលនយោបាយ ផែនការ និងវិធានការសម្រាប់គ្រប់គ្រងសមាសភាគចង្រៃ។

4. អាជ្ញាធរទាំងនេះក៏បានផ្តល់ការបណ្តុះបណ្តាលដល់កសិករឱ្យចេះអនុវត្តវិធានការចម្រុះ ដូចជា ការកំណត់រកសមាសភាគចង្រៃ ការត្រួតពិនិត្យសមាសភាគចង្រៃ ការវិភាគលើសមាសភាគចង្រៃ ការរៀបចំបញ្ជីសមាសភាគចង្រៃ និងការឃ្លាំមើលសមាសភាគចង្រៃ វិធានការដើម្បីត្រួតពិនិត្យ និងប្រប្រាស់សារធាតុគីមី និងរុក្ខជាតិសម្រាប់ត្រួតពិនិត្យ ការជំរុញឱ្យមានការប្រើប្រាស់វិធានការជីវសាស្ត្រសម្រាប់គ្រប់គ្រងសមាសភាគចង្រៃ ការកាត់បន្ថយ ការប្រើប្រាស់សារធាតុគីមី និងការអនុវត្តវិធានការគ្រប់គ្រងសមាសភាគចង្រៃចម្រុះប្រកបដោយនិរន្តរភាព។ អាជ្ញាធរទាំងនេះក៏បានផ្តល់ការបណ្តុះបណ្តាលដល់កសិករអំពីការប្រើប្រាស់ថ្នាំកសិកម្មគីមីឱ្យបានត្រឹមត្រូវផងដែរ ដើម្បីធានាឱ្យការគ្រប់គ្រងសមាសភាគចង្រៃអាចដំណើរការទៅប្រកបដោយប្រសិទ្ធភាពខ្ពស់ មានសុវត្ថិភាពសម្រាប់មនុស្ស សម្រាប់សមាសភាគចង្រៃក្នុងកសិដ្ឋាន និងសម្រាប់បរិស្ថាន។ អាជ្ញាធរទាំងនេះក៏បានរៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយអំពីការការពាររុក្ខជាតិ និងបទដ្ឋានគតិយុត្តស្តីពីការធ្វើចត្តាឡីស័ក និងបង្កើនបច្ចេកទេស IPM ដល់កសិករ។ល។ ផងដែរ។

5. ចំណាយសម្រាប់ដំណើរការទីភ្នាក់ងារការពាររុក្ខជាតិទាំងនេះ ទទួលបានការឧបត្ថម្ភពីថវិការដ្ឋ។ បុគ្គលិករបស់ទីភ្នាក់ងារទាំងនេះ ក៏ធ្វើការងារក្នុងគម្រោង និងកម្មវិធី ដែលទទួលបានហិរញ្ញប្បទានពីប្រភពផ្សេងទៀត ផ្តោតលើការស្រាវជ្រាវ និងផ្តល់ការបណ្តុះបណ្តាលបន្ថែមដល់កសិករជារៀងរាល់ឆ្នាំផងដែរ។

6. ការប្រើប្រាស់ថ្នាំកសិកម្ម និងការអនុវត្តការគ្រប់គ្រងសមាសភាគចង្រៃចម្រុះក្នុងខេត្តគោលដៅរបស់គម្រោង៖ ការអង្កេតដែលធ្វើឡើងដោយអគ្គនាយកដ្ឋានកសិកម្មកាលពីឆ្នាំ ២០១៤ និងការចុះត្រួតពិនិត្យទូទាំងប្រទេសកាលពីឆ្នាំ ២០១៣ លើអ្នកផ្គត់ផ្គង់ថ្នាំកសិកម្ម និងថ្នាំកម្ចាត់

រុក្ខជាតិចង្រៃនៅតាមទីរួមខេត្ត និងមជ្ឈមណ្ឌលចែកចាយធំៗផ្សេងទៀត បានរកឃើញថា ផលិតផលដែលលក់ដូរពេញនិយមជាងគេ រួមមាន៖ abamectin, chlorpyrifos, cypermethrin, glyphosate, imidacloprid។ នៅខេត្តភាគខាងជើង ដែលជាតំបន់មានការប្រើប្រាស់ថ្នាំកម្ចាត់រុក្ខជាតិចង្រៃលើដំណាំពោត និងកៅស៊ូ ផលិតផលសំខាន់ៗដែលដាក់លក់រួមមាន ថ្នាំកម្ចាត់រុក្ខជាតិចង្រៃ Glyphosate, Paraquat និង Atrazine។ បច្ចុប្បន្ននេះ សម្រាប់ការបង្កបង្កើនផលស្រូវ និងការដាំពោត កសិករមិនប្រើថ្នាំកសិកម្មឡើយ លើកលែងតែបន្លែមួយចំនួន។ ការត្រួតពិនិត្យទាំងនេះក៏បានបង្ហាញឱ្យឃើញផងដែរ ពីផលិតផលដែលបង្កគ្រោះថ្នាក់ខ្ពស់ និងបង្កបញ្ហាច្រើនជាងគេ ដូចជា monocrotophos, methyl parathion, methamidophos, mevinphos, endosulfan។ល។ លែងមាននៅលើទីផ្សារទៀត លើកលែងតែដបចាស់ៗដែលគេប្រទះឃើញម្តងម្កាល។ ផលិតផលដែលត្រូវបានហាមឃាត់ ហើយនៅតែបន្តរកឃើញជាទៀងទាត់ គឺ paraquat និង methomyl។ នេះគឺដោយសារតែផលិតផលទាំងនេះ ទើបតែត្រូវបានហាមឃាត់មិនឱ្យប្រើប្រាស់កាលពីពេលថ្មីៗនេះតែប៉ុណ្ណោះ (២០១០) និងនៅបន្តអនុញ្ញាតឱ្យប្រើប្រាស់ក្នុងប្រទេសជិតខាត ដែលអ្នកប្រើប្រាស់ ឬអ្នកលក់រាយនៅបន្តទិញយកមកប្រើប្រាស់ ឬលក់ក្រៅផ្លូវការ។ ការហាមប្រាមមិនឱ្យមានការប្រើប្រាស់ថ្នាំកសិកម្ម ដែលបង្កគ្រោះថ្នាក់ខ្ពស់ក្នុងប្រទេសចិត ហាក់បីដូចជាមិននាំឱ្យមានការបញ្ចេញលក់ស្តុកចាស់ៗនូវថ្នាំកសិកម្មទាំងនេះក្នុងប្រទេសកម្ពុជាឡើយ។ គេពុំបានរកឃើញស្តុកថ្នាំកសិកម្មដែលប្រើលែងកើតក្នុងទ្រង់ទ្រាយធំនោះឡើយ។

7. ថ្នាំកម្ចាត់សត្វល្អិតត្រូវបានប្រើប្រាស់ភាគច្រើនលើបន្លែ (ដូចជា សណ្តែកកួរ ម្ទេស ស្ពៃក្តោប ស្ពៃចិន) និងដំណាំដែលអាចលក់បានតម្លៃខ្ពស់លើទីផ្សារ និងពពួកដំណាំដែលដាំក្នុងចម្ការធំៗ ដូចជា ដំណៅកៅស៊ូជាដើម។ ការចុះប្រមូលទិន្នន័យនៅមូលដ្ឋាន ដែលធ្វើឡើងដោយកម្មវិធីជាតិ IPM និងអគ្គនាយកដ្ឋានកសិកម្ម បានបង្ហាញថា កសិករនៅកំពុងបន្តប្រើប្រាស់ថ្នាំកសិកម្មមិនសមស្របនៅឡើយ។ ការខ្វះចំណេះដឹងរបស់កសិករ គឺជាឧបសគ្គដ៏ធំមួយ។ ការប្រើមិនត្រឹមត្រូវនេះមានដូចជា ការលាយដោយមិនដឹងច្បាស់ ការប្រើប្រាស់ថ្នាំកសិកម្មមិនត្រូវ ការប្រើប្រាស់មិនត្រូវកម្រិត។ល។ កម្រមានការប្រើប្រាស់ឧបករណ៍ការពារខ្លួនឱ្យបានគ្រប់គ្រាន់ណាស់។ ហាងភាគច្រើនមានលក់ស្រោមដៃ និងម៉ាសការពារ ប៉ុន្តែឧបករណ៍ការពារខ្លួនទាំងនេះគឺពុំគ្រប់គ្រាន់សម្រាប់ការពារទប់ទល់នឹងសារធាតុគីមីគ្រោះថ្នាក់ណាស់។ អ្នកទិញថ្នាំកសិកម្មកម្រទិញឧបករណ៍ការពារខ្លួន ហើយហាងលក់ថ្នាំកសិកម្ម ក៏មិនផ្តល់ឧបករណ៍ការពារខ្លួនទាំងនេះដោយមិនគិតថ្លៃនោះដែរ។ ដបថ្នាំកសិកម្ម ដែលប្រើអស់ពាក់កណ្តាល ជារឿយៗត្រូវបានរក្សាទុកនៅក្នុងផ្ទះ ឬនៅជិតអាហារ ដែលហូបចុកក្នុងផ្ទះ និងដាក់កន្លែងដែលក្មេងងាយស្រួលយកមកលេង។ ដបថ្នាំកសិកម្មដែលប្រើរួចជារឿយៗត្រូវបានចោលនៅតាមទីវាល ឬទៅក្នុងប្រឡាយលូ។

8. មជ្ឈមណ្ឌលការពារដំណាំរបស់អគ្គនាយកដ្ឋានកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (និងកម្មវិធីជាតិ IPM) បានរៀបចំកម្មវិធីសិក្សារយៈពេលបីថ្ងៃ សម្រាប់បណ្តុះបណ្តាលកសិករអំពីការកាត់បន្ថយហានិភ័យនៃថ្នាំកសិកម្ម (FT-PRR) ក្នុងគោលបំណងបង្កើនការយល់ដឹង អភិវឌ្ឍន៍សមត្ថភាព និងជួយឱ្យសហគមន៍មូលដ្ឋានចេះរៀបចំ និងអនុវត្តផែនការសកម្មភាពរបស់ខ្លួន សម្រាប់កាត់បន្ថយហានិភ័យនៃការប្រើប្រាស់ថ្នាំកសិកម្ម។ គិតត្រឹមខែ មិថុនា ឆ្នាំ ២០១៤ កសិករឡាវប្រមាណ ៤.៩០០ នាក់ (ក្នុងនោះស្រី ១.៦០០ នាក់) បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលកសិករស្តីពីការកាត់បន្ថយហានិភ័យនៃការប្រើប្រាស់ថ្នាំកសិកម្ម ក្នុងភូមិចំនួន ១៤៩ នៃស្រុកចំនួន ៣៤ ក្នុងខេត្តចំនួន ៩។

9. ការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសមាសភាគចង្រៃចម្រុះដែលធ្វើពេញមួយរដូវ តាមរយៈសាលាស្រែកសិករ ជារឿយៗក៏បានបញ្ចូលវគ្គសិក្សារយៈពេលខ្លី សម្រាប់កសិករស្តីពីការកាត់បន្ថយហានិភ័យនៃការប្រើប្រាស់ថ្នាំកសិកម្មផងដែរ។ សាលាស្រែកសិករទាំងនេះ ផ្តល់លទ្ធភាពឱ្យកសិករអាចរៀនសូត្រ និងអនុវត្តការគ្រប់គ្រងសមាសភាគចង្រៃចម្រុះ ដើម្បីកាត់បន្ថយការប្រើថ្នាំកសិកម្មលើសកម្រិត ក្នុងការបង្កបង្កើនផលដំណាំ។

10. កម្មវិធីជាតិ IPM បានអនុវត្តសាលាស្រែកសិករផ្តោតលើការគ្រប់គ្រងសមាសភាគចង្រៃ

ពេញមួយរដូវចំនួន ៨០៦ វគ្គ ដែលក្នុងនោះមានកសិករបង្កបង្កើនផលស្រូវ កសិករដាំបន្លែ និងកសិករដាំដើមឈើហូបផ្លែជាង ២៤.៣៥០ នាក់បានទទួលការបណ្តុះបណ្តាលនេះ។ ទោះជាយ៉ាងណាក៏ដោយ នៅមានការងារជាច្រើនទៀត ដែលត្រូវធ្វើ។ ការកាត់បន្ថយហានិភ័យនៃថ្នាំកសិកម្ម និងការអនុវត្តការគ្រប់គ្រងសមាសភាគចង្រៃចម្រុះនៅកម្រិតកសិដ្ឋាននៅបន្តជាអាទិភាពរបស់រដ្ឋាភិបាល។

11. បើតាមក្រមប្រតិបត្តិអន្តរជាតិស្តីពីការចែកចាយ និងការប្រើប្រាស់ថ្នាំកសិកម្ម ត្រូវមានការគោរពទៅតាមគោលការណ៍ដូចខាងក្រោម សម្រាប់ការគ្រប់គ្រងសមាសភាគចង្រៃចម្រុះ៖

12. ស្តង់ដារប្រតិបត្តិត្រូវបានចែងក្នុងក្រមនេះ៖ ១.៧.៦ ត្រូវបានរៀបចំឡើង ដើម្បីជំរុញឱ្យមានការគ្រប់គ្រងសមាសភាគចង្រៃចម្រុះ (IPM) (រាប់បញ្ចូលទាំងការគ្រប់គ្រងភ្នាក់ងារចម្លងជំងឺចម្រុះ សម្រាប់ពពួកសមាសភាគចង្រៃ ដែលអាចបង្កការគំរាមកំហែងដល់សុខភាពសាធារណៈផងដែរ)។

13. គួរមានការខិតខំប្រឹងប្រែងរួមគ្នាពីសំណាក់រដ្ឋាភិបាល ដើម្បីរៀបចំ និងជំរុញឱ្យមានការប្រើប្រាស់ការគ្រប់គ្រងសមាសភាគចង្រៃចម្រុះ។ លើសពីនេះស្ថាប័នផ្តល់កម្ចី ទីភ្នាក់ងារផ្តល់ជំនួយ និងរដ្ឋាភិបាលគួរគាំទ្រដល់ការរៀបចំគោលនយោបាយជាតិស្តីពីការគ្រប់គ្រងសមាសភាគចង្រៃ និងលើកកម្ពស់ទស្សនទាន និងការអនុវត្តការគ្រប់គ្រងសមាសភាគចង្រៃចម្រុះ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ គួរធ្វើឡើងផ្អែកទៅតាមយុទ្ធសាស្រ្តវិទ្យាសាស្រ្ត និងយុទ្ធសាស្រ្តផ្សេងទៀត ដែលបង្កើនការចូលរួមរបស់កសិករ (ដូចជា ក្រុមស្រ្តីជាដើម) ទីភ្នាក់ងារផ្សព្វផ្សាយ និងអ្នកស្រាវជ្រាវផ្ទាល់នៅកសិដ្ឋាន។

14. រាល់អ្នកពាក់ព័ន្ធទាំងអស់ ដូចជា កសិករ និងសមាគមកសិករ, អ្នកស្រាវជ្រាវអំពី IPM, ភ្នាក់ងារផ្សព្វផ្សាយ, ទីប្រឹក្សាផ្នែកដំណាំ, ឧស្សាហកម្មចំណីអាហារ, អ្នកផលិតថ្នាំកសិកម្មជីវសាស្រ្ត និងថ្នាំកសិកម្មគីមី, អ្នកជំនាញខាងបរិស្ថាន និងតំណាងក្រុមអតិថិជន គួរបំពេញតួនាទីផ្តួចផ្តើមគំនិតជាមុន ក្នុងការរៀបចំ និងជំរុញឱ្យមានការគ្រប់គ្រងសមាសភាគចង្រៃចម្រុះ។

15. រដ្ឋាភិបាលដែលមានការគាំទ្រពីអង្គការអន្តរជាតិ និងអង្គការថ្នាក់តំបន់ដែលពាក់ព័ន្ធ គួរលើកទឹកចិត្ត និងជំរុញឱ្យមានការស្រាវជ្រាវ និងការបង្កើតនូវជម្រើសផ្សេងទៀត ដែលបង្កហានិភ័យតិចតួច ដូចជា៖ ការប្រើប្រាស់សារធាតុត្រួតពិនិត្យ និងបច្ចេកទេសត្រួតពិនិត្យបែបជីវសាស្រ្ត ថ្នាំកសិកម្ម ដែលមិនផ្សំពីសារធាតុគីមី និងថ្នាំកសិកម្មដែលផ្តោតចំប្រភេទសមាសភាគចង្រៃ និងដែលរលាយចូលទៅក្នុងដីបន្ទាប់ពីប្រើប្រាស់រួច និងបង្កហានិភ័យដល់មនុស្ស និងបរិស្ថាន។

16. រដ្ឋាភិបាលគួរ៖ ៥.១.៧ ផ្តល់សេវាផ្សព្វផ្សាយ និងសេវាប្រឹក្សា និងព័ត៌មានឱ្យបានគ្រប់គ្រាន់ដល់សមាគមន៍កសិករអំពីយុទ្ធសាស្រ្ត និងវិធីសាស្រ្តគ្រប់គ្រងសមាសភាគចង្រៃចម្រុះ និងព័ត៌មានអំពីប្រភេទផលិតផលថ្នាំកសិកម្មដែលអាចយកមកប្រើប្រាស់បាន។

17. រដ្ឋាភិបាលគួរ៖ ៨.១.៤ ធានាថា រាល់ការផ្តល់ឧបត្ថម្ភធន ឬការផ្តល់អំណោយ និងថ្នាំកសិកម្ម នឹងបង្កឱ្យមានការប្រើប្រាស់ថ្នាំកសិកម្មលើសលុប ឬពុំសមហេតុសមផល ដែលអាចបង្វែរចំណាប់អារម្មណ៍ពីការប្រើប្រាស់វិធានការផ្សេងទៀត ដែលមាននិរន្តរភាពជាងនេះ។

18. ផែនការគ្រប់គ្រងសមាសភាគចង្រៃ

19. គេរំពឹងថានឹងពុំមានការធ្វើលទ្ធកម្មថ្នាំកសិកម្មក្រោមគម្រោងនេះឡើយ ហើយការប្រើប្រាស់ថ្នាំកសិកម្មជារួមនឹងមានការថយចុះ បន្ទាប់ពីមានការបង្ហាញការអនុវត្តល្អផ្នែកសិកម្ម។ ទោះជាបែបនេះក៏ដោយ បច្ចុប្បន្ននេះ កសិករនៅក្នុងតំបន់គម្រោងកំពុងប្រើប្រាស់ថ្នាំកសិកម្ម ដូច្នេះ ផែនការនេះ នឹងត្រូវអនុវត្តចំពោះសកម្មភាពគម្រោងដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរការអនុវត្តកសិកម្ម និង/ឬការស្តារឡើងវិញ ឬការអភិវឌ្ឍប្រព័ន្ធធារាសាស្រ្តដែលមានស្រាប់ ដែលអាចជំរុញឱ្យកសិករបង្កើនការប្រើប្រាស់ថ្នាំកសិកម្ម ប្រសិនបើពុំមានការផ្តល់ការបណ្តុះបណ្តាល ឬការពិនិត្យតាមដាននោះទេ។ ផែនការនេះមានបីផ្នែក៖ (i) ការអនុវត្តបទបញ្ជារបស់រដ្ឋាភិបាលស្តីពីការត្រួតពិនិត្យការប្រើប្រាស់ថ្នាំកសិកម្ម, (ii) ការបណ្តុះបណ្តាលអំពីទស្សនទានរួមអំពីថ្នាំកសិកម្ម និង/ឬវិធីសាស្រ្តដទៃទៀត ដើម្បីឱ្យមានការប្រើប្រាស់ថ្នាំកសិកម្មប្រកបដោយសុវត្ថិភាព និង (iii) ការពិនិត្យតាមដាន។ ទិដ្ឋភាពរួមទូទៅនៃបទបញ្ជាលេខ ២៨៦០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចរកបាន

ក្នុងឧបសម្ព័ន្ធទី ២ ហើយ ផែនការគ្រប់គ្រងសមាសភាគចង្រៃក្នុងទម្រង់សាមញ្ញមានបង្ហាញជូនក្នុងឧបសម្ព័ន្ធទី ៣។ គេគួរមើលឯកសារទាំងពីរនេះសម្រាប់គ្រប់អនុគម្រោងទាំងអស់ ក្រោមគម្រោង CASDP។

ឧបសម្ព័ន្ធទី ១០៖ ទម្រង់សម្រាប់ពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ នៃសហគ្រាសកសិកម្ម និង សហគ្រាសដែលមានស្រាប់ ដែលត្រូវទទួលបានហិរញ្ញប្បទានក្រោមសមាសភាគរង ១.២

1. ទម្រង់នេះត្រូវបំពេញដោយអ្នកដែលត្រូវបានចាត់តាំងឱ្យធ្វើការពិនិត្យលើទិដ្ឋភាពបរិស្ថាន និងសង្គមនៃពាក្យសុំឥណទានពីជំនួយឥតសំណង/កម្ចីពីកម្មវិធីផ្តល់ឥណទាន ហើយព័ត៌មាននេះគួរប្រមូលពីសហគ្រាសផ្ទាល់ និងធ្វើការផ្ទៀងផ្ទាត់ តាមរយៈការពិនិត្យលើការផ្សព្វផ្សាយព័ត៌មានក្នុងមូលដ្ឋាន និងការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន។ ប្រសិនបើចម្លើយគឺ បាទ/ចាស ចំពោះសំណួរនៅក្នុងទម្រង់ពិនិត្យផ្ទៀតផ្ទាត់ភាពត្រឹមត្រូវនេះ នោះគួរមានការពិគ្រោះយោបល់ជាមួយក្រុមការងារ (task team) របស់ធនាគារពិភពលោកសិន មុនធ្វើការសម្រេចចិត្តថាតើត្រូវផ្តល់ហិរញ្ញប្បទានដល់សំណើនេះ ឬអត់។

| ការពិនិត្យផ្ទៀងផ្ទាត់លើភាពត្រឹមត្រូវផ្នែកការការពារផលប៉ះពាល់បរិស្ថាន និងសង្គមសម្រាប់សហគ្រាសកសិកម្មដែលមានស្រាប់ | |
|---|---|
| **១. ព័ត៌មានទំនាក់ទំនង** | |
| - តើក្រុមហ៊ុនមានចាត់តាំងបុគ្គលិកណាម្នាក់ ឱ្យទទួលខុសត្រូវលើការពិនិត្យ និងតាមដានការការពារផលប៉ះពាល់បរិស្ថាន និងសង្គម ដែរឬទេ?<br> បាទ/ចាស  ទេ<br>ប្រសិនបើ បាទ/ចាស សូមផ្តល់ឈ្មោះ និងព័ត៌មានទំនាក់ទំនង។ | ឈ្មោះ<br>លេខទូរសព្ទ |
| **២. ការពិនិត្យបឋម និងការកំណត់ពីប្រភេទបរិស្ថាន** | |
| - សូមបញ្ជាក់ថា អនុគម្រោងនេះ ពិតជាមិនត្រូវបានបញ្ចូលទៅក្នុងបញ្ជីអវិជ្ជមានពិតប្រាកដមែន<br>- តើអនុគម្រោងនេះជាអនុគម្រោងប្រភេទ B ឬប្រភេទ C?<br> B  C | បាទ/ចាស<br><br>ប្រភេទ C – សូមបន្តដោយពុំចាំបាច់ពិនិត្យផ្ទៀងផ្ទាត់ផ្នែក បរិស្ថាន និងសង្គមបន្តទៀតឡើយ និងផ្ញើទម្រង់តារាងទី ៣<br>ប្រភេទ B – បន្តបំពេញទម្រង់នេះទៀត |
| **៣. ភាពអនុលោមទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីការការពារផលប៉ះពាល់បរិស្ថាន និងសង្គម** | |
| តើអ្នកស្នើអនុគម្រោងនេះ បានទទួលរាល់លិខិតអនុញ្ញាត/ការឯកភាពពីអាជ្ញាធរ (ក្រសួងបរិស្ថានដែរឬទេ)?<br> បាទ/ចាស  ទេ | សូមរៀបរាប់ |
| តើសហគ្រាសនេះធ្លាប់មានឧបទ្ទវហេតុផ្នែកបរិស្ថានអ្វីដែលឬទេ នៅក្នុងរយៈពេល ២ ឆ្នាំចុងក្រោយ ដែលតម្រូវឱ្យមានការជូនដំណឹងទៅដល់និយតករដែរឬទេ? | |
| តើនៅក្នុងរយៈពេល ២ ឆ្នាំចុងក្រោយនេះ តើសហគ្រាសនេះធ្លាប់ទទួលបានសេចក្តីជូនដំណឹងពីការបំពានលិខិតអនុញ្ញាតផ្នែកបរិស្ថាន អាជ្ញាប័ណ្ណ ឬសេចក្តីជូនដំណឹងឱ្យធ្វើការកែលម្អពីនិយតករដែរឬទេ? | |
| តើនៅក្នុងរយៈពេល ២ ឆ្នាំចុងក្រោយនេះ តើសហគ្រាសនេះធ្លាប់មានឧបទ្ទវហេតុ សុខភាព និងសុវត្ថិភាព ឬឧបទ្ទវហេតុដែលនាំឱ្យមានបាត់បង់ជីវិតមនុស្ស និងការរងរបួសធ្ងន់ធ្ងរ និង/ឬការខូចខាតបរិស្ថានគួរឱ្យកត់សម្គាល់ដែរឬទេ? | |

| | |
|---|---|
| តើការដ្ឋាន/ក្រុមហ៊ុននេះ មានលិខិតអនុញ្ញាត/ការឯកភាព ពាក់ព័ន្ធទាំងអស់ពីអាជ្ញាធររដ្ឋាភិបាល និងមានលិខិតអនុញ្ញាត ប្រតិបត្តិការផ្នែកបរិស្ថានសំខាន់ៗ ឧទាហរណ៍លិខិតយល់ព្រមឱ្យប្រតិបត្តិការ និងការអនុញ្ញាតពាក់ព័ន្ធនឹងសំណល់គ្រោះថ្នាក់ ប្រសិនបើមាន ដែរឬទេ? | |
| **៤. កិច្ចពិគ្រោះយោបល់ជាមួយអ្នកជិតខាង និងគ្រួសារ** | |
| ប្រសិនបើនឹងមានការសាងសង់ការពង្រីកអគារជាដើម តើសហគ្រាសនេះបានពិគ្រោះយោបល់ជាមួយអ្នកដែលនឹងរកផលប៉ះពាល់ដែរឬទេ? | ☐ បាទ/ចាស ☐ ទេ<br>សេចក្តីពិពណ៌នាដោយសង្ខេប |
| តើសហគ្រាសនេះធ្លាប់ពាក់ព័ន្ធនឹងជម្លោះពាក់ព័ន្ធនឹងដីធ្លីកាលពីពេលថ្មីៗនេះ (ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ) ឬជម្លោះដីធ្លីដែលកំពុងបន្តរហូតមកដល់ពេលបច្ចុប្បន្ននេះ ជាមួយភូមិ ឬគ្រួសារជិតខាងដែរឬទេ? | ☐ បាទ/ចាស ☐ ទេ<br>សេចក្តីពិពណ៌នាដោយសង្ខេប |
| តើក្រុមហ៊ុននេះធ្លាប់ពាក់ព័ន្ធនឹងជម្លោះទាក់ទិននឹងធនធានធម្មជាតិ (ឧទាហរណ៍ ការទទួលបានវត្ថុធាតុដើម ការទទួលបានទឹក) ជាមួយភូមិ ឬគ្រួសារជិតខាង កាលពីពេលថ្មីៗនេះ (ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ) ឬកំពុងជាប់ពាក់ព័ន្ធនឹងវិវាទបែបនេះរហូតមកដល់ពេលបច្ចុប្បន្ននេះដែរឬទេ? | ☐ បាទ/ចាស ☐ ទេ<br>សេចក្តីពិពណ៌នាដោយសង្ខេប |
| **៥. ទិដ្ឋភាពបរិស្ថាន** | |
| តើមានផលប៉ះពាល់ និង/ឬហានិភ័យសំខាន់ៗអ្វីខ្លះដែលអាចកើតមានឡើង?<br>✓ សូមធីកក្នុងប្រអប់ដែលពាក់ព័ន្ធ<br>☐ ការប្រើប្រាស់សារធាតុមានគ្រោះថ្នាក់សារធាតុគីមី<br>☐ ការបង្កើតសំណល់គ្រោះថ្នាក់<br>☐ ការប្រើប្រាស់ឈើ<br>☐ ការបញ្ចេញទឹកស្អុយពីសហគ្រាស<br>☐ ការបំភាយខ្យល់<br>☐ បញ្ហាសំឡេងរំខានពីសហគ្រាស | សូមផ្តល់យោបល់អំពីភាពធ្ងន់ធ្ងរ និងវិធានការដើម្បីកាត់បន្ថយ, កាត់បន្ថយឱ្យនៅជាអប្បបរមា, បញ្ចៀសផលប៉ះពាល់ទាំងនេះ។<br>សូមបញ្ជាក់ ប្រសិនបើអាជីវកម្មនេះនឹងប្រើប្រាស់បញ្ជីត្រួតពិនិត្យសម្រាលផលប៉ះពាល់/ផែនការគ្រប់គ្រងដែលពាក់ព័ន្ធនានា។ សូមរៀបរាប់ពីប្រភេទបញ្ជីត្រួតពិនិត្យ ឯកសារណែនាំ ឬ ECOP ដែលនឹងត្រូវយកមកប្រើប្រាស់។ សូមភ្ជាប់ឯកសារនានា។<br>មានគំរូ ECOPs សម្រាប់សកម្មភាពអនុគម្រោងចំនួន ៤ប្រភេទ ក្រោម ESMF នេះ។ |
| តើលិខិតបទដ្ឋានគតិយុត្តបរិស្ថាននៅថ្នាក់ជាតិ ឬថ្នាក់មូលដ្ឋានតម្រូវឱ្យសហគ្រាសនេះរៀបចំរបាយការណ៍វាយតម្លៃ ឬធ្វើការពិនិត្យលើផលប៉ះពាល់បរិស្ថាន ឬសង្គមដែរឬទេ? | ☐ បាទ/ចាស ☐ ទេ<br>ប្រសិនបើតម្រូវឱ្យមានការរៀបចំរបាយការណ៍ស្តីពីការវាយតម្លៃបរិស្ថានបឋមក្រោមច្បាប់របស់ប្រទេសឡាវ អ្នកស្នើគម្រោងអាចបន្តដាក់សំណើសម្រាប់អនុគម្រោង ប៉ុន្តែមិនត្រូវទម្លាក់សាច់ប្រាក់ឡើយ រហូតដល់ពេលដែលធនាគារពិភពលោកពិនិត្យឡើងវិញ និងផ្តល់អនុម័តលើរបាយការណ៍វាយតម្លៃបរិស្ថានបឋមនេះ ហើយអ្នកដាក់សំណើអនុគម្រោង ផ្តល់ការជូនដំណឹងអំពីការឯកភាព ដែលទទួលបានពីក្រសួងបរិស្ថាន ឬ PONRE។<br>សវនកម្មលើផលប៉ះពាល់បរិស្ថាន និងសង្គមអាចធ្វើឡើងលើអនុគម្រោងដែលត្រូវបានស្នើឡើងក៏ដូចជា លើទីតាំងដែលមានស្រាប់ ដើម្បីធានាថា ទីតាំង |

| | |
|---|---|
| | និងប្រតិបត្តិការដែលមានស្រាប់ អនុលោមទៅតាមច្បាប់បរិស្ថាន និងសង្គម ដែលពាក់ព័ន្ធ លិខិតបទដ្ឋានគតិយុត្ត និងលក្ខខណ្ឌតម្រូវ ក្នុងគោលនយោបាយដែលពាក់ព័ន្ធរបស់ ធនាគារពិភពលោក។ នេះរួមមាន ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម ដែលកើតចេញពីសកម្មភាព កន្លងមក/សកម្មភាពដែលកំពុងមាន និង សំណើអនុគម្រោង។ |
| **៦. សុខភាព និងសុវត្ថិភាពការងារ** | |
| តើសហគ្រាសនេះបង្កហានិភ័យគ្រោះថ្នាក់ធ្ងន់ធ្ងរ (ដូចជា អគ្គីភ័យ ការផ្ទុះ ការបញ្ចេញសារធាតុគីមីពុល ឬសារធាតុគីមីគ្រោះថ្នាក់) ដែរឬទេ? | ☐ បាទ/ចាស ☐ ទេ<br>ប្រសិនបើ បាទ/ចាស តើមានវិធានការអ្វីខ្លី ត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីឆ្លើយតបចំពោះបញ្ហានេះ |
| តើសហគ្រាសនេះ ទទួលរងគ្រោះថ្នាក់គួរឱ្យកត់សម្គាល់ ពាក់ព័ន្ធនឹងការងារ (ដែលនាំឱ្យមានការរងរបួសធ្ងន់ធ្ងរ ឬការបាត់បង់ជីវិត) ក្នុងអំឡុងរយៈពេល ៥ ឆ្នាំចុងក្រោយដែរឬទេ? | |
| តើសហគ្រាសនេះ ត្រូវការផែនការសុខភាព សុវត្ថិភាព និង/ឬ ផែនការឆ្លើយតបចំពោះស្ថានភាពបន្ទាន់ដែរឬទេ? | ☐ បាទ/ចាស ☐ ទេ<br>ប្រសិនបើ បាទ/ចាស តើមានលិខិតអនុញ្ញាត ការត្រួតពិនិត្យ លិខិតបញ្ជាក់ដែរឬទេ? |
| តើមានការដាក់ឱ្យអនុវត្តនូវវិធានការសុវត្ថិភាព សមស្របសម្រាប់កម្មករដែរឬទេ? | ☐ បាទ/ចាស ☐ ទេ<br>ប្រសិនបើ បាទ/ចាស តើវិធានការអ្វីខ្លះ ដែលត្រូវបានដាក់ឱ្យអនុវត្ត ប្រសិនបើ ទេ តើមានបញ្ហាគួរឱ្យព្រួយបារម្ភអ្វីខ្លះ? |
| **៨. កម្លាំងពលកម្ម** | |
| តើគេរំពឹងថានឹងមានចំនួនកម្មករប៉ុន្មាននាក់? | |
| សម្រាប់សហគ្រាសនេះ តើមានការកំណត់អាយុអប្បបរមា ប៉ុន្មានឆ្នាំសម្រាប់កម្មករដែលត្រូវធ្វើការងារក្នុងសហគ្រាសនេះ? | ☐ បាទ/ចាស ☐ ទេ<br>(សូមរៀបរាប់) |
| តើមានវិវាទការងារកាលពីពេលថ្មីៗនេះ (ក្នុងរយៈពេល ៥ ឆ្នាំ ចុងក្រោយ) ឬដែលមិនទាន់បានដោះស្រាយដែរឬទេ? | ☐ បាទ/ចាស ☐ ទេ<br>ប្រសិនបើ បាទ/ចាស សូមរៀបរាប់ |
| តើមានការចោទប្រកាន់ថាមានការរើសអើងក្នុងការងារ (ចំពោះស្ត្រីជនជាតិភាគតិច ឬស្ត្រី) ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះដែរឬទេ? | |

| **IV.** សេចក្តីសន្និដ្ឋាន | |
|---|---|
| **ព័ត៌មានផ្សេងទៀត**<br>ព័ត៌មានផ្សេងទៀត ដែលអាចមានប្រយោជន៍ ឧទាហរណ៍ ព័ត៌មានពីអតិថិជន និងគូប្រកួតប្រជែងគុណភាពនៃការ | **យោបល់៖** |

| | |
|---|---|
| ពិនិត្យដោយអាជ្ញាធរ និយតកម្ម ឬឯកសារបង្ហាញពីពាក្យបណ្ដឹងនានា។ល។ | |
| កាលបរិច្ឆេទ | |
| **អនុសាសន៍របស់អាជ្ញាធរ**<br>***<u>អនុម័ត</u>***<br><br>**ហត្ថលេខា**<br>**ឈ្មោះ**<br>**ការបញ្ជាក់របស់មន្ត្រីបង្គោល/ទីប្រឹក្សាទទួលបន្ទុកការការពារផលប៉ះពាល់បរិស្ថាន និងសង្គម**<br>**ហត្ថលេខា**<br>**ឈ្មោះ** | **អនុគម្រោង**<br><br>**ឈ្មោះ** |

ឧបសម្ព័ន្ធទី ១១៖ បញ្ជីវត្តមានអ្នកចូលរួមក្នុងកិច្ចពិគ្រោះយោបល់ស្តីពី ESMF កាលពីថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## បញ្ជីវត្តមាន

**ប្រជុំអំពី** ៖ ពិគ្រោះយោបល់លើផ្នែកការការពារបរិស្ថាន និងសុវត្ថិភាពសង្គម (Consultation Workshop on Environmental and Social Safeguard) នៃសំណើគម្រោងស្តីពីពិពិធភាវូបនីយកម្មកសិកម្មនៅកម្ពុជា "Cambodia Agricultural Sector and Diversification Project-CASDP" នៅភោជនីដ្ឋានទន្លេបាសាក់២

**ក្រោមអធិបតីភាព** ៖ លោកបណ្ឌិត សរ ចិត្រា អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ថ្ងៃទី២០ខែកក្កដា ឆ្នាំ២០១៨

| ល.រ | ឈ្មោះ | អង្គភាព | ឋានៈ | ទូរស័ព្ទ | អ៊ីម៉ែល | ហត្ថលេខា |
|---|---|---|---|---|---|---|
| 1 | [illegible] | GDAHP | [illegible] | 089697986 | [illegible] | [signature] |
| 2 | [illegible] | [illegible] | [illegible] | 011888864 | | [signature] |
| 3 | [illegible] | [illegible] | [illegible] | 096666288 | thimsaat@gmail. | [signature] |
| 4 | [illegible] | [illegible] | [illegible] | 012389184 | sovuth@gmail.com | [signature] |
| 5 | [illegible] | [illegible] | [illegible] | 011244522 | Buthy@gmail.com | [signature] |
| 6 | [illegible] | [illegible] | [illegible] | 012756165 | orkreth@gmail.com | [signature] |
| 7 | [illegible] | [illegible] | [illegible] | 085999025 | | [signature] |
| 8 | [illegible] | [illegible] | [illegible] | 098 466 643 | [illegible]@gmail.com | [signature] |
| 9 | [illegible] | [illegible] | [illegible] | 012 812440 | [illegible] | [signature] |
| 10 | [illegible] | [illegible] | [illegible] | 012645592 | phattav@gmail.com | [signature] |
| 11 | [illegible] | NGO Forum | [illegible] | 012887598 | narin@ngoforum.org.kh | [signature] |
| 12 | [illegible] | [illegible] | [illegible] | 012 557500 | beseakmeng@yahoo.com | [signature] |
| 13 | [illegible] | GDAHP, MAFF | Officer | 012887880 | vizally62@gmail.com | [signature] |
| 14 | [illegible] | PDAFF. BTB | [illegible] | 01731186 | sovanmonyin@gmail.com | [signature] |

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## បញ្ជីវត្តមាន

ប្រជុំពិភាក្សា ៖ ពិគ្រោះយោបល់លើផ្នែកការការពារបរិស្ថាន និងសុវត្ថិភាពសង្គម (Consultation Workshop on Environmental and Social Safeguard) នៃសំណើគម្រោងស្តីពីពិពិធកម្មវិស័យកសិកម្មនៅកម្ពុជា "Cambodia Agricultural Sector and Diversification Project-CASDP" នៅភោជនីយដ្ឋានទន្លេបាសាក់២

ក្រោមអធិបតីភាព ៖ លោកបណ្ឌិត សរ ចិត្រា អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ថ្ងៃទី២០ខែកក្កដា ឆ្នាំ២០១៨

| ល.រ | ឈ្មោះ | អង្គភាព | ឋានៈ | ទូរស័ព្ទ | អ៊ីម៉ែល | ហត្ថលេខា |
|---|---|---|---|---|---|---|
| 1. | [illegible] | GDAHP | [illegible] NAHPRI | 096 66 77 158 | sicksophary@yahoo.com | |
| ២ | [illegible] | PDAD-R-T | [illegible] | 0977686805 | | |
| 3 | [illegible] | PDAD MDK | [illegible] | 012950686 | | |
| 4 | [illegible] | Amret | | 012 306990 | | |
| 5 | [illegible] | AMRET | [illegible] | 012 666844 | | |
| 6 | [illegible] | [illegible] | [illegible] | 012 700 311 | simHuy98@Gmail.com | |
| 7 | [illegible] | [illegible] | [illegible] | 012 996944 | | |
| 8 | [illegible] | [illegible] | [illegible] | 012922918 | | |
| 9 | [illegible] | [illegible] | [illegible] | 012854656 | | |
| 10 | [illegible] | [illegible] | [illegible] | 092 500812 | | |
| 11 | [illegible] | [illegible] | [illegible] | 0978363234 | | |
| 12 | [illegible] | [illegible] | [illegible] | 012950859 | | |
| 13 | [illegible] | [illegible] | [illegible] | 012 823277 | | |
| 14 | [illegible] | [illegible] | [illegible] | 012638377 | | |

| ល.រ | ឈ្មោះ | អង្គភាព | ឋានៈ | ទូរស័ព្ទ | អ៊ីម៉ែល | ហត្ថលេខា |
|---|---|---|---|---|---|---|
| 15 | [illegible] | [illegible] | [illegible] | 012848889 | | |
| 16 | [illegible] | MOWRAM | [illegible] | 099674672 | | |
| 17 | [illegible] | [illegible] | [illegible] | 012828883 | sarathchao@gmail.com | |
| 18 | [illegible] | [illegible] | PDS | 012863997 | pheachkong@gmail.com | |
| 19 | Leng Bunlong | World Bank | Env Specialist | 012946161 | | |
| 20 | [illegible] | [illegible] | DAPSPS [illegible] | 012354963 | | |
| 21 | [illegible] | [illegible] | [illegible] | 011902380 | praklaoylau@yahoo.com | |
| 22 | [illegible] | [illegible] | [illegible] | 012551390 | | |
| 23 | [illegible] | [illegible] | [illegible] | 011927862 | amphirum@yahoo. | |
| 24 | Iean Russell | FAO | Policy Officer | 0963755118 | iean.russell@fao.org | |
| 25 | Heng Sokk | CAVAC | WEE Advisor | 092458878 | | |
| 26 | Sran Chhav | MOWRAM | Chief of office | 089285145 | sranchhav5@gmail | |
| 27 | SENG ROSOMA | MAD | [illegible] | 012692862 | | |
| 28 | SENG THAVIN | MRD | [illegible] | 077500501 | sengthavin@gmail.com | |
| 29 | Men Pagnchakroat | CARDI | [illegible] | 012821681 | mp.roat@gmail.com | |
| 30 | Teu Chandy | NGOF | [illegible] | 017580802 | chandy@ngoforum.org.kh | |
| 31 | BUT SAMBATH | MAFF | [illegible] (DIC) | 098992666 | | |
| 32 | | | | | | |

| ល.រ | ឈ្មោះ | អង្គភាព | ឋានៈ | ទូរស័ព្ទ | អ៊ីមែល | ហត្ថលេខា |
|---|---|---|---|---|---|---|
| 15 | [illegible] | LoLC | CEO | 081 861002 | sokvoeun@lolc.com.kh | |
| 16 | Cheav Summary | CIRD | PO | 089553403 | summarycheav@cird.org.kh | |
| 17 | Phon Reno | DAI | Vice Chief | 017574716 | ai_reno@yahoo.com | |
| 18 | POL VANNA | WB | PA | 012 676588 | vpol@worldbank.org | |
| 19 | Man sotheary | GDA (DIHSC) | [illegible] | 012 818082 | mansotheary.gda@gmail.com | |
| 20 | Ly Monirath | MRD | officer | 077229255 | rath.dawson@gmail.com | |
| 21 | KHY YOUKHENG | GDAHP | Deputy Director | 011 758268 | khyyoukheng@yahoo | |
| 22 | In chantha | DEIC/GDA | Deputy Director | 012 867174 | inchantha@yahoo.com | |
| 23 | Heng Saopheakkum | MRD/ | Vice Chief | 099959686 | pheakkum-mrd@gmail.com | |
| 24 | Kotam Sonavan | PDAFF-Kg. Cham | Deputy Director | 012 890695 | kotam.sonavan@yahoo. | |
| 25 | Keo Sovathapheap | MOWRAM | Deputy Director | 012 889959 | keosovathapheap@gmail.com | |
| 26 | Khy Kosal | MAFF | Deputy Director | 081839345 | kosalkhy@yahoo.com | |
| 27 | CHEA PISEY | MAFF | Deputy Director | 012919249 | Pisey28@gmail.com | |
| 28 | Roeun chantha | DIC/MAFF | Chief office | 012350269 | chantha-roeun168@gmail.com | |
| 29 | Sat Savdy | DIC/MAFF | Vice Chief | 012369839 | sat.savdy@yahoo.com | |
| 30 | VIRAK CHAN | WB | WSS | 012 557667 | vchan1@wb.org | |
| 31 | KONG VOUCHSIM | DAL/MAFF | Senior staff | 012831113 | kongvouchsim@gmail.com | |
| 32 | Pen Channy | MAFF | — | 092988897 | channypen82@gmail.com | |
| 33 | Nhem Posuy | CO: AA | Admin | 077 909801 | posuy@kurodapepper.com | |
| 34 | KOAM SOKUN | MAFF | officer | 012835590 | | |
| 35 | | | | | | |